

# អត្ថបទ បានចុះផ្សាយនៅឆ្នាំ - ២០១៦

## ប្រភេទ នៃ ការពិភាក្សាសាន យោបាយ

សរសេរដោយ ឧប សៅ សង្ហា

## មាតិការឿង


_____ 1
ទស្សនវិស័យ ឆ្នាំ ២០១៨ _____ 4
ស្រុកខ្មែរ _____ 18
យុវជនខ្មែរ _____ 22
ជម្រើស នៃវិចារណញ្ញាណ ? _____ 36
ជួបសម្លុត ជួបស្លាប់ _____ 43
ល្បិចដោះខ្លួន _____ 47
មហាជ័យជំនះយួន _____ 51
អំណាចព្រះរាជាអាស្រ័យរដ្ឋធម្មនុញ្ញ _____ 54
ហេតុ ឬ លក្ខខណ្ឌ នៃ គ្រោះថ្នាក់ នៅស្រុកខ្មែរ _____ 63
ស្មារតីសក្តិភូមិ _____ 74
វិរបុរសជាតិ _____ 77
ចុះឈ្មោះបោះឆ្នោត និង ចូលរួមបោះឆ្នោត _____ 87
ការស្នេហាជាតិ, ការជឿ, ការសង្ឃឹម _____ 94
គុណប្រយោជន៏ នៃការចរចារ _____ 103
គុណសម្បត្តិ នៃមហាបុរស _____ 108
ករណី លោក ប៉ែន សុវណ្ណ _____ 112
ការរើសយក នៃ គំនិត  បរាជ័យនិយម ? _____ 136
គុណូបការៈ និង ភក្តីភាព _____ 139
សោភ័នភាព នៃ ភាសា ខ្មែរ _____ 142
គ្រាណា យុត្តិធម៌ ក្លាយជា រំពាត់ របស់ អំណាច... _____ 150
កំនួច នៃ បញ្ហាខ្មែរ ចង ដោយ យួនកុម្មុយនិស្ត _____ 157

យុត្តិធម៌ ចាត់ការរហ័ស របស់ បក្សសង្គ្រោះជាតិ ____________________162
គណបក្សសង្គ្រោះជាតិជាសេចក្តីខ្មាសសំរាប់ជាតិខ្មែរ ________________166
ដំណាក់ការថ្មី នៃទំនាក់ទំនង សហរដ្ឋអាមេរិក ជាមួយនឹង យៀកណាមកុម្មុយនិស្ត ________________________________________________177
តើអាជ្ញាធរយួននៅស្រុកខ្មែរនឹងចាប់ខ្លួន លោក កឹមសុខាដែរឬទេ ? _181
យួនត្រួតត្រានៅស្រុកខ្មែរ មិនគោរពច្បាប់ខ្មែរ______________________188
រាជានិយមខ្មែរ ____________________________________________194
ឈានទៅចាប់យកអ្វី ? ______________________________________199
ផលាយួនកុម្មុយនិស្ត នៅស្រុកខ្មែរ ____________________________205
ហេតុផល នៃ ដំណោះស្រាយ __________________________________215

# ទស្សនវិស័យ ឆ្នាំ ២០១៨

*សេរីការ*



ឆ្នាំ ២០១៦

បើយើង ធ្វើការរំលឹកទៅឆ្នាំ ២០១៣ យើងឃើញថា នៅពេលនោះ មានកើត កម្លាំង លទ្ធិប្រជាធិបតេយ្យ ជាយថាភូត (authentique) គាំទ្រ គណបក្សសង្គ្រោះជាតិ ដែលអាច ឲ គណបក្ស នេះ ទទួលបាននូវ ជោគជ័យ មិនអាច ប្រកែកបាន ក្នុងការបោះឆ្នោត។ ជវនៈ ឬ សន្ទុះ នេះ បង្កើត ជា ស្នូល នៃកម្លាំង នយោបាយ គឺ អត្ថិភាព នៃ ក្រុម អ្នកនាំ ដ៍ទុកចិត្ត (leadership) សំរាប់ គណបក្ស ដែល មាន រូប លោក សម រង្ស៊ី និង កឹម សុខា ជា អវតា នៃ កម្លាំង គណបក្ស ផង និង អ្នកប្រជាធិបតេយ្យ ផង គឺ ថា វា ដូចជា មាន ឧទ័យភាព (émergence) នូវ ថាមវន្ត នៃ ជ័យជំនះ អាចមានបាន របស់ កម្លាំង កុសល (bien) លើ អកុសល (mal) ដែល នាំ ឲ ប្រជាពលរដ្ឋខ្មែរ មាន សេចក្តីសង្ឃឹម លើ គណបក្សសង្គ្រោះជាតិ ទុក ជា គណបក្ស ផ្លាស់អំណាចដឹកនាំ ឬ ទ្វេបថ (alternance) សំរាប់ ដឹកនាំជាតិ។ អបរូប (ប្រែប្លែករូបខុសពីប្រក្រតីដើម) កម្រោល នៃ បន្ទាត់នយោបាយ របស់ គណបក្សសង្គ្រោះជាតិ ក្រោយពី ការបោះឆ្នោត នាំ ឲ ម្ចាស់ឆ្នោត មើល លែងឃើញ នូវ

គោលជំហរ គណបក្ស ដែល ខ្លួនបោះឆ្នោតអោយ។ អបរូប នេះ ធ្វើ ក្នុងនាម វប្បធម៌សន្ទនា គ្មានគោលការណ៍ច្បាស់លាស់ ដែល នាំ អោយ មាន អាការ ជា ការសុំចាញ់ របស់ អ្នកខ្សោយ ចំពោះ អ្នកខ្លាំង បង្កើត បរិយាកាស ស្អុកស្អាញ បន្ថែម ក្នុង ជីវិតភាពនយោបាយ គឺ ការលាយឡំគ្នា នូវ កុសល នឹង អកុសល ត្រូវ នឹង ខុស ថ្វីបើ នាំគ្នា យកពាក្យ «រក្សា សន្តិភាព» មកធ្វើ ជា គោលដៅ នៃ ដំណោះស្រាយ វិបត្តិ នយោបាយ។ បន្ទាត់ នយោបាយ ភាន់ច្រឡំនេះ នាំបង្កើត អោយមាន អនាធិបតេយ្យ ក្នុង ជួរ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ៖ ម្នាក់ៗ ស្វែងរកប្រយោជន៍ផ្ទាល់ ខ្លួន ដូចយ៉ាង ទង្វើ រក ការទាក់ទង របស់ លោក សម រង្ស៊ី ជាមួយលោក ហ៊ុន សែន គឺ ជា កិច្ចសៀនមមៀន (isolé dans son coin) គ្មាន ដើម គ្មាន ចុង ហើយ នៅពេល ដែល វា ជំពប់ គ្មាន នរណា ដឹងច្បាស់ពិត ថា មកពីហេតុអ្វី នោះផង ព្រោះ រូបភាព មិត្តភាព ជា គូស្នេហ៍នយោបាយ លោក ទាំងពីរ វា ស្ទើរ តែ គ្មាននរណា ម្នាក់ជឿបាន ថា វា អាច ប្រេះ ឆាប់ រហ័ស បាន ដូច្នេះ។

ឆ្នាំ ២០១៥ ដែល ទើបតែ កន្លងផុតទៅ ទុក ស្នាម អវិជ្ជមាន បិទជិត នូវ ទស្សនវិស័យ នៃ អនាគត ប្រសើរ សំរាប់ ប្រជាជាតិខ្មែរ។ គេអាចទុក ជា ឆ្នាំ ស្លុកស្នាញ គ្រប់ វិស័យ ជា ពិសេស ក្នុង វិស័យ សេរីភាព សិទ្ធិមនុស្ស និង នយោបាយ ដែល មានព្រឹត្តិការណ៍ ក្តៅៗ ជាច្រើនជាស្នាម ដូចយ៉ាង ការវាយ អ្នកតំណាងរាស្ត្រ ពីររូប នៃ គណបក្សសង្គ្រោះជាតិ ពីសំណាក់ ជនពាល ការហូត ដំណែង លោក កឹម សុខា ការដក សមាជិកភាព ជា តំណាងរាស្ត្រ លោក សម រង្ស៊ី ការចាប់ សកម្មជន នយោបាយ និង សមាជិក សភា លោក ហុង សុខ ហួរ ដាក់ ពន្ធនាគារ ជម្លោះដីធ្លី ចាស់ ថ្មី គ្មាន ដំណោះស្រាយ បញ្ហា ព្រំដែន។ល។ ព្រឹត្តិការណ៍ ទាំងឡាយ នេះ កើតឡើង ត្រួតគ្នា បន្ថែម លើ វិបត្តិ ចាស់ ដែល មាន កើតឡើង តាំង ពី ឆ្នាំ ១៩៩៣ មក ម្លេះ ពូន ដូច ជា គំនរ សំរាម ទុកចោល ជួនកាល នាំគ្នា គ្របបិទ លាក់ បាន តែ មួយរយៈ ធ្វើ ជា ដំណោះស្រាយ តែ ក្លិន ស្អុយ នៃ បញ្ហា ភាយ ពេញ បរិយាកាស នាំ បន្ទប់នូវ ដង្ហើម នៃ លទ្ធិប្រជាធិបតេយ្យ ដែល ប្រជាជាតិខ្មែរ ត្រូវ ការជា ចាំបាច់ សំរាប់ ដោះស្រាយ គ្រប់ បញ្ហា ក្នុងអារម្មណ៍

ឯកភាពជាតិ។ តែ ឯកភាពជាតិ នេះ មិនមែន ជា ចិត្ត នាការ បែបតែមួយ (pensée unique) ព្រោះ ដំណោះស្រាយ វា មាន វិធីសាស្ត្រ ជា ច្រើន សំរាប់ យកវា មកដោះស្រាយ អាស្រ័យហេតុនេះ ត្រូវមាន ការពិភាក្សា ជា ជំរើសវាងគ្រប់ នាងការ នៅក្នុង សង្គមជាតិ ដើម្បី រក ដំណោះស្រាយណា ដែល វា អាចអោយផលល្អ។

«មិនឆ្លើយ មិនឈ្លោះ» ជា គោលវិធី (démarche) ថ្មី ក្នុង គោលដៅ ចាស់ របស់ គណបក្សសង្គ្រោះជាតិ សំរាប់ ឆ្នាំ ២០១៦ គឺ ប្តូរ អ្នក ដឹកនាំនៅ ឆ្នាំ ២០១៨ តាម ការបោះ ឆ្នោត។ តាម សំដី លោក កឹម សុខា នៅ ក្នុង គោលវិធី ថ្មី នេះ មាន បែងចែក ជា បី ដំណាក់កាល៖ ដើរ ទៅរក ការ បោះឆ្នោត - ដើម្បី ឈ្នះ - ដើម្បី ដឹកនាំ ជាតិ។ ដើម្បី ធ្វើ ឲ បាន សំរេច នូវ គោលដៅ នេះ លោក កឹម សុខា ថ្លែងថា គណបក្ស លោក ប្រើ យុទ្ធសាស្ត្រ «មិនឆ្លើយ-មិនឈ្លោះ» ហើយ សមាជិក គណបក្ស និមួយៗ ត្រូវ ប្រមូលផ្តុំ ថាមពល ធ្វើ កិច្ចការអ្វី ដែលខ្លួន ត្រូវធ្វើ។

បើយើង យក គោលវិធី នេះ មក សង្កេតមើល យើង យល់ថា ជា យុទ្ធសាស្ត្រ ដ៍ ចម្លែង មួយ ហើយ វា ដូច ជា ទទ្ទប (démarche craintive) មាន បដិវាទកម្ម (contradiction) នឹង បច្ច័យភាព (logique) នៃ សកម្មភាព របស់ គណបក្ស នយោបាយ គឺ ធ្វើ ការពិភាក្សាសា ជាជំរៅ ជាមួយ គូប្រកួត។ ការពិភាក្សាសា ជា ជំរៅ គឺ ចាំបាច់ ត្រូវមាន ចម្លើយ និង ជម្លោះមតិ ជា អហិង្សា គឺថា ការពិភាក្សាសា អញ្ញថាភាព (débat contradictoire) ដើម្បី រាវរក ការពិត ជូន ដល់ ប្រជាពលរដ្ឋ ៙ គាត់ បាន ដឹង ច្បាស់លាស់ ព្រោះ គាត់ ជាម្ចាស់ឆ្នោត អាច ៙ គាត់ មាន លទ្ធភាព បោះឆ្នោត ប្រកបដោយ សតិសម្បជញ្ញៈ ជ្រើសរើស អ្នកដឹកនាំ។ យើង យល់ឃើញថា យុទ្ធសាស្ត្រ នេះគឺ ជា ផលវិបាក កើត ចេញមក ពី យុទ្ធវិធី ភាន់ច្រឡំ ហើយនិង ការសម្រេច ខុស ត្រូតៗគ្នា ជាច្រើន របស់ អ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ ក្រោយពី ការបោះឆ្នោត ២០១៣ ដូចយ៉ាង ៖ ចូល រដ្ឋសភា ដើម្បី កៅអី, វប្បធម៌សន្ទនា គ្មាន គោលការណ៍ ដើម្បី រកសុខ ជា អាថិ។ មកដល់ ពេលនេះ គណបក្ស សង្គ្រោះជាតិ កំពុង ទទួលរង នូវ ផលវិបាក នៃ ទង្វើ ភាន់ច្រឡំ

របស់ អ្នកដឹកនាំ ខ្លួន គឺថាគ្រប់ ទង្វើ ណាដែល គ្មាន ភាព ជាប់លាប់ នឹង គោលដៅ វា តែងតែ ហុច លទ្ធផល អវិជ្ជមាន ដូច្នេះ នោះឯង។

នៅទីនេះ យើង គ្មានយោបល់ ជា មេរៀន អ្វី សំរាប់ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ នោះឡើយ ព្រោះ យើងយល់ថា គតិបណ្ឌិត (idéal) វា ជួនកាល ជា សត្រូវ នឹងរបៀបធ្វើ (pratique) ដូចជា អ្នកចង់បាន និង អ្នកធ្វើជួនកាល អាច មាន ជម្លោះ នឹងគ្នា ព្រោះ អ្នកចង់បាន ជា អ្នកគំនិតនិយម រីឯ អ្នកធ្វើ វិញ ជា អ្នកការណ៍និយម[1] តែងតែ ជួប ឧបសគ្គ គ្រប់ បែបយ៉ាងក្នុងកិច្ចការ របស់ខ្លួនដែល កំពុងធ្វើ មិនអាច បំពេញចិត្តឆាប់ រហ័សដល់ អ្នកចង់បាន។ យើង ដឹង ថា កត្តា ពេលវេលា មាន សារៈសំខាន់ ក្នុង ការអនុវត្តន៍ គំរោង អ្វីមួយ ដែល វា មានដើមមាន ចុង (début et fin) របស់វា ហើយគំរោង និមួយៗ តែងតែ មាន គតិបណ្ឌិត ដែល ជា តម្លៃ របស់វា។

[1] អ្នកការណ៍និយម ; pragmatiste

អាស្រ័យហេតុនេះ អ្នកធ្វើ ត្រូវ ចាំបាច់ ផ្តោតគំនិត ជានិច្ច ទៅលើ គតិបណ្ឌិត ដែល មាន ចែង ច្បាស់លាស់ នៅក្នុង នីតិវិធី នៃ គំរោង (procédure du projet) ដែល ខ្លួន យក មកប្រតិបត្តិ តាម គោលវិធី នៃ ការអនុវត្តន៍ (processus d’application) របស់ ខ្លួន។ ការបាត់ ចក្ខុវិស័យ លើ គតិបណ្ឌិត គឺ អាចនាំអោយ វង្វេងទិស នោះឯង។

បើ យើង យក គោលវិធី ថ្មី នៃ គណបក្សសង្គ្រោះជាតិមក ប្រដូច នឹង គំនិត របស់ យើង ខាងលើនេះ យើង ឃើញ ថា គតិបណ្ឌិត របស់ សង្គ្រោះជាតិ គឺ ការប្តូរ អ្នកដឹកនាំ បច្ចុប្បន្ន ដែល ជា គោលដៅ ចាស់ ហើយ គោលវិធីថ្មី ដែល ជា គោលវិធី នៃ ការអនុវត្តន៍ គឺ មិនឆ្លើយ-មិនឈ្លោះ។ តាមពិត គោលវិធី ថ្មី នេះ គណបក្ស សង្គ្រោះជាតិ បាន យកមក អនុវត្តន៍ រួចហើយ នា ឆ្នាំ២០១៣-២០១៤។ ដូច្នេះ គោលវិធី សំរាប់ឆ្នាំ២០១៦ គឺ ស្ថានភាព ដូចដែលបានធ្វើ រួចមកហើយ (statu quo) ដែល នាំ លើក ជា សំណួរថាតើ គណបក្សសង្គ្រោះជាតិ មានអ្វីថ្មីដើម្បី រំលើង ស្ថានភាព ជា គ្រោះថ្នាក់ដល់ ជាតិ ឬ ប្រឈរមុខនឹង ថាវរភាព (ភាពមិនដែលប្រែប្រួល) របស់ គណបក្ស ប្រជាជន ដែល គេប្រើ

គ្រប់ មធ្យោបាយ ដើម្បី រក្សាអំណាច ? នៅក្នុង ឆ្នាំ ២០១៥ គណបក្សសង្គ្រោះជាតិ ដើរ ថយរហូត នៅចំពោះ គ្រប់ការឈ្លានពាន មក លើ ខ្លួន ពីសំណាក់ អាជ្ញាធរ ឬ ក្រុមអនាមិក រណប គណបក្ស កាន់អំណាច ទោះបី ការឈ្លានពាន ប៉ះពាល់ ដល់ និមិត្តរូប នៃ តម្លៃ គណបក្ស ដែលមានរូប លោក សម រង្ស៊ីនិង កឹម សុខាជា តំណាង ក៍ដោយ។ ខ្សែ ក្រហម ដែល ជា ខ្សែ គូស ជា កំរិត ខណ្ឌ សំរាប់ ការពារអធិបតេយ្យភាព និង កិត្តិយសរបស់ គណបក្ស ត្រូវ បាន ពួកអ្នក កាន់អំណាច ប្រមាថ គ្មានរញ៉ូរា តែគ្មាន ប្រតិកម្ម ណាមួយ ថ្ងូនល្មម (adéquate) ឬ សមាមាត្រ នឹង ទង្វើ បំពាន អយុត្ត នោះឡើយ បែរ ជា បញ្ឆៀល សំដី ដើម្បី រកសុខ ដូចយ៉ាង យុទ្ធសាស្ត្រ មិនឆ្លើយ-មិនឈ្លោះ។ តែ ការពិត យុទ្ធសាស្ត្រនេះ វា ជា ចម្លើយ នៅក្នុង ស្ថានភាព ទាល់ច្រក តែប៉ុណ្ណោះ។ម្យ៉ាងវិញទៀត យុទ្ធសាស្ត្រ នេះ សំរាប់ តែ ពួកអ្នកដឹងនាំ គណបក្សសង្គ្រោះជាតិ នាំ គ្នា ដេក ឆ្លៀត ស៊ី អត្ថប្រយោជន៍គ្រប់ បែបយ៉ាង ដែល ពួក អ្នកកាន់អំណាច គេ ផ្តល់អោយ ដោយចេញមុខក្តី ឬ ដោយ អាថ៌កំបាំង ក្តី។ រាល់ យុទ្ធសាស្ត្រ នយោបាយ

ណា ដែល មាន ជាប់ ជាមួយ អត្ថប្រយោជន៍ របស់បុគ្គល ទោះបី វា មានតិចតួច ក្តី គឺ មិនយូរឡើយ នឹងធ្វើ អោយ ក្រខូក់ឈ្មោះ ដល់ គណបក្ស នយោបាយ ជា ពុំខាន ឧទាហរណ៍ ថ្មីៗនេះ ក្នុងចំណោម ឧទាហរណ៍ ជាច្រើន គឺ សមាជិក របស់ គណបក្សសង្គ្រោះជាតិ នៅក្នុង គ.ជ.ប.[2] នាំ គ្នា បោះឆ្នោត ជ្រើសតាំង បេក្ខជន អគ្គលេខាធិការ គ.ជ.ប. ផ្ទុយពី ការចង់បាន របស់គណបក្ស។ ទោះបីលោកកឹម សុខា ខំជួសជុល ទង្វើ លលា ឬ មិនសមហេតុ នេះ តាមសំដី និយាយទៅកាន់ប្រជាជន ជា អ្នកគាំទ្រ គណបក្ស ថាកុំ៤ ទុកចិត្ត ទៅលើ គ.ជ.ប. ពេក ក៍ដោយ ក៍ពុំអាច បំភ្លឺ នូវ គោលជំហារ គណបក្ស បាននោះដែរ ផ្ទុយទៅវិញ មានតែ បន្ថែម នូវ ការមិនច្បាស់លាស់ ព្រោះកំណើតគ.ជ.ប. ថ្មីនេះ ដែល គណបក្ស យក វា មកធ្វើ ជា ជោគជ័យ កើតមក ពី វប្បធម៌សន្ទនា របស់ខ្លួន ជាមួយ គណបក្ស កាន់អំណាច។ បើលោក កឹម សុខា គាត់មាន សន្ទិះ (doute) ទៅ

---

[2] គ.ជ.ប.= គណកម្មាធិការជាតិរៀបចំការបោះឆ្នោត។

លើ គ.ជ.ប. ហើយ គាត់ អំពាវនាវ ដល់ អ្នកគាំទ្រខ្លួន កុំ អោយ ទុកចិត្ត ពេក តើ លោក កឹម សុខា មាន ដំណោះស្រាយបែប ណាទៅ សំរាប់ ការបោះឆ្នោត នា ឆ្នាំ ២០១៧-១៨ អោយ វាមានលក្ខណៈ ប្រជាធិបតេយ្យ ពិត ?

ប្រាកដ ណាស់ ដូច លោក កឹម សុខា គាត់ ថ្លែង ថា គណបក្សសង្គ្រោះជាតិ ជា គណបក្ស ដែលប្រជាពលរដ្ឋខ្មែរមាន សេចក្តីសង្ឃឹម ច្រើន ជាងគេ តែ ចំពោះយើង មើលឃើញ ថា សេចក្តីសង្ឃឹម នោះ ជា សេចក្តីសង្ឃឹម គ្មានជម្រើស ដែលនាំ អោយ ប្រជាពលរដ្ឋ បោះឆ្នោត គ្រាន់តែ សំរាប់ បោះបង់អ្វី ដែល ទើសទែង ឬ បោះឆ្នោត អបទេស (vote exutoire) ដែល គណបក្សសង្គ្រោះជាតិ ពុំ អាច ឆ្លៀត ទុក វា ជា កម្លាំង នយោបាយ សំរាប់ ការពារ ជ័យជំនះ របស់ ខ្លួន បាន នោះឡើយ ដូច មាន កើតឡើង នៅក្នុង ឆ្នាំ ២០១៣៖ ពាក្យ ស្លោក ស្រែកថា «ដូរ ឬ មិនដូរ» វា ស្ថិត នៅក្នុង សតិរបស់ ម្ចាស់ឆ្នោត មិន អាច សាបសូន្យ ទៅ បាននោះឡើយ ស្រាប់តែ ឥឡូវ ចេញ ពាក្យ ស្លោក ថ្មី «មិន ឆ្លើយ-មិនឈ្លោះ»។ យើង ចង់សួរទៅ លោក កឹម សុខា ថា តើ គាត់ មាន បំណង អោយ អ្នករងគ្រោះ ដេកចាំតែបោះ

ឆ្នោត ក្នុង ជីវភាព អត្ថខាត់ សំរាប់ អោយ គាត់ និង បក្ស ពួក បានទទួល បៀវត្ស និង អត្ថប្រយោជន៍ជា សម្ភារៈ ក្នុង ឋានៈ ជា តំណាងរាស្ត្រ នោះឬ ? តាម ពិតពាក្យស្លោក នេះ ជា សារ ផ្ញើរ ទៅ ពួក អ្នកកាន់អំណាច ដើម្បី សុំសុខ តែ ប៉ុណ្ណោះ ហើយ ដេកចាំ បោះឆ្នោត សំរាប់ លំអ របប ដូច លោក កឹម សុខា គាត់ អន្ទង សុំ កុំ អោយ អ្នកគាំទ្រ គណបក្ស ឈប់ រិះគន់ តាមកំហឹង ដល់ ពួក អ្នកកាន់ អំណាច ព្រោះ គាត់ ខ្លាច លោក ហ៊ុន សែន ចោទ ប្រកាន់ គាត់ ថា មិនចេះ អប់រំ សកម្មជន គណបក្ស ដូច លោក ហ៊ុន សែន ធ្លាប់ចោទ ប្រកាន់ លោក សម រង្ស៊ី ថា ចរចារ តែឆ្លៀត ជាន់ជើង។។ ដូច្នេះ គោលវិធី ថ្មី សំរាប់ ឆ្នាំ ២០១៦ ជា អាការៈក្រៅ (simulacre) សំរាប់ តែបោះឆ្នោត សិន ហើយ សូម នាំគ្នា គិត ជាថ្មី ។ រួម សេចក្តី មក ទស្សនវិស័យ របស់ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ សំរាប់ឆ្នាំ ២០១៦ គឺ គ្មាន អ្វី ដូរ នោះឡើយ ហើយនឹង បន្ត រហូត ដល់ ឆ្នាំ២០១៨ បើ ពួក អស់លោក ទាំងនោះ ចេះ គ្រប់គ្រង ការរក សេចក្តីសុខ ជាមួយ លោក ហ៊ុន សែន ឬ លោក សមរង្ស៊ី គាត់យល់ ស្រប នឹង យុទ្ធវិធី «មិនឆ្លើយ-មិន

ឈ្លោះ» ឬ លោក ហ៊ុន សែន គាត់ រក្សាអារម្មណ៍ ល្អរបស់គាត់ បាន។ ដូច្នេះ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ មិនមែន ជា ម្ចាស់ នៃ យុទ្ធសាស្ត្រ របស់ខ្លួន ព្រោះ វា រំពឹង ទៅលើ កត្តាក្រៅដូចយ៉ាង កត្តា លោកហ៊ុន សែន និង លោកសម រង្ស៊ី ដែល កំពុង រស់ នៅ ក្រៅប្រទេស ហើយ ប្រឹង ធ្វើសកម្មភាព គ្រប់បែបយ៉ាងដើម្បីឲខ្លួន នៅមាន ឥទ្ធិពលលើ ក្រុម អ្នកដឹកនាំ។ គេដឹង ថា កត្តា នៃ អនាគតនយោបាយ អង្គឹអង្គែ របស់ លោក សម រង្ស៊ី នាំ អោយ សហការី ស្មោះត្រង់នឹងគាត់ នាំគ្នា ស្វែង រកសុខ រៀងៗខ្លួនព្រោះ គ្មាន ការទុកចិត្ត ឬ គ្មាន សេចក្តីរាប់អាន លើលោកកឹម សុខា ព្រោះ ពួក នេះ យល់ឃើញ ថា លោក កឹម សុខាគ្មាន ជម្មានរូប និងគុណសម្បត្តិ សំរាប់ ដឹកនាំ គណបក្សនោះ ឡើយ។ រសាប់ (malaise) នេះ នាំអោយ លទ្ធវត្ថុ (chose acquise) កើតពីកម្លាំងរួម នៃ អ្នកប្រជាធិបតេយ្យនិយម ដើម្បី បង្កើត គណបក្សសង្គ្រោះជាតិ កំពុងរលាយ បន្តិចម្តងៗ បើក ឱកាស អោយ ពួកអ្នកកាន់អំណាច គេឆ្លៀត ទាញយក ប្រយោជន៍បាន យ៉ាង ងាយស្រួល បំផុត។ «មិនឆ្លើយ-មិនឈ្លោះ» មិនពិត ជាកម្លាំង

មាន ប្រសិទ្ធិភាព នោះឡើយ ព្រោះ ជា មធ្យោបាយ ដែល ពួក អ្នកកាន់អំណាច គេ ចង់ ឲ គណបក្សសង្គ្រោះជាតិ យកវា មក ប្រើ ដើម្បី ទុក ពេលវេលា បន្ថែម ដើម្បី ឲ ពួក គេ ពង្រឹង អំណាច របស់គេ។ ទន្ទ្បះភាព (solidité) នៃ អំណាច នេះឯង ដែល ជា កម្លាំងទាញ យកបាន ឬ បន្សាប (neutraliser) សមាជិក ថ្នាក់ដឹកនាំ គណបក្សស ង្គ្រោះជាតិ ដែល កំពុង ចាប់ផ្តើម មាន រួចហើយ ឧទាហរណ៍ ដូច បាន ជំរាប ខាងលើ គឺ លទ្ធផល នៃ ការ បោះឆ្នោតជ្រើសរើស អគ្គលេខាធិការ នៃ គ.ជ.ប.ថ្មីៗ នេះហើយការណ៍បែបនេះ នឹង មាន កើតបន្ត ថែមទៀត ពី ពេលនេះ រហូត ដល់ ឆ្នាំ ២០១៨ ដូច មាន នៅក្នុង សម័យ រលំ នៃគណបក្សហ្វុនស៊ីប៉ិច នោះឯង។ រួមសេចក្តី មក គោលវិធី «មិនឆ្លើយ-មិនឈ្លោះ» ជា សេចក្តីភាន់ គំនិត (illusion) សំរាប់ អ្នកទុនខ្សោយ យកមក អនុវត្តន៍ ចង់បំភាន់ (illusoire) ដើម្បីលាក់បាំង នូវទុព្វលភាព របស់ខ្លួន តែប៉ុណ្ណោះ។ គណបក្ស សង្គ្រោះជាតិ អាចមាន គោលវិធី ប្រសើរ ជាង គោលវិធី «មិនឆ្លើយ-មិនឈ្លោះ» ព្រោះខ្លួន នៅមាន សក្តានុពល បើ អ្នកដឹកនាំ នៅ មាន

សេចក្ដី ក្លាហាន បំពេញ តួនាទី របស់ខ្លួន ជា អ្នកប្រឆាំង ពិតប្រាកដ នៅក្នុង អារម្មណ៍ ជា អ្នកប្រជាធិបតេយ្យ និយមលះបង់ ប្រយោជន៍បុគ្គល ឬ បក្សពួកអញ។ លោក កឹម សុខា គាត់ ធ្លាប់ ប្រើពាក្យ ស្លោក ដ៏ ល្អ របស់ គាត់ ថា «ខ្លាច ឃ្លាន ខ្លៅ» ហើយ ពាក្យ ស្លោកនេះឯង វា ជាបច្ចុប្បន្នភាព របស់ អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ។

សេរីការ



ឆ្នាំ ២០១៦

# ស្រុកខ្មែរ

គេថា ស្រុកខ្មែរ មាន អ្នកដឹកនាំ ពន្លង់ ក្នុង អវិជ្ជា យកក្បួនលក់ជាតិ ជា នាយកធម៌ យករាស្ត្រ ធ្វើ ឈ្នាន់ជាន់ ដើម្បី ពាក់ងារ ជា អភិជន អហិរិក[3] ភ្លេច វណ្ណភាពខ្លួន ពីកំណើតជា អ្នកស្រែ រស់ ជា រាស្ត្រទាស ក្រោម បារមី ស្ដេច និងអាមាត្រ គ្រលង់ ប្រើ អំណាចជា យុត្តិធម៌ ប្រើ វណ្ណៈ ជា អាជ្ញា ស័ក្ករូប ជា ព្រះ អួតខ្លួន ថា ជា អ្នកមានបុណ្យ។ សព្វថ្ងៃ ស្ដេច ថ្មី បាក់ អំនួត រស់ ជា អ្នកក្បត់ រាជសក្តិ ព្រោះ ខ្លាច ពួកជើងកាប់ចាក់ ប្លន់បាន រដ្ឋ យកមក ធ្វើ ជា កម្មសិទ្ធិ ដាច់មុខ នាំគ្នា បង្កើត យុត្តិធម៌ តាម ចិត្តចង់បាន ចាប់ អ្នកស្នេហាជាតិ និង អ្នកការពារសិទ្ធិ មនុស្ស ដាក់គុក ឥតមាន ការវិនិច្ឆ័យ សម្លាប់ អ្នកជា ចោទ ថា អ្នកក្បត់ជាតិ ព្រោះ ខ្លួន មាន យួន ជា អ្នក ការពារ ជា បងធំ រស់ជាអ្នកធំ នៅកម្ពុជា មានងារ ជា មន្ត្រីជាតិខេមរា ដូរឈ្មោះ ជា ខ្មែរ សែនពិរោះ រួចធ្វើជា អ្នក

---

[3]អហិរិក ; sans pudeur, ignoble។

អាន់ជ្រីពេញក្រសួង។ យួន ទុក អោយ ខ្មែរ សម្លាប់ ខ្មែរ ដោយ សេរី តែកុំប៉ះពាល់ ដល់បងប្អូនយួន ជា អ្នកមានគុណ មាន ថ្ងៃទី ៧ មករា ជា ទីវា រំលឹកខួប ថា ខ្មែរ ជំពាក់បំណុល សងមិនដាច់ ទាំងដើមទាំងការ ត្រូវប្តូរនឹងទឹកដី ជា កតវេទិតា[4] អោយ យួន រាប់លានមករស់ក្នុងទឹកដីកម្ពុជា ជា ម្ចាស់ បំណុល ស៊ីការប្រាក់ រហូតដល់ ជាតិខ្មែរស្លាប់ ដើម្បី យួន ស្រួលចាប់ត្រី នៅ បឹងទន្លេសាប។

ខ្មែរអ្នកគិតជាតិ សព្វថ្ងៃ កំពុងរស់ ជា ថ្មី ក្នុងសម័យ យួន យកដី កម្ពុជាក្រោម តែហាក់បីដូច ជា ខ្វះមេរៀន ក្នុងសតិ នាំគ្នា គិតចុះគិតឡើង មិនហួសពី ប្រយោជន៍អាត្មា មើលឃើញខ្មែរ អ្នកមានទុក្ខ ជា អ្នកដទៃ ឃើញ អ្នកជាប់គុក ដើម្បី ជាតិ ជា មនុស្ស មាន កម្ម នាំគ្នា សម្ងំស្ងៀម លែងហ៊ាន និយាយស្តី រហូត អ្នកខ្លះ នាំគ្នា បង្កើត វប្បធម៌ ជាមនុស្សគ មិនឆ្លើយ មិនឆ្លងនឹង អយុត្តិធម៌ តាំងខ្លួន ជា ពុធជន ដេកចាំ បោះឆ្នោតស្រំដែល សំរាប់អោយយួន

---

[4]កតវេទិតា ; remerciement sans fin។

កាន់តែហួរ ចូលស្រុក គ្មានកំរិត ហើយ មិនយកមេរៀន ប្រវត្តិសាស្ត្រជា ពន្លឺ និង មិនខ្វល់នឹងព្រឹត្តិការណ៍បច្ចុប្បន្ន ទុកជាយោង នាំគ្នាគិតស្រំដែលថា សពាសីហនុ ជា ព្រះគ្រូ មាន ក្បួន យុទ្ធសាស្ត្រ ជា គាថា ហើយ នាំគ្នាទុកអាណត្តិ ទី ៥ ជា មហាជោគជ័យ ព្រោះមាន គ.ជ.ប. ថ្មី សំរាប់ការពារ ការបោះឆ្នោត សំរាប់ ឈ្នះឃ្លួន តែគ្មាន ពាង សំរាប់ ត្រង ទុក ទឹកភ្លៀង នៃ ជោគជ័យ ដើម្បី រាស្ត្រ ពិសា អោយបាត់ ជម្ងឺអយុត្តិធម៌ អោយមានកម្លាំង ជា រាស្ត្រ ជា អ្នកឈ្នះ ដែលជាម្ចាស់ នៃ អំណាចរដ្ឋ។

សាធុ! សាធុ! សូមអោយ ការគិត ទាំងឡាយនោះ មាន រាសី អាចនឹង ឈ្នះឃ្លួន ដូចប្រាថ្នា ព្រោះ វា ជា សុភកថា របស់ ខ្មែរ មួយនគរ, ប៉ុន្តែ ខ្មែរ លែង មាន ជំនឿ ព្រោះ ឃើញច្បាស់ថា ការបោះឆ្នោត មិនមែន ជា ការផ្លាស់ប្តូរ អ្នកដឹកនាំ តែ បែរទៅជា ការបែងចែកគ្នា នូវ កៅអីយស រវាង អ្នកលួចចិត្តម្ចាស់ឆ្នោត នឹង អ្នកលួចឈ្នះឆ្នោត នាំ គ្នាចែកឡាន ចែកលុយ រស់នៅ មាន បុព្វសិទ្ធិ ជា ឯក ឧត្តម ជា វណ្ណៈ សក្តិភូមិ ទុក រាស្ត្រម្ចាស់ឆ្នោត ជា កញ្ជះ សំ រាប់ បោះឆ្នោត ដើម្បី លើក អស់លោក ដាក់លើ ហែម

(piédestal) ហើយ នាំគ្នា ដើរ ហ៊ឹហា ធ្វើឫកជាម្ចាស់រាស្ត្រ, ស្ថានភាព បែបនេះ គេហៅថា លោកដាំចុះ (le monde à l'envers) ព្រោះ អស់លោក មាន ពុទ្ធិវិបល្លាស (maladie mentale) មើលឃើញ សភា ថាជា សង្គ្រោះជាតិ ដែល មាន ឃួនពេញទឹកដី រស់ ជា ម្ចាស់ ខ្មែរ ពេញសិទ្ធិ មានខ្មែរ ធ្វើវន្ទា ឈ្មោះថា រាជរដ្ឋាភិបាល។

អស់កាលដ៏ឡូង នៅស្រុកខ្មែរ មាន លើសទៅទៀតគឺវិបត្តិសីលធម៌ ដូចមាន ផ្កាថ្លែងក្នុងសៀវភៅ លោក បុណ្ណ ចាន់មុល (ចរិកខ្មែរ) ដែល ជា កត្តា នាំ អោយ សង្គមខ្មែរ បាត់នូវសាមគ្គីភាពជាតិ នាំបែក ជា ផ្នែកបក្សពួក រកចំណេញក្រុម ពីសម្បត្តិជាតិ មិនបរិបូរណ៍នាំគ្នា ហែកចែក គ្មានសល់ ទុកអោយរាស្ត្រ រស់ ជា រាស្ត្រទាស ទុរា របស់ នាយទុនទុច្ចរិតគ្រប់សញ្ជាតិ នាំគ្នាជាន់កខ្មែរ លានប្រស្រី ដើម្បី រកចំណេញហួសកំរិត។

# យុវជនខ្មែរ

សេរីការ



ឆ្នាំ ២០១៦

## អារម្ភកថា

តើដំណើរ របស់អ្នក (យុវជន) ទាំង កំហឹង ផង និង សេចក្តីសប្បាយ រីករាយ ផង កំពុងសំដៅ ទៅទីណា យ៉ាង បន្ទាន់ ? តើ ជា ជំហាន ក្នុង សេចក្តីសង្ឃឹម ឬ ការអស់សង្ឃឹម ? ជា អភិចលនា នៃ វិវាទកម្ម[5] ឬ ជា ចាគបត្រ[6] ? សំនួរនិមួយៗ ទាំងឡាយនេះ សុទ្ធ ជា វិញ្ញាសា សំរាប់ វ័យយុវភាព ដែលជា ពន្លក នៃ ដំណើរ នៃ ជីវិត នៃ នរជាតិ នៅក្នុងលោកិយនេះ។សូម អ្នក កុំមាន បារម្ភ អ្វី ព្រោះ សំនួរ ទាំងឡាយនេះ យុវជន គ្រប់ទំនាន់ (génération) តែងតែ សួរ ដល់ ខ្លួនឯង ជា និច្ច ព្រោះ មិនទាន់ នរណាម្នាក់ រក ចម្លើយឃើញ នៅឡើយ ដ្បិត ទុក្ខ របស់ជាតិខ្មែរ វាធំ មហិមា ដែល មិនអាច ជនខ្មែរម្នាក់ៗ មើលឃើញនឹងភ្នែកបើ គ្មាន សតិសម្បជញ្ញៈ ធ្វើជា អតិសុខុមទស្សន៍ សំ

---

[5] អភិចលនា នៃ វិវាទកម្ម= Effervescence de contestation។
[6] ចាគបត្រ= ករលះបង់សិទ្ធិអោយអ្នកណាម្នាក់, ការអត់ធ្មត់ទ្រាំទ្រ ; Résignation។

រាប់ ឆ្លុះមើល ទុក្ខជាតិ រយឆ្នាំ។ គេ ថា អ្នក ជា កុលបុត្រ-កុលធីតា ជា ពូជ ខ្មែរអង្គរ កសាងប្រទេស ទៅ ជា មហានគរ មាន បុរី ល្អឆើតឆាយ ដូចដ្ឋាន ព្រះឥន្ទ្រ មាន ព្រះមហាក្សត្រ ជា ស្តេច ចក្រវាល មាន ទេវតានានា ចាំ ថែរក្សា ជាតិ សាសនា អោយបាន ថ្កុំថ្កើង មិនចេះដាច់, តែ គេ ពុំបាន ប្រាប់ថាអ្នក ជា អ្វី ? ជា ឧបករណ៍ នៃ មហានគរ ឬ ជា នាដការ នៃ សេចក្តីថ្កុំថ្កើង ?

សេចក្តីក្រើន ស្មារតី នេះ ជា ការរំឭក បែប ទេវវិទ្យា ឬ ជា ជំនឿសាសនា នូវ ជា អនុសារ នៃ ជាតិខ្មែរ តាំងពី បុរាណកាល។ តែ ជាតិសម័យ ត្រូវការ ទស្សនវិទ្យា និង វិទ្យាសាស្ត្រ ជា អាហារ សំរាប់ ប្រាជ្ញា ; សួរថា តើ មាន នរណា ជា អ្នក ទង់ទាញ អ្នក អោយ ចេះ ពិចារណា ក្រៅពី សាលារៀន គ្រប់ ជាន់ថ្នាក់ ? បរិវិតក្ក (réflexion) នៃយុវជន ត្រូវមាន អ្នក ជួយ បំភ្លឺប្រាជ្ញា ឈ្មោះថា គ្រូ, តែ ត្រូវមាន គំរូ សង្គមល្អ ជា មូលដ្ឋាន ទើប វា ជា ជំនួយ អាច ជួយ អ្នក ឲ មានក្តី ។ ដូច ទស្សនវិទូ បារាំងសែស ឈ្មោះ Jean Jacques Rousseau សរសេរ ថា៖ «*នរជាតិ កើតមក ជា ទារកដ៏បរិសុទ្ធ តែ សង្គម ជា អ្នកដឹកនាំ មនុស្ស អោយ ខូច*»។ ដូច្នេះ នៅក្នុង សង្គម

ល្អ អ្នក ជា ដុំថ្ម ប៉ុន្តែ អ្នក មាន លទ្ធភាព នៅក្នុង ប្រព័ន្ធ សិក្សា ច្នៃ ខ្លួនអ្នក អោយ ក្លាយ ជា ដុំពិជ្រ មាន លោកអ្នក គ្រូ ជា ក្បួនចំណេះ មាន មាតាបិតា ជា សរុណៈ (សេចក្តីទីពឹង) តាំង ពីកុមារភាព រហូត ដឹងក្តី មានវិជ្ជា ដែល គេ ទុកអ្នក ជា អ្នកចេះដឹង។សេចក្តីសង្ឃឹម របស់ អ្នក ជា សញ្ញា នៃ សុខភាពសតិ មាំទាំ របស់អ្នក ដែល ជា មមង្ការ[7] សំរាប់ ធ្វើ មុខបាទ[8] ដើម្បីអ្នក និង សំរាប់អ្នកក្នុងដំណើរ នៃ ជីវិត ជា មនុស្ស លោក។ ជំនឿអ្នក លើ សេចក្តីសង្ឃឹម អបរាជ័យ ជា អនាគតល្អ ដល់អ្នកនិងសង្គម ទុក អោយ យុវជន ទំនាន់ក្រោយ គេ យក ជា ទំនៀម ព្រោះអ្នក ជា អធុនិក រស់ក្នុង បច្ចុប្បកាល ទុកស្មាមដល់ អនាគតកាល។ ដូច្នេះ បវត្តកាល នេះហើយ[9] ដែល អ្នកត្រូវធ្វើ អ្វី ដែល អ្នក ចង់បាន ក្នុងនាម ជានរៈអារ្យ: (humain civilisé) ក្នុង វ័យ នៃ បុប្ផា កំពុងរីក នៅក្នុងសួន។

---

[7] មមង្ការ= សម្បត្តិផ្ទាល់របស់អាត្មា ; propriété de soi-même។
[8] មុខបាទ= ករណីកិច្ចផ្ទាល់អាត្មា ; devoir personnel។
[9] បវត្តកាល នេះហើយ = c’est maintenant។

## សុខដុម

យុវជន ជា និមិត្តរូប នៃ ភាពបរិសុទ្ធ តែក៏មានភាពស្រួយ នោះដែរ។ សេចក្តីសប្បាយ និងមនសិការ លាយឡំគ្នា វាជា ទម្លាប់អាក្រក់ ដែលមិនចង់លះបង់[10] របស់ មនុស្សម្នាក់ៗ ,តើ ល្បាយ (mélange) នេះ វា អាច បង្កើត អោយមាន សុខដុម ក្នុង ជីវិត យុវជន បាន ដែរ ឬទេ ? រឿងនេះ វា អាស្រ័យ ទៅលើ ឧត្តមគតិ នៃ យុវជនម្នាក់ៗ បើ សេចក្តី សប្បាយ វាជា អំពើ អកុសល ដូចយ៉ាង ចាស់ បុរាណខ្មែរ ហៅថា ឆ្កួតបីះ ឆ្កួតស្រី, ឆ្កួតស្រានិង ឆ្កួតល្បែង ហើយ ខ្មែរ អធុនិក បន្ថែម នូវ ឆ្កួតបី យ៉ាងទៀត គឺ ឆ្កួតបុណ្យ, ឆ្កួត ប្រាក់ និង ឆ្កួតបរទេស[11], ទាំង ៦ឆ្កួត នេះ ខ្មែរយើង ហៅ ថា «គ្រប់មេ គ្រប់ពង» គឺ ពិត ជា អន្តរការណ៍[12] នៃ សុខដុម ជា ពុំខាន។ អំពើល្អ, អំពើអាក្រក់, វាចាល្អ, វាចា

---

10 ទម្លាប់អាក្រក់ដែលមិនចង់លះបង់= Péchés mignon។
11 ឆ្កួតបរទេស គឺ ឆ្កួតបំរើប្រយោជន៍បរទេស។
12 អន្តរការណ៍ = អត្ថទោស, ទំនាស់, ទុម្មល ; inconvénient។

អាក្រក់, គំនិតល្អ, គំនិតអាក្រក់ វាមិនអាច រួមរស់ ជា គូគ្នា មាន សុខដុម បាន នោះឡើយ។ហេតុនេះឯង បានជា យុវជនម្នាក់ៗ ត្រូវ ខំពង្រឹង ធាតុស្រួយ របស់ ខ្លួន អោយក្លាយជា លោហធាតុ ជា ចិត្តខ្ពស់ សំរាប់ កាត់ផ្តាច់ ល្អ ពីអាក្រក់ ដើម្បី រស់នៅ មានសុខដុម ក្នុង ជីវិត របស់ខ្លួន។ តែ ការស្វែងរក សុខដុម ក៏មិនមែន ជា ការស្វែងរក ភាពគ្មានដល់សុក្រឹត មិនចេះចប់ ព្រោះមនុស្សលោក ជា តួអង្គមនុស្ស មានកំរិត[13] ក្នុងពេលវេលា និង ទីកន្លែងរស់នៅ, អាស្រ័យហេតុនេះ យុវជនម្នាក់ៗ ត្រូវ មាន អាទិភាព របស់ខ្លួន ក្នុង ការ ស្វែងរក អត្ថសុភមគ្គល[14] ក្នុងនរបរិមាត្រ[15] ។តួអង្គមនុស្ស មិនមែនជា អាទិទេព, ជា ព្រះពុទ្ធ, ដូច្នេះ វិរយភាព សាមីចិ[16] របស់ខ្លួន គឺ ធ្វើ នៅក្នុង លទ្ធភាព ជា មនុស្ស ដែលមាន សីលធម៌ ជា គោល ដូច ព្រះអង្គ Dalaï Lama បាន សរសេរ[17] ថា៖ « *ចេតភាព នៃ មនុស្ស គឺមាន*

[13] តួអង្គមនុស្ស មានកំរិត= Etre limité។
[14] អត្ថសុភមគ្គល=Bonheur personnel។
[15] នរបរិមាត្រ= Dimension humaine។
[16] វិរយភាពសាមីចិ= effort convenable។
[17] L'appel au monde du Dalaï Lama ។

*សារសំខាន់ ប្រសើរជាង ភាពជាចិត្ត នៃ សាសនា ; គឺ វា ជា ការលំអៀង មាន នៅក្នុងចិត្ត ជា មនុស្សលោក ទៅលើ សេចក្ដីស្នេហា នៃ ចិត្តមេត្តា និង មិត្តភាព ដែល ជា សីលធម៌ នៃ នរជាតិ ឯករាជ ពីជំនឿសាសនា : ក្រមសីលធម៌ និង ធម៌សាសនា ខុសគ្នា ដូចជា ទឹក នឹង តែ»។*

មិត្តភាព នេះ ហើយ ដែលមាន នៅក្នុង ចិត្តមេត្តា នៃ យុវជន ក្នុងនាម សម្ព័ន្ធ បរិសុទ្ធចិត្ត[18] រវាង បុគ្គល នឹង បុគ្គល ក្នុង យុពា[19] រួមរស់ ក្នុង ហោរា[20] មាន បំណង តែមួយ គឺ ឆ្លៀតរស់ជា អ្នក ឥតទុក្ខ ក្នុងចិន្ដា។ សេចក្ដី បរិសុទ្ធចិត្ត នេះឯង ជា សោភ័នភាព របស់ វ័យយុវភាពរស់ គ្មានកង្វល់ចិត្ត ក្នុង បច្ចុប្បន្នកាល ; ម្សិលម៉ិញ ថ្ងៃចាស់ ; ថ្ងៃស្អែក ថ្ងៃថ្មី ; ថ្ងៃនេះជាការពិត តែមួយគត់ សំរាប់ ជីវិតភាព នៃ សុខោផិក[21] ប្រកបដោយ សុខដុមរមនា សុខកំបុត (brèves) រវាង ចិត្តសស្អាត នឹង ពេល

---

[18] បរិសុទ្ធចិត្ត = Innocence។
[19] យុពា = Ensemble des jeunes។
[20] ហោរា = ពេលវេលាមានកំរិត ; Temps limité។
[21] សុខោផិក ; un être heureux។

វេលា ដូច បុប្ផារីក នឹង ទឹកសន្សើម។ តែបើសុខដុម នៃ យុវជន គ្មាន សិក្ខាបទ នៃ សច្ចភាព វា នឹងបង្កើត ឲមាន ទំនាស់ រវាង គំនិត នឹង អំពើ ដូច ជា នាវា គ្មាន នាវិកនាយក (capitaine) រសាត់អន្ទែត ក្នុង មហាសាគរ។

## សច្ចះភាព

សច្ចភាព កើតពី ការអប់រំ ទាំងផ្លូវ កាយ និង ចិត្ត មិន លែងឡើយ ដែល ជា ប៉ប៉ែរ នៃ វ័យយុវភាព បង្កើត ការ ចេះដឹង គ្រប់ វិជ្ជា មាន យោគ:, ទស្សនវិជ្ជា, វិទ្យាស្សស្ស, ប្រវត្តិសាស្ត្រវិទ្យា ជា អាថ៌ សុទ្ធ ជា ចំណេះ ជា កូនសោ សំរាប់ បើក ទ្វា សតិសម្បជញ្ញៈ ដើម្បី សម្លាប់ ឲអស់ នូវ ភាព ខ្លៅ ជា ភាពចង្រៃ នៃ ជីវិត។ យុវជន ជា ទំពាំង ស្នងឫស្សី ត្រូវមាន បរិស្ថានល្អ ជា បាទ សំរាប់ ទ្រ ទំនង នៃ ការ អប់រំ ដែល ជា គំណាក់ការ ចាំបាច់ នៅពេល ប្រភាត (aurore) នៃ វ័យយុវភាព។ បើ បាទ ស្អុយរលួយ ម្តេចក៏ អាច នឹងមាន ទ្រនាប់ មិនរអិលទប់ មិនឲដួលបាន ?

ម្លោះហើយ យុវជន ត្រូវការ បរិស្ថានល្អគឺសង្គម មាន សីល ធម៌ សំរាប់ ជា ការទ្រទ្រង់ ដល់ ប្រព័ន្ធ នៃ សិក្សាធិការ។

សិក្សាធិការជាតិ នេះឯង ជាគំរូ នៃ សេចក្ដីល្អ សំរាប់ យុវជន, ជា សមភាព នៃ ភ័ព្វសំណាង របស់ យុវជន គ្រប់មជ្ឈដ្ឋាន ក្នុង សង្គម ស្វែងរក ការចេះដឹង គ្មាន កង្វល់ អំពី ថវិកា មាតា បិតា ព្រោះ សិក្សាធិការជាតិ ជា អំពើឥតយកតម្លៃ ដែលជា កាតព្វកិច្ច របស់ រដ្ឋ ចំពោះ ប្រជាពលរដ្ឋ។ ការអប់រំ ត្រូវសញ្ជឹងគិត នូវ ការលើកដំកើង នៃ វប្បធម៌ជាតិ ស្របគ្នា នឹង វិជ្ជាបច្ចេកទេស គ្រប់បែបយ៉ាង ដើម្បី អោយ យុវជន ក្លាយ ជា ពលរដ្ឋមាន មោទនភាព នឹង ជាតិសាសន៍ខ្លួន និង ជា បុគ្គលគុណវុឌ្ឍិ (qualifié) ក្នុង ការងារ។ វប្បធម៌ និង ឯកទេស ជាគូចាំបាច់ សំរាប់ ជីវិតភាព អាជីព ដែលទុកជា គុណសម្បត្តិ របស់ បុគ្គលម្នាក់ៗ។ មនុស្សល្អ ជាមនុស្ស មាន វប្បធម៌ ក្នុង សីលធម៌, មនុស្ស ប្រសើរ ជា មនុស្ស មាន វប្បធម៌ និង មាន វិជ្ជា សំរាប់ទ្រទ្រង់ ការរស់នៅ ដល់ខ្លួន និងគ្រួសារ។ មនុស្សពាល ជា មនុស្ស អវិជ្ជា រស់ ជា បុគ្គលទុច្ចរិតទុកជា អាត្មាត (parasite) បំផ្លាញ សង្គម។ បុគ្គលបែបនេះ ទោះបី ពាក់ងារ ជា ឧត្តមជន គ្រប់យសស័ក្តិ ក៏ពុំ

អាចកែ នាមរូប[22]ខ្លួន ពី ក្អាត ទៅ ជា ហង្ស បាន នោះឡើយ។ មនុស្ស អវិជ្ជា មាន ភាពត្រចេះត្រចង់ នៅតែ ក្នុងមជ្ឈដ្ឋាន ទុច្ចរិត តែប៉ុណ្ណោះ។

ទទួលបាន ការអប់រំមូលដ្ឋាន គ្រប់គ្រាន់ហើយ យុវជនត្រូវរក នូវ ការបង្ហាត់បង្រៀន ជាបន្ត ទាំងផ្លូវគំនិត និងបច្ចេកទេស គ្រប់ ពេលវេលា ក្នុង ជីវិតភាព អាជិព របស់ខ្លួន ព្រោះសង្គមមនុស្ស ក្នុងពិភពលោក ដើរទៅមុខជានិច្ច ហើយ បច្ចេកទេស មាន សេចក្តី ចម្រើន មិនចេះដាច់ដ្បិត ការវិវត្តន៍ ជា សារជាតិ នៃ មនុស្សជាតិដែលជាចលករ នៃ ការបង្កើតគ្រប់បែបយ៉ាង ដែលជាកត្តានូវការរីកចំរើន នៃ នរជាតិ ក្នុងឋានៈ ជា តួអង្គសង្គម, ម្លោះហើយ សិក្សាធិការជាតិ, សិក្សាធិការអាជិព និង សិក្សាធិការការស្រាវជ្រាវ និង អភិវឌ្ឍន៍ ត្រូវ បង្ហាញ នូវ សច្ចភាព នៃ ការវិវត្តន៍ ដល់ យុវជន ដើម្បីអោយ យុវជន រស់នៅក្នុង ការពិត ជានិច្ច លើ មគ៌ា ជិវិតរបស់ខ្លួន។ និច្ច

---

[22] នាមរូប = Mentalité et physique។

លនិយម ជា សត្រូវ មរណា នឹង ការរីកចំរើន ដ្បិតសង្គម ជាតិ ណាមួយ រស់នៅ ក្នុង អចលកម្ម វាពិត ជាក្លាយ ជា សង្គម លែងប្រែប្រួល នាំឲក្រិនបញ្ហា ហើយ កន្ទ្រោន ចាំតែ ថ្ងៃស្លាប់។ រឿងនេះ ជា សច្ចភាព ដែល យុវជន យកវាមក ពិចារណា អំពី គុណធម៌ (vertu) នៃ ប្រពៃណី អោយ យល់ ដឹង អំពី អត្ថប្រយោជន៍ និង អត្ថទោស (inconvénient) សំរាប់ ការរស់នៅ របស់ ខ្លួន និង នៅក្នុង សង្គមជាតិ ព្រោះ ការចេះ យកចេញ ល្អ ពី អាក្រក់ ជា សច្ចភាព ដាច់ ខាត សំរាប់ ការរស់នៅ នៃមនុស្សលោក។

## យុត្តិធម៌

គេ និយាយ ថា ការពិត មិនត្រូវ និយាយទាំងអស់ នោះទេ ព្រោះ វា អាច នាំ ទុក្ខ ដល់អាត្មា តែ នៅមុខ តុលាការ ជន ជាប់ចោទ ក៏ដូច អ្នកប្តឹង ត្រូវធ្វើ សច្ចាប្រណិធាន និយាយ ការពិត គ្មានខ្វះគ្មានលើស ដូច្នេះ សច្ចាភាព នេះឯង ជា បុញ្ញាកិរិយា សំខាន់ របស់ យុវជន ស្រឡាញ់ យុត្តិធម៌។

បើគ្មាន សច្ចភាព គឺ គ្មាន យុត្តិធម៌, បើគ្មាន យុត្តិធម៌ គឺ ជា រជ្ជសត្វ[23] ក្នុងនោះ មាន កម្លាំងបាយ ជាអំណាច មាន រាជសីហ៍ ជា ស្តេចព្រៃ ទុកសត្វទុនខ្សោយ ជារាស្ត្រខ្ញុំស្តេចកំណាច។ នៅក្នុង យុត្តិធម៌ យុវជន ព្រមគ្នា ជា បុគ្គលភាព, នីតិបុគ្គល, រូបវន្តបុគ្គល, បុគ្គលឯកជន, នីតិបុគ្គលសាធារណៈ គឺជា ភោគី (possesseur) នៃសិទ្ធិ, ដូច្នេះ ជាពលរដ្ឋ (citoyen) ពេញលក្ខណៈ ស្គាល់ សិទ្ធិ និង ករណីយកិច្ច ស្គាល់ខុស ស្គាល់ត្រូវ ដែលជា កម្លាំង ពលរដ្ឋថ្មី នាំអោយ ប្រជាជាតិ រស់ ពព្រើស បន្តពី ទំនាន់ មួយ ទៅ ទំនាន់មួយ។ គឺថា យុវជន-ពលរដ្ឋ ជា អ្នកអោយ កម្លាំង ដល់ ប្រជាជាតិក៍ដូចគ្នានឹង យុវជន-គិលាន[24]នាំ អោយ ជាតិ ស្គាល់ ទុរពល។ យុវជន-ពលរដ្ឋ ជា និមិត្តរូប នូវ ជ័យជំនះ នៃ យុត្តិធម៌លើ អយុត្តិធម៌ ព្រោះ ជ័យជំនះនេះ បង្ហាញ នូវ អត្ថភាព

---

[23] រជ្ជសត្វ[23] = Règne des animaux។

[24] យុវជន-គិលាន= Jeunesse dans un état maladif។

ពិត នៃ យុវជន-មុនភាវករ[25] នូវ កម្លាំងជាតិ ដែល មាន យុត្តិធម៌ ជា និយតករ (régulateur)។

នៅក្នុង ប្រទេសមួយ ដែល យុត្តិធម៌ ត្រូវ អំណាចផ្តាច់ការ ប្រមាថ ឬ មាន យុត្តិធម៌ ទទួលបញ្ជា ច្បាស់ ជា យុវជន មាន តួនាទី ត្រឹមតែ ជា ឧបករណ៍ នយោបាយ សំរាប់ បំរើ របបដឹកនាំ តែប៉ុណ្ណោះ។ នៅពេលដែល យុត្តិធម៌ក្លាយ ជា បាវ បំរើ អំណាច ហើយ យុវជន ក្លាយ ជា ឧបករណ៍ នយោបាយ ច្បាស់ជា អំណាចផ្តាច់ការ នឹងមាន ជ័យជំនះ តែ ជ័យនេះឯង ដល់ វេនវា នឹងក្លាយ ជា អាវុធ សំរាប់ សម្លាប់ យុវជន មុន គេ បង្អស់ ព្រោះ យុវជន-ឧបករណ៍ មាន ប្រយោជន៍ ដល់ អំណាចផ្តាច់ការ តែមួយ រយៈ ដូច បុរាណភាសិតខ្មែរ ចំណារ ថា «ជិះក្របី ចំឡងភក់, ដល់ ត្រើយសោយគូត»។

បើ គ្មាន យុត្តិធម៌ ច្បាស់ ជា គ្មាន ប្រជាធិបតី (la démocratie)បើ គ្មាន ប្រជាធីបតី ច្បាស់ជាគ្មាន យុវជន

---

25 មុនភាវករ = ដែលបង្កើតឡើងវិញ ; régénérateur។

ត្រពាំង ស្ទងឫស្សី បើគ្មាន យុវជន ជា បញ្ញាវន្ត ច្បាស់ ជា ប្រជាជាតិ គ្មានអនាគត, រឿងនេះ វា មាន ហូរហែ នៅ ក្នុង ដំណើរ នៃ អត្ថង្គត[26] នៃ ប្រជាជាតិ ដូច សព្វថ្ងៃ នៅ ស្រុកខ្មែរ អ្នកនយោបាយ គ្រប់និន្នាការ នាំគ្នា បង្កើត ប្រជាធិបតី គ្មាន យុត្តិធម៌ ដែល ជា ដំណើរ វិការរូប (transformation) នៃ យុវជនបរិសុទ្ធ នៅស្រួយគំនិត អោយក្លាយ ជា យុវជន នយោបាយ ក្នុងនាម វប្បធម៌ សន្ទនា គ្មាន សច្ចភាព គ្មាន យុត្តិធម៌ ជា មូលដ្ឋាន នៅ ក្នុងសង្គម គ្មាន សុខដុម ដ្បិត ជា ដំណើរ ឥតអាចថយ ក្រោយបាន ទោះចង់ ឬ មិនចង់ក្តី ព្រោះជា ផ្លូវ ដែល យៀកណាម គេគូរខ្សែ ជា ទំនាក់ ៤ អ្នកនយោបាយខ្មែរ ដើរ ដោយ គន្លង ឆ្ពោះទៅរក ការបង្កើត សហព័ន្ធឥណ្ឌូចិន ដែល មាន យៀកណាម ជា នាយក។ តើយុវជនខ្មែរ សព្វថ្ងៃ កំពុង ធ្វើ អ្វី ? គ្រប់ គណបក្ស នយោបាយ គេ ឆ្លើយ

[26] ដំណើរ នៃ អត្ថង្គត = Processus de décadence។

ព្រម គ្នា ថា យុវជន ខ្មែរ កំពុង រៀបចំ សស្រិច[27] ការបោះឆ្នោត នៅតាម មូលដ្ឋាន។

សាធុ ! សាធុ ! ព្រោះ ចម្លើយ បែបនេះ វា សមមូល្យ (ស្មើ) នឹង ពាក្យ ស្លោក ឥតយក កម្រៃ មួយកាក់ មួយសេនពី អ្នកកាន់ អំណាច ជា នរិន្ទ[28] : ជយោ យៀកណាម ! ជយោ សម្ដេច ហ៊ុន សែន !។

[27] សស្រិច ; continuellement។
[28] នរិន្ទ= អ្នកដែលជាធំលើអស់ជន, ដែលជាម្ចាស់នៃមនុស្ស។

# ជម្រើស នៃវិចារណញ្ញាណ ?

*សេរីការ*



ឆ្នាំ ២០១៦

ថ្នាក់ដឹកនាំ គណបក្សសង្គ្រោះជាតិ បានជ្រើសរើសលោក កឹម សុខា ធ្វើជាប្រធាន ក្រុមអ្នកតំណាងរាស្ត្រ របស់បក្ស នៅរដ្ឋសភាជំនួសលោក សម រង្ស៊ី។ ទង្វើនេះ ជាការសំរេច មានលក្ខណៈជាឧទ្ទាមកម្ម ប្រឆាំងនឹងលោក សម រង្ស៊ី ឬ ជា ជម្រើសដោយវិចារណញ្ញាណ ?

យោងតាមផ្លូវច្បាប់ លោក សម រង្ស៊ី ត្រូវរដ្ឋសភា ដកហូត សិទ្ធិរបស់គាត់ ចេញពី សមាជិក រដ្ឋសភារួចមកហើយ ដូច្នេះឈ្មោះគាត់មិនត្រូវមាន នៅក្នុងតារាង នៃតំណាង រាស្ត្រទៀតនោះឡើយ អាស្រ័យហេតុនេះ បានជាពួកអ្នក តំណាងរាស្ត្រ នៃគណបក្សប្រឆាំង ត្រូវដកងារគាត់ ជា ប្រធានរបស់ខ្លួន។ សួរថា តើថ្នាក់ដឹកនាំគណបក្សសង្គ្រោះ មានបានគោរពលក្ខន្តិកៈ របស់បក្សដែរឬទេ នៅក្នុងនីតិ វិធី នេះ ? បើធ្វើទៅតាមច្បាប់ វាជា សិទ្ធកម្ម[29] តែបើទង្វើ

---

29 សិទ្ធកម្ម ;Acte accompli légalement។

នោះ វាផ្ទុយនឹងច្បាប់ ហើយធ្វើតាមបញ្ជាលោក ហ៊ុន សែន វាជា ឧទ្ទាមកម្ម នោះឯង។

តែទោះបីយ៉ាងណា ស្ថានភាព ដែលកំពុងមានកើតឡើង នៅក្នុងគណបក្សសង្គ្រោះជាតិ វាមានរូបរាង ជា ទន្ទប[30] របស់ពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ជាពិសេស លោក កឹម សុខានៅចំពោះមុខ តម្រេករបស់លោក ហ៊ុន សែន ចង់បាន គឺ បំបែកបំបាក់អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ។ ទង្វើលោក ហ៊ុន សែន វាគ្មានលក្ខណៈ ជា យុទ្ធសាស្ត្រអ្វីនោះឡើយ គឺប្រើអំណាច សម្លុត ពួកអ្នកដឹកនាំបក្សប្រឆាំង អោយទទួលយកដំណោះស្រាយរបស់ខ្លួនតែម្តង។ តែគេអាចសួរជាសំនួរបានថាតើអ្នកដឹកនាំគណបក្សប្រឆាំង អាចមានជម្រើសដែរឬទេ ?

អ្នកខ្លះ មាន វិស័យមតិ ថា លោក កឹម សុខា គាត់គ្មានជម្រើស នោះឡើយ បើចង់ចូលរួមរួម ជា ធម្មតា ក្នុងការ

[30] ទន្ទប ;ធ្វើដោយភិតភ័យ ;démarche craintive។

បោះឆ្នោតខាងមុខនេះ ព្រោះគោលដៅសមុដ្ឋាន[31]របស់គណបក្សប្រឆាំងគឺការបោះឆ្នោត ត្រូវតែគាត់សុខចិត្តធ្វើតាមលោក ហ៊ុន សែន ចង់បាន ទោះបីត្រូវប្តូរនឹង សាមគ្គីភាព រវាងគាត់ជាមួយលោក សម រង្ស៊ី ក៏ដោយ ដែលគេហៅថា អកុសលចាំបាច់ ដើម្បីបោយយកប្រយោជន៍នៅថ្ងៃស្អែក។ វិស័យមតិនេះ បន្ថែមទៀតថាពួកអ្នកដឹកនាំ និង សកម្មជន របស់គណបក្សប្រសង្គ្រោះជាតិ ត្រូវដូរចរិត និង ពាក្យពេជ្យពី អ្នកប្រឆាំងគ្មានយោគយល់ មកជា អ្នកប្រឆាំងសមរម្យ ដើម្បី ប្រមូលផ្តុំកម្លាំង បុកទៅរកតែការបោះឆ្នោត ដែលជា លាភូបនិសា[32] អាចនឹងឈ្នះគណបក្សកាន់អំណាច ដូចពាក្យថា ជ័យជំនះនៅទីបញ្ចប់ជាការបញ្ជាក់នូវមធ្យោបាយ យកវាមកអនុវត្ត។

តែអ្នកខ្លះទៀត មានវិស័យមតិផ្ទុយថា វិរកម្ម[33] របស់លោក កឹម សុខា ជាអត្តឃាតកម្មនយោបាយ ព្រោះវាធ្លាប់

31 គោលដៅសមុដ្ឋាន ; objectif primordial។
32 លាភូបនិសា; Agir en vue d'obtenir la chance។
33 វិរកម្ម ; une geste។

មានកើតឡើងរួចហើយពីអតីតកាល ដូចយ៉ាង ទង្វើរបស់ពួកអ្នកដឹកនាំគណបក្ស ហ៊្វុនស៊ីប៉ិច ជាឧទាហរណ៍ និងថ្មីៗនេះ គឺ ទង្វើរបស់លោក សម រង្ស៊ី តែម្តង គឺរកទំនាក់ទំនងជាឯកសិទ្ធ ជាមួយលោក ហ៊ុន សែន តែលទ្ធផល វានាំទុក្ខដល់ខ្លួនទៅវិញ ព្រោះលោក ហ៊ុន សែន គាត់ធ្វើដើម្បីតែប្រយោជន៍គាត់ផ្ទាល់ ត្បិតការចែកប្រយោជន៍ វាជាគ្រោះថ្នាក់ដល់គាត់។ ហើយទម្លាប់ដែលលោក ហ៊ុន សែន បានធ្វើមក វាតែងតែនាំមកនូវជ័យជំនះដល់គាត់ជានិច្ច ហេតុនេះឯង បានជាគាត់មិនដូរ របៀបចាត់ការរបស់គាត់នោះឡើយ។ ទំនាក់ទំនងជាឯកសិទ្ធ រវាង លោក កឹម សុខា ជាមួយលោក ហ៊ុន សែន សព្វថ្ងៃ វាមិនខុសគ្នានឹង ករណីលោក សម រង្ស៊ី ពីមុននោះដែរ គឺទាក់ទងក្នុងភាពអាថ៌កំបាំង ឬ ចរចាជាសម្ងាត់រវាងបុគ្គលនឹងបុគ្គលដែលនាំបង្កើតមន្ទិលសង្ស័យនៅក្នុងជួរគណបក្សប្រឆាំងផង និងនៅក្នុងសាធារណជនផង។ លោក ហ៊ុន សែន កំពុង អោយលោក កឹម សុខា តែងខ្លួនជាសិប្បនិម្មិត ធ្វើជាគូរចរចាជាមួយគាត់ ដូចឆ្មា ចាប់កណ្តុរបាន យកមកប្រលែងលេងសិន មុននឹងសម្លាប់។ លោក ហ៊ុន សែន ផ្ទេរ

ងារ និង កិត្តិយសលោក សម រង្ស៊ី អោយទៅលោក កឹម សុខា នៅក្នុងលក្ខខណ្ឌដកលោក សម រង្ស៊ី ជាការណ៍ ពីប្រធានគណបក្ស។ លោក កឹម សុខា និង ពួកអ្នកដឹកនាំគណបក្សសង្គ្រោះ ព្រមទាំងភរិយា លោក សម រង្ស៊ី សុខចិត្ត ទទួលយក សម្រេក របស់លោក ហ៊ុន សែន ប្រកបដោយ សេចក្ដីសប្បាយរីករាយជាខ្លាំង ព្រោះពួកគាត់ដេករង់ចាំជាងប្រាំខែមកហើយ នូវសេចក្ដីអត់ឱនបែបនេះ។

ជា នយោបាយ ជម្រើស តែងតែមានជានិច្ច ជាពិសេសគណបក្សសង្គ្រោះជាតិ ដែលមានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋ ដូច្នេះ ជម្រើស វាបិតនៅលើ ឆន្ទះរបស់ពួកអ្នកដឹកនាំ ព្រោះថា មនោមយិទ្ធ[34] វាជាកម្លាំងតស៊ូមួយ មុនគេបំផុតរបស់មនុស្សលោក។ បើមានវាហើយ គឺច្បាស់ជា វាមិនធ្លាក់ ទៅក្នុងព្រហ្មលិខិតនោះឡើយ។ មនោមយិទ្ធ នេះឯង ដែលនាំអោយគណបក្សសង្គ្រោះជាតិ ឈ្នះឆ្នោតនៅ

[34] មនោមយិទ្ធ ;pouvoir de volonté។

ឆ្នាំ ២០១៣។ តែដោយសារអ្នកដឹកនាំ នាំគ្នាបោះបង់វាចោល បាន ជា វា មាន កម្មវិបាក មកដល់សព្វថ្ងៃនេះ។ នរណាក៏យល់ព្រម ទទួលស្គាល់ថា ដំណោះស្រាយដ៏ល្អប្រសើរ នៃសព្វវិវាទ គឺការចរចាជាមួយគូសត្រូវនោះឯង តាមមធ្យោបាយ ជា ការផ្តល់ពត៌មាន ក្តី ជាការជួបជជែកគ្នាផ្ទាល់ ក្តី ជាការបង្ហាញសកម្មភាព ក្តី តែមធ្យោបាយទាំងនោះ ត្រូវប្រកាន់នូវតម្លៃនឹងន្ទួន នៃសីលធម៌ នៅក្នុងប្រយោជន៏ជាតិ ទើបវាជាដំណោះស្រាយប្រកបដោយអត្ថសារៈ សំរាប់ប្រជាជាតិខ្មែរ។ តែបើជាមធ្យោបាយ ក្រវិកក្រវង់ ឆ្ពោះទៅរក ប្រយោជន៏ឯកជន នាំអោយខូចខាតដល់ ប្រយោជន៏ជាតិ វាច្បាស់ ជា ផ្លូវទុច្ចរិត នោះឯង។ លោក កឹម សុខា និង ពួកអ្នកដឹកនាំគណបក្សសង្គ្រោះជាតិ កំពុងបន្ត ដើរលើផ្លូវ ដែលលោក ហ៊ុន សែន បញ្ជាអោយដើរតាំងពីឆ្នាំ ២០១៤មក តែលើកនេះគ្មានលោក សម រង្ស៊ី ជាអ្នកកាន់ទង់បក្ស។ ដូច្នេះ ព្រឹត្តិការណ៏ ដែលកំពុងកើតឡើងនេះ វា គ្មានអ្វី ជា ព្រឹត្តិការណ៏ថ្មី នោះឡើយ វា

គ្រាន់តែប្តូរ អ្នកកាន់ទង់តែប៉ុណ្ណោះ។ គម្បស្ថាន[35] នៃ ដំណើរនេះ គឺ ការបោះឆ្នោត គ្មានសេរី និង គ្មានយុត្តិធម៌ នោះឯង ដែលមាន គ.ជ.ប. មិនឯករាជ្យ ជាអ្នកចាំប្រកាស ជ័យជំនះ គណបក្សប្រជាជន ដែលជាវិជ័យ ខុសពី លទ្ធផលពិត។ ដូច្នេះ អ្វីដែលធ្លាប់ មានកើតឡើងនៅឆ្នាំ ២០១៣ នឹងមានកើតឡើង ម្តងទៀតនៅឆ្នាំ ២០១៧-២០១៨។ ត្រូវដឹងថា នៅក្នុង អាណត្តិរដ្ឋសភា ទី៥ ជា រយៈពេល ទុក អោយ ជនជាតិយួន ដែលមករស់នៅស្រុកខ្មែរ ខុសច្បាប់ ក្លាយជា ប្រជាជនកម្ពុជា ពេញលេញ ចំណែក សំរាប់ អណត្តិរដ្ឋសភា ទី៦ នៅពេលខាងមុខ គឺ ធ្វើអោយយួន មានសញ្ញាតិកម្ពុជា ក្លាយ ជា ម្ចាស់ស្រុកខ្មែរ មានចំនួនច្រើនលើសជនជាតិខ្មែរ។ សួរថា តើនៅក្នុងរឿងនេះ លោក សម រង្ស៊ី ជា អ្នករងគ្រោះ ឬ ជា អ្នកស៊ីគ្រលំ ?

---

[35] គម្បស្ថាន ;destination។

# ជួបសម្លុត ជួបសម្លាប់

*សេរីការ*



ឆ្នាំ ២០១៦

ជួបសម្លុត និង ជួបសម្លាប់ អំណើះតទៅ ជា រហស្សនាម ពួកបាតដៃទី៣ ដែលមាន លោក ហ៊ុន សែន ជា មេក្លោង ប្លន់អំណាចរាស្ត្រ ដើម្បីយកទៅបំរើ ប្រយោជន៍យួន ស៊ីផលកម្រៃ ពី ពួកឈ្មួញទុច្ចរិត និង ក្រុមគ្រួសារខ្លួនមានទុនក្នុងក្រុមហ៊ុននានា នៅស្រុកខ្មែរ និង ជាម្ចាស់សហគ្រាសមួយចំនួន។ សកម្មភាពនេះ អាចនាំឲមានទំនាស់ផលប្រយោជន៏ និងប៉ះពាល់ដល់គុណធម៌ ដែលជាការនាំឲខូចប្រយោជន៍ជាតិ។ ក្រុមបាតដៃទី៣ បែងចែក ជា ពិពិធសាខា (agences diverses) ដូចមាន៖ ប្រព័ន្ធតុលាការ អាជ្ញាធរព្រហ្មទណ្ឌ អ្នកនាំពាក្យ និង ឃាតករស៊ីឈ្នួលសម្លាប់មនុស្ស។ ការចោទ ការចាប់ និង ការនិយាយបំភាន់ជា ភារកិច្ចរបស់ពួកក្រុមសម្លុត រីឯ អំពើឃាតកម្មវិញ ជាមុខងាររបស់ក្រុមស៊ីឈ្នួលសម្លាប់មនុស្ស ហើយ ក្រុមទាំងពីរនេះស្ថិតនៅក្រោមបញ្ជាអាជ្ញាធរ អាណានិគមយួន ដែលមានលោក ហ៊ុន សែន ជាស្រមោល នៃអំណាចផ្តាច់ការ។ អំពើឃាតកម្មលើរូប លោក កែម ឡី ឈុត វុទ្ធី ជា វិជ្ជា និង ខ្មែរស្នេហាជាតិដទៃទៀត សុទ្ធជាស្នាដៃថោកទាប របស់ក្រុម

បាតដៃទី៣នេះ។ ដូច្នេះមិនអាចរកយុត្តិធម៌ជូន ដល់ជនរងគ្រោះបាននោះឡើយ ព្រោះឃាតករ និងអាជ្ញាធរ ធ្វើអង្គេត ជា ក្រុម តែមួយ។ អាស្រ័យហេតុនេះ កុំនាំគ្នានិយាយថា ទុកអោយ អាជ្ញាធរ និង តុលាការ គេធ្វើការ ព្រោះនៅស្រុកខ្មែរ គ្មានទីតិរដ្ឋនោះទេ។ បើខ្មែរយើង នៅតែនាំគ្នាឈរមើល អំពើឃាតកម្មលើអ្នកស្នេហាជាតិ និងការបំពានច្បាប់ លើ ប្រជាពលរដ្ឋ ពីសំណាក់អំណាចយួន នៅស្រុកខ្មែរ ប្រើបាតដៃទី៣ខ្មែរ សំរាប់សម្លុត-សម្លាប់ខ្មែរ ឃាដកម្ម ដ៏ថោកទាប នឹងមានកើតឡើងជានិច្ច។ ខ្មែរយើង ត្រូវហ៊ាន លើក យកដើមទង (arrière-plan) នៃ អំពើឃាតកម្ម នេះ មកបង្ហាញជាសាធារណ: ថានរណាជា អ្នកទទួលខុសត្រូវ ដើម្បីក្រងជាស្មារតីជាតិ ប្រឆាំងនឹងអំពើថោកទាបនេះ។ តុណ្ហីភាព របស់ខ្មែរយើងនៅចំពោះមុខអំពើអប្រិយ លើរូប លោក កែម ឡី គឺ ជាលិខិតអនុញ្ញាតអោយ អាជ្ញាធរ អាណានិគមយួន បន្តសម្លាប់ខ្មែរអ្នកស្នេហាជាតិ នៅថ្ងៃស្អែកជាពុំខាន។ ហើយ សូមអោយខ្មែរយើង កុំជឿងប់ថា វប្បធម៌សន្ទនា ជាការស្រោចស្រង់ខ្មែរ ព្រោះសន្ទនាជាស្នូំ ជាការសូមចុះចាញ់ តែប៉ុណ្ណោះ។ មានតែ

ការងើបឈររួម នៃប្រជាពលរដ្ឋ បង្កើតជា កម្លាំងជាតិ ធ្វើសកម្មភាពតស៊ូអហិង្សា (បាតុកម្មស្របច្បាប់) ពាសពេញនគរទើប ប្រជាជាតិខ្មែរយើង អាចរំដោះខ្លួន ចេញពីអាណានិគមយួន ដែលមាន បាតដៃទី៣ខ្មែរជា ឃាតករសម្លាប់ខ្មែរគ្នាឯង ដើម្បី ការពារប្រយោជន៏យួននៅស្រុកខ្មែរ។ កាលសម័យខ្មែរក្រហម មាន ប៉ុល ពត ជា មេឃាតករ សម្លាប់ខ្មែរដើម្បី យកដីរាស្ត្រ ដាំលទ្ធិកុម្មុយនិស្ត រីឯសម័យ អាណានិគមយួនសព្វថ្ងៃ មាន ហ៊ុន សែន ជាអ្នកសម្លាប់ខ្មែរ ដើម្បី ទទួលជនជាតិយួនរាប់លាននាក់ អោយចូលមករស់នៅក្នុងស្រុកខ្មែរ ក្នុងឋានៈជា អ្នកមានគុណលើជាតិ។ ប៉ុល ពត ក្តី ហ៊ុន សែន ក្តី សុទ្ធជាចលករ នៃយួនូបនីយកម្ម មួយចាញ់បោកយួនព្រោះល្ងង់ មួយទៀតចូលយួនត្រង់ៗព្រោះលោភលន់ តែកម្មវិបាក នៃអំពើ របស់ជនទាំងពីរ មានតែមួយ គឺបំផ្លាញប្រជាជាតិខ្មែរ ដែលអាចអោយអ្នកដឹកនាំយួនគេអាចធ្វើបូរណកម្ម (intégration) នៃស្រុកខ្មែរ បញ្ចូល ក្នុង ស្រុកយួន ដើម្បី ធ្វើសមានកម្ម (assimilation) នៃជនជាតិម្ចាស់ស្រុក អោយក្លាយជាអនុប្រជាជន របស់ជនជាតិយួននៅកម្ពុជា។ ជួបសម្លុត និងជួប

សម្លាប់ជាយុទ្ធសាស្រ្តយួនដែលខ្មែរយើង កំពុងនាំគ្នាឈរមើលវា ដោយអប្បសក្ខ (impuissance) នៅចំពោះមុខឃាដកម្មលើរូប លោកកែម ឡី ដែលជា ឃាដកម្មម្តងទៀត លើអ្នកស្នេហាជាតិខ្មែរ ដួលស្លាប់ដើម្បីការពារជាតិខេមរា។ តើសេចក្តីស្លាប់នេះ វាមានន័យអ្វី បើ គ្រាន់ តែ ខ្មែរយើងនាំគ្នាឈរយំជាជនតក់ស្លុត ? កំរិតនៃអំណត់អត់ឱន (seuil de tolérance) ចំពោះអំពើព្រៃផ្សៃ របស់ពួកអ្នកដឹកនាំសព្វថ្ងៃ វាហួសយូរយារមកហើយ ដែល នាំអោយ អំណត់ខ្មែរយើង ដែលយើងទុកវាជា គុណធម៌ ប្រែក្លាយជាទុព្វលភាពនៅចំពោះមុខ អនារ្យធម៌ (barbarie) នេះ។ ដូច្នេះ អង្គុយយំសង្វេក អន្ទង ហៅទេវតា អោយលោកជួយជាតិខ្មែរ មិនគ្រប់គ្រាន់សំរាប់ទុបទល់នឹងអំពើឃាតកម្មនោះបានទេ ក៏ដូចគ្នាអង្គុយចាំ បោះឆ្នោត គ្មានយុត្តិធម៌ គ្មានសេរី នោះដែរហើយ នឹង រង់ចាំស្រកោក នូវអន្តរាគមន៏អន្តរជាតិ។ បើខ្មែរយើង មិនជួយខ្លួនឯងសិន តាម សកម្មភាពដ៏វិសាល គឺច្បាស់ជាគ្មានបរទេសនិងទេវតាណាអាចជួយខ្មែរបាន នោះឡើយ ! ពេលវេលា រង់ចាំ វា ជា ឃាតករ សម្លាប់ ប្រជាជាតិខ្មែរ នៅ អបរសម័យ។

# ល្បិចដោះខ្លួន

សេរីការ



ឆ្នាំ ២០១៦

ព្រះមហាក្សត្រ មានព្រះរាជហឫទ័យ ទទួលយល់ព្រមការស្នើរសូមរបស់លោក ហ៊ុន សែន អោយលើកលែងទោសដល់លោក គឹម សុខា។ រាជវិរកម្មនេះ វាមានអាការក្រៅ ដូចជាមានខ្លឹមសារណាស់ សំរាប់យុត្តិធម៌ ដែល ពួកអ្នកដឹកនាំគណបក្សប្រឆាំង គេ ទុកជា ដំណោះស្រាយ នយោបាយមួយដំណាក់ការ។ តែបើយើងយកវា មកពិចារណាបន្តិច យើងឃើញថា អំពើនេះ វាជា គោលវិធី ជាទម្លាប់ របស់ពួកអ្នកកាន់អំណាច គេយកវាមកប្រើ សំរាប់ពង្រឹង អំណាចផ្តាច់ការ របស់គេតែប៉ុណ្ណោះ ហើយក៏វា មិនមែនជា ដំណោះស្រាយនយោបាយ ជាស្ថាពរអ្វីនោះដែរ ដូចដែលធ្លាប់មានពីអតីតកាលមក ផ្ទុយទៅវិញ កាលណា វា មាន គោលវិធីនេះកើតឡើងម្តងៗ គឺច្បាស់ជាវាមាន សិថិលភាព[36] រវាងបក្សប្រឆាំង ជាមួយនិង លោក ហ៊ុន សែន ដែលជាការស៊ុមគ្រលុំ ជា សេចក្តីវិនាស ដល់ លិទ្ធិប្រជាធិបតេយ្យ និង

36 សិថិលភាព ;Concession, compromis។

ប្រយោជន៍ជាតិ ជាពុំខាន ដូចលោក សម រង្ស៊ី និង ហ៊ុន សែន ធ្លាប់បានធ្វើជាច្រើនដងរួចមកហើយ។ ទោះបី លោក កឹម សុខា គាត់អះអាងថា វាគ្មានការដោះដូរ តែ គាត់ មិនបាន គិតថា ធម្មជាតិ នៃនីតិវិធី លើកលែង ទោសនេះ វាមានធាតុជាការដោះដូរ រួចស្រេចទៅហើយ។ ដូចយ៉ាង គាត់បានសរសេរសំបុត្រ ផ្ញើចំពោះលោក ហ៊ុន សែន សារភាព ទទួលស្គាល់គ្រប់កំហុស ដែលគាត់បាន ប្រព្រឹត្តជាមុនសិន រួចហើយ ស្នើរសូមលោក ហ៊ុន សែន មេត្តាជួយ ធ្វើអន្តរាគមន៍ ចំពោះដល់ព្រះមហាក្សត្រ អោយ ព្រះអង្គ លើកលែងទោសដល់ខ្លួន។ ទទួលកំហុសក្នុង ករណីបែបនេះ គឺទទួលស្គាល់ អយុត្តិធម៌ ថាជា យុត្តិធម៌។

មួយវិញទៀត សេរីភាពរបស់លោក កឹម សុខា នៅពេលនេះ ជា ប្រាក់កក់ របស់គាត់ ទុកអោយលោក ហ៊ុន សែន សំរាប់ ធានា នូវ សេចក្តីសុខ ដល់ លោក ហ៊ុន សែន និង ក្រុម គ្រួសារ និង ការចូលធ្វើ សហការរបស់ពួកអ្នកដឹកនាំ បក្ស ប្រឆាំង នៅក្នុង យុទ្ធសាស្ត្រឃួន។ ដូច្នេះសេរីភាពនេះ វា

គ្មានអត្ថរស់ជា ជវនៈ[37] នៃការតស៊ូ ដើម្បី ប្តូរអំណាចផ្តាច់ការនោះឡើយ។ លោក ហ៊ុន សែន សុខចិត្តអោយលោក កឹម សុខា រួចទោស ដើម្បីធ្វើជា មេបន្ទុក ទទួលខុសត្រូវ នូវគ្រប់ សកម្មភាព ជាសំដីក្តី ជា អំពើក្តី ដែលទុកជាការប្រឆាំងនឹង បក្សរបស់គាត់ ពុំនោះសោត លោក កឹម សុខា នឹងអាចទទួល ការចោទប្រកាន់ជាថ្មី នូវកំហុសសិប្បនិម្មិត ជាច្រើនទៀត ដែលតុលាការ មិនទាន់បានសំរេច ដូចគ្នានឹង ករណីលោក សម រង្ស៊ី នោះដែរ។ ការពិតវាមិនពិបាកនឹងមើលឃើញនោះឡើយ ខ្មែរយើង គ្រាន់តែនាំគ្នាតាមដានដល់គ្រប់សកម្មភាព លោក កឹម សុខា ក្តី សម រង្ស៊ី ក្តី និង ពួកអ្នកដឹកនាំបក្សប្រឆាំងក្តី ចាប់ពីពេលនេះទៅ វានឹងឃើញមារយាទពិត របស់ពួកគាត់ស្រេចទៅហើយ គឺជាមារយាទចុះចាញ់លោក ហ៊ុន សែននោះឯង។ ពាក្រស្លោក ‹ដូរឬមិនដូរ› វាជាប្រយោគកន្លង ចប់ពេញ

[37] ជវនៈ ; bond, élan។

លេញទៅហើយ សំរាប់ ការបោះឆ្នោត ឃុំសង្កាត់ នៅឆ្នាំ ២០១៧ និង ការបោះឆ្នោតសភា នៅឆ្នាំ២០១៨។

យើងមាចសន្និដ្ឋានបានថា សេរីភាពលោក កិម សុខា គឺ ជា ល្បិចដោះខ្លួន[38] របស់គាត់ផ្ទាល់តែប៉ុណ្ណោះ។ តែយើង អបអរសាទរដល់គាត់ ដែលអាចវិលត្រឡប់ មករស់នៅជា ធម្មតា ជា មួយគ្រួរសារវិញ ដែល ជា សុភមង្គល នៃមនុស្ស លោក។ តែត្រូវលោក កឹម សុខា មានសតិសម្បជញ្ញៈថា នៅ ជុំវិញ រឿង ស្រីមុំ មាន មនុស្ស ដទៃទៀត គេកំពុង ជាប់ ពន្ធនាគារ នៅឡើយ។

---

38 ល្បិចដោះខ្លួន; faux-fuyant។

# មហាជ័យជំនះយួន

*សេរីការ*



ឆ្នាំ ២០១៦

សេចក្តីសង្ឃឹមលើការបោះឆ្នោតនៅក្នុងបរិបទខ្មែរសព្វថ្ងៃ ជាការទទួលស្គាល់មហាជ័យជំនះយួននៅស្រុកខ្មែរ ព្រោះខ្មែរយើង នាំគ្នា ទទួលស្គាល់របបផ្តាច់ការ ដែលមានយួនជា អ្នកដឹកនាំ ជា អកុសលអាចទទួលយកបាន។ សេចក្តីសង្ឃឹមនេះ ជា ឧន្នាគ៌ា[39] សំរាប់ប្រជាជាតិខ្មែរ ព្រោះជាចាគប័ត្រ[40] នៅក្នុងអារម្មណ៏អនានុភាព គឺថា ដឹងច្បាស់ថា វា នឹងនាំមក នូវមហាទុក្ខដល់ជាតិ តែគ្មានដំណោះស្រាយផ្សេងមួយទៀត ក្រៅពីទទួលស្គាល់ជាតុណ្ហី[41] នៃមហាជោគជ័យយួនតែប៉ុណ្ណោះ។ បក្សប្រឆាំងនៅឆ្នាំ២០១៤ សំរេច ចូលជាសមាជិកក្នុងសភា ដោយមានសេចក្តីសំអាងថានឹងអាចធ្វើអោយ លទ្ធិប្រជាធិបតេយ្យ ដើរទៅមុខ អោយជាតិ មាន ការរីកចំរើន និង កំណែទំរង់ ច្បាប់បោះ

---

39 ឧន្នាគ៌ា ;Chemin du mal។
40 ចាគប័ត្រ ;Résignation ;ការលះបង់សិទ្ធិអោយអ្នកណាម្នាក់, ការអត់ធ្មត់ទ្រាំទ្រ។
41 តុណ្ហី ;Tacite ;ដោយកាត់យល់, ដែលស្ងៀម, តុណ្ហីភាព។

ឆ្នោត ដើម្បី អោយការបោះឆ្នោត សមតាម សមធម៌ និង មានយុត្តិធម៌។ តែផ្លែ ដែលបក្សប្រឆាំងបេះ គឺវាមានរស់ជាតិ ជា ផលាក្រពុលសំរាប់ប្រជាជាតិខ្មែរទៅវិញ មិនតែប៉ុណ្ណោះ ពួក អ្នកដឹងនាំ បក្សប្រឆាំង កំពុងស៊ុមក្រលុំ ជាមួយ បក្សកាន់ អំណាចផ្តាច់ការ អោយខ្មែរបរិភោគផ្លែក្រពុលនោះឯង។ យើងឃើញថ្មីៗនេះ ទរទស្សន៍ជាតិ គេផ្សាយ សំនួរ និង ចម្លើយ នៅរដ្ឋសភា រវាងបក្សប្រឆាំងជាមួយ រាជរដ្ឋាភិបាល ដើម្បីបង្ហាញអោយឃើញថានៅស្រុកខ្មែរ មានអនុវត្ត លទ្ធិប្រជាធិបតេយ្យ មានសេរីភាពនយោបាយ ព្រោះបក្សប្រឆាំង មានលទ្ធិភាពត្រួតពិនិត្យសកម្មភាពនៃរដ្ឋាភិបាល។ សួរថា ចុះហេតុអ្វីបានជាអ្នកដឹកនាំបក្សប្រឆាំងសុញ្ញគំនិត ធ្លាក់ទៅក្នុងកញ្ជោតភាពបែបនេះ ? យួនអង្គុយមើលទរទស្សន៍ នាំគ្នាសើច ឃើញលោក តំណាងរាស្ត្របក្សប្រឆាំងចោទសួរ ប្រកបដោយសុរោហារ ដល់ រដ្ឋមន្ត្រី ខ្វះសមត្ថភាព ដូចដៃគូ អ្នកច្រៀងអាយ៉ៃ ព្រោះអ្នកសួរ ភ្លេចគិតថាមេបក្សរបស់ខ្លួនទាំងពីរកំពុង រស់នៅ ក្នុងការឃុំឃាំង ដោយខ្លួនឯង មួយនៅបរទេស មួយទៀតនៅទីស្តីការនៃគណបក្ស ហើយ មិត្តខ្លួន

មួយចំនួនទៀត រស់នៅក្នុង គុកព្រៃស។ សេរីភាព ក្នុងស៊ុម[42] នេះ តើពួកអ្នកដឹកនាំគណបក្សប្រឆាំង នៅក្នុងសតិរបស់គាត់ គាត់ទុកជាសេរីភាព ប្រកបដោយ មោទនភាពនោះឬ ? បើការ វិលត្រឡប់ ចូលរដ្ឋសភាវិញ ដើម្បីបំពេញសិទ្ធិ ត្រឹមអាច កោះហៅរដ្ឋមន្ត្រី មកចោទសួរតែប៉ុណ្ណោះ វាគ្មាន ខ្លឹមសារអ្វី ដល់ប្រយោជន៍ជាតិនោះឡើយ ព្រោះ សិទ្ធិក្នុងស៊ុមនេះ វានៅ ក្នុងមហាជ័យជំនះយួន គេបើក អោយប្រើ សំរាប់តែលាងដៃប្រឡាក់ឈាម នៃពួកជនផ្តាច់ការ តែប៉ុណ្ណោះ។

---

[42] សេរីភាពក្នុងស៊ុម ;liberté cadrée។

*សេរីការ*



ឆ្នាំ ២០១៦

# អំណាចព្រះរាជាអាស្រ័យរដ្ឋធម្មនុញ្ញ

មានអ្នកច្បាប់មួយចំនួនគិតថា ព្រះមហាក្សត្រខ្មែរ ទទួលអំណាចធម្មនុញ្ញពីប្រជាពលរដ្ឋ ព្រោះពួកគាត់ នាំគ្នាកាត់យល់ថា អំណាច ព្រះរាជា ជា អំណាចប្រត្យក្ស[43]។ ការបកស្រាយតាមបញ្ញានេះ ជាសិទ្ធិសេរីភាពរបស់បុគ្គលនិមួយៗ តែវានាំ បង្កើតជា ការពិភាក្សាសាពិរុទ្ធ[44] នៅក្នុងមជ្ឈដ្ឋាននៃ អ្នកប្រជាធិបតេយ្យ។ ត្រូវដឹងថា ការកាត់យល់នេះ វាមានតាំង ពីយូរយារមកហើយ គឺ តាំងតែពីស្រុកខ្មែ រមានរដ្ឋធម្មនុញ្ញ ទី១នៅឆ្នាំ ១៩៤៧ ដែលជ្រើសរើសយករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញជារបបដឹកនាំជាតិ។

នៅក្នុង វិបត្តិនយោបាយ នៅស្រុកខ្មែរសព្វថ្ងៃនេះ ហាក់បីដូចជា អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ គេយកស្ថាប័ន

---

43 អំណាចប្រត្យក្ស ; pouvoir réel។
44 ការពិភាក្សាសាពិរុទ្ធ ; débat contradictoire។

ព្រះមហាក្សត្រ មកធ្វើជា មធ្យោបាយ សំរាប់រកដំណោះស្រាយបញ្ហានយោបាយ ដោយយក មាត្រា៩[45] ជាយោង។

សួរថា នៅក្នុង បរិបទ នៃ ជីវិតភាព នយោបាយខ្មែរបច្ចុប្បន្ន ការយក តួនាទីខ្ពង់ខ្ពស់ របស់ព្រះមហាក្សត្រ ជាអាជ្ញាកណ្តាល ដើម្បីធានានូវការប្រព្រឹត្ត នៃអំណាចសាធារណៈ អោយ មាន ភាពទៀងទាត់ តើមិនទុកជា សម្មានការ[46] ប្រកប ដោយ គ្រោះថ្នាក់ នូវ ការវិលត្រឡប់វិញ នៃ របប រាជាធិបតេយ្យ ឬ របប រាជានិយមផ្តាច់ការ ដែរ ឬទេ ?

## រំឭកអំពីសកម្មភាពថ្មីៗ របស់ ព្រះរាជា

ត្រូវរំឭកអំពី ការបំពានជាក់ស្តែង នៃ ច្បាប់រដ្ឋធម្មនុញ្ញ ពីសំណាក់ ព្រះមហាក្សត្រ សីហមុនី នៅពេល បើកសម័យប្រជុំដំបូង ប្រកាស នូវ សុពលភាព នៃ អាណត្តិទី៥ របស់

---

[45] មាត្រា៩ : ព្រះមហាក្សត្រទ្រង់ មានតួនាទីខ្ពង់ខ្ពស់ជា អាជ្ញាកណ្តាលដើម្បី ធានាការប្រព្រឹត្ត នៃអំណាចសាធារណៈ អោយមានភាពទៀងទាត់។

[46] សម្មានការ ; considération។

សមាជិកនិមួយៗ នៃរដ្ឋសភា ដោយគ្មានការចូលរួមប្រជុំពី អ្នកតំណាងរាស្ត្រជាប់ឆ្នោត របស់ គណបក្សសង្គ្រោះជាតិ ចំនួន៥៥នាក់។ ការបំពាន ជាក់ស្តែងនេះ រំលេច នូវកង្វះនៃសុពលភាព របស់ព្រះអង្គ ជាអាជ្ញាកណ្តាលជាតិ ពីព្រោះព្រះអង្គ មិនមែនជាតំណាង នូវ សីលធម៌, អព្យាក្រឹតភាព និង អនាគតិ ដែលគេទុកជា គុណសម្បត្តិដ៏ប្រសើរ របស់អាជ្ញាកណ្តាល ត្រូវ មាន ជា ដាច់ខាត នៅក្នុង ស្មារតី របស់ខ្លួន ព្រោះខ្លួនជាអគ្គបុរស។

នៅទីនេះ យើង រំឭកបំថែមដែរ អំពី គម្លាត នៃគំនិត របស់ ព្រះរាជា ពី មាត្រា៨ នៃរដ្ឋធម្មនុញ្ញ[47] គឺទ្រង់ បាន ឡាយ ព្រះហត្ថលេខា លើសន្ធិសញ្ញាបន្ថែម ជាមួយប្រទេសយៀកណាម នៅឆ្នាំ ២០០៥ ដើម្បី ប្រទាន សច្ចាប័ន

47 មាត្រា៨ : ព្រះមហាក្សត្រព្រះអង្គទ្រង់ជាជានិមិត្តរូបនៃឯកភាពជាតិនិងនិរន្តរភាពជាតិ។

ព្រះមហាក្សត្រទ្រង់ជា អ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជាទ្រង់ជា អ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជានិងការគោរពសន្ធិសញ្ញាអន្តរជាតិ។ ពលរដ្ឋ

លើ សិទ្ធិសញ្ញា រវាងខ្មែរយួន នៅឆ្នាំ ១៩៧៩, ១៩៨២, ១៩៨៣ និង ១៩៨៥ ដែល កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ១៩៩១ បានទុកជាមោឃ:។

អង្គហេតុសំខាន់ ទាំងពីរនេះឯង ដែល បញ្ជាក់អោយឃើញ ច្បាស់ថា ព្រះរាជាខ្មែរបច្ចុប្បន្ន មិនបានដើរតួនាទីព្រះ អង្គ ជា អ្នកការពារ ប្រយោជន៍ប្រជាជាតិខ្មែរ នោះឡើយ ដូច្នេះទ្រង់ មិនអាចធ្វើជា អាជ្ញាកណ្តាល សំរាប់ដោះស្រាយ វិបត្តិជាតិ បានឡើយ, ជា ពិសេសទៅទៀត ក្នុងឋានៈ ព្រះ អង្គ ជាព្រះរាជា អាស្រ័យរដ្ឋធម្មនុញ្ញ ទ្រង់គ្មានអំណាចអ្វី សំរាប់ធ្វើអន្តរាគមន៍ ក្នុងកិច្ចការ នយោបាយ និង យុត្តិ ធម៌ ក្នុងនាម នៃការបែងចែកអំណាចធម្មនុញ្ញ។

## អំណាច ព្រះរាជា ជា អំណាច និមិត្តរូប ឬ ជា អំណាច ប្រត្យក្ស ?

យើងសួរ ជា សំណួរថា តើ ប្រជាពលរដ្ឋ ដែល ជា ម្ចាស់ នៃ អំណាច មានប្រគល់ថ្វាយអំណាច ដល់ព្រះរាជាដែរឬទេ ? គឺគ្មាននោះឡើយ ដែលមានបញ្ជាក់ នៅក្នុង មាត្រា៧៖ ព្រះ

មហាក្សត្រកម្ពុជា ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។

បើយើងយក គំនិត នៃរដ្ឋធម្មនុញ្ញ មកពិនិត្រ យើងឃើញថា ប្រជាពលរដ្ឋ ដែល ជា ម្ចាស់អំណាច បាន ប្រគល់អំណាចខ្លួនរួចហើយ ដល់អ្នកតំណាងរបស់ខ្លួន គឺ តំណាងរាស្ត្រ ដូច្នេះ មិនអាច យល់បានថា នៅ មាន ចំណែក នៃអំណាចខ្លះ ដែល ប្រជាពលរដ្ឋ ប្រគល់ថ្វាយដែរដល់ ព្រះរាជា ដែល ទ្រង់ស្ថិតនៅក្រៅ ក្របខណ្ឌ អំណាចនីតិបញ្ញត្តិ, អំណាចនីតិប្រតិបត្តិ និង តុលាការ។ អំណាចត្រ័យៈនេះទៀត មានក្ខណៈ ជា ការ កាន់កាប់អំណាចប្រតិភូ ហើយអ្នកកាន់កាប់ ជា អ្នកទទួលខុសត្រូវ នៅចំពោះមុខប្រជាពលរដ្ឋអធិបតេយ្យ ព្រោះ ប្រជាពលរដ្ឋ មាន អំណាចត្រួតពិនិត្រ និង ដាក់ទោស លើខ្លួន គ្រប់ពេលវេលា។ ក្នុងករណី ដែល ព្រះរាជា ជា អភិសិត្តរាជ[48] មាន មាត្រា៧បដិញ្ញាត ថា អង្គព្រះមហាក្សត្រ មិនអាច នរណារំលោភ

[48] អភិសិត្តរាជ ; roi sacré។

បំពានបានឡើយ ដូច្នេះ នៅក្នុងលក្ខណៈនេះ គេអាចសួរថា តើ ប្រជាពលរដ្ឋ ដែលជាម្ចាស់អំណាច មានសិទ្ធិអ្វីនឹងអាចត្រួតពិនិត្រ និង ដាក់ទោសព្រះរាជា បាន ?

## ពិនិត្រអំពីគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ

ការប្រគល់អំណាចប្រតិភូ មានលក្ខណៈសំខាន់បីយ៉ាង៖ ជាការប្រគល់ ក្នុងរយៈពេល បណ្ដោះអាសន្ន, ជា ការប្រគល់មាន កម្រិតដែន អំណាច និង ជា ការប្រគល់ អាចត្រឡប់មកម្ចាស់វិញបាន។

## ១. លក្ខណៈ នៃ ការប្រគល់ក្នុងរយៈពេលបណ្ដោះអាសន្ន

ប្រជាពលរដ្ឋ មិនអាច ប្រគល់អំណាច ទាំងអស់ របស់ខ្លួនអោយ បុគ្គលម្នាក់ ក្នុងរយៈពេល គ្មានទីបញ្ចប់ នោះឡើយព្រោះ ការប្រគល់បែបនេះ វា មាន ភាពរូប ដូចជា ការប្រគល់ អំណាចផ្ដាច់ការ នោះឯង តែ ប្រជាពលរដ្ឋអាចពិភាក្សារួម (répartir des tâches collectives) ខ្លះ ជាអចិន្ត្រៃយ៍ ដូច ជា កិច្ចការសន្តិសុខក្រៅប្រទេស ឬ ការស្រុះស្រួលគ្នា ក្នុង ប្រទេស ដោយ បែងចែក ដាច់ឡែក រវាង ដំណែង

(fonction) នឹង សាម៉ិជន (titulaire) គឺទុក ដំណែង ជាមុខងារ ជា អចិន្ត្រៃយ៍ រីឯ សាម៉ិជន វិញ គឺ ជាការតែងតាំងមាន កំរិតពេលវេលា ដើម្បី វៀរចាក កុំអោយ សាម៉ិជនអស់មួយជីវិតនោះ ក្លាយទៅ ជា ជនផ្តាច់ការ។ ដោយសារព្រះរាជា មាន ដំណែងអស់មួយជីវិត ដូច្នេះ ក្នុងលក្ខណៈបែបនេះ ព្រះអង្គមិនអាចមានអំណាច ដែលជា អំណាចធម្មនុញ្ញ របស់ប្រជាពលរដ្ឋបាននោះឡើយ ព្រោះម្ចាស់អំណាច មានតែមួយគត់ គឺ ប្រជាពលរដ្ឋ។

## ២. លក្ខណៈ នៃ ការប្រគល់ ដោយ មាន ដែនកម្រិត នៃ អំណាច

មានកិច្ចការខ្លះ មាន ការពិបាកនឹងកម្រិត នូវដែន នៃ អំណាច ព្រោះ សាម៉ិជន ត្រូវការ ត្រួតត្រា ក្នុងវិស័យ ដ៏ពិសាល (domaines très vastes) ដូចជា វិស័យ ការពារជាតិ, កិច្ចការទូត និង យុត្តិធម៌។ តែ ទោះបី យ៉ាងណា ក៏ដោយ សម៉ិជន ដូច ជា មេទ័ព, ទូត និង អយ្យការ មិនអាច ធ្វើ អ្វីបាន ស្រេចតែចិត្តខ្លួននោះឡើយ ព្រោះការប្រគល់អំណាចនេះ វានៅតែមាន បដិអំណាច (contre-

pouvoir) ជា ប្រយោល សំរាប់ ត្រួតត្រាវាជានិច្ច។ ដោយសារ ព្រះរាជា ជា បុគ្គល មិនអាច នរណា រំលោភ បំពានបាន ដូច្នេះ មិនអាចមាន បដិអំណាច ណាមួយ អាចត្រួតត្រា ព្រះអង្គបាននោះឡើយ។

## ៣. លក្ខណៈ នៃ ការប្រគល់អាចត្រឡប់មកម្ចាស់វិញបាន

ម៉េចនឹងអាចដកហូតអំណាចព្រះរាជាបានវិញ ដោយមិន បាច់ វិនិច្ឆ័យ កំហុសព្រះរាជាសិន អំពី ការខ្វះសមត្ថភាព បំពេញ ភារកិច្ច ដែលប្រជារាស្ត្រ ប្រគល់ថ្វាយ ? ដូចគេដឹង ថា ព្រះរាជា ជា បុគ្គលពិសិដ្ឋ មិនអាចនរណា រំលោភ បំពានបាន និង គ្មាន ការទទួលខុសត្រូវ លើអ្វីមួយ ដូច្នេះ នៅពេលព្រះអង្គ មាន ទំនាស់ ក្នុងភារកិច្ច របស់ ព្រះអង្គ ជា មួយ នឹងអ្នកភាគច្រើន នៅក្នុងរដ្ឋសភា ហើយ ព្រះ អង្គ គ្មាន អំណាចរំលាយ រដ្ឋសភាព្រោះ រដ្ឋសភា មានការ ទទួលខុសត្រូវ តែនៅ ចំពោះប្រជាពលរដ្ឋ ដែលជាម្ចាស់ អំណាច ក្នុងករណីបែបនេះ មាន តែ ដំណោះស្រាយ មួយ គត់ គឺ ព្រះរាជា ត្រូវដាក់រាជ្យ ព្រោះ រដ្ឋសភា ក៏គ្មាន អំណាច ដករាជ្យព្រះអង្គបាននោះដែរ ព្រោះ ព្រះអង្គទទួល

រាជ្យ អស់មួយជីវិត។ ឧបមាថា ព្រះរាជា ក្នុងនាម ព្រះអង្គ ជា អគ្គមេបញ្ជាការ ជាន់ខ្ពស់ នៃ កងទ័ពជាតិ ប្រើអំណាច យោធា ដើម្បី បង្ក្រាប អ្នកជំទាស់នឹងព្រះអង្គ សួថា តើ នរណា អាច ទប់ ព្រះអង្គ បាន បើ សិន ជា ព្រះអង្គ ជា អ្នកកាន់កាប់អំណាចប្រត្យក្ស ?

តាម វិស័យមតិ របស់យើង ដំណោះស្រាយ នៃ វិបត្តិ នយោបាយ បច្ចុប្បន្ន មិនមែន ត្រូវយក ព្រះរាជា ជា មធ្យោបាយដោះស្រាយ តាម ការប្រគល់ អំណាច ដល់ព្រះ អង្គក្ដី ឬ យក ព្រះអង្គ ធ្វើជា អាជ្ញាកណ្ដាលក្ដី ព្រោះ ព្រះ រាជា ទ្រង់គ្មាន អំណាចប្រត្យក្ស អ្វីនោះឡើយ, អំណាចព្រះ អង្គ ជា អំណាចនិមិត្តរូប តែប៉ុណ្ណោះ។ ដំណោះស្រាយ គឺ ស្ថិត នៅក្នុង កណ្ដាប់ដៃ ប្រជាពលរដ្ឋ ព្រោះ ជា ម្ចាស់ អំណាចប្រត្យក្ស ហើយ ជា អ្នកមានកាតព្វកិច្ច ការពារ ផលប្រយោជន៍ជាតិ។

# ហេតុ ឬ លក្ខខណ្ឌ នៃ គ្រោះថ្នាក់ នៅស្រុកខ្មែរ

*សេរីការ*



ឆ្នាំ ២០១៦

ខ្មែរយើងគួរ ពិចារណាអំពី ហេតុ (cause) និង លក្ខខណ្ឌ (conditions) ដែល នាំ អោយ អំណាចផ្តាច់ការ នៅស្រុកកខ្មែរ មាន សព្វានុភាព ដូចសង្សារ។ អ្នកខ្លះយល់ឃើញថា ហេតុ គឺ មកពីខ្មែរយើង បែកបាក់គំនិតគ្នាជាទម្លាប់ ផ្ទុយពី គំនិតថា « សាមគ្គីភាព ជាកម្លាំង » ដូច្នេះ ខ្មែរយើង ត្រូវ រួបរួមគ្នា ទើបអាចនឹងកំទិចឲសាបសូន្យ នូវអំណាចផ្តាច់ការបាន។ គំនិតនេះជាការដេញរកហេតុផល ឈរលើ ទស្សនៈ នៃ សហេតុធម៌ (causalité)។ ឧទាហរណ៍ បន្ទាប់ពីតុលាការ របស់លោក ហ៊ុន សែន កាន់ទោសលោក កឹមសុខា ដាក់ ពន្ធនាគារ ចំនួន៥ខែ ពីបទ មិន ចូល ខ្លួន តាម ដីកា តុលាការ លោក កឹម សុខា បានប្រកាស (៩ កញ្ញា) បញ្ជាក់ អំពី គោលជំហរ របស់គាត់ ហើយ គាត់ ធ្វើការ អំពាវនាវ ដែលនាំឲរំភើបចិត្ត ឲខ្មែររួបរួមគ្នា ដើម្បីប្រឆាំងនឹងអំពើ អយុត្តិធម៌ ឬ ដោះស្រាយ នូវគ្រប់ចំណោទនយោបាយ រវាង ខ្មែរនិងខ្មែរ តាមសន្តិវិធី ។ បើយើងយកហេតុ នូវការខ្វះ សាមគ្គីភាព ជា កត្តា នៃដំណើររសាយ នៃអំណាចផ្តាច់ការ នៅស្រុកខ្មែរ គឺជា ការសង្កត់បញ្ជាក់ នូវកំហុស ជាសីលធម៌

រួមគ្នា របស់ខ្មែរយើងនៅចំពោះមុខប្រជាជតិខ្លួនឯង។ បើនិយាយអោយស្រួលយល់ គឺថា ខ្មែរយើង មិនបានបំពេញការណើយកិច្ចខ្លួន ជា ពលរដ្ឋ ដើម្បី ការពារសិទ្ធិ សេរីភាពរបស់ខ្លួន ដោយ ប្រើអាវុធ សាមគ្គីភាព ជា កម្លាំងជាតិ។

នៅក្នុងទស្សនៈ នៃ សហេតុផម៍ ខាងលើនេះ គេមិនបានលើក យកមក ពិចារណាអំពី លក្ខខណ្ឌ ជា ច្រើន ដែលបង្កើត ឲមាន អំណាចផ្តាច់ការ នៅស្រុកខ្មែរ ដូចយ៉ាងរចនាសម្ព័ន្ធ នៃសង្គមខ្មែរ ប្រពៃណីជាតិ ចិត្តគំនិត របស់ពួកជនាធិប (les politiques) និង កត្តា មកពី ក្រៅប្រទេស។ ដូច យើងដឹង ស្រាប់ហើយថា នៅ សម័យ ដែលស្រុកខ្មែររុងរឿង ហៅថា « មហានគរ » ជាសម័យ ដឹកនាំដោយ របបសមស្ត (régime totalitaire) គឺ ជា របប បង្ខំ ប្រជាពលរដ្ឋ ឲធ្វើតាម មនោគមវិជ្ជា របស់អ្នកដឹកនាំ។ ការណ៏នេះជាទំនាស់នឹង ទស្សនៈ នៃ ការដឹកនាំសម័យ គឺថា អំណាចផ្តាច់ការជា សត្រូវនឹង សេចក្តីរុងរឿង។ ភាព មាន ន័យមិនច្បាស់ (ambiguïté) នៅក្នុងស្មារតីខ្មែរយើង អំពីរបបផ្តាច់ការ គឺ ការទទួល ស្គាល់ សម័យ មហានគរ ជា គំរូល្អប្រពៃ នៃរបបដឹកនាំជាតិ។ គំនិតនេះ គឺវាជា អនុទស្សន៏ នៃរូបភាព

(représentation de l'image) ឬ ការបង្ហាញ នៃ រូបថត នៃ ប្រវត្តិសាស្ត្រ តែវាមិនមែនជា ការមើលឃើញ នូវការវិវត្តន៍នៃ ព្រឹត្តការណ៍ បន្តៗគ្នា មាន នៅពេលនោះ ដែលវាអាចនឹងមាន សភាព ច្របូកច្របល់ជាច្រើន មិនដូចរូបថត ជា រូបភាពនិច្ចល (image immobile) នោះឡើយ។ ជា ធម្មតា កម្លាំងខ្មែរ មាននៅពេលនោះ វាជាជាង ជា កម្លាំងកើតមកពីការបង្ខំ ពីសំណាក់ អ្នកដឹកនាំផ្តាច់ការ ដើម្បី បំរើ ប្រយោជន៍ឯកជន ជាង ប្រយោជន៍ទូទៅ។ ម៉្យាងទៀត នៅក្នុងលក្ខខណ្ឌ បែបនេះនៅពេលនោះ គេអាចសន្និដ្ឋានបានថា មហិទ្ធានុភាពខ្មែរ វា មាន លក្ខណៈ ជា មហិទ្ធានុភាព បង្ខំ និង វិត្ថារកម្មនិយម (une grande puissance coercitive et expansionniste) ដូច មហានគរ ដទៃទៀត នៅសម័យនោះ។ យើងលើក ចំណុចនេះ មកបង្ហាញ នៅក្នុងគោលបំណងចង់បញ្ជាក់ថា ជួនកាល អ្វីមួយដែលយើងយល់ឃើញថា វាជា សច្ចៈភាព ជា ដាច់ខាត តាមពិត វាគ្រាន់តែជា សច្ចៈភាព មិនទៀង (vérité relative) ឬ ជា សម្មតសច្ចៈ (vérité conventionnelle) បើ យើងលើកយក គ្រប់លក្ខខណ្ឌ នៃសច្ចៈភាព មកពិនិត្យវា ជាលំអិត។

ដូច្នេះ លក្ខខណ្ឌ នេះឯង វាមានសារៈសំខាន់ ព្រោះវាជាកត្តា បណ្ដាលអោយមាន ឬ បង្កើត នូវព្រឹត្តិការណ៍អ្វីមួយ។ ឧទាហរណ៍៖ នៅស្រុកខ្មែរមានរបបផ្ដាច់ការ មិនមែនមកពីហេតុថា ខ្មែរមិនរួបរួមគ្នានោះឡើយ ផ្ទុយទៅវិញ វាមានលក្ខខណ្ឌ ជាច្រើន ដែលនាំអោយខ្មែរយើង ពិបាករួបរួមគ្នា ព្រោះនៅស្រុកខ្មែរ វារមែងមានជានិច្ច នូវអំណាចផ្ដាច់ការ ដែលមានខ្លឹមគោលការណ៍របស់វាគឺ « បំបែក ដើម្បីងាយត្រួតត្រា »។

ភាពខុសគ្នា រវាង ហេតុ និង លក្ខខណ្ឌ នេះឯង ដែលតម្រូវអោយ អ្នកនយោបាយ ធ្វើរោគវិនិច្ឆ័យ (diagnostic) អោយដឹក ច្បាស់ អំពី រោគលក្ខណៈ ទើប នឹង អាច ដាក់មហោសថ (remède efficace) ត្រូវ នឹងរោគ។ ឧទាហរណ៍មួយទៀត ដែលយើងលើកយកវាមកពិនិត្យ នៅក្នុង បរិបទនយោបាយនៅស្រុកខ្មែរសព្វថ្ងៃ គឺវិស័យមតិ លោក សុន ឆ័យ មន្ត្រីជាន់ខ្ពស់ នៃគណបក្សសង្គ្រោះជាតិ គាត់ថ្លែងថ្មីៗនេះ បែបជាការបន្ទោនកាយ (humilité) ថា គណបក្សរបស់គាត់ សុខចិត្តទទួលរងគ្រប់អំពើអយុត្តិធម៌ ពីសំណាក់គណបក្សកាន់អំណាច ដើម្បី រកដំណោះស្រាយតាមសន្តិវិធី

ព្រោះមិនចង់អោយជាតិខ្មែរដើរតាម គន្លងប្រវត្តិសាស្ត្រ គឺ ជម្លោះជាហិង្សាឥតចប់ រវាងខ្មែរនឹងខ្មែរ ដូច្នេះដើម្បីបញ្ឈប់ នូវ វិនាដកម្ម នេះ ភាគីខ្មែរនិមួយៗ គួរ ចរចាជាមួយគ្នា។ គំនិតនេះ ជា ខ្សែនាយក នៃ ដំណោះស្រាយរបស់ គណបក្សសង្គ្រោះជាតិ ដែល អ្នកដឹកនាំបក្សអោយឈ្មោះថា វប្បធម៌ សន្ទនា ព្រោះ ជា សន្តិវិធី។ យើងដឹកថា និមិត្តរូប នៃសន្តិវិធីនោះ គឺ តំណាងដោយ អរហន្ត (saint homme) Mohandas Gandhi ទេសជន(homme d'Etat) Nelson Mandela សម្តេច Dalaï Lama និង មហាបុរស Martin Luther King ហៅថា ផ្លូវអហិង្សា។ តែផ្លូវនោះ វាមិនដូចគ្នានឹង ផ្លូវ របស់ គណបក្ស សង្គ្រោះជាតិ ក្នុងចំណុចសំខាន់មួយ គឺ សង្គ្រោះជាតិ ឈរលើ ស្មារតី « ទទួលរង » (esprit Subir) ព្រោះ ថា ទទួល រងគឺ ទទួល ស្គាល់ ធម្មានុរូប នៃ អំពើអកុសល (subir c'est d'accepter la légitimité du mal)។ រីឯ ផ្លូវ របស់ គារវរូប (idole) នៃ មនុស្សជាតិ ទាំងបួន ដែលយើង បានរាយនាម ខាងលើនេះវិញ គឺ នៅក្នុង ស្មារតី « តវ៉ា » (esprit Contester) ដែលជា ការតស៊ូសកម្ម ប្រឆាំងនឹង អំណាចសង្កត់

សង្គិន។ ភាពខុសគ្នានេះ ហាក់ដូចមួយជា ផ្លូវទាល់ មួយទៀតជា ផ្លូវចំហរ។

ការយល់ឃើញថា កង្វះសាមគ្គីភាព រវាងខ្មែរនឹងខ្មែរ ដែលនាំ ឲស្រុកខ្មែរ ត្រូវអន្តរាយ ដោយប្រទេសជិនខាង និងអំណាច ផ្តាច់ការ ជា ទស្សនៈ បរាជ័យនិយម (défaitisme) ព្រោះ យកគំនិតនិយម (idéalisme) ជាហេតុ នៃបញ្ហាប្រត្យក្ស (problèmes réels) របស់ ប្រជាជាតិខ្មែរ។ ត្រូវដឹងថា សង្គមជាតិខ្មែរ ពីបុរាណកាលមក ជា សង្គម មាន ប្រជាពលរដ្ឋ ជាសភាគ តែ ប្រព័ន្ធនយោបាយ នៃ ការរៀបចំសង្គម ជាប្រព័ន្ធ វណ្ណវិភាគ បែងចែក ប្រជាពលរដ្ឋ និង ផែនដី ជាចំណែក សម្បត្តិដាច់មុខ (apanage) មាន ម្ចាស់ ជា រាជវង្សានុវង្សរង់តូច (ព្រះអានុជ និង មាតា ព្រះមហាក្សត្រជាអាថ៌)។ ម្ចាស់ម្នាក់ៗ មានរាស្ត្រ មានរដ្ឋមន្ត្រី មានរាជការ និងមានរាជវាំង (maison royale) រៀងៗខ្លួន សោយសម្បត្តិ ដែលខ្លួនមាននោះតាមសេរី។ កាតព្វកិច្ច តែមួយគត់ ដែលខ្លួនត្រូវមាន ចំពោះព្រះមហាក្សត្រ គឺសេចក្តីស្មោះត្រង់ដាច់ខាតតែប៉ុណ្ណោះ។ ប្រព័ន្ធរដ្ឋបាលបែបនេះ វាមានគុណប្រយោជន៍របស់វា គឺជា ការរំលែង កិច្ចការរដ្ឋ ពី ព្រះមហាក្សត្រផង

និង កាន់កាប់ទឹកដីជាតិ បានសព្វអន្លើ ក្នុងព្រះរាជាណាចក្រផង។ តែក៏វាមានគុណវិបត្តិច្រើនណាស់នោះដែរ ព្រោះវាជាកត្តា នៃការបំបែក នៃឯកភាពជាតិ ព្រោះនៅក្នុងផែនដី ជា ចំណែក សម្បត្តិដាច់មុខ ដែល មាន ម្ចាស់នោះតែងតែគិតពីប្រយោជន៍ខ្លួន មុននឹងគិតពីប្រយោជន៍ជាតិ។ ត្រូវដឹកថា អាណាព្យាបាលបារាំង មិន ត្រឹមតែ បាន សង្គ្រោះជាតិខ្មែរពី មហិច្ឆិតា នៃការលួចទឹកដីខ្មែរ ពីសំណាក់ប្រទេស សៀម និងយួន នោះទេ គឺ ថែមទាំង រៀបចំស្រុកខ្មែរអោយមាន ឯកភាពជាតិមួយភាគថែមទៀត។ ការណ៏នេះ វាក៏អាចចាត់ទុកបាន ជា ទិដ្ឋភាពជាវិជ្ជមាន មិនដាច់ខាត របស់អាណានិគមបារាំងនោះដែរ ដោយប្រៀបធៀប នឹងស្ថានការណ៏ជាតិ ក្នុងហានភាគី (situation du pays en état de péril)។ ក្រោយ ពី ស្រុកខ្មែរ បាន ទទួលឯករាជ្យ ពីបារាំង ឯកភាពជាតិ វានៅស្រួយណាស់ នៅចំពោះមុខ ការគំរាម របស់យួនកុម្មុយនិស្ត ព្រោះវាប្រើ គ្រប់ល្បិចទុច្ចរិតដើម្បី វាយបំបែក ឯកភាពជាតិខ្មែរ។ មួយវិញទៀតនយោបាយ ផ្ដេសផ្ដាស របស់សម្ដេចសីហនុ នៅទសវត្សរ៏ ៦០/៧០ ហុចឪកាសបន្ថែមឲយួនកុម្មុយនិស្ត វាយបំបែក

បាន នូវ ឯកភាពជាតិ នៅក្នុងពេលសង្គ្រាម រវាង ខ្មែរសាធារណរដ្ឋ នឹងយួនកុម្មុយនិស្ត (១៩៧០-១៩៧៥)។ រីឯ ជ័យជំនះ ដោយអះអាង (soi-disant la victoire) របស់ ពួកខ្មែរក្រហមវិញ មិនបានស្រោចស្រង់ជាតិខ្មែរ ដូចមានគ្រោងទុក ក្នុងផែនការបដិវត្តនោះឡើយ ផ្ទុយទៅវិញ វាថែមទាំង បំផ្លាញទាំងអស់ នូវជីវកម្លាំងជាតិខ្មែរ បើកឱកាសជាទីបញ្ចប់ ឲយួនកុម្មុយនិស្ត ចូលកាន់កាប់ ដោយយោធាស្រុកខ្មែរ បានងាយស្រួលបំផុត ហើយយួន បង្កើតរបបដឹកនាំ មានខ្លួនជាខ្មែរ តែខួរក្បាលជាយួន សំរាប់សម្លាប់ប្រជាជាតិខ្មែរតែម្តង។ ការវិលត្រឡប់ នៃសម្តេច សីហនុ និង រាជវាំង ជា លំអ (palais royal de parade) គឺ ជា គ្រោះនយោបាយ (calamité politique) សំរាប់ជាតិខ្មែរ ជាជាង ជា អបុញ្ញកិច្ច (exploit) នៃ ការសង្គ្រោះជាតិ។ រាជានិយម ដោយអះអាងថា ជា និមិត្តរូប នៃ ឯកភាពជាតិ ឯករាជ្យជាតិ និង ការពារបូរណភាពទឹកដីខ្មែរ ប្រែក្លាយទៅជារាជវាំង នៃ សហការ ជាមួយ របបចោរម័ទ (kleptocratie) ដែលមានយួន កុម្មុយនិស្ត ជា អ្នកដឹកនាំ។ សហការនេះ វា កំរាប (écraser) បន្ត នូវសាមគ្គីជាតិ មាន រាស្រ្ត ជាធិបតេយ្យ ដែលវា

មានខ្លឹនសារ ខុសពី សាមគ្គីភាព រូបសូន (union moulée) ទុករាស្ត្រ ជា ទាសករ សំរាប់តែលំអ របបដឹកនាំ ដូច្នេះ កង្វះសាមគ្គីភាពខ្មែរ វាមិនមែនជាហេតុ នៃទុក្ខរបស់ជាតិខ្មែរនោះឡើយ ព្រោះកង្វះនេះ ពួកអ្នកដឹកនាំ សម័យដើមនិងយួនកុម្មុយនិស្តសព្វថ្ងៃ ជាអ្នកបង្កើត លក្ខខណ្ឌគ្រប់បែបយ៉ាង ដើម្បីងាយត្រួតត្រា ប្រជាពលរដ្ឋខ្មែរ ; ចំពោះយួនកុម្មុយនិស្ត គឺ គេងាយស្រួល ប្លន់យកទឹកដីខ្មែរ។

ដូច្នេះ បើ ខ្មែរយើង ចេះតែនាំគ្នា យល់ឃើញ ថា ទុក្ខ របស់ជាតិខ្លួន គឺ ត្រឹមតែ មកពីហេតុ នៃ កង្វះសាមគ្គី រវាងខ្មែរដោយមិនបានយកវាមកពិចារណា អំពីលក្ខខណ្ឌរបស់វា ឲបានច្បាស់លាស់ គឺខ្មែរយើង នៅតែ មិនអាចរកឃើញ នូវដំណោះស្រាយ ត្រឹមត្រូវនៅចំពោះមុខ បញ្ហាជាតិខ្មែរនោះឡើយ។ ដំណោះស្រាយ ត្រឹមត្រូវនោះ គឺ មាន តែលទ្ធិប្រជាធិបតេយ្យ ព្រោះ វា នឹងបង្កើត លក្ខខណ្ឌថ្មី សំរាប់ អោយខ្មែរយើង ក្លាយ ជា ប្រជាពលរដ្ឋ ជា អ្នកទទួលខុសត្រូវ លើជោគវាសនារបស់ខ្លួន។ ទទួលស្គាល់ នូវជម្មានរូប របបនៅស្រុកខ្មែរសព្វថ្ងៃ គឺទទួលស្គាល់ថា នៅស្រុកខ្មែរ មានលទ្ធិប្រជាធិបតេយ្យ ដូច្នេះខ្មែរយើងត្រូវតែគោរពជាដាច់ខាត

នូវគ្រប់ច្បាប់ទាំងឡាយ ដែលរបបនោះ គេបង្កើតឡើង សំរាប់តែ សង្កត់សង្កិត សិទ្ធិ និង សេរីភាព របស់ពលរដ្ឋ។ នៅស្រុកខ្មែរសព្វថ្ងៃ គ្មាន នីតិរដ្ឋ នោះទេ មាន តែ រដ្ឋក្រដាស ដែល លោក សុខ ឥសាន និង ផៃ ស៊ីផាន ជាអ្នកនាំពាក្យ ដែលខ្មែរបំពាក់ រហស្សនាម ឆ្កែព្រុស យកច្បាប់សរសេរ នៅលើក្រដាស មកអានដោយមោហាគតិ[49]។ នៅក្នុងបរិបទនយោបាយខ្មែរសព្វថ្ងៃ ខ្មែរយើង ត្រូវប្រើ សិទ្ធិ សេរីភាព ខ្លួន ដែលមានចែង នៅក្នុងរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ដើម្បីនាំមកវិញ នូវ លទ្ធិប្រជាធិបតេយ្យ ដែល ជា ខ្លឹមសារ នៃ កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ១៩៩១ ដូច្នេះត្រូវនាំគ្នាធ្វើមហាបាតុកម្មស្របច្បាប់ ដើម្បី បង្កើតលក្ខខណ្ឌ នៃ ជ័យជំនះ យុត្តិធម៌ លើ អយុត្តិធម៌ នៅពេលនោះច្បាស់ជាខ្មែរយើងរកឃើញ សាមគ្គីភាព មាននៅក្នុងនីតិរដ្ឋ។ នៅក្នុងលោកនេះ សព្វដង របបផ្តាច់ការ វាតែងតែ រលំជានិច្ច ហេតុតែ ទម្ងន់ នៃអំពើអកុសលរបស់ខ្លួន វាធ្ងន់ហួស

---

49 ដោយមោហាគតិ=សេចក្តីលម្អៀងបំពាក់បំពានព្រោះការមិនយល់ដឹង។

កំរិត ដែលខ្លួន អាចទ្របាន ដូចនៅក្នុងបុរាណភាសិតចារថា៖

« **ឈាមស្រែក ស្បែកហៅ** »

# ស្មារតីសក្តិភូមិ

*សេរីការ*



ឆ្នាំ ២០១៦

ថ្មីៗនេះ លោក គង់ គាំ អតីត ប្រធាន គណបក្ស សមរង្ស៊ី សួរ ជា សំណួរថា គាត់ ជួយគណបក្សសង្គ្រោះជាតិ ក្នុងនាម ជាអ្វី ? កូនប្រុសរបស់គាត់ ដែលជាអ្នកដំណាងរាស្ត្រ ឆ្លើយ តប ជាសំណើរមិនចំពោះថា គួរ លោក សម រង្ស៊ី តែងតាំង ឪពុកលោក ជាអ្នកតំណាងកិត្តិយស នៃគណបក្សសង្គ្រោះ ជាតិ ដើម្បី ឲគាត់ មានងារជាផ្លូវការ ក្នុងការបំពេញ បេសកកម្ម គ្រប់សារពើ ដើម្បីគណបក្ស។ សំនួរ និងការស្នើ នេះ ជា ស្មារតីសក្តិភូមិ (esprit féodal) ហើយក៏ជា ការបង្ហាញ ដែរ នៃ មានសិកភាព (mentalité) របស់ថ្នាក់ដឹកនាំកំពូល នៃ បក្សសង្គ្រោះជាតិ ចង់ តែ ពាក់ងារ ជា កិត្តិយសនោះដែរ។ លោក គង់ គាំ គួរគាត់គិតទៅវិញថា បើគាត់ចង់សង្គ្រោះ ជាតិ មានចិត្ត ជា អ្នកស្នេហាជាតិ ឬ ជា អ្នកបំរើប្រជា ពលរដ្ឋ វាជា កិត្តិយស ដ៏ឧត្តុងឧត្តមណាស់ទៅហើយ មិន ចាំបាច់គាត់ ស្វែងរកងារ ជាផ្លូវការអ្វីផ្សេងទៀតនោះឡើយ។ បំរើជាតិ ក្នុងនាមជា កម្មិកសមាជិក (bénévolat) វាមាន ប្រយោជន៍ និងកិត្តិយស សំរាប់ លោក គង់ គាំ ជាង ក្នុង នាមលោក ជា អ្នកតំណាងកិត្តិយស ក្នុង ស្មារតីសក្តិភូមិ។

តែលោក គង់ តាំគាត់មិនអាចយល់បាន នូវខ្លឹមសារ នៃភាពថ្លៃថ្នូរ ជា អ្នកស្នេហាជាតិ បាននោះឡើយ ព្រោះ ទាំងស្មារតី និងសព៌ាង្គកាយ របស់គាត់ វារស់ជាសុខដុម នៅក្នុងប្រព័ន្ធ របបចោរម៉ែទ (kleptocratie) ពីយូរយារ មកហើយ ហើយសុភមង្គលអាត្មានេះ ដែល នាំ អោយគាត់ មិនដែលបានទឹកឃើញផ្ញើអភិវឌ្ឍន៍ នូវស្មារតីជាតិរបស់គាត់ម្តងណាឡើយ ទោះបីបុត្ររបស់គាត់ ធ្លាប់បានទទួលរងគ្រោះនូវ អំពើព្រៃផ្សៃ ពី សំណាក់ របបផ្តាច់ការ យ៉ាងណាក្តី។ ប្រតិកម្ម នៃ ការលាលែង ពី ដំណែង ប្រធាន គណបក្សសមរង្ស៊ី និងបញ្ឈប់សកម្មភាពនយោបាយរបស់គាត់នៅពេលនោះ វា គ្រាន់តែ ជា ការភ័យខ្លាច នៃ ការសងសឹកបន្ថែមទៀតរបស់ លោក ហ៊ុន សែន មកលើរូបគាត់តែប៉ុណ្ណោះ។

ស្មារតីសក្តិភូមិនេះ វាជា ក្អែលដុះស្និម នៃក្រុមអ្នកដឹកនាំ និងអ្នកនយោបាយខ្មែរសព្វថ្ងៃនេះ នាំគ្នាបង្កើត នូវប៉ាឆាសំរាប់ អោយឃ្មួន ដុតខ្មោច ប្រជាជាតិខ្មែរ ព្រោះ អ្នកទាំងនោះ មាន រោគឆ្កួត ប្រាំយ៉ាង គឺ ស្រី ស្រា ល្បែង យសស័ក្ក និងលុយ ដែល ជា វិឃ្នភាព (ឧបសគ្គ) សំរាប់ ការពារ

ជាតិ និងរក្សាសេចក្តីថ្លៃថ្នូរ ជា នរជន។ ពួកមនុស្សបែប នេះមិនអាចមាន ឧមា (paix) ក្នុងចិត្ត បាននោះឡើយ ព្រោះ សេចក្តីលោភ វាជា ផ្លូវជីវិត របស់ គាត់ នៅក្នុង មជ្ឈដ្ឋាន គ្មាន ខ្លឹមសារអប់រំ (base de l’éducation) នៃសីលធម៌ នៃមនុស្សជាតិ។

# វិរបុរសជាតិ

សេរីការ



ឆ្នាំ ២០១៦

ខ្ញុំធ្លាប់បាន សរសេរ អត្ថបទមួយ ជា ភាសារបារាំង ដាក់ចំណងជើង ថា « នគរមួយ គ្មាន វិរបុរសជាតិ » នៅក្នុងគំនិត (esprit) របស់ខ្ញុំ គឺខ្ញុំ ចង់បង្ហាញ អត្តនោម័តិ[50] ដល់មហាជនខ្មែររថា នៅក្នុងសង្គមខ្មែរ នៅ មិនទាន់ មានឯកភាព នៅឡើយ ទៅ លើសកម្មភាព របស់បុគ្គលណាម្នាក់ ដែល អាចឲមតិសាធារណៈជន បំពាក់ងារ ដល់ជននោះ ជាវិបុរសជាតិ ព្រោះស្រុកខ្មែរយើង តាំងពីអតីតកាលរហូត មកដល់ បច្ចុប្បន្នកាល នៅរស់ ជា និច្ច ក្នុងឥទ្ធពលអំណាចនយោបាយ ឥតមានកំរិត ដែល វា នាំ ឲមានភាពច្របូកច្របល់ សំរាប់ធ្វើការវិនិច្ឆ័យ រកការពិតលើអំពើល្អអំពើអាក្រក់ សំរាប់ជាតិ ដែល សុទ្ធជា អំពើមានការជាប់ទាក់ទិនជានិច្ចក្នុងអំណាចនយោបាយ ដែលវាអាចកែខៃបាន សជាខ្មៅ ឬ ខ្មៅជាស។ អំណាច អាចប្តូរបាននេះឯងដែលនាំឲខ្មែរយើង មានការសង្ស័យច្រើន ទៅលើអ្វីដែល

---

50 អត្តនោម័តិ=opinion personnelle។

មានចារទុកក្នុងប្រវត្តិសាស្ត្រ ជាពិសេស ប្រវត្តិនយោបាយ ដែល វា អាច មាន លក្ខណៈ ជា សេចក្តីសរសើរ ហួសហេតុ (panégyrique) ចំពោះអ្នកដឹកនាំ ដែលអ្នកនិពន្ធណាម្នាក់ គេលើកយកមកសរសេរ តាមការបញ្ជា ពីសំណាក់អ្នកមានអំណាច ដែលខ្លួនជាអ្នកបំរើ ឬ គ្រាន់ជាការបញ្ចេញអត្តនោម័តិ ព្រោះខ្លួនមានការស្ញប់ស្ញែង ទៅលើស្នាដៃ ឬ គុណសម្បត្តិរបស់អ្នកដឹកនាំណាម្នាក់តែប៉ុណ្ណោះ តួយ៉ាង អ្នកសីហនុនិយម គេទុក សព សីហនុ ជាវិរបុរសជាតិ។ សួរថា ចុះហេតុអ្វីក៏ពួកខ្មែរក្រហម មិនអាចទុក ប៉ុល ពត ជាវិរសបុរសជាតិបាន ? ព្រោះសីហនុ និង ប៉ុល ពត ជាមិត្តរួមអាវុធផង និងជាមិត្តរួមរស់ ក្នុងវង្សកុម្មុយនិស្តផង ហើយមាន វិរបុរសរួមតែមួយទៅទៀត គឺ ម៉ៅសេទុង។ ការពិបាក មានក្នុងប្រវត្តិសាស្ត្រនយោបាយខ្មែរ គឺការគូសព្រំដែនរវាងប្រវត្តិវិទ្យា នឹងអ្វីៗ ដែលបុគ្គលណាម្នាក់ បានឃើញដោយភ្នែក ហើយយកមកសរសេរ ជាការចងចាំទុកសំរាប់មហាជន ឬការសរសេរ សំរាប់ឃោសនានយោបាយ ជាផ្លូវការក្តី ឬលាក់មុខក្តី។ ក្នុងចំណុចនេះ យើងសួរថា តើអភិញ្ញាណ (connaissance) ណាមួយ ដែលខ្មែរយើង អាចទុកជា

ប្រវត្តិវិទ្យា ឬ ជា និក្ខេបបទ ជា ផ្លូវការ របស់ជាតិខ្មែរ ? ចំពោះអ្នកប្រវត្តិសាស្ត្របរទេសល្បីល្បាញ ដែលគេ ទុកជាអ្នកជំនាញ នៃ ប្រវត្តិសាស្ត្រខ្មែរ ជាពិសេស បារាំងសែស បានចែកច្បាស់ថា អ្វីដែលទុកស្នាម តាមការសរសេរក្តី តាមសក្ខីកម្ម ជាសំដីក្តី ជាការចងចាំក្តី មានមុន និង ក្រោយសម័យអង្គរ ច្រើនមានលាយឡំ ដោយរឿងព្រេង ជាងប្រវត្តិវិទ្យា ព្រោះនិវេទន៍[51] ទាំងនោះ គ្មានពស្តុតាង ជាសម្ភារៈ សំរាប់ យកមកពិនិត្យបញ្ជាក់នូវការពិត។ តែ លោក អេង សុត អ្នកស្រាយជ្រាវប្រវត្តិសាស្ត្រខ្មែរ ដ៏ល្បី ម្នាក់[52] មានយោបល់ថា ឯកសារ សរសេរ ដោយបុព្វបុរស ខ្មែរអំពីប្រវត្តិសាស្ត្រ ក្រោយសម័យអង្គរ មានជាប់ពិតរឿង ព្រេងរបស់ព្រះបាទត្រសក់ផ្អែម ប៉ុន្តែបើនឹងកាត់ចោល វា នាំឲ្យអ្នកអានមើលមិនយល់ ប៉ុន្តែ រឿងបន្តមកទៀត មាន ក្នុង ឯកសារ បូរាណខ្មែរនោះ ចាប់ផ្តើមមាន លក្ខណៈ ជា

---

51 និវេទន៍ការឲដឹង។=

52 ឯកសារស្រាវជ្រាវដោយលោកអេងសុតជា"ព្រះរាជពង្សាវតាខ្មែរ"ឬ"មហាបុរសខ្មែរ" ឯកសាដកស្រង់ពីសាស្ត្រាវិត,តែលោកយកមកសរសេរជាអក្ខរាវិរុទ្ធសម័យដើម្បីឲបច្ចាជនខ្មែរសព្វថ្ងៃអាចអានបានងាយស្រួល។

ប្រវត្តិវិទ្យាពិត។ លក្ខណៈនេះ ត្រូវបាន ប្រវត្តវិទូបារាំងសែស ខ្លះ គេបានយល់ស្របតាមដែរ។ យើងឃើញថា លោក អេង សុត លោក មាន ការប្រុងប្រយ័ត្នណាស់ ក្នុងការប្រើពាក្យ ដូច យ៉ាង យកពាក្យ « មហាបុរស » តែមិនប្រើពាក្យ « វិរបុរស » ព្រោះ ថា ពាក្យវិរបុរស ជាពិសេសក្នុងសភាពការណ៏នយោបាយនៅក្នុងស្រុកខ្មែរ តាំងពីប្រទេស ទទួលបានឯករាជ្យមក នាំ បង្កើត ជា សង្គ្រាម មតិ ឬ ប៉ាកកា (polémique) ក្នុងមជ្ឍដ្ឋានអ្នកចេះដឹងខ្មែរគ្រប់ថ្នាក់។ ពាក្យមហាបុរស គឺគ្រាន់តែទុកបុគ្គលម្នាក់ ដែលបានធ្វើកិច្ចការដ៏សំខាន់អ្វីមួយ សំរាប់ជាតិ ដូច្នេះពាក្យនេះ អាចជាពាក្យ អព្យាក្រឹត។ ក្នុងគតិ អ្នកចេះដឹងខ្មែរខ្លះ ពាក្យនេះ បើក ចំហរ ឲ អ្នកអាន មាន លទ្ធភាពធ្វើការវិនិច្ឆ័យ ដោយ ខ្លួនឯង ទៅលើស្នាដៃ ដ៏វិសេសវិសាល របស់ បុគ្គលនោះ។ ការបារម្ភធំមួយទៀត របស់លោក អេង សុត គឺ លោក មិនចង់ ឲអ្នកផងឯទៀត ចោទលោកថា លោក ជាជនលោភា (homme ambitieux) ហ៊ានវិនិច្ឆ័យ ចាត់តាំងបុព្វបុរស ខ្មែរណាម្នាក់ ជាវិរបុរស ព្រោះ លោក យល់ឃើញ ថា បុគ្គលម្នាក់ មិនអាចមានសិទ្ធិអះអាងថា ជននេះ ជន

នោះ ជា វិរបុរស បាននោះឡើយ ព្រោះ គុណភាព នៃវិរបុរសនេះ វា ត្រូវមាន ការដឹងឮ ទទួលស្គាល់ជាសាធារណៈ ឬជាការកំណត់ ពីស្ថាប័នជាតិ ដែលមាន នីតិសម្បទា (habilité) អាចសំរេចបាន។ យើងលើកបញ្ហានេះមកនិយាយ ពុំមែនមានបំណង ឃាត់ឃាំង អ្នកផងឯទៀត មិនឲមានសិទ្ធិ បំពាក់ងារឲវរជនណាម្នាក់ជាវិរបុរសនោះឡើយ ព្រោះសិទ្ធិនេះជា សេរីភាព របស់ មនុស្សម្នាក់ៗ ប៉ុន្តែការប្រើសេរីភាពនេះ ពុំគួរយកមកធ្វើ ជា ការពោលអាង ថាអ្វី ដែលខ្លួន ទុកជាសរណៈ ឬ ជា អត្តចំនឿ គឺជា សេចក្ដីពិតដាច់ខាតនោះឡើយ ព្រោះដូចយើងបានពិពណ៌នាខាងលើរួចមកហើយថា ងារ វិរបុរសនេះ វាមានភាពប្រែប្រួលជានិច្ចនៅក្នុងប្រទេសណា ដែល មិនទាន់មាន ស្ថិរភាពនយោបាយ។ ឧទាហរណ៏ដូចជាអ្នកស្នេហាជាតិ ពោរកំបោរ អាចារ្យស្វា ក្រឡាហោមគង់ ឧកញ៉ាឈូក ស៊ឹងង៉ុកថាញ់ ប៉ាចឈឺន ស៊ឹមវា អៀវកើស ។ល។ សុទ្ធជាវិរជន ហ៊ានដើបប្រឆាំងនឹង អាណានិគមបារាំង ដែលខ្មែរ អ្នកស្នេហាជាតិយើងភាគច្រើន ក្នុងសហកាល ទុកអស់លោក ជាវិរបុរស តែផ្ទុយទៅវិញ ពួកអ្នកគាំទ្ររបបរាជានិយម កុម្មុយនិស្ត ពួក

គេ មិនបានទុកអ្នកស្នេហាជាតិទាំងនោះជា វិរបុរសជាតិនោះឡើយ នេះហើយ ជាការបញ្ជាក់ អំពីព័ន្ធភាព (relativité) នៃងារ វិរបុរស ដែលវាអាច ចោទជាបញ្ហា នូវអត្ថភាព នៃវិរបុរសជាតិខ្មែរ ព្រោះវាគ្មាន ការព្រមព្រៀង រវាងគ្នា ជាមាត្រដ្ឋានជាតិ (consensus à l'échelle nationale) ផ្ទុយទៅវិញ វាអាចមាន វិរបុរស របស់ពួកនិយមអ្វីមួយ (isme) ដែលជាវិរបុរសក្រុមបក្ស តែប៉ុណ្ណោះ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំចង់ណាស់ឲមាន វិរបុរសជាតិ តែជាអកុសលរបស់ស្រុកខ្មែរយើង ដែលជានគររស់នៅជានិច្ច ក្រោមរបបផ្តាច់ការ ហើយសព្វថ្ងៃនេះ ស្ថិតនៅ ក្រោម អាណានិគមយួន ពួកទាំងនោះគេ ប្រើមធ្យោបាយ គ្រប់បែបយ៉ាង កុំអោយខ្មែរយើង មាន មូលដ្ឋាន ប្រយោជន៏រួមតែមួយ សំរាប់ ធ្វើបុនភាវកម្ម (régénérer) នូវកម្លាំងជាតិ ឲមាន មហិទ្ធានុភាព ជានិច្ចភាព ក្នុងការការពារជាតិ។

## សេចក្តីសន្និដ្ឋាន

ខ្ញុំលើកយក សំដី របស់ អ្នកនិពន្ធបារាំងសែសម្នាក់ ឈ្មោះ Paul Dreyfus ជូនជាមតិសំរាប់ខ្មែរយើងយកទៅពិចារណា

ដែលមាន សេចក្តីដូចខាងក្រោមនេះ៖ « *នៅក្នុងប្រវត្តិសាស្ត្រខ្មែរដ៏វែងអន្លាយ គេអាចផ្ទើសង្ខេបបានលើ សភាពការណ៍ពីរ ដែលមានទស្សនៈផ្ទុយគ្នា៖ នៅពេលណាជាតិខ្មែរខ្លាំង ខ្មែរ តែងតែចិញ្ចឹម ទឹកចិត្តមើលងាយ ជាតិ សៀម និង យួន ជានិច្ច តែនៅពេលជាតិខ្មែរខ្សោយ គឺច្បាស់ជាត្រូវជាតិ សៀម និង យួន ដែល ជា អ្នកជិតខាងមិនល្អ ឆ្លៀតលួចទឹកដីខ្មែរ ហើយពេលខ្លះ គឺប្លន់យកតែម្តង*[53] » សំណេរនេះ វាចោទ ជា សំណួរថា តើខ្មែរយើងយកលក្ខណវិនិច្ឆ័យ នៃ វិរបុរស របស់ខ្មែរយើង នៅត្រឹមតែ បុគ្គលណាជា អ្នកមានជ័យជំនះលើ សៀម និង យួនតែប៉ុណ្ណោះឬ ? ចុះបើនៅពេលដែល ប្រទេសទាំងពីរនេះ គេមានជ័យជំនះលើខ្មែរវិញ តើខ្មែរយើងជាអ្វី ? ដូចយ៉ាងបច្ចុប្បន្ននេះ អ្នកឈ្នះខ្មែរ គឺយៀកណាម ដែលចូលមកក្នុងស្រុកខ្មែរបង្កើតនិងការពាររបបផ្តាច់ការ ដើម្បី បំផ្លាញជាតិខ្មែរ ដូច្នេះ តើ

---

[53] Paul Dreyfus – Pol Pot, le bourreau du Cambodge Edition Stock 2000) : Toute la longue histoire des Khmers peut se résumer à deux situations antithétiques : ou bien le Cambodge est puissant et il nourrit une hostilité méprisante envers l'Annam et le Siam ; ou bien le Cambodge est faible et alors il est grignoté, parfois même presque dévoré par ses deux mauvais voisins។

មានខ្មែរណា ជា វិរបុរស របស់ខ្មែរយើង នៅ ក្នុង បរាជ័យ នេះ ?

នៅក្នុសភាពការណ៏ ជាគ្រោះថ្នាក់ដល់អាយុជីវិតជាតិនេះ ខ្មែរយើងត្រូវមាន វិរបុរស មិនមែនជាបុគ្គលអស្ចារ្យ តែជាគំនិត តស៊ូរួមគ្នា (l’esprit de la résistance collective) ជាស្មារតីរៀសរៃ មានជំនឿក្នុងខ្លួនឯង ថាជា កាតព្វកិច្ចរួមគ្នា ជា កម្លាំងជាតិ ដើម្បីប្រយុទ្ធ រំដោះជាតិ ជាបន្ទាន់ពី អាណានិគមយួន។ វិរបុរស- គំនិត (esprit-héros) វាអាចមាន លាន់ទឹកលាន់ដីពេញនគរ ដែល គ្មាន កម្លាំងអាវុធណា អាចឃុំឃាំងវាបាន ព្រោះ វាមាន នៅក្នុងទឹកចិត្តខ្មែរគ្រប់គ្នា នៅគ្រប់ទីកន្លែងដែលខ្មែរជាជនរងគ្រោះ។ តែកម្លាំងទឹកចិត្ត ហៅថា វិរបុរស-គំនិត នេះ វាអាចចោទជាសំណួរថាតើនរណាជាអ្នកដឹកនាំ ? បើខ្មែរយើងជ្រាបនៅក្នុងចិត្ត នូវគំនិតតស៊ូ និង វិរបុរស-គំនិត ប្រាកដជា ខ្មែរយើងរកឃើញក្រុមអ្នកដឹកនាំ ជាពុំខាន ព្រោះ ក្រុមនោះ វានឹងកើតចេញដោយខ្លួនឯង នៅក្នុងគំនិតរួមគ្នានោះឯង។ ក្រុមអ្នកដឹកនាំនោះ ច្បាស់ជាគាត់មាន មូលដ្ឋាន គំនិតសំខាន់ៗ គឺ ការគោរព សិទ្ធិមនុស្ស និង រានផ្លូវ (ouvrir une route)

អហិង្សា ជាមាគ៌ា សំរាប់តស៊ូ ព្រោះ ការយកអំពើហិង្សា ទៅប្រឆាំងនឹងអំពើហិង្សា វានាំធ្វើឲអំពើនេះ វានៅឋិតថេរជានិច្ច។ ទោះ ការប្រព្រិត្តិ អំពើហិង្សា ត្រឹមត្រូវក្តី បើអ្នកប្រព្រឹត្តិ គ្មានមានសេចក្តីសង្ឃឹម លើ គោលការណ៍ នៃ អហិង្សា ក្នុងគំនិតខ្លួន គឺវាគ្មាន ប្រសិទ្ធិភាពអ្វីនោះឡើយ សំរាប់សង្គម ដូចយ៉ាង ប៉ុល ពត ធ្វើបដិវត្តហិង្សាដើម្បី រំលំសង្គមចាស់នោះឯង។ តែជួនកាល អំពើហិង្សានោះ វាក៏ជាមធ្យោបាយតែមួយគត់ដែរ សំរាប់បំបាត់ នូវអំពើហិង្សាដូចយ៉ាងសង្គ្រាមប្រឆាំងនឹងរបបណាស៊ី របស់ Adolf Hilter តែ សង្គ្រាមនោះ គឺ ធ្វើឡើងនៅក្នុងសេចក្តីសង្ឃឹមអហិង្សា គឺរំដោះ ប្រជាពលរដ្ឋ នៅអ៊ឺរូប ពី របប ប្រល័យពូជសាសន៍ ដើម្បី សន្តិភាព និង សេរីភាព។ រួមសេចក្តីមកគឺថា ទស្សនះ នៃ សេចក្តីសង្ឃឹមអហិង្សា គឺ ជា ផ្លូវអនាគតសំរាប់មនុស្សជាតិ។ ដើម្បីទៅដល់ សេចក្តីសង្ឃឹមនោះ គឺគ្រប់មធ្យោបាយ ដែលយកវាមកប្រើ ត្រូវមាន មូលដ្ឋានច្បាប់ជាគ្រឹះ។ នៅក្នុង បរិបទខ្មែរ ច្បាប់ ជា អាវុធតស៊ូ គឺ កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ១៩៩១ និង រដ្ឋធម្មនុញ្ញបច្ចុប្បន្ន ដែល កើតចេញពី កិច្ចព្រមព្រៀងសន្តិភាព

នោះឯង។ ដូច្នេះ ដើម្បីដឹកនាំការតស៊ូនោះ ខ្មែរយើង ត្រូវមាន វិរបុរស-គំនិត ជា បឋម ដែល ជា អវតា នៃសេចក្តីសង្ឃឹម នៃ ប្រជាជាតិខ្មែរ ព្រោះ ការតស៊ូរំដោះជាតិ ពីអាណានិគមយួន និង រំលំរបបផ្តាច់ការ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ដូច្នេះ ប្រជាពលរដ្ឋខ្មែរ ត្រូវដើរតួដោយខ្លួន ជា វិរបុរសជាតិ ព្រោះ វិរបុរស-បុគ្គល (homme-héros) នាំឲមាន ការពិភាក្សា ឥតផលសំរាប់ការតស៊ូ។ នៅពេលណាស្រុកខ្មែរ មាន ឯករាជ្យពេញលេញ អនុវត្តលទ្ធិប្រជាធិបតេយ្យ ជា យថាភូត នៅពេលនោះខ្មែរយើងច្បាស់ជារកឃើញ ដោយខ្លួនឯង នូវ វិរបុរស-បុគ្គល កើតចេញពី វិរបុរស-គំនិត ជាពុំខាន សំរាប់ប្រជាជាតិខ្មែរ។ បើមហាបុរស កែម ឡី ស្លាប់ដើម្បី ជាតិ គឺ នៅ មាន កែម ឡី រាប់លាននាក់ទៀត បន្តការតស៊ូជាតិ។

*សេរីការ*



ឆ្នាំ ២០១៦

# ចុះឈ្មោះបោះឆ្នោត និង ចូលរួមបោះឆ្នោត

ចុះឈ្មោះបោះឆ្នោត ជា ករណីយកិច្ច របស់ជនខ្មែរម្នាក់ៗ ដើម្បីបំពេញលក្ខណៈខ្លួន ជា ពលរដ្ឋ មានការទទួលខុសត្រូវ លើជោគវាសនាជាតិ ម្លោះហើយ ត្រូវនាំគ្នាទៅចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត។ អត្ថៈពិសេស (signification particulière) មួយទៀតដែរ គឺ ការសំដែងទឹកចិត្ត នៃសេចក្ដីស្រឡាញ់លទ្ធិប្រជាធិបតេយ្យ ព្រោះការបោះឆ្នោត ជា អត្ថរស់មួយនៃលទ្ធិនេះ។ ទៅចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ជា ដំណាក់ការចាំបាច់ណាស់ សំរាប់ទទួលសិទ្ធិ ជាពលរដ្ឋ ដែលជាម្ចាស់អំណាច ក្នុងការជ្រើសរើសតាមការបោះឆ្នោតរើសតំណាងប្រជាពលរដ្ឋ សំរាប់ដឹកនាំកិច្ចការជាតិ ក្នុងនាម ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ។ ពិតមែនហើយថា ការចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត វាមិនមែន ជា កាតព្វកិច្ច ជាគតិយុត្ត តែវា ជា កាតព្វកិច្ច ជា សីលធម៌ ព្រោះ បើសិនជនខ្មែរមានចិត្តព្រងើយនឹងករណីយកិច្ចនេះ វាអាច ជា គ្រោះថ្នាក់ ដល់ប្រជាជាតិ ដ្បិត វាអាចបើកដៃអោយពួកអ្នកភាគតិចសកម្ម (minorité agissante) ចាប់យកអំណាចដឹកនាំជាតិបាន ព្រោះពួកនេះគេសកម្មណាស់ ក្នុងជីវិតភាព

នយោបាយ ត្ចូយ៉ាង ជនជាតិយួន ដែលមករស់នៅស្រុកខ្មែរមានសញ្ជាតិ ជា ខ្មែរ ត្រូវច្បាប់ក្តី ខុសច្បាប់ក្តី គេនាំគ្នាសម្រុកទៅចុះឈ្មោះបោះឆ្នោតដើម្បី ការពារប្រយោជន៍និគមជនគេជា ពិសេស បើគេមាន ឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺគេក្លាយ ជា ពលរដ្ឋខ្មែរពេញលេញ ដូច្នេះ គេជាម្ចាស់អំណាច នៅក្នុងស្រុកខ្មែរស្របតាមច្បាប់រដ្ឋធម្មនុញ្ញ។ ខ្មែរយើងដឹងច្បាស់ថា ជនជាតិយួនមានសញ្ជាតិ ជាខ្មែរ ជា អតិថិជន នៃគណបក្សប្រជាជនកម្ពុជា ព្រោះជាអ្នកបោះឆ្នោត អោយតែគណបក្សនេះ មិនមែន ដើម្បីការពារប្រជាយោជន៍ជាតិខ្មែរនោះឡើយ ព្រោះប្រយោជន៍ខ្មែ រវាផ្ទុយគ្នាស្រឡះពី ប្រយោជន៍ នៃប្រជាជាតិយួន ដែលមានប្រវត្តិសាស្ត្រខ្មែរ និង ការពិត នៃស្ថានភាពនៅស្រុកខ្មែរសព្វថ្ងៃ ជាភស្តុតាង។ តែអ្នកដែលបោះឆ្នោតអោយគណបក្សប្រជាជនកម្ពុជា ក្នុងឋានៈ ជា ពលរដ្ឋខ្មែរស្របច្បាប់ វាជា សេរីភាពរបស់ គេដែលខ្មែរសព្វគ្នាត្រូវគោរពព្រោះជា សេរីភាពស្របច្បាប់។ ដូច្នេះបញ្ហា នៃការបោះឆ្នោត វាមិនឋិត នៅលើ សេរីភាព របស់ពលរដ្ឋខ្មែរម្នាក់ៗក្នុងការជ្រើសរើសគណបក្សណាមួយ ដែលខ្លួនជ្រើសយក ជា

តំណាង នៃគោល សន្ទវត្តគំនិត (idée intime) របស់ខ្លួននោះឡើយ បញ្ហា ដែលមាន វានៅលើ ការប្រគល់សញ្ជាតិខ្មែរឲជនបរទេស ដែលរស់នៅក្នុងស្រុកខ្មែរ ថាតើ ការប្រគល់នេះ វាស្របនឹងច្បាប់ នៃសញ្ជាតិខ្មែរដែរឬទេ ? បើវាស្របនឹងច្បាប់ គឺវាច្បាស់ជាគ្មានបញ្ហានោះឡើយ តែបើវាផ្ទុយនឹងច្បាប់វិញ អ្នកដែលប្រឆាំងនឹងសិទ្ធិ អោយជនបរទេសមានសញ្ជាតិខ្មែរខុសច្បាប់ ចុះឈ្មោះ ក្នុងបញ្ជីបោះឆ្នោត វាជាបដិយោគ ជាធម្មានុរូប (opposition légitime) ព្រោះ វាជាករណីកិច្ច របស់ពលរដ្ឋខ្មែរម្នាក់ៗ ដែល ជា ម្ចាស់អំណាចប្រើសិទ្ធិ ដើម្បីការពារប្រយោជន៍ជាតិ។ បើនៅប្រទេសមាននីតិរដ្ឋ ពលរដ្ឋម្នាក់ៗ ឬ រួមគ្នា ជា សមូហជន អាចប្តឹងផ្ទាល់ទៅអាជ្ញាធរពាក់ព័ន្ធ ឬ ជូនដំណឹងទៅរដ្ឋសភាតាមរយៈតំណាងរាស្ត្រ អោយពិនិត្យ ជាចាំបាច់ នូវករណីនេះ តែដោយសារនៅស្រុកខ្មែរ ជា ប្រទេសគ្មាននីតិរដ្ឋបញ្ហាគតិយុត្តនេះ វាក្លាយទៅជា វិបត្តិ នៃវិស្សសភាព (crise de confiance) ទៅលើអ្នកដឹកនាំ និងគ្រប់ស្ថាប័នជាតិ ជាពិសេស ទៅលើប្រព័ន្ធយុត្តិធម៌។ ការមាន វិបត្តិ នៃវិស្សសភាពនេះឯងហើយ ដែល នាំអោយ ខ្មែរយើងមួយភាគ

អស់មានជំនឿ ទៅលើការបោះឆ្នោតតែម្តង ព្រោះទុកវាគ្រាន់តែ ជា មធ្យោបាយខុសកន្លងធម៌ សំរាប់គណបក្សកាន់អំណាច នៅក្រោមអាជ្ញាធរអណានិគមយួន រក្សាអំណាចផ្តាច់ការរបស់ខ្លួនតែប៉ុណ្ណោះ។ បើយើងលើកយក ករណី គ.ជ.ប. សព្វថ្ងៃ ដែលជា អង្គការ ដែលគណបក្សប្រឆាំង គេទុកជាស្នាដៃអភិសម័យ (œuvre réussite) របស់គេ យើងឃើញថា វាគ្មានសុពលភាពត្រឹមត្រូវ សំរាប់ធ្វើកិច្ចការរបស់ខ្លួនផង ព្រោះសមាជិករបស់ខ្លួនម្នាក់ កំពុងនៅក្នុងពន្ធនាគារ ដែលនាំអោយ គោលវិធី នៃការសំរេចយកមតិភាគច្រើនជាបានការ បាត់នូវសមតា ដូច្នេះ ដំណើរការ នៃគ.ជ.ប. សព្វថ្ងៃ វាអាចចាត់ទុកវា ថាខុសច្បាប់ផងដែរ តែករណីនេះ គណបក្សប្រឆាំង គាត់ធ្វើមិនដឹងឮទេ។

គួរខ្មែរយើងចែកអោយដាច់ អំពី ករណីយកិច្ច របស់ខ្មែរម្នាក់ៗ ទៅចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ពី ការចូលរួមបោះឆ្នោត។ ទី១ត្រូវតែធ្វើជាការចាំបាច់ ព្រោះវាជាករណីយកិច្ចរបស់ពលរដ្ឋ តែចំពោះករណីទី២ ត្រូវនាំគ្នាគិតពិចារណាអោយបានច្បាស់លាស់ ព្រោះវាអាចនឹងមានកម្មវិបាក បើសិននាំគ្នា ចូលរួមបោះឆ្នោត ក្នុងការបោះឆ្នោតមួយ ឥត

សេរី និងឥតយុត្តិធម៌ ព្រោះគ្រប់បញ្ហា វានឹងមានកើតឡើងដូចគ្នានឹងការបោះឆ្នោត នៅឆ្នាំ ២០១៣ គឺថា គណបក្សកាន់អំណាច គេមិនគោរពឆន្ទៈ របស់ម្ចាស់ឆ្នោតជា ដាច់ខាតព្រោះថា គេមានម្ចាស់រួចហើយ គឺអ្នកដឹកនាំយួនកុម្មុនិស្ត ដែលជា ម្ចាស់អំណាច នៅស្រុកខ្មែរ។ពួកអ្នកដឹកនាំយួន គេយកការបោះឆ្នោត សំរាប់តែបំភាន់សហគមអន្តរជាតិថា អំណាចនៅស្រុកខ្មែរ ជា អំណាចធិបតេយ្យ ដូច្នេះមិនអាចបរទេសណា អាចជ្រៀតជ្រែកចូល នៅក្នុងកិច្ចការផ្ទៃក្នុង របស់កម្ពុជាបាននោះឡើយ។ រួមសេចក្តីមក គឺថា បើស្រុកខ្មែរស្ថិតនៅក្រោមឥទ្ធិពលយួនកុម្មុនិស្ត វាមិនអាចនឹងមាន ការបោះឆ្នោត ជាសេរី និងប្រកបដោយ យុត្តិធម៌ បាននោះឡើយ ម្លោះហើយ គ្រប់គណបក្ស នយោបាយ ដែល យកការ បោះឆ្នោត ជាមធ្យោបាយ សំរាប់ប្តូរអ្នកដឹកនាំគឺគ្រាន់តែ ជាមាយាការ (illusion) ហើយ យកសេចក្តីភាន់នេះទៅបញ្ឆោតប្រជាពលរដ្ឋថាវាជាសេចក្តីពិត។

អ្វីដែលយើងលើកយកមក បង្ហាញនៅទីនេះ វាមិនមែនជា ឱវាទ តែគ្រាន់តែ ជាការណ៍ សួរជា សំណួរមួយចំនួន

(questionnement) ដល់អ្នកនយោបាយ និងប្រជាពលរដ្ឋខ្មែរ ថា តើ នរណាជា អ្នករងគ្រោះ រហូតមក ដល់សព្វថ្ងៃនេះ ? បើនាំគ្នាឆ្លើយថា ប្រជាពលរដ្ឋខ្មែរ ជា អ្នករងគ្រោះ ដូច្នេះយើងអាចសួរ ជា សំណួរមួយទៀតថា ការបោះឆ្នោត នៅក្នុងរបបបច្ចុប្បន្ន ដែលខ្មែរភាគច្រើន ទុកជា តិរច្ឆាន តើវាពិត ជា ដំណោះស្រាយអាក្រក់តិចជាងគេនោះដែរឬទេសំរាប់ប្រជាជាតិខ្មែរ ? ចម្លើយ គឺវាមាននៅក្នុងសតិសម្បជញ្ញៈរបស់ខ្មែរម្នាក់ៗនៅពេលបោះឆ្នោត។ បើខ្មែរយើង មើលឃើញថា ការបោះឆ្នោត វាគ្រាន់តែជាការបញ្ឆោត របស់យួន កុម្មុយនិស្ត ពួកអ្នក ជាប់ឃ្នាង និងពួកអ្នកនយោបាយជាប់នៅក្នុងទ្រុងយួន ហើយនៅតែនាំគ្នាចូលរួមបោះឆ្នោត ដូច្នេះ កិច្ចហ្នេះ (cet acte) គឺជាការទទួលខុសត្រូវរបស់ខ្មែរទាំងពួង នៅចំពោះ កម្មវិបាកបន្ទួន កើតមានឡើងពីរាល់ការបោះឆ្នោត នៅក្នុងយុទ្ធសាស្ត្រ របស់អ្នកដឹកនាំយួន សំរាប់លេបយកទឹកដីខ្មែរ។ កុំនាំគ្នានឹកស្មានថា ករណីខ្មែរ វាដូចគ្នានឹងប្រទេសភូមា ព្រោះប្រទេសភូមា មិនស្ថិតនៅក្រោម អំណាចបរទេស ណាមួយឡើយ ដូច្នេះ គេអាចមាន ការផ្សះផ្សាជាតិ ដើម្បីប្រយោជន៍ របស់

ប្រជាជាតិគេ រីឯនៅស្រុកខ្មែរ  វិញអ្នកដឹកនាំយួន គេទុកការផ្សះផ្សាជាតិ រវៀងខ្មែរនឹងខ្មែរ ជា សត្រូវនឹងប្រយោជន៍គេ  តែម្តង។ ត្រូវដឹងថា អាក្យកិរិយានយោបាយ (posture politique) របស់ គណបក្ស សង្គ្រោះជាតិ « មិនយកខ្មែរណាជាសត្រូវ » ជា  ឧត្តមគំនិតមួយល្អណាស់ តែនៅក្នុងបរិបទខ្មែរ គំនិតនេះ វា គ្រាន់ តែ ជា គតិបណ្ឌិត ឬ ជាមធ្យោបាយវៀចវេរ ពីបញ្ហាពិត (biais du problème réel) ដែលនាំឲអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ និងគណបក្ស ដទៃទៀតមើលឃើញតែ ការបោះឆ្នោត ក្នុងលក្ខណៈយ៉ាងណាក្តីជា ដំណោះស្រាយតែមួយគត់ សំរាប់សង្គ្រោះប្រជាជាតិខ្មែរ។ អនាគតកាលនឹងថ្លែងទុក្ខម្តងទៀត ពីជំនឿស៊ប់លើ ការបោះឆ្នោតនេះ។ ដូច្នេះ ការចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតមិនមានន័យថាត្រូវតែចូលរួមបោះឆ្នោត  នៅក្នុងយុទ្ធសាស្រ្តយួនកុម្មុយនិស្តនោះឡើយ។

# ការស្នេហាជាតិ, ការជឿ, ការសង្ឃឹម

*សេរីការ*



ឆ្នាំ ២០១៦

ជាតិ និង មាតា មាន ខ្លឹមសារ តែ មួយ សំរាប់ កូនខ្មែរ កើត ជាខ្មែរ រស់ ជាខ្មែរ ដើម្បី ជាតិខេមរា។ តើ គំនិត នេះ ជា គំនិត ប្រាកដ ដែរឬទេ ?

នៅក្នុង គំនិត ស្នេហាជាតិ ដែល ជា មនោសញ្ចេតនា ខ្ពស់ ដល់កំរិត នៃ ជនជាតិ និមួយៗ ចំពោះ ប្រជាជាតិ របស់ខ្លួន។ គេ តែង ប្រៀបធៀបមាតា ទៅ នឹង ជាតិដើម្បី សម្តែង អោយឃើញ នូវ ទឹកចិត្តស្នេហាជាតិ។ សួរជា សំណួរថា តើសេចក្តីស្នេហាជាតិមានរូបភាពបែបណា ?

ជា ពលិកម្ម ក្នុងចិត្តឆន្ទៈ នៃ បុគ្គល ហ៊ានស្លាប់ ដើម្បីជាតិ ដែល គេទុក ជា វិរបុរស, ជា អ្នកការពារជាតិ តាម លទ្ធភាព ដែលខ្លួន មាន, ជា ពលរដ្ឋ ចេះដឹង និង អនុវត្តទៀងប្រយ័ត្នប្រយែងនូវ សិទ្ធិ និង ករណីយកិច្ច ជា ពលរដ្ឋតាមច្បាប់ជា ធរមាន។ បើយើងយក កត្តា ទាំងបីនេះមកពិចារណា យើងឃើញ ថា សេចក្តីស្នេហាជាតិ មាន សញ្ញាណបីយ៉ាង៖ ១. អ្វីដែល កើតពីចិត្ត, ២. អ្វីដែលត្រូវធ្វើ, ៣. អ្វីដែលត្រូវគោរព។ នៅក្នុង សញ្ញាណ ទាំងបីយ៉ាងនេះ វាមាន

គោល គំនិត ធំពីរ យ៉ាង៖ ១. ការជឿ, ២.ការសង្ឃឹម។ ការជឿ គឺ ជឿ លើ អ្វីមួយ ដែល នៅក្រៅចិត្ត គឺថា វត្ថុនៅក្រៅនោះ ជវនចិត្តទៅរកជំនឿ លើខ្លួន ; រីឯ ការសង្ឃឹម វិញ គឺមាន នៅក្នុង ចិត្ត ហើយ ចេញពី ចិត្ត ជឿ ទៅលើ អ្វីមួយដែល នៅ ពីក្រៅចិត្ត។ រួមសេចក្ដីមក យើងអាច និយាយជាសង្ខេបបានថា ការជឿ គឺមាន កម្លាំងក្រៅ ឆក់ទាញចិត្ត, ចំណែក ការសង្ឃឹម គឺ កម្លាំង ក្នុងចិត្ត ឆក់យក អ្វីមួយ ដែល ចិត្ត មាន សង្ឃឹម ចំពោះវា។ បើយើង យកសញ្ញាណ ទាំងនោះ មក ដាក់ នៅ ក្នុង សេចក្ដីស្នេហាជាតិវិញ តើ វា នឹងមាន សារជាតិ បែបណា?

ជាតិ ជា សញ្ញាណ អរូបិយ ទោះបី ខ្លួន មាន លក្ខណៈ អតិសេដ្ឋ សំរាប់ ប្រជាពលរដ្ឋ,អាស្រ័យហេតុនេះ គេ ត្រូវ អោយរូបភាពមួយ សំរាប់ សំគាល់ជាតិ ; រូបភាពនោះ គឺ ប្រជាជាតិ ដែល មាន ទឹកដី, ប្រជាពលរដ្ឋ, អ្នកដឹកនាំ, ភាសា, ប្រពៃណីយ និង ប្រវត្តិសាស្ត្រ។ ការបង្ហាញ រូបភាព បែបនេះ គឺ គេ ប្ដូរ លក្ខណៈ អរូបិយ អោយក្លាយជា លក្ខណៈសាមញ្ញ ស្រួល មើលឃើញ រូបភាព នៃ ជាតិ។ តែ រូបភាពបែបនេះ ក៏អាច ចោទជា សំនួរថា តើ សេចក្ដីស្នេហាជាតិ

គឺ ជា សេចក្តីស្នេហា វត្ថុធាតុ ទាំងអស់ផ្តុំ ជា ប្រជាជាតិ ឬ អាច មាន សេចក្តីស្នេហាជាតិ លើ ភាគខ្លះៗ បាន ?

បើយក សារព័ន ជា លក្ខន្តិកៈ ខានមិនបាន គឺ វាជា ទស្សនៈ តឹងតែងន័យ ព្រោះគេទុក ជាតិ ជា សាកលសរីរៈ មិនអាច បែងចែក ជា ភាគបាន, ដូច្នេះ បើ ខ្វះ វត្ថុធាតុ ណាមួយ គឺ ជាតិ គ្មាន ខ្លឹមសារជាតិ នោះឡើយ, ដោយហេតុនេះ សេចក្តីស្នេហាជាតិ គឺជា សេចក្តីស្នេហា ខ្លឹមសារជាតិ នោះឯង។ គេ អាច ទុក ទស្សនៈ នេះ ជា ទស្សនៈ បូរណនិយម (intégrisme) ដែល ពួកអ្នកដឹកនាំ របប សិទ្ធិអំណាច ឬ សមស្តនិយម យកវាមកប្រើ ជា គោលការណ៍ របស់ខ្លួន គឺថា ស្រឡាញ់ជាតិ មិនមែន គ្រាន់តែស្មោះនឹងខ្លួននោះឡើយ គឺ ត្រូវស្រឡាញ់ ដល់ ខ្លួន ជា ដាច់ខាត ដូចយ៉ាង បង្កើត ពាក្យ បិតាជាតិជា អាទិ។ តែ មាន ទស្សនៈ រីកសាយន័យ មួយដែរ គឺ ជាតិ ជា ប្រជាពលរដ្ឋ ធិបតេយ្យ ដែល ទុក ជា វត្ថុធាតុ សមុដ្ឋាន (primordial) ព្រោះ ជា ម្ចាស់ នៃ ច្បាប់ទាំងឡាយ នៃ ជាតិ ដែលមាន នីតិរដ្ឋ។ ទស្សនៈ នេះ ជា ទស្សនៈទំនើប ចេញអំពី ដំណើរ នៃ ការលូតលាស់ នៃ បញ្ញា នៃ មនុស្សជាតិ ដែល ជា ឧទ័យ

(émergence) នូវ អំណាចច្បាប់ លើ អំណាចផ្ដាច់ការ។ នៅក្នុងអត្ថរស នៃ ទស្សនៈ នេះ ដែលនាំបង្កើតបាន នូវ លទ្ធិប្រជាធិបតេយ្យ ដែលជា របបដឹកនាំជាតិ មានជោគជ័យលើ របបដឹកនាំទាំងអស់ មាននៅក្នុងលោកមកដល់ សព្វថ្ងៃនេះ។ ដោយហេតុនេះ អត្ថន័យ នៃ សេចក្ដីស្នេហាជាតិ គឺជា សេចក្ដីស្រឡាញ់ នៃ ប្រជាពលរដ្ឋ លើខ្លួនឯង ដែលមាន ច្បាប់ ជា អ្នកគ្រប់គ្រង។ សេចក្ដីស្នេហា បែបនេះ មិនទុក ជា អត្តស្នេហានិយម (narcissisme) នោះឡើយ ព្រោះ ជា សេចក្ដីស្រឡាញ់ រួមគ្នា នៅក្នុង ប្រយោជន៍រួម ដើម្បី កសាង នូវ អនាគត សាធារណ៍ (avenir commun) ដែល មាន ប្រជាជាតិ ជា មូលដ្ឋាន នៃ សុខតមកម្ម (harmonisation) របស់ ប្រជាពលរដ្ឋ។យើងអាច សន្និដ្ឋានបានថា សេចក្ដីស្នេហា តាម ទស្សនៈ តឹងតែងន័យ គឺ ជា សេចក្ដីស្នេហាជាតិ ជា វត្ថុវិស័យ (objectif) ឬការបង្ខំដើម្បីបំរើ ប្រយោជន៍ ដែល មាននរណាម្នាក់ ឬ ក្រុមណាមួយ គេ សម្លឹង ឃើញ នូវ គោលដៅ សំរាប់ ការពារ ឬ ទាញយកបានប្រយោជន៍ ពី សេចក្ដីស្នេហានេះ, បើតាម ទស្សនៈ វិកសាយន័យ ឬ ទំនើបវិញ ជា សេក្ដីស្នេហាជាតិ បរិសុទ្ធ មិន

ប្រាថ្នា ប្រយោជន៍ ក្នុង វត្ថុវិស័យ រកចំណេញពី សេក្តីស្នេហាជាតិ ព្រោះ ជា សេចក្តីស្នេហាជាតិ នៃ ប្រជាពលរដ្ឋ ដោយ ប្រជាពលរដ្ឋ និង ដើម្បី ប្រជាពលរដ្ឋ នៅក្នុង ការជឿដល់ ភាពឧត្តម នៃ មាតុភូមិ និង ការសង្ឃឹម ដល់ជាតិជា ជម្រក នៃ សន្តិវាទ សំរាប់ ការរស់នៅ នៃ ជីវភាពរាល់ថ្ងៃ។

**១. ការជឿ ដល់ ភាពឧត្តម នៃ មាតុភូមិ** : ជាទូទៅ រូបភាពនេះ គឺជា គុណសម្បត្តិ នៃ ប្រជាពលរដ្ឋដែលមាន នៅក្នុង កំណប់ នៃ បញ្ញាជាតិ និង ការរិកចំរើន នៃមនុស្សជាតិ។ ដូច្នេះ ការជឿនេះ ជា បឋម គឺ ការជឿលើ សមត្ថភាពខ្លួនឯង ជា ប្រជាពលរដ្ឋ មាន សហបញ្ញា មាំទាំ ដែល អាច បញ្ចេញអោយឃើញ នូវ សមត្ថភាព និង សមត្ថកិច្ច របស់ បុគ្គល ម្នាក់ៗ ដើម្បី ទទួលបន្ទុក នូវ ករណីយកិច្ច របស់ខ្លួន ជា ពលរដ្ឋ។ នៅក្នុង របប លទ្ធិប្រជាធិបតេយ្យ តំណាង វា មាន ការជ្រើសរើស អ្នកដឹកនាំ ដោយ ប្រជាពលរដ្ឋ មានការចេះដឹង ដូច្នេះ ជា ជម្រើស ធ្វើ សមោធនា (secréter) ចេញពី ប្រជាពលរដ្ឋ នូវ ពុជអ្នកដឹកនាំ សំរាប់ ដឹកនាំជាតិ មាន អាណត្តិ, ផ្ទុយទៅវិញ បើ ប្រជាពលរដ្ឋ គ្មាន ការចេះដឹង គឺ ច្បាស់ ជា មាន ទុរជន ឆ្លៀត យក

ប្រព័ន្ធ ជ្រើសរើស នេះដើម្បី ដណ្តើម អំណាច: ការជ្រើសរើស ដោយ សាកលជាកម្លាំង នៃ ចំនួន, តែបើចំនួននោះជា ចំនួន ល្ងង់ខ្លៅ និង ខ្វាក់ប្រាជ្ញា គឺ នាំអោយ ដំណើរនៃប្រទេស ដើរ ឆ្ពោះទៅរក មហន្តរាយ។ ដូច្នេះ ការជឿ ទៅលើ វត្ថុ, គំនិត, អង្គការ, គណបក្ស នយោបាយ,បុគ្គលណាមួយក្តី វា ជា កម្លាំង ស្រូបចិត្ត អ្នកដទៃអោយជឿលើខ្លួន។ គុណភាព នៃការជឿ វា ស្ថិតនៅត្រង់ ថា អ្នកជឿនិង អ្នកអោយគេជឿ វា មាន ធាតុតែមួយហើយមានគោលដៅ តែមួយ, ជា ឧទាហរណ៍៖ ធាតុតែមួយ គឺ ប្រជាជាតិរួម, គោលដៅតែមួយ គឺ ប្រយោជន៍ជាតិ។ អ្នកអោយគេជឿនិងអ្នកជឿ ជា សរីរៈ តែមួយ មាន ជីវិតតែមួយ គឺ ស្លាប់-រស់ប្រកោះគ្នា តាម ដង្ហើម នៃ ប្រជាជាតិ, ដូច្នេះ ការមានសម្ពាន ទៅវិញទៅមក រវាង អ្នកទាំងពីរ គឺជាគុណភាព នៃ ដំណើរធម្មតា នៃ ប្រជាជាតិ មានសុខដុមដែលតែងតែ ស្វែង រកជានិច្ច នូវ អ្វី ដែល ជា ដំណើរល្អ របស់ខ្លួន ដែលខ្លួនមាន។ ការស្វែងរក នេះឯង គឺជាមគ្គនកម្ម (ការរើសសម្រាំង) យក គោលវិធីណា ដែល ល្អជាងគេ ក្នុងចំណោម គោលវិធី ល្អៗ ទាំងឡាយ ដែល ខ្លួនយល់ដឹង ដូច

គ្មានទឹង លទ្ធិប្រជាធិបតេយ្យ ពហុបក្ស មានអ្នកបោះឆ្នោត ធ្វើការជ្រើសរើសគណបក្ស នយោបាយ ណាមួយដែលខ្លួន ទុកជា វរបក្ស សំរាប់ ដឹកនាំជាតិ មាន អាណត្តិ។

**២. ការសង្ឃឹម ដល់ ជាតិ** : ដូចបាន ជំរាបខាងលើ រួច ហើយ ថា ការសង្ឃឹម ជា កម្លាំងដែលមាននៅក្នុងបញ្ញា ដូច្នេះ កម្លាំងនេះ មិនមែនជាកម្លាំងអកម្ម គឺមានន័យ ថា មិនត្រឹមតែមាននៅក្នុងចិត្តនោះឡើយ គឺ ត្រូវតែ អនុវត្ត វា តាម បញ្ញា គឺមានន័យថា ជា កម្លាំងសកម្មដែល ធ្វើ អោយ កម្លាំងនេះ ចេញពីចិត្ត ក្លាយ ជា កម្លាំងអំណាច បញ្ញា របស់ប្រជាពលរដ្ឋ ដើម្បី ធ្វើ សមិទ្ធិកម្ម នូវ អ្វី ដែល ខ្លួន ចង់បានៈ អ្នកណា មាន កម្លាំងចិត្ត ជា កម្លាំង អំណាចបញ្ញា សំរាប់ ស្វែងរកអ្វីមួយ ដែល ខ្លួនមានសង្ឃឹម តែង ទទួលបាន ដូចសេចក្តីប្រាថ្នា។ អំណាចបញ្ញា តែង តែ រស់នៅក្បែរ ជានិច្ច នឹង ភាពចាំបាច់ របស់ ប្រជា ពលរដ្ឋ ព្រោះ ការខ្វះ របស់ចាំបាច់ ជាដំណើរ ឈានទៅ រក ការចង់បាន, ដូច្នេះការសង្ឃឹម ឬ ការចង់បានជា កម្លាំងចិត្ត សកម្មពិត ដែល មិនអាចរលត់បាន នោះ ឡើយព្រោះអ្នកត្រូវការ របស់ចាំបាច់ តែងតែ មានសង្ឃឹម

ហើយ ស្វែងរក ឬ អនុវត្ត ការចង់បាននោះ ជាអនន្តរនិង អបរិយោសាន លុះបានសម្រេច ព្រោះ របស់ចាំបាច់ វា ជារឿង ជីវិត ឬ រឿង ជាតិ។

រួមសេចក្តីមក បើ មាន ការសង្ឃឹម តែ អង្គុយ ដេកចាំវាអោយ កើតមកខ្លួនឯង ដូចខ្មែរយើង នាំគ្នា រង់ចាំព្រះបាទធម្មិក ក្នុង ទុក្ខព្រួយខាងផ្លូវចិត្ត (tribulation) គឺច្បាស់ជា ការរងចាំនោះ វា ជា ការសង្ឃឹម ក្នុងការអស់សង្ឃឹមតែប៉ុណ្ណោះ។ បើ មាន ការជឿ តែជឿ ទៅលើអ្វីមួយដែល មិនចេញមកពី អត្តៈបញ្ញា គឺ ជា ការជឿ គ្មានការពិចារណា ; ហេតុដូច្នេះ គឺ គ្មាន សេចក្តីស្នេហាបាននោះទេ ព្រោះសេចក្តីស្នេហាជាតិ វា មានធាតុ ជាបញ្ញា, មិនមែនគ្រាន់តែ ដាំបង្កប់ ក្នុង ទឹកចិត្ត ; វា កើតមានឡើងពី ការត្រិះរិះ ការពិចារណា ពិស្តារ មិនមែន ជា ឧបបាតិក (né de lui-même) ក្នុង ភាពថៃដន្យ សំរាប់ ល្បិតដោះខ្លួន ឬក្តុលគំនិត សម្របនឹង កាលៈទេសៈ អ្វីមួយ នោះឡើយ។

យ៉ាងនេះ ការស្នេហាជាតិ, ការជឿលើជាតិ, ការសង្ឃឹមដល់ជាតិ វាជា សារព័នសណ្ឋិត ក្នុង ស្មារតី មាន បញ្ញាសក្តា

របស់ ប្រជាពលរដ្ឋ ដែល ជា ប្រភព ឋាមពល ជា ថេរ ចិរកាល រុញដំណើរ នៃ ប្រជាជាតិ អោយ ដើរ ទៅរក គោលដៅ នៃ ការរីកចំរើន ដែល ជា មនោមយិទ្ធ សន្ទិដ្ឋិក (pouvoir de la volonté visible) មាន សម្រេក និងទំនាក់ចិត្ត នៃ មនុស្សជាតិ។ សារព័ន នេះឯង ជាសេចក្តីត្រូវការចាំបាច់ របស់ ប្រជាជាតិនិមួយៗ ដែលតម្រូវ អោយ ប្រជាពលរដ្ឋ មានចិត្តរំជួល ប្រកបដោយ សម្មានភាព នៃ ការស្នេហាជាតិ,ការជឿ និង ការសង្ឃឹម ជា បញ្ញា, ជា ការពិចារណា ដើម្បី ជា កម្លាំងពភឹល សំរាប់ ធ្វើអភិវឌ្ឍន៍សង្គមជាតិ ដែល ទុក មនុស្សលោក ជា ខ្លឹមសារ នៃ នរសង្គមក្នុង បច្ចុប្បន្នសម័យ ក៏ដូចក្នុង អបរសម័យ លើក្រឡាប្រឹថពី នេះ។ នរសង្គមល្អ ជាជម្រក ដ៏ប្រពៃ សំរាប់មនុស្សលោក បីដូចប្រជាជាតិ ជា ផ្ទះសំបែង ដ៏សុខសំរាប់ប្រជាពលរដ្ឋ អម្បាលដូច មាតា ជា សេចក្តីស្នេហា សំរាប់កូន។ ដូច្នេះ ការប្រៀបធៀប មាតា ទៅនឹងជាតិ គឺជាមនោសញ្ចេតនា នៃសេចក្តីស្នេហាបរិសុទ្ធ និងឧត្តមបំផុតរបស់ ប្រជាពលរដ្ឋចំពោះ ជាតិ និង កូន ចំពោះ មាតា។

# គុណប្រយោជន៍ នៃការចរចារ

*សេរីការ*



ឆ្នាំ ២០១៦

គណបក្ស សង្គ្រោះជាតិ កំពុង ស្វែងរក ការចរចាជាថ្មី ជាមួយ គណបក្ស កាន់អំណាច ក្រោយពីបានធ្វើពហិការ មិនព្រមចូល ប្រជុំពេញអង្គ នៅរដ្ឋសភា អស់រយៈពេល៤ ខែមកហើយ។ កលហប្បវឌ្ឍនី (motifs de désaccord) មាន ច្រើន គឺ គណបក្សកាន់អំណាច រំលោភ អភ័យឯកសិទ្ធិ សមាជិក សភា ប្រើ ប្រព័ន្ធ តុលាការ ដើម្បី ចាប់ តំណាងរាស្ត្រ សមាជិក ព្រឹទ្ធសភា សកម្មជន គណបក្សប្រឆាំង សមាជិក អង្គការសង្គមស៊ីវិល និង គ.ជ.ប.[54] ដាក់ពន្ធនាគារ។

យើងអាចសួរថា នៅក្នុង បរិបទ នេះ ការចរចារជាថ្មីតាម របៀបចាស់ រវាងគណបក្សទាំងពីរ តើ ជា គុណប្រយោជន៍ (enjeux) អ្វីដែរ សំរាប់ប្រជាពលរដ្ឋខ្មែរ ?

ដំណោះស្រាយណា ដែល យក សន្តិវិធី ជា ផ្លូវស្រាយចំណង នៃ វិបត្តិគឺ ជា មាគ៌ាដ៏ប្រសើរសំរាប់ប្រយោជន៍ជាតិ តែបើ

---

54 គ.ប.ជ. :គណកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ជា ការប្រជុំ សម្ងាត់ ដើម្បី រួមគំនិត ក្បត់ រាស្ត្រ ដូចសព្វ ដង សន្និវិធី នោះ វា គ្រាន់ តែ ជា ការចង កំណួច បន្ថែម ដើម្បី បិទមុខ វិបត្តិ តែប៉ុណ្ណោះ។ ទង្វើនេះឯង វា កំពុងមាននៅក្នុងជំនួប ជាទម្លាប់ រវាងគណបក្សកាន់ អំណាច ជា មួយបរបក្ស (parti adverse) មាន អាសនៈ នៅរដ្ឋ សភា។ ដូច្នេះ គុណប្រយោជន៍ នៃ ការចរចានោះ គឺវាគ្មាន អ្វីជាធំដុំនោះឡើយ សំរាប់ប្រជាពលរដ្ឋខ្មែរ បើសិនជាអ្នក ដឹកនាំគណបក្សសង្គ្រោះជាតិ គាត់នាំគ្នាធ្វើការចរចា នៅ ក្នុង ស្ថានភាព ទាល់ច្រក ហើយ និង សំរាប់ ឆ្លើយតប ជា វិជ្ជមាន ចំពោះ សារ របស់ លោក ហ៊ុនសែន កំពុងមាន សម្ពាធពីសហគមន៍អន្តរជាតិ ថាអាចនឹងមាន ដំណោះ ស្រាយ រវាងបក្សទាំងពីរនៅរដ្ឋសភា។ ដើម្បី បង្ហាញ សុទ្ធ ចិត្ត បញ្ឆោតភ្នែក បក្សកាន់អំណាច តាមរយៈ គណកម្ម ការ អចិន្ត្រៃយ៍ នៃរដ្ឋសភា បាន ប្រានចោល នូវ សំណើរ របស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សូមដកហូតអភ័យឯកសិទ្ធិ របស់ តំណាងរាស្ត្រ ពីរ រូប នៃ គណបក្សប្រឆាំង។ ទង្វើ ទាំងឡាយនេះ មាន ចំហាយក្លិន ឆ្គុយឆ្ងាញ់ នាំឲអ្នក ដឹកនាំ គណបក្ស សង្គ្រោះជាតិ ស្រក់ទឹក មាត់នាំគ្នាធ្វើការ

សំរេច ចូលប្រជុំ ពេញអង្គ នៅរដ្ឋសភាវិញ ដើម្បី ចូលរួម ជប់លៀង ជា ថ្មី ជាមួយ បក្សកាន់អំណាច។ បើតាមសំដី លោក សុន ឆ័យ មន្ត្រីជាន់ខ្ពស់ នៃ គណបក្ស សង្គ្រោះជាតិ គាត់ថ្លែង ជា សាធារណ ថា បក្ស របស់គាត់ មិនដែលប្រើ ពាក្យ ពហិការ នោះឡើយ គ្រាន់តែថា មិនចូលប្រជុំពេញ អង្គ នៅរដ្ឋសភា ព្រោះ តំណាងរាស្ត្រ របស់បក្សគាត់ មាន ការបារម្ភ អំពីសន្តិសុខ ក្រោយពី តំណាងរាស្ត្រ ពីរនាក់ ជា ក្មី ត្រូវបាន មនុស្សមួយក្រុម វៃទាត់ធាក់ នៅក្បែររដ្ឋសភា ព។ សំដី លោក សុន ឆ័យ ជា សំដី អវមាន (ការមើលងាយ) ដល់ ប្រជាជនខ្មែរ ដោយយក អត្ថៈ នៃ ពាក្យ ពហិការ មក ឲ និយមន័យ ខុសពី ប្រយោគ « មិនចូលប្រជុំ » ដែល វា អវិរុទ្ធ (ដែលមិនខុស) នឹង ពាក្យពហិការ ដើម្បី សម្រួបនឹង គម្រេក របស់ខ្លួន។ ចំណែកលោក យ៉ែម បុញ្ញឫទ្ធិ វិញ ជា សហជីវិន ឯកតោ (ជាមួយ) នឹង លោក សុន ឆ័យ គាត់ លើក ជា លេស ថា ចូលរួមចំណែក ដើម្បី លើកកំពស់ ស្ថាប័ នរដ្ឋសភា។ សំដី អសាធុ (ពុំប្រពៃ) នេះ មិនមែន ជា សំដី របស់ វរជន ចេះដឹងនោះឡើយ ព្រោះ វា មានអត្ថៈ ជាសំដី អែបនែបនឹង បក្សកាន់អំណាច តែប៉ុណ្ណោះ ព្រោះ ស្ថាប័ន

រដ្ឋសភាសព្វថ្ងៃ វាជាស្ថាប័ន របស់បក្សប្រជាជន មិនមែនជា ស្ថាប័នជាតិ នោះទេ ហើយ បានបង្ហាញ នូវ ធាតុពិតរបស់ ខ្លួន គឺ ជា ឧបករណ៍ នៃ អំណាចផ្តាច់ការ យកវិធីសម្លាប់ មនុស្ស ជា នយសាស្ត្រ (science politique) ទៅហើយ។ ចុះហេតុដូចម្តេច បាន ជា លោក សុន ឆ័យ អ្នកនយោបាយដែល មាន ពិសោធន៍ និង លោក យ៉ែម បុញ្ញឫទ្ធិ អ្នកអប់រំយុវជន នៃ បក្ស យកគំនិត គ្មានខ្លឹមសារ មកធ្វើជាខ្សែនាយកនយោបាយ របស់គណបក្ស ដែលនាំឲគណបក្ស ចុះកំពស់ នយោបាយ ទៅវិញ ផ្ទុយ ពី ជោគ (atout) ដែល ខ្លួនកំពុងមានគឺការគាំទ្រ ពីសំណាក់ ប្រជានិករ និងសហគមន៍អន្តរជាតិ។ អ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ ទុក គណបក្សខ្លួន ជាតំណាង នៃ យុត្តៈ (juste) ; តើ យុត្តៈ វានឹងអាចរួមចំណែក ជាមួយនឹង អយុត្ត (injuste) បានដែរឬទេ ?

អកុសល (le mal) ដែល អ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិកំពុងធ្វើ ឲ អ្នកគាំទ្រខ្លួន ឈឺចិត្ត និងខកចិត្ត គឺ សំដីគ្មាន ការទទួល ខុសត្រូវ នោះឯង។ ត្រូវដឹងថា ប្រវត្តិសាស្ត្រមិន ផ្តន្ទាទោស ពួកអ្នកក្បត់ជាតិ នោះឡើយ ព្រោះ អំពើក្បត់ជាតិ គឺ វា មានទោស រួចស្រេចភ្លាមៗ តែ ប្រវត្តិសា

ស្ត្រ នឹងបន្ទោស ពួដែលតាំងខ្លួន ជាអ្នកសង្គ្រោះជាតិ តែដើរលើមាគ៌ាបំផ្លាញជាតិទៅវិញ។

# គុណសម្បត្តិ នៃមហាបុរស

*សេរីការ*



ឆ្នាំ ២០១៦

មហាបុរសជាតិជាច្រើន លោកបានបូជាជីវិតលោកសំរាប់ជាតិ របស់លោក ក្នុងការតស៊ូ ជួនតាមកម្លាំងកាយ ជួនតាមបញ្ញា តែកម្លាំងទាំងពីរនេះ លោកប្រើវា នៅក្នុងគុណធម៌ ជា និច្ច។ គុណសម្បត្តិ របស់ លោក គឺ លោក មានជំនឿ និង សត្យ ទៅលើកុសលដែលជាថាមពល នៃសេចក្តីក្លាហាន របស់លោក។ ទោះបី លោក ខ្វះ កម្លាំងកាយ ខ្វះមធ្យោបាយ ជា សម្ភារៈក្តី តែ លោក ប្រើបញ្ញាប្រឈមមុខឥតតក់ស្លុត តទល់នឹងអំពើហិង្សាក្បត់ជាតិ ដែលជាអំពើចង្រៃ បំផ្លាញជាតិ។ មហាបុរសជាតិ មិនដែល ភូតកុហកប្រជាពលរដ្ឋ ដើម្បី បោយយកប្រយោជន៍ ហេតុនេះឯងបានជា លោកច្រើនជា បុគ្គលគ្មានសម្បត្តិ ហើយមិនមែនជាពាណិជ្ជគិតតែរកចំណេញ ព្រោះបេះដូង នៃសកម្មភាពរបស់លោក គឺការសង្គ្រោះជាតិ និង អ្នកទន់ខ្សោយ ដែលលោក ទុកសកម្មភាព នេះជា ធម៌ នៃ នរជន ត្បិតមនុស្សលោក មាន លក្ខណសម្បត្តិ របស់រូបធាតុពីរយ៉ាងសំខាន់ គឺ៖ ខ្លួនជាម្ចាស់ នៃខ្លួនឯង និង មេត្តាធម៌ ចំពោះ អ្នកដទៃ។ មហាបុរសជាតិ តែងតែ ផលិត នូវ កិត្តិយស និង ស

ក្លាតេជ (bravoure) ជា អ្នកស្នេហាជាតិ ហ៊ានស្លាប់ ដើម្បី ប្រជាជាតិ។ ក្នុង សកម្មភាព នៃ ការពារជាតិ ត្រូវមាន កម្លាំងកាយពិត តែកម្លាំងនេះ ត្រូវដឹកនាំ ដោយកម្លាំងចិត្តប្រកប ដោយគុណធម៌។ កម្លាំងចិត្ត នេះឯង ដែល នាំ អោយ អ្នកស្នេហាជាតិ មិនដែលមាន គំនិត ចុះចាញ់ នៅចំពោះមុខ សត្រូវជាតិ រត់គេចខ្លួន ស្វែងរកសុខផ្ទាល់ខ្លួន។ ភាពដ៏ ខ្ពង់ខ្ពស់ នេះឯង ដែល ជា តម្លៃសាមាន្យ (valeur commune) នៃ មហាបុរសជាតិះ ស្លាប់ ដើម្បី បំរើជាតិ ប្រសើរជាងរស់ សំរាប់ បំផ្លាញជាតិ ឬ ជា មនុស្សកំសាក។ មរណភាពលោក កែម ឡី ជា វិជ្ជាឈុត វុទ្ធី សុទ្ធជាគំរូ នៃគុណសម្បត្តិ នៃ មហាបុរសជាតិ ក្នុង ចំណោម នៃ មហាបុរសជាតិ មាននៅក្នុង ប្រវត្តិសាស្ត្រជាតិខ្មែរយើង សំរាប់កូនខ្មែរ នាបច្ចុប្បន្នកាលនេះ និង ជំនាន់ក្រោយ។ ខ្មែរយើង ត្រូវមាន សតិសម្បជញ្ញៈ ថា នៅមាន អ្នកស្នេហាជាតិ នឹងស្លាប់ សំរាប់ ការពារជាតិ នៅថ្ងៃមុខជាពុំខាន នៅក្នុងបរិបទស្រុកខ្មែរសព្វថ្ងៃនេះ។ ពលិកម្មនេះជាតម្លៃ នៃការតស៊ូ របស់ កូនខ្មែរ ដើម្បី ឯករាជ្យជាតិ សេរីភាព និង លទ្ធិប្រជាធិបតេយ្យ សេរី។ ខ្មែរយើង ត្រូវឈប់ មាន ទុក្ខស្តាយ

ក្រោយ ព្រោះ ចេះតែនាំគ្នា អង្គុយ ស្រកោក (en vain) ចាំព្រះបាទធម្មិក មកជួយជាតិ អស់ច្រើនសតវត្ស រួចមកហើយ។ មហាបុរសខ្មែរ លោកសុខចិត្តស្លាប់ ដើម្បី ទៅ បើកទ្វារ ការតស៊ូជាតិ ដូច្នេះខ្មែរយើង កុំនាំគ្នា ឈរ អោបដៃនៅមាត់ទ្វារមើល ដំណើររហ័ស នៃ ការទ្រុឌទ្រោមជាតិខ្លួនព្រោះ បើជាតិស្លាប់ ជាតិសាសន៍ខ្មែរយើង ក៏នឹង រលាយនោះដែរ។ កុំនាំគ្នា យល់ឃើញថា របប ហ៊ុន សែន គ្រាន់បើជាង របប ប៉ុល ពត ហើយ កុំនាំគ្នាច្រឡំថា សន្តិភាពសព្វថ្ងៃ ជា សន្តិភាព សំរាប់ ប្រជាពលរដ្ឋខ្មែរ ព្រោះ យល់បែបនេះ គឺខ្មែរយើង ច្បាស់រស់ជាខ្ញុំ នៃជនអាណានិគមយួនជានិច្ច។ រកសុខ សំរាប់តែអាត្មា សំរាប់តែគ្រួសារ ជា សភាវគតិធម្មតា របស់ សត្វលោក តែ សុខបែបនេះ គ្មានគង់វង់បានយូរ នោះឡើយ ព្រោះ ជា សេចក្តីសុខ អត្តទត្ថ បុគ្គលដែល វា ផ្ទុយពី ធម្មជាតិ នៃ មនុស្សលោក ដែល ជា អ្នកបង្កើតអារ្យធម៌។ ដូច្នេះសុខបែបនេះ ដែល មហាបុរសខ្មែរគ្រប់ជំនាន់ លោក មិនយកមកប្រតិបត្តិ ព្រោះ វាជាអំពើអកុសល និងកុទិដ្ឋិ សំរាប់ មនុស្សជាតិ និង ប្រជាជាតិ ជាពិសេស នៅពេលដែលជាតិ កំពុងមានវិនិបាត (អាសន្ន)។

គំនិត ស្នេហាជាតិ របស់ មហាបុរសខ្មែរ ដែលបាន បូជាជីវិត សំរាប់ ជាតិ មិន បញ្ចប់ ក្រោយពី ឈាបនកិច្ច នោះឡើយ ផ្ទុយទៅវិញ វា ជា ដំណាក់ការថ្មី នៃ វិត្ថារកម្ម នៃកម្លាំង គំនិតស្នេហាជាតិ គ្មាន ដែន សំរាប់ ឃាត់ឃាំងបាននោះឡើយ។ គេអាច ឃុំឃាត់កាយ អ្នកស្នេហាជាតិបាន តែគេពុំអាច ឃុំឃាំងគំនិត របស់គាត់បាននោះទេហើយ គ្មាន ពេលវេលាណា អាច លុបបំបាត់ នូវ គំនិតនោះអោយសាបសូន្យទៅបានដែរ។ ការបូជាជីវិតសំរាប់ជាតិជាអំពើ គង្វាន (action audacieuse) វា ប្រែក្លាយ ជា ព្រលឹងជាតិ រស់នៅផ្តិតជាប់ ក្នុងអនន្តកាល ដែល ជា អនន្តគុណ សំរាប់ប្រជាជាតិ។ ព្រលឹងជាតិ នេះឯង ដែល ជា អាត្ម័ន និងកម្លាំងស្នូល របស់ ជាតិ ដែលបន្តុះគំនិត នៃ សេចក្តីស្នេហាជាតិ ដល់កូនខ្មែរ បន្តពីជំនាន់មួយ ទៅជំនាន់មួយទៀតដែលជា មូលស្ថាបនា នៃ ប្រជាជាតិ។ ដូច្នេះ ប្រទេស គ្មានមហាបុរសជាតិ គឺ ជាប្រទេស គ្មានព្រលឹងជាតិ ជា ប្រជាជាតិ គ្មាន បដិសរីរៈ (anticorps) សំរាប់ ការពារ កាយ និងគំនិតជាតិ។

## ករណី លោក ប៉ែន សុវណ្ណ

*សេរីការ*



ឆ្នាំ ២០១៦

ការទទួលស្គាល់ថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ ជាទិវារំដោះជាតិខ្មែរ ពីរបប ប្រល័យពូជសាសន៍ នៃកងទ័ពយួន នៅស្រុកខ្មែរ គឺជាការទទួលស្គាល់ សាធារណរដ្ឋប្រជាមានិតកម្ពុជា បង្កើតដោយយួន ជារដ្ឋខ្មែរមួយស្របច្បាប់ ក្នុងចំណោមរដ្ឋដ៏ទៃទៀត មាននៅស្រុកខ្មែរ។ រដ្ឋដែលយួនបង្កើតនេះ គ្មានការទទួលស្គាល់ពីសំណាក់អង្គការសហប្រជាជាតិ រស់មានជីវិតដោយសារកងទ័ពយួន ជា អ្នកចិញ្ចឹមបីបាច់ថែរក្សា សំរាប់តែបំរើនយោបាយយួន ហើយ មើលងាយប្រជាជនខ្មែរ ដែលជា ប្រជាជន មាន ប្រវត្តិសាស្ត្រច្បាស់លាស់ ទុកជា ជាតិពិន្ទ តែប៉ុណ្ណោះ ក្នុងចំណោមជាតិពិន្ទមាននៅស្រុកខ្មែរ ដូចមានសរសេរ នៅក្នុងសៀវភៅមានចំណងជើងថា ‹សង្គ្រាមមិនប្រកាស ប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា› ផ្សាយចេញពី ទីស្តីការរដ្ឋមន្ត្រីក្រសួង

ការបរទេស ជាភាសារបារាំងនៅឆ្នាំ១៩៨៥[55]។ លោក ប៉ែន សុវណ្ណ, ចាន់ ស៊ី និង ហ៊ុន សែន មានងារជានាយករដ្ឋមន្ត្រី នៅក្នុង សាធារណរដ្ឋប្រជាមានិតកម្ពុជា មិនអាចទុកជានាយករដ្ឋមន្ត្រីស្របច្បាប់ជាតិខ្មែរបាននោះឡើយ។ ហេតុនេះឯង គេមិនអាចនិយាយឬសរសេរថា សពលោក ប៉ែន សុវណ្ណ ជាអតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រខ្មែរបាននោះទេ ហើយគាត់ក៏មិនមែនជាបិតានៃថ្ងៃទី៧ មករា នោះដែរ។ បើចង់អោយកិត្តិយសដល់លោក ប៉ែន សុវណ្ណ

---

[55] Il convient de préciser tout d'abord une question de terminologie qui étonne et déroute parfois certaines personnes s'intéressant au Kampuchéa « Kampuchéa » est reprise du terme traditionnel dont la transcription en français est « Cambodge », en anglais « Cambodia » … Jusqu'en mars 1970, le pays se dénommait Royaume du Cambodge. Sous le régime de Lon Nol, il prit le nom République Khmère (1970-avril 1975). Le régime de génocide de Pol Pot le changea en Kampuchéa Démocratique (avril 1975-Janvier 1979). Depuis la victoire du 7 janvier 1979 jusqu'à l'heure actuelle, le pays prit le nom de République Populaire Du Kampuchéa (R.PK.). Les Khmers ne constituent que l'une des ethnies du Kampuchéa, bien que largement majoritaire dans le pays. Il est donc plus exact d'employer le terme « peuple kampuchéen » plutôt que le terme « peuple khmer ». Dans ce livre comme ailleurs, le terme « réactionnaires khmers » se réfère plus spécialement aux trois factions khmères du « gouvernement de coalition du Kampuchéa démocratique ».

វាមានចំណុចផ្សេងដែលនឹងអាចលើកវាយកបង្ហាញបាន តែទោះបីយ៉ាងណា ក៏វាមិនដាច់ខាតបាននោះដែរ ព្រោះថានរណាម្នាក់ក៏ដោយ ដែលយកឈ្មោះខ្លួនទៅភ្ជាប់នឹងថ្ងៃទី៧ មករា គឺច្បាស់ជាក្លាយជាប្រធានបទនៃការជជែករកខុសត្រូវមិនចេះចប់ ព្រោះនៅក្នុងវិស័យមតិខ្មែរលើថ្ងៃទី៧ មករា គ្មានការព្រមព្រៀងរវាងគ្នានោះឡើយ ដ្បិតប្រភពនៃថ្ងៃទី៧ មករា វាចេញពីការប្រព្រឹត្តអំពើឈ្លានពីសំណាក់យួនមកលើស្រុកខ្មែរ។

## ខ្មែរ អ្នករងគ្រោះ ក្នុង របប ខ្មែរក្រហម

តែបើគ្មានថ្ងៃទី ៧ មករា គេអាចសួរថា តើវាសនា នៃប្រជាពលរដ្ឋខ្មែរ វាលុះភាពបែបណា ?

ថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ ជា ការរំដោះខ្លួន ចេញពី អវិនិច្ឆ័យ[56] រស់នៅក្នុងរបបគ្មានជាតុជាមនុស្ស ព្រោះមានអំណាច សម្លាប់មនុស្សលោក ដើម្បីបំរើតណ្ហាអាត្មា។ របប

---

56 អវិនិច្ឆ័យការឈឺចាប់ក្នុងកាយនិងចិត្ត។ ;

នេះ ជា រដ្ឋខ្មែរ ពេញច្បាប់ ទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ត្រូវមានកាតព្វកិច្ចខ្លួន ជាអ្នកការពារប្រជាពលរដ្ឋ ការពារ អធិបតេយ្យភាពជាតិ និង បូរណភាពដែនដីខ្មែរ ដូច្នេះមិនអាច ដូចមានខ្មែរមួយចំនួន មានវិស័យមតិថា ជនឃាតកម្ម មានកើតឡើងនៅក្នុងរដ្ឋ កម្ពុជាប្រជាធិបតេយ្យ ជាល្បិចយួនកុម្មុយនិស្ត ដើម្បី សម្លាប់ខ្មែរនោះឡើយ។ បើលើកយកលេសនេះ សំរាប់ការពារខ្លួនដូចលោក នួន ជា អតិតអ្នកដឹកនាំរដ្ឋកម្ពុជា និងបក្សកុម្មុយនិស្តខ្មែរ គឺវាវិតតែបង្ហាញបន្ថែម នូវគំនិតស្រាលរបស់គាត់ក្នុងឋានៈជា អ្នកដឹកនាំផង និងជា បញ្ញវន្តផង ព្រោះថា គ្មាននរណា ឬ អង្គការណាមួយ ស្គាល់មារយាទយួន កុម្មុយនិស្ត ជាង បក្សកុម្មុយនិស្តខ្មែរ នោះឡើយ ដ្បិតបក្សនេះធ្លាប់បានធ្វើសហការជិតស្និទ្ធជាបក្សកុម្មុយនិស្តយួន ដូច្នេះ បើចាញ់បោកសត្រូវ ដោយស្គាល់សត្រូវច្បាស់ គឺជាកំហុស មិនអាច ដោះទោសបាននោះឡើយ ព្រោះវាជាគ្រុរទោស[57] នៃការទទួលខុសត្រូវ របស់អ្នក

---

[57] គ្រុរទោសកំហុសដ៏ធំ។ ;

ដឹកនាំ មានបន្ទុក លើ កិច្ចការជាតិ ដែល ត្រូវមាន សតិមន្ត[58] ដោយ ការប្រុងប្រយ័ត្ន គិតយល់ដឹង ជា ស្រេច ដល់អំពីល្បិចកលសត្រូវ។ បើជាបញ្ញវន្ត ការលើកយកលេសយួននេះ វាជាការបន្ទោកបញ្ហាខ្លួនឯងតែប៉ុណ្ណោះ ព្រោះអ្នកចេះដឹង ត្រូវមាន ការពិចារណា លើ អំពើរបស់ខ្លួន រកហេតុផលច្បាស់លាស់ សំរាប់បំភ្លឺ តាមបញ្ញា នូវ បញ្ហា នៃ មនុស្សជាតិ។ បើចំណេះចេះដឹង យកវាមកប្រើ សំរាប់តែការពារអត្ថប្រយោជន៍បុគ្គល វា គ្រាន់តែ ជា ល្បិច សំរាប់ រកសេចក្តីសុខដល់អាត្មា តែប៉ុណ្ណោះ ដែលគេអាច ប្រដូចគ្នានឹងសត្វ មានសភាវគតិ សំរាប់រស់នៅក្នុងសុខដុមនៃធម្មជាតិនោះឯង។

អាស្រ័យហេតុនេះ ខ្មែររងគ្រោះនឹងរបបខ្មែរក្រហម ទុកថ្ងៃទី៧ មករា ជាថ្ងៃរំដោះខ្លួន ពីគ្រោះកំណាចដល់អាយុជីវិត គឺ ជា វិចារណញ្ញាណ នៃ កំហឹង ជា ជនរងគ្រោះ ដែលអាចយល់បាន អំពី គោលចំណង់នេះ។ គ្មាន នរណាម្នាក់ អាច

58 សតិមន្តអ្នកមានស ;្មារតី។

បន្ទោសនូវអារម្មណ៍នេះ បាននោះឡើយ ព្រោះ អវិនិច្ឆ័យ នៅចំពោះមុខ អំពើអាយុត្តិធម៌ វា ជា អត្ថរស់ នៃ មនុស្សលោក។

## គុណវុបត្តិ នៃថ្ងៃទី៧ អករា ឆ្នាំ ១៩៧៩

តែថ្ងៃទី៧ មករា វាមានគុណវិបត្តិរបស់វាផ្ទាល់ ព្រោះការរំដោះ នោះ ទោះបី ចុះនាម ក្នុងសង្គហកម្ម[59] នៃ មនុស្សលោក ក៏ដោយ តែ វា ជា ឧបករណ៍ នយោបាយ សំរាប់ បំរើប្រយោជន៍ នយោបាយ របស់ អ្នកនយោបាយ គឺ បក្សកុម្មុយនិស្តយួន ដែល តែង មាន មហិច្ឆិតាខ្ជាប់ខ្ជួន លេបស្រុកខ្មែរ ចូល ទៅក្នុង ពោះ សហព័ន្ធឥណ្ឌូចិន។ នៅក្នុងគោលដៅ នេះឯង ដែល ធ្វើ អោយ រូបភាព នៃ សង្គហកម្មមាន សទិសភាព ដូច ជា អ្នកឆ្លៀតឱកាស បោយយកប្រយោជន៍ ពី ស្ថានការ ប្លែក អស្ចារ្យមួយ កើតនៅស្រុកខ្មែរ គឺ ខ្មែរសម្លាប់ខ្មែរគ្នាឯង។ ទ័ពយួនកុម្មុយនិស្ត វាយយកស្រុកខ្មែរ បានយ៉ាងងាយស្រួលបំផុត សូម្បី យួនខ្លួន

---

59 សង្គហកម្ម ;ការធ្វើសេចក្ដីសង្គ្រោះ។

ឯង ក៏គេ ស្ទើរ តែមិនជឿបាន ព្រោះតែ ខ្មែរបាត់ព្រលឹងជាតិ ដ្បិត បក្ស កុម្មុយនិស្តខ្មែរ សម្លាប់ព្រលឹងជាតិចោល ដើម្បី ដាំបង្កប់ជំនួសព្រលឹងបក្ស នៅក្នុងសតិប្រជាជាតិខ្មែរ ដែលជាការផ្សាំប្រឆាំងនឹងធម្មជាតិនៃប្រជាជាតិខ្មែរ

គួរពិចារណា ជា ជម្រៅ ទៅលើធាតុ នៃ វិនាដកម្ម របស់ប្រជាពលរដ្ឋខ្មែរ នៅពេលនោះ គឺ ជា ធាតុលទ្ធិកុម្មុយនិស្តយក មក អនុវត្ត នៅក្នុងបដិវត្តន៍ដាច់ខាត[60] មួយ ដែលមិន ទុក សេចក្តីថ្លៃថ្នូរ នៃ មនុស្សលោក ជា ខ្លឹមសារ នៃមនុស្សជាតិ។ គោលដៅ តែមួយគត់ របស់ បដិវត្តន៍ គឺឆព្វណ្ណរង្សី នៃ បក្សកុម្មុយនិស្ត ទោះបីបក្ស ត្រូវរំលាយជីវិតមនុស្ស គ្មាន កំរិតចំនួន យ៉ាងណាក៏ដោយ គឺថាជា បដិវត្តន៍ ដ៏បរិសុទ្ធ ដែល ពិភពលោក មិនដែលធ្លាប់ឃើញ គឺបង្រួញដំណាក់ការ នៃ ដំណើរ នៃ វិការរូប ឬ ការប្រែផ្លាស់រូបសង្គម អោយ ក្លាយ ជា សង្គម កុម្មុយនិស្ត បានយ៉ាងរហ័ស បំផុត ដែល គេ អោយ ឈ្មោះ ថា ដំណើរមហាលោត

---

60 បដិវត្តន៍ដាច់ខាត ; révolution radicale។

ផ្លោះ។ ជាតុ នៃ បដិវត្តន៍ ដាច់ខាត នោះឯង ដែល សម្លាប់ ប្រជាជនខ្មែរ ដល់ ចំនួនលាន ដែល ជា ចំនួន វិសម្មាមាត្រ នឹង ចំនួន ប្រជាពលរដ្ឋខ្មែរ។

រីឯថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ វិញ វានៅរក្សាជាតុកុម្មុយនិស្ត ទាំងស្រុងនៅក្នុង គោលកាណ៍បដិវត្តន៍ថ្មី គឺ បដិវត្តន៍អន្តរជាតិយួន ដឹកនាំ ដោយបក្សកុម្មុយនិស្តយួន ឬ ឥណ្ឌូចិន ដើម្បី វាយ កំទិច បក្សកុម្មុយនិស្តជាតិ (បក្សកុម្មុយនិស្តខ្មែរ) និង រំលាយ ប្រជាជាតិ ខ្មែរ និង លាវ អោយរលាយចូលទៅក្នុងប្រជាជាតិយួន ដែលបក្សកុម្មុយនិស្តយួន គេទុក ជា ប្រជាជាតិប្រមុខ នៅឥណ្ឌូចិន។ បដិវត្តន៍នេះ គឺ បក្សកុម្មុនិស្តអន្តរជាតិយួន គេ អោយ ឈ្មោះ ថា ទន្លេបីហូរ ចូល ទៅក្នុង មហាសាគរ តែមួយ គឺ មហាយៀកណាម។ បដិវត្តន៍ ខ្មែរក្រហម ប្រើ អាវុធ សំរាប់សម្លាប់ ប្រជាជនខ្លួនឯង ចំណែកឯ បដិវត្តន៍អន្តរជាតិយួន វិញ ប្រើ ប្រជាករយួន[61] ចូលមករំលាយប្រជាជនខ្មែរ/លាវ។ លទ្ធផលនៃទី

[61] ប្រជាករយួន ; la masse de la population vietnamienne។

បញ្ចប់ របស់ បដិវត្តន៏កុម្មុយនិស្ត ខ្មែរក្តី យួនក្តី គឺ ការរំលាយ ប្រជាជាតិខ្មែរ។ ប៉ុល ពត រំលាយជាតិខ្លួនឯងនៅក្នុងអន្ទការនិយម រីឯ យួនកុម្មុយនិស្ត វិញ រំលាយជាតិខ្មែរនៅក្នុង យុទ្ធសាស្រ្ត ច្បាស់លាស់។ ដូច្នេះចំពោះយួនកុម្មុយនិស្ត ការប្រើថ្ងៃទី៧ មករា គ្រាន់តែជា ដំណាក់ការអន្តរការសំរាប់ ធ្វើ ជា ប្រតិដ្ឋាន ដើម្បី លោតផ្លោះអោយបានរហ័សដល់គោលដៅ របស់ បដិវត្តន៏ អន្តរជាតិយួន តែប៉ុណ្ណោះ។ នៅក្នុង មនោគតិយួននេះឯង ដែល យួន គេ ទុកអោយសពលោក ប៉ែន សុវណ្ណ កាល គាត់ នៅមានជីវិត ប្រើសំដីក្រោយ ពី យួនដោះលែង អោយ មករស់នៅស្រុកខ្មែរវិញ ថាគាត់ជាបីតាថ្ងៃទី៧ មករា។ គេអាចសួរជាសំនួរថា ចុះហេតុដូចម្តេច បាន ជា លោក ប៉ែន សុវណ្ណ តាំង ខ្លួន ជា អ្នកប្រឆាំងយួន តែ បែរ ជា គាត់ទុកថ្ងៃទី៧ មករា ជាស្នាដៃពិសេស របស់ គាត់ទៅវិញ ? សំនួរនេះឯង ដែលនាំអោយយើង លើកយកករណី លោក ប៉ែន សុវណ្ណ ដាក់លើក្តាល្បែង ក្រឡាចត្រង្គយួន ដើម្បី យល់ដឹង អំពី តួនាទីជាកូនរ៉ែកនៅក្នុងល្បែងយួននោះ។

## ក្រឡាចត្រង្គយួន

យើងមើលឃើញថា ករណី សពលោក ប៉ែន សុវណ្ណ ជាករណីសំរាប់សិក្សា[62] នយោបាយមួយ គួរលើកវាយកមកសិក្សាទុកជាចំណោះបញ្ហា។

នៅទីនេះ យើងមិនយកបុគ្គល ប៉ែន សុវណ្ណ មកធ្វើជាប្រធានបទសំរាប់ធ្វើការទិតៀន ឬ សរសើរនោះឡើយ ព្រោះបុគ្គលនេះ បានទទួលអនិច្ចកម្មទៅហើយ ហើយព្រលឹងលោក នាំយកកម្មផលរបស់ខ្លួន ស្របតាមពុទ្ធសាសនា ទៅរករូបថ្មីសំរាប់កើត ក្នុងជាតិខាងមុខ តាមគុណស្រ័យ ដែលខ្លួនបានប្រព្រឹត្តគ្រប់អតីតជាតិ។ តែដោយសារ សពលោក ប៉ែន សុវណ្ណ ធ្លាប់ជា ជននយោបាយម្នាក់ បានទុកស្នាម នៃសកម្មភាពនយោបាយ នៅក្នុងប្រវត្តិសាស្ត្រជាតិ ដែលជាស្នាម មានន័យមិនច្បាស់លាស់នៅក្នុងវិស័យមតិនៃសាធារណជន បានជាយើងលើកយក ករណីរបស់គាត់

---

[62] ករណីសំរាប់សិក្សា ; cas d’école។

មកសិក្សា ដូច ធ្លាប់ បានសិក្សា លើ អ្នកនយោបាយ ដទៃទៀតនោះដែរ ដើម្បី ទុក ជា ចំណេះនយោបាយ។

## សង្ខេប ពង្សាវតារ របស់ លោក ប៉ែន សុវណ្ណ

លោក ប៉ែន សុវណ្ណ កើតនៅថ្ងៃទី១៥ មេសា ឆ្នាំ១៩៣៦ នៅស្រុកត្រាំកក់ ក្នុងខេត្ត តាកែវ។ កាលពីកុមា លោក ស្ម័គ្រចិត្ត ចូលធ្វើជាសកម្មជនក្នុងជួរ ចលនាខ្មែរឥស្សរៈ។ នៅឆ្នាំ១៩៥១ លោក បានចូលធ្វើជាសមាជិក បក្សកុម្មុយនិស្តឥណ្ឌូចិន។ បន្ទាប់ពីចុះហត្ថលេខា នៃកិច្ចព្រមព្រៀងរវាងបារាំង/យួន នៅឆ្នាំ១៩៥៤ (ថ្ងៃទី១៨ តុលា) នៅទីក្រុងបារីស លោក បានស្ម័គ្រចិត្ត ចេញពីស្រុកខ្មែរទៅរស់នៅទីក្រុងហាណូយ នៅ ប្រទេសយួន ក្នុងចំណោម យុវជនខ្មែរចំនួន ២៥០០ នាក់ ដែលនៅពេលនោះខ្មែរអោយឈ្មោះថា ខ្មែរយៀកមិញ ។ នៅទីក្រុងហាណូយ លោកបានចូកសិក្សា នៅក្នុងសាលានយោបាយ នៃបក្សកុម្មុយនិស្តយួន ហើយនៅបំរើបក្សនេះ នៅក្នុងសង្គ្រាមនៅយៀកណាម រហូតមកដល់ឆ្នាំ១៩៧០ ឆ្នាំដែលទ័ពយួនកុម្មុយនិស្តចាប់វាយប្រហារកងទ័ពជាតិខ្មែរ ពីថ្ងៃទី២៧ មិនា។ នៅក្នុងសមរភូមិនៅស្រុក

ខ្មែរ បក្សកុម្មុយនិស្តយួន បានបញ្ជូនលោកមកស្រុកខ្មែរ ដើម្បីជា ជំនួយការ ក្នុងផ្នែកវិទ្យុបដិវត្តន៍ នៅក្នុងជួរ រណសិរ្សរួមជាតិខ្មែរ តស៊ូប្រឆាំងនឹង របប សាធារណរដ្ឋខ្មែរ។ នៅ ឆ្នាំ ១៩៧៤ យួនកុម្មុយនិស្ត បាន អោយ លោក វិលត្រឡប់ទៅស្រុកយួនវិញ។ ក្រោយពីរណសិរ្សរួមជាតិខ្មែរ មានជ័យជំនះ លើ សាធារណរដ្ឋខ្មែរ នៅ ឆ្នាំ ១៩៧៥ បក្សកុម្មុយនិស្តខ្មែរ ដណ្តើមបាន អំណាចទាំងអស់ពី សម្តេច សីហនុ ដែល ពេលនោះ ព្រះអង្គ ជា ប្រមុខ នៃ រាជរដ្ឋាភិបាលរួបរួមជាតិខ្មែរ ហើយបង្កើតរដ្ឋ កម្ពុជាប្រជាធិបតេយ្យ ជារដ្ឋកុម្មុយនិស្ត បន្តធ្វើបដិវត្តន៍ ដាច់ខាត ដើម្បី កសាងកម្ពុជា ថ្មី មាន ភក្តីភាព នឹង លទ្ធិកុម្មុយនិស្ត បរិសុទ្ធ។ គោលការណ៍នោះ នាំ បង្កើត ទំនាស់ ជា មួយ បក្សកុម្មុយនិស្តយួន ដែលបានទទួលជ័យជំនះលើ យៀកណាមខាងត្បូង ដែលជារដ្ឋសេរី។ នៅក្នុងទំនាស់នោះឯង បក្សយួនកុម្មុយនិស្តបានបញ្ជូនលោកប៉ែនសុវណ្ណ នៅក្នុងអំឡុងឆ្នាំ ១៩៧៧ មកធ្វើសកម្មភាព នៅតាមព្រំដែនខ្មែរ/លាវ ដើម្បីប្រមូលខ្មែរ ដែលរត់ភៀសខ្លួនពីរបបខ្មែរក្រហមទៅពួននៅទីនោះ និង ខ្មែរអ្នកភ្នំ (ហៅ ថា ខ្មែរលើ) ធ្វើ ចលនា

ប្រឆាំង ដើម្បី រំលំ រដ្ឋ កម្ពុជា ប្រជាធិបតេយ្យ។ នៅចុងឆ្នាំ ១៩៧៨ កងទ័ពយៀកណាម បាន ចូល វាយប្រហារ កម្ពុជា ប្រជាធិបតេយ្យ ទទួល បាន ជ័យជំនះទាំងអស់នៅថ្ងៃទី៧ មករា ហើយ បង្កើតរដ្ឋាភិបាលខ្មែរមួយ ដែល មាន លោក ហេង សំរិន ជានាយក និង លោក ប៉ែន សុវណ្ណ ជា ឧប នាយក ទទួលបន្ទុកកិច្ចការការពារជាតិ។ នៅឆ្នាំ១៩៨១ បក្សបដិវត្តន៍ប្រជាជនកម្ពុជា បានតែងតាំង លោក ប៉ែន សុវណ្ណ ជា លេខាធិការទី១បក្ស។ នៅថ្ងៃទី២៧ មិថុនា លោក បាន ត្រូវតែងតាំង ជា រដ្ឋមន្ត្រីទី១ នៃ សាធារណរដ្ឋប្រជា មានិតុកម្ពុជា ដែល ទើបតែ បានបង្កើតឡើង។ នៅថ្ងៃទី៤ ធ្នូ ឆ្នាំ១៩៨១ លោក ប៉ែន សុវណ្ណ ប្រកាសលាលែងពីគ្រប់ ដំណែង ហើយវិលត្រឡប់ទៅស្រុកយួនវិញ។ តាមផ្លូវការ រ ដ្ឋាភិបាលថ្មី ដឹកនាំ ដោយលោក ហេង សំរិន ប្រកាសថា លោក ប៉ែន សុវណ្ណ ត្រូវបានអនុញ្ញាតអោយទៅសំរាកកាយ នៅស្រុកយួន។ តែតាមប្រភព ក្រៅផ្លូវការវិញ គេដឹង ថា លោក ប៉ែន សុវណ្ណ ត្រូវយួនដកចេញពីដំណែង ដោយសារ គាត់ មិនព្រម ធ្វើតាម អនុសាសន៍យួន។ តាមប្រភពក្រៅ ផ្លូវការនោះទៀត បានអោយដឹងថា លោក ប៉ែន សុវណ្ណ

ត្រូវ យួនយក ទៅដាក់គុក អស់រយៈ ប្រាំពីរឆ្នាំ និង អស់រយៈ ៣ឆ្នាំទៀត នៅក្នុង ការឃុំឃាំង នៅក្នុងផ្ទះ នៅទីក្រុងហាណូយ។

នៅឆ្នាំ១៩៩២ យួនបានអនុញ្ញាតអោយលោក ប៉ែន សុវណ្ណ វិលត្រឡប់ មករស់នៅស្រុកខ្មែរវិញ នៅស្រុកស្លួលក្នុងខេត្តតាកែវ។នៅឆ្នាំ១៩៩៤ លោក ប៉ែន សុវណ្ណ ត្រូវតែងតាំងជាទីពឹក្សាបក្សប្រជាជនខ្មែរ (ឈ្មោះថ្មី នៃបក្សបដិវត្តន៍កម្ពុជា) នៅខេត្តតាកែវ។ នៅថ្ងៃទី២៦ មិថុនា លោក ប៉ែន សុវណ្ណ បាន បង្កើត គណបក្ស នយោបាយ មាន ឈ្មោះ ថា ‹គណបក្ស ដើម្បី គាំទ្រ ជាតិខ្មែរ› ចូលរួមបោះឆ្នោតសភា នៅឆ្នាំ១៩៩៨ តែមិនបានទទួលអាសនៈនៅក្នុងរដ្ឋសភា។ នៅឆ្នាំ២០០៣ លោក ប៉ែន សុវណ្ណបានបង្កើត គណបក្សថ្មីមួយ ជា មួយ ព្រះអង្គម្ចាស់ ចក្រពង្ស ឈ្មោះ ‹គណបក្សព្រលឹងខ្មែរ› ដើម្បី ចូលរួមបោះឆ្នោតសភា តែមិនបានទទួលអាសនៈដែរនៅក្នុងរដ្ឋសភា។ នៅឆ្នាំ២០០៧ លោក ម៉ែន សុវណ្ណ បានចូលធ្វើជាសមាជិក គណបក្សសិទ្ធិមនុស្ស ដឹកនាំដោយ លោក កឹម សុខា ហើយ ត្រូវបានតែងតាំងជា អនុប្រធានគណបក្ស។ នៅពេលបោះឆ្នោតសភា នៅ

ឆ្នាំ ២០១៣ នៅក្នុងជួរ គណបក្ស សង្គ្រោះជាតិ លោក ប៉ែន សុវណ្ណ បាន ជាប់ឆ្នោតជាតំណាងរាស្ត្រ នៅខេត្តកំពង់ស្ពឺ។ លោក បាន ទទួល អនិច្ចកម្ម នៅថ្ងៃទី២៩ តុលា ឆ្នាំ២០១៦ ក្នុងជន្មាវស្សា៨០ឆ្នាំ។

## សកម្មភាព លោក ប៉ែន សុវណ្ណ លើ ក្រឡាចត្រង្គយួន

យើង គ្មាន ការសង្ស័យ ទៅ លើ សុទ្ធចិត្ត នៃ ទឹកចិត្តស្នេហាជាតិរបស់លោក ប៉ែន សុវណ្ណ នោះឡើយ ព្រោះ វា ជា អារម្មណ៏ផ្ទាល់ របស់ គាត់ ក្នុងនាម គាត់ ជា កូនខ្មែរម្នាក់។ អ្វីដែល លោក ប៉ែន សុវណ្ណ ពោលអះអាង ដូចគាត់ធ្លាប់បាននិយាយថា ‹អ្វីក៏ដោយវាមានការពិតតែមួយ› ដូច្នេះ សច្ចៈភាព គឺខ្លួនគាត់ ជា អ្នកទទួល ខុសត្រូវ តែម្នាក់ឯង នៅចំពោះមុខ ប្រវត្តិសាស្ត្រជាតិ។ តែសច្ចៈភាព នេះ វាបើកចំហរ ជា សំនួរ អនេកប្បមាណ ព្រោះ វា ជា ប្រធានបទ នៃ ប្រវត្តិសាស្ត្រ នយោបាយ ហើយ ពេលវេលា នៃ នយោបាយ នៅស្រុកខ្មែរ វា មិនទាន់ ចប់សព្វគ្រប់នៅឡើយ នៅក្នុងជំពូក នៃ ក្រឡាចត្រង្គយួន នៅស្រុកខ្មែរ។

យើងដឹងថាលោក ប៉ែន សុវណ្ណ ជាផលនៃបក្សកុម្មុយនិស្ត យួនព្រោះលោកបានទទួលការអប់រំពីបក្សនេះ សំរាប់បំរើយុទ្ធសាស្ត្រនយោបាយមួយច្បាស់លាស់។ ដូច្នេះលោក ប៉ែន សុវណ្ណ ជាបឋម ជនកុម្មុយនិស្ត បន្ទាប់មកជា និរសាររបស់បក្សកុម្មុយនិស្តយួន និង ទី បញ្ចប់ ជា ភ្នាក់ងារប្រតិបត្តិ នៃ នយោបាយ បក្ស។ វត្ថុទាំងបី នេះឯង ដែល សាលានយោបាយ នៃ បក្សកុម្មុយនិស្តយួន គេ យក មកធ្វើ ជាគោលដៅ នៃ កម្មវិធីសិក្សា ដែល ត្រូវតែអោយបានសំរេចជាដាច់ខាត នៅក្នុង ក្របខណ្ឌ នៃ ការអប់រំ ដល់សិស្ស ជាសមាជិកបក្ស ដែល មាន សញ្ជាតិ ជា ខ្មែរ លាវ និង ជាតិពិទ្ធ ដ៏ទៃទៀត។ នៅក្នុងពុម្ភនេះឯង ដែលសង្ខារ ជីវិតភាពនយោបាយ ក៏ដូច ជីវិតភាព រស់នៅ របស់ លោក ប៉ែន សុវណ្ណ នៅ លើ ក្រឡាចត្រង្គយួន។

**គំនិត ជំទាស់នឹងយួន របស់ លោក ប៉ែន សុវណ្ណផុសចេញ បែបណា ហើយ នៅពេលណា ?**

តាម ការអះអាង របស់លោក ប៉ែន សុវណ្ណ គឺផុសចេញនៅឆ្នាំ១៩៧៩ ឆ្នាំដែលកងទ័ពយួន វាយ យក ស្រុកខ្មែរបាន។

ធាតុនៃទំនាស់គឺ ពាក់ព័ន្ធនឹងប្រយោជន៍ប្រឆាំងគ្នា រវាងយួននិងខ្មែរលើលក្ខន្តិកៈស្រុកខ្មែរនៅក្រោមការកាន់កាប់នៃកងទ័ពយួន។លោក ប៉ែន សុវណ្ណ ទាមទារ លក្ខន្តិកៈ នៃអធិបតេយ្យភាពពេញលេញ រីឯយួនវិញ គេ អនុវត្ត របបនៃការកាន់កាប់ទាំងអស់ទោះបីគេ បង្កើតរដ្ឋាភិបាលខ្មែរតែ គ្រាន់ សំរាប់ ធ្វើឡប់ឡែ ប៉ុណ្ណោះសោត។ សួរថា តើការអះអាងនោះ មាន ហេតុផល (logique) វា ដែរ ឬទេ នៅក្នុង បរិបទខ្មែរ និង យួន នៅពេលនោះ ?

បើការអះអាង របស់ លោក ប៉ែន សុវណ្ណ ជា រឿងពិត គឺ ជាការធ្វើ អត្តឃាតកម្ម ប៉ុណ្ណោះសោត ព្រោះនៅក្នុងបរិបទនៅពេលនោះ វា គ្មាន ហេតុផល អ្វី ដែល ត្រូវលោក ប៉ែន សុវណ្ណ ទាមទារ អធិបតេយ្យភាពខ្មែរ នោះឡើយ បើគាត់ជា អ្នកនយោបាយ មាន ការពិសោធន៍ ជា ពិសេស បានទទួល ការអប់រំច្បាស់លាស់ ពីបក្សកុម្មុយនិស្តយួន។ ចំពោះយួន វា ជា ឱកាសដ៏ល្អ កម្រមានណាស់ វាយយកស្រុកខ្មែរបានងាយស្រួលបែបនេះ ដូច្នេះ ជា ដាច់ខាត យួន ត្រូវរកគ្រប់ មធ្យោបាយ យ៉ាងណា ដើម្បី ត្រួតត្រាស្រុកខ្មែរ អោយបាន ដូច លោក ផាំ ហ្វាន់ដុង, អតីតរដ្ឋមន្ត្រី ទី១ យួន,

ពេលនោះបានថ្លែងថា ស្ថានការណ៍ នៅស្រុកខ្មែរគឺ មិនអាចវិលត្រលប់ថយក្រោយ បានវិញនោះឡើយ។ នៅក្នុងបរិបទបែបនេះ ការទាមទាររបស់លោក ប៉ែន សុវណ្ណ ជាទង្វើមិនស្របនឹងពេលវេលាសោះឡើយ ហើយ គឺជា ការធ្វើអត្តឃាតកម្មខ្លួនឯងនោះដែរ។ សួរទៀតថា ចុះបើលោក ប៉ែន សុវណ្ណ គាត់ហ៊ាន ធ្វើពលិកម្ម អនុបមា ហ៊ាន ប្រឆាំងយួន នៅពេលនោះ តើ វា អាចមានទង្វើនោះបានដែរឬទេ ? បើយក រយៈផ្លូវ នៃ សកម្មភាពមកពិនិត្យមើល យើងឃើញថា គាត់មាន ស្វាមីភក្តិនឹង ខ្សែបន្ទាត់ នយោបាយ នៃ បក្ស កុម្មុយនិស្តយួន ព្រោះវា ជា ឧបនិស្ស័យ របស់គាត់ តាំង ពី កុមារភាព មកម្លេះ៖ បើបក្ស អោយ មកធ្វើសកម្មភាព នៅស្រុកខ្មែរ គាត់មក បើ បក្ស អោយគាត់វិលត្រឡប់ ទៅស្រុកយួនវិញ គាត់ ឥតប្រកែក។ ស្វាមីភក្តិនោះ វា ក្លាយ ជា លក្ខណៈស្វ័យប្រវត្តិ របស់ជនកុម្មុយនិស្ត ចំពោះបក្ស ដែល វា មាន នៅក្នុងទឹកចិត្តរបស់លោក ប៉ែន សុវណ្ណ ព្រោះ គាត់ មាន ឱកាសច្រើនណាស់ ធ្វើ ជម្រើស រវាងប្រយោជន៏ខ្មែរ និង យួន តែ គាត់ តាំងពីឆ្នាំ១៩៥៤ មកតែងតែ ជ្រើសរើស ខាងយួនជានិច្ច ដូច្នេះ វាគ្មានហេតុ

ផលអ្វី ដែល គាត់ ដូរចិត្ត ប្រឆាំងនឹង យួនវិញ នៅឆ្នាំ ១៩៧៩ នោះឡើយ។ តែលោក ប៉ែន សុវណ្ណ អាចសង្កៀរចិត្ត នឹងយួន នាំអោយគាត់មាន សង្កោបៈ[63] (irritation) មិន អាច សង្កត់ចិត្តបាន លើ ប្រការយួន មិន ប្រគល់ការ ទទួល ខុសត្រូវគ្រប់គ្រាន់ អោយគាត់ត្រួតត្រា លើក្រុមខ្មែរ ក្រហម ដែល បានរត់ចូលជួរយួន។ សេចក្តីក្តៅក្រហាយក្នុង ចិត្តនេះឯង ជា ចំណុចខ្សោយរបស់ ប៉ែន សុវណ្ណ ជា មនុស្ស លោភ លុបលើ ប៉ែនសុវណ្ណ ជា យុទ្ធកៈបក្ស ព្រោះគាត់ វាយ តម្លៃ ស្មានខុស ថា ស្វាមីភក្តី សុចរិត បំផុត របស់ គាត់ ចំពោះ បក្សកុម្មុយនិស្តយួន គួរ តែ យួន ទុកចិត្តលើគាត់ ក្នុងកិច្ចការការ ត្រួតត្រាលើខ្មែរ។ ត្រូវដឹងថា កាលយួនប ញ្ជូនលោក ប៉ែន សុវណ្ណ មកធ្វើ បេសកកម្មនៅស្រុកខ្មែរ នៅអំឡុងឆ្នាំ ១៩៧០-៧៤ ពួកខ្មែរក្រហម មិនសូវរាប់អាន នឹង គាត់ សោះឡើយ ទំនាក់ទំនាក់ គឺ កំរិតត្រឹមការងារ តែ ប៉ុណ្ណោះសោត ព្រោះ គាត់ មានមារយាទ បញ្ញោ ជា និរ សាយួន ផង ជា ខ្មែរអ្នកតស៊ូ ហេតុនេះឯង បានជាគាត់

---

[63] សង្កោបៈ សេចក្តីក្តៅក្រហាយ ;។

គ្មាន ប្រជាប្រិយភាពទេ នៅ ក្នុង រណសិរ្សរួមជាតិ កម្ពុជា (F.U.N.K)។ ក្រោយ ពី កិច្ចព្រមព្រៀងសន្តិភាព ២៧ មករា ឆ្នាំ១៩៧៣ បក្សកុម្មុយនិស្តយួន បានដក និរសា ខ្លួន មួយចំនួន ចេញពីស្រុកខ្មែរ មាន យួនផង និង ខ្មែរយៀកមិញផង ក្នុងចំណោមនោះ មានលោក ប៉ែន សុវណ្ណ នោះដែរ ព្រោះ លោក ប៉ែន សុវណ្ណ យួនមិនដែល ប្រើ គាត់ នៅស្រុកខ្មែរ ជា ភ្នាក់ងារ ជ្រៀតចូល (agent infiltré) ទៅក្នុងអង្គការខ្មែរក្រហមនោះទេ គឺប្រើក្នុងឋានៈជានិរសាយួន ចេញមុខ ក្នុងលក្ខន្តិកៈ ជា អ្នកសហប្រតិបត្តិការ (coopérant) ក្នុង វិស័យបច្ចេកទេស ផ្នែកវិទ្យុដិវត្តន៍ ហើយខ្លួនគាត់ ក៏មិនដែល ខំប្រឹងប្រែង ធ្វើចិត្ត និង កាយ អោយ ក្លាយ ជាខ្មែរក្រហមនោះដែរ។

ប្រាំឆ្នាំក្រោយមកទៀត គឺនៅអំឡុងឆ្នាំ ១៩៧៨-៧៩ ទើបយួន បញ្ជូនលោក ប៉ែន សុវណ្ណ មកស្រុកខ្មែរ ម្តងទៀតជាមួយកងទ័ពយួន ដើម្បី វាយ រំលំរបបកម្ពុជាប្រជាធិបតេយ្យផង និង កាន់កាប់ស្រុកខ្មែរ ខាងកើតទន្លេមេកុងផង។ តែជ័យជំនះទាំងអស់យ៉ាងឆាប់រហ័សដោយមិនដឹងខ្លួន នៃ កងទ័ពយួន លើកងទ័ពខ្មែរក្រហម នាំ អោយយួន

កែ តម្រូវ យុទ្ធសាស្ត្រ អោយស្របនឹង ស្ថានការណ៍ថ្មី គឺប្រើ លោក ប៉ែន សុវណ្ណ ដែល ជា ខ្មែរយៀកមិញ ដែល ជា មនុស្សយួន ហើយ គេ ទុកចិត្ត ១០០% អោយរៀបចំ ស្ថាប័ន ខ្មែរ ជា សារពើថ័ក្រ សំរាប់ បំរើនយោបាយយួន។ ការ បញ្ចេញ លោក ប៉ែន សុវណ្ណ ជា តស្សរជនទី១នៅស្រុកខ្មែរ នាំ បង្កើត បញ្ហា ជា ច្រើនដល់យួន ទី១ គឺបញ្ហា ការរងការ រួបរួម ពីក្រុមអតីតខ្មែរក្រហម ដែលរត់ មកចូលយួន ព្រោះ លោក ប៉ែន សុវណ្ណ គាត់ គ្មានចរិត ជា អ្នកបង្រួប បង្រួមនោះឡើយ ទី២ គឺ បញ្ហា មុខមាត់ នៃ របបថ្មី ដែល យួន គេ បង្កើតនៅស្រុកខ្មែរ គឺ សាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រោះឈ្មោះ ប៉ែន សុវណ្ណ វា បន្លឺសម្លេង ជា យួនពេក ដ្បិត គាត់ ជាខ្មែរយៀកមិញ ក្នុងបញ្ហាទី៣ វាអាចនឹងអាច មាន ពិត លើ ទំនាស់ រវាងលោក ប៉ែន សុវណ្ណ ជាមួយនឹង យួន ដែលលោក ប៉ែន សុវណ្ណ គាត់អះអាងថាជាទំនាស់នៃ ប្រយោជន៍ខ្មែរ នឹងយួន។ ដើម្បី ដោះស្រាយ បញ្ហា ទាំងបី យ៉ាងនេះឯង ដែលយួន ដកលោក ប៉ែន សុវណ្ណ ចេញពី ដំណែង ហើយ អោយវិល ត្រឡប់ ទៅរស់នៅស្រុកយួនវិញ។ ប្រការ យក លោក ចាន់ ស៊ី ដែលជា អតីតខ្មែរយៀកមិ

ញដែរ មកជំនួសលោក ប៉ែន សុវណ្ណ តែតែងតាំងលោក ហ៊ុន សែន អតីតខ្មែរក្រហម ជារដ្ឋមន្ត្រីក្រសួងការបរទេស ជា ការស្ទង់ធាតុ (dosage) របស់យួន ដើម្បីរក សមតា នៃនយោបាយក្នុងប្រទេស និងក្រៅប្រទេស។ ទោះបីយ៉ាងណាក៏ដោយ យួនត្រូវតែដកលោក ប៉ែន សុវណ្ណ ពីគ្រប់ដំណែងនៅស្រុកខ្មែរ ព្រោះលោក ប៉ែន សុវណ្ណ យួនយកទៅអប់រំតាំងពីយុវភាព មិនមែន សំរាប់ បំរើ នយោបាយយួន នៅស្រុកខ្មែរនោះទេ គឺយួន គេ ហ្វឹកហ្វឺនគាត់ ក្នុងមុខងារ ជានិរសា នៃ បច្ចេកទេស សុទ្ធសាត ក្នុង ក្របខណ្ឌ បក្សកុម្មុយនិស្ត ឥណ្ឌូចិន។

យួនអោយលោក ប៉ែន សុវណ្ណ វិលត្រឡប់មកស្រុកខ្មែរវិញ នៅ ឆ្នាំ ១៩៨១ និង អនុញ្ញាត អោយធ្វើសកកម្មភាពនយោបាយមានកំរិត គឺនៅក្នុងក្របខណ្ឌជា និរសា នោះឯង។ ការបង្កើតគណបក្សក្តី ចូលរួមក្នុងគណបក្សក្តី គឺស្ថិតនៅក្នុង ការត្រួតពិនិត្យ របស់យួនផ្ទាល់តែម្តង សូម្បីលោក ហ៊ុន សែន ក៏ គ្មាន ឥទ្ធិពលអ្វីទៅលើលោក ប៉ែន សុវណ្ណ ដែរ ព្រោះ លោក ប៉ែន សុវណ្ណ ជា ជនឯករាជ្យ ពី

ប្រព័ន្ធនៅស្រុកខ្មែរ។ សួរថា ចុះហេតុអ្វីបាន ជា លោក ប៉ែន សុវណ្ណ ហ៊ាន និយាយ រិះគន់ យួន ?

នៅក្នុង ចំណុចនេះ វា គ្មាន អ្វីពិបាកនឹង យល់នោះឡើយ ព្រោះ បើយួន អនុញ្ញាតអោយគាត់ មករស់ នៅស្រុកខ្មែរ និង មានលទ្ធភាព អាចធ្វើ សកកម្មភាព នយោបាយ បានខ្លះ យួន ត្រូវអនុញ្ញាត អោយ គាត់ មាន សេរីភាព ធ្វើ ការរិះគន់ ដល់នយោបាយយួន នៅស្រុកខ្មែរ ព្រោះយួនគេ លែង ទុក ជា ល្បិចលាក់បាំងអ្វីទៀតនោះឡើយ ពីព្រោះគេ យល់ឃើញថា ការអនុវត្តចេញមុខ វាមានប្រសិទ្ធិភាពជាង ធ្វើលាក់មុខ នៅក្នុងបរិបទខ្មែរសព្វថ្ងៃ គឺអនុវត្តលទ្ធិប្រជាធិបតេយ្យ ជា សំដី តែប៉ុណ្ណោះ។ ដូច្នេះ វា ការរិះគន់ របស់ លោក ប៉ែន សុវណ្ណ វា គ្រាន់តែជាសំដី ក្នុងចំណោមសំដីរាប់ លានរបស់ខ្មែរ តែ វា គ្រាន់តែ ជា សំដីខកចិត្តតែប៉ុណ្ណោះ សោត ដូចគ្នានឹងខ្មែរយើង នៅកម្ពុជាក្រោមនោះដែរ។ រួម សេចក្តីមក ករណីរបស់លោក ប៉ែន សុវណ្ណ គឺជាសញ្ញា នៃ មហាជោគជ័យយួន កុម្មុយនិស្ត នៅស្រុកខ្មែរ នោះឯង ព្រោះ ថា ទោះបីមានខ្មែរ ស្អប់យួន ឬ ស្រឡាញ់យួន តែខ្មែរ ទាំងអស់គ្នា ត្រូវ តែ រស់នៅ ជា ដាច់ខាត នៅក្នុងក្រឡាច

ចត្រង្គយួន។ ប្រការនេះ ត្រូវសហគមនអន្តរជាតិ ទទួលស្គាល់ថា បើ ចង់ អោយ ឥណ្ឌូចិន មាន សន្តិភាព ត្រូវតែ យល់ ព្រម ប្រគល់ ស្រុកខ្មែរ និងលាវ អោយ ទៅ យួនត្រួតត្រា។

# ការរើសយក នៃ គំនិត បរាជ័យនិយម ?

*សេរីការ*



ឆ្នាំ ២០១៦

ការដែល គណបក្សសង្គ្រោះជាតិ ប្រកាស ថា បាតុកម្ម អហិង្សា ប្រឆាំង នឹង លោក ហ៊ុន សែន នៅពេលដែល គាត់ ទៅ ចូលរួម ប្រជុំ សមាគម នៃ ប្រជាជាតិ នៅ ដំបន់ អាស៊ី ភាគអគ្នេយ៍ (ASEAN) ធ្វើឡើង នៅ សហរដ្ឋអាមេរិក ក្នុង រដ្ឋ កាលីហ្វូកនី ក្នុង ខែ កុម្ភៈ ខាងមុខនេះ មិនមែន អ្នកគាំទ្រខ្លួនជា អ្នករៀបចំ នោះឡើយ។ ការប្រកាស បែប នេះ ជា ចម្លើយ នឹងប្រតិកម្មរបស់លោក ហ៊ុន សែន ថា បើ មាន បាតុកម្ម ប្រឆាំងគាត់ គាត់ សុំសិទ្ធិ ធ្វើ បាតុកម្ម ប្រឆាំងនឹងអ្នកដឹកនាំ គណបក្សប្រឆាំង នៅ ក្នុង ស្រុកវិញ។ ចម្លើយ នេះ វា ផ្ទុយគ្នា នឹង គោលវិធី ថ្មីសំរាប់ ឆ្នាំ ២០១៦ «មិនឆ្លើយ-មិនឈ្លោះ» របស់ គណបក្សសង្គ្រោះ ជាតិ រួចបាត់ ទៅហើយ។ យើង សង្កេតឃើញថា សម្ពាធ ម្លុឹង របស់ លោក ហ៊ុន សែន ទៅលើ គណបក្សប្រឆាំង វា មានសភាពកាន់តែ តឹងតែងឡើងៗ ; សួរ ថា តើ គណបក្សសង្គ្រោះ អាច មាន លទ្ធភាព ទប់ទល់បានដែរ ឬទេ ដោយអាចនៅតែ រក្សាគោលជំហរ ទ្រឹស្តី របស់ ខ្លួន ?

ការប្រកាស ធ្វើ ឡើង រឿយៗ ដើម្បី រកសុខ នេះ វា បង្ហាញ អោយ ឃើញ ថា អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ មាន ការលំបាក ជ្រើសរើស នូវ ការរើសយក (options) អ្វីមួយ ពិតប្រាកដ នៅ ចំពោះមុខ សម្ពាធ លោក ហ៊ុន សែន ហើយ នៅក្នុង ស្ថានភាពនេះ នាំ ៤ ពួក គាត់ ប្រកាន់ យក ដោយ អសម្បជញ្ញៈ នូវ ចរិក ថា ភាពអ្នកគិតតែ ប្រយោជន៍ខ្លួន (vénalité)។ អ្នកដឹកនាំ គណបក្សសង្គ្រោះ ជាតិ គួរយល់ឃើញ ផ្ទុយទៅវិញ ថា បាតុកម្ម អហិង្សា ទោះបី ចេញ ពីប្រភព ណាមួយ ក៏ដោយ គឺ វា ជា ការជួយ ជម្រុញ ដល់ ការកសាង លទ្ធិប្រជាធិបតេយ្យ ជា ពិសេស នៅ ក្នុង បរិបទ ខ្មែរ បច្ចុប្បន្ន។ បើ អ្នកដឹកនាំ គណបក្ស សង្គ្រោះ មិនទាំងហ៊ាន លើកទឹកចិត្ត បាតុករ អហិង្សា នៅ ក្រៅប្រទេស ដើម្បី សំដែង នូវវិស័យមតិ ជំទាស់នឹង នយោបាយរបស់ លោក ហ៊ុន សែន នោះផង ; សួរ ថា តើ រាល់ សុភា (ការប្រជុំមហាជន) របស់ គណបក្ស តាម ឃុំ ស្រុក ខេត្ត បច្ចុប្បន្ន ធ្វើឡើង ដើម្បី អ្វី ក្នុង ឋានៈ ជា គណ បក្សប្រឆាំង។ គ្រាន់តែ រៀបចំប្រព័ន្ធដឹកនាំ ដើម្បី ដឹកនាំ ជាតិ នៅពេល ឈ្នះឆ្នោត ២០១៨ ? ការរៀបចំ នេះ ត្រូវការ

មធ្យោបាយ ជា សម្ភារៈ ជា ធនធានមនុស្ស និង សេចក្ដីក្លាហានរួម ហើយ ការស្វែងរក សេចក្ដីក្លាហានរួម នេះឯង ជា គោលដៅ សំខាន់ នៃ ការប្រជុំ ព្រោះ វា ជា ការបំផុស មហាជន អោយ ក្រោកឡើង ដើម្បី ទាមទារ ដណ្ដើម សិទ្ធ អំណាច ប្រជាពលរដ្ឋ តាម សន្តិវិធី ដែល ខ្លួន ជា ម្ចាស់ អំណាច។ ក្នុងចំណោម សន្តិវិធី គឺ មាន បាតុកម្ម អហិង្សា ដែលជា ផិតវិញ្ញាត្តិ ស្របច្បាប់ (expression légitime) របស់ ប្រជាជនខ្មែរ ដែល កំពុង រងគ្រោះនឹង អំពើ អយុត្តិធម៌ គ្រប់បែបយ៉ាង។ តែបើអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ យល់ឃើញ ថា វា ជា គ្រោះថ្នាក់ ដល់ខ្លួន គួរតែ នាំគ្នា ដូរឈ្មោះ «សង្គ្រោះជាតិ» ជា «សង្គ្រោះបរិយាកាសបោះឆ្នោត» ទៅវិញ ទើប វា សមស្របនឹង សច្ចាធុដ្ឋាន របស់ខ្លួន គឺ «ដំណើរទៅរកការបោះឆ្នោត» ជា អនន្ត ; សួរ ថា តើ ដំណើរនេះ វា នឹងអាច មាន អនុរាគត (bonne arrivée) សំរាប់ ជាតិខ្មែរ ដែរ ឬទេ ?

# គុណូបការៈ និង ភក្តីភាព

សេរីការ



អ្នកដឹកនាំ តែងជួបប្រទះ ជានិច្ច នូវ ការត្រូវរើស (dilemme) សហការី (ការិនី) ល្អប្រសើរដើម្បីជួយ ផ្ញើ កិច្ចការ របស់ខ្លួន ឬ ទទួលខុសត្រូវ លើ វិស័យ ណាមួយ។ បញ្ហា ពិបាក ក្នុង ការជ្រើសរើស គឺ ត្រូវ សំរេច លើ លក្ខណៈ ពីរយ៉ាង៖ គុណូបការៈ ឬ ភក្តីភាព។ ក្នុង ជម្រើស នេះ បើ ជាការ ល្អ ត្រូវ មាន ទាំងពីរ លក្ខណៈ ព្រោះ ថា៖

គុណូបការៈ៖ មុខងារ (fonction) និមួយៗ វា មាន សមត្ថកិច្ច (compétence) នៃ មុខងារ និងសមត្ថភាព (capacité) របស់ អ្នក ដឹកនាំ ការងារ។ សមត្ថកិច្ច និង សមត្ថភាព នេះ ត្រូវ អ្នកទទួល មុខងារ មាន ចាំបាច់ នូវ គុណូបការៈ ដែលជា មូលដ្ឋាននៃ ការពិសោធន៍ និង គុណសម្បត្តិ របស់ បុគ្គល។ អ្នកដឹកនាំការងារ ប្រកប ដោយ គុណូបការៈ ត្រូវ មាន លក្ខន្តិកៈ ពីរយ៉ាង៖ ទទួល ការ តែងតាំង តាមច្បាប់ ឬ អ្នក មាន វិញ្ញាបនប័ត្រ (statut titulaire) និង លក្ខន្តិកៈ បុគ្គល ផ្ទាល់ ឬ គុណសម្បត្តិ របស់ ខ្លួនផ្ទាល់ (statut personnel)។ កត្តា ទាំងពីរនេះ ដែល នាំ

អោយ អ្នកដឹកនាំការងារ មាន ធម្មានុរូប ចំពោះ អ្នក ដ៏ទៃ និង អ្នកនៅក្រោមការដឹកនាំរបស់ខ្លួន ព្រោះ វា ជាតម្លៃ អត្តនោម័តិ (valeur subjective) សំរាប់ គេ យកមកធ្វើ ជា លក្ខណវិនិច្ឆ័យ លើ តម្លៃ ជា អ្នកដឹកនាំការងារ។ ដូច្នេះ ធម្មានុរូប មិន ត្រឹមតែមាន តម្លៃ នៃ ច្បាប់ឬវិញ្ញាបនប័ត្រ ដែល ជា អាការក្រៅ (aspect extérieur) របស់ មុខងារ; លើសពី តម្លៃ នេះ វា មាន តម្លៃ នៃ គុណូបការៈ ដែល ជា អាការក្នុង របស់ អ្នកកាន់ការងារ។ សហការី (ការិនី) ដ៏ប្រសើរ ក៏ ដូច អ្នកដឹកនាំ ខ្លួនឯងដែរ ត្រូវចាំបាច់ មាន គុណូបការៈ នេះឯង។

ភក្ដីភាព៖ ភក្ដីភាព ជា កត្តា បន្ថែម លើ កត្តា គុណូបការៈ ទើប វា អាច មាន ប្រយោជន៍ដល់ការងារ។ ភក្ដីភាព មាន ពីរ ថ្នាក់៖ ភក្ដីភាព នៅក្នុង ក្របខណ្ឌ ការងារ និង ភក្ដីភាព ទៅលើអ្នកដឹកនាំ ដែល ប្រគល់ ការទុកចិត្ត មកលើខ្លួន។ តែ ភក្ដីភាព ត្រូវ ឋិត នៅក្នុង ក្របខ័ណ្ឌច្បាប់ ជានិច្ច ពុំនោះ ភក្ដីភាព វា នឹងដូរ ធម្មជាតិ របស់ វា ពី គុណធម៌ ទៅជា អគុណធម៌។ ជាទូទៅ អ្នក ដែល មាន គុណូបការៈ តែងតែ មាន សម្មាភក្ដីភាព (loyauté juste) ព្រោះ វា

មាននៅក្នុង គុណសម្បត្តិ របស់ខ្លួន។ អ្នក ដែល គ្មាន គុណូបការៈ ភាគ ច្រើន ជា មនុស្ស ទុរជនប្រើ ភក្តីភាព ជា ឧបករណ៍ សំរាប់ តែ បំរើ អត្ថប្រយោជន៍ របស់ ខ្លួន។ អ្នកដឹកនាំ មាន សហការី (ការិនី) ច្រើន ជា មនុស្ស គ្មាន គុណូបការៈ ជ្រើសយកតែ មនុស្ស ដូចខ្លួន។ ការយក ញាតិឬមិត្តភក្តិ ធ្វើជា សហការី (ការិនី) មិនសុទ្ធ ជា អំពើ មិន ល្អនោះឡើយ បើ ជន នោះ មាន គុណូបការៈ សំរាប់ ដឹកនាំការងារ។ តែ បើ ការជ្រើសរើស ផ្អែក តែ ទៅលើ លក្ខណវិនិច្ឆ័យ នៃ ភក្តីភាព តែមួយគត់ វា ប្រហែលជា នាំមក នូវទុក្ខ ច្រើនជាង នូវ សេចក្តីសុខ ព្រោះ ភក្តីភាព គ្មាន គុណូបការៈ ជា អាវុធ មុខពីរ៕

# សោភ័នភាព នៃ ភាសា ខ្មែរ

*សេរីការ*



ភាសា ខ្មែរ មាន អាយុ ច្រើន សតវត្សមកហើយ ដើរតួ យ៉ាងសំខាន់ នៅក្នុង ការវិត្តន៍ នៃ អារ្យធម៌ប្រជាជាតិខ្មែរ , មាន ទុកស្នាម នៅ ក្នុង អក្សរសាស្ត្រជាតិ គ្រប់គ្រាន់ សំរាប់ បញ្ជាក់ នូវ អត្តភាព វិភូ របស់ ខ្លួន។ ជា ភាសា មាន ដុះដាល ដោយ មនោគតិ នាំ អោយមាន លទ្ធភាព អាច សំដែង នូវ អារម្មណ៍ ជា សំដី ក្តី ជា ការសរសេរ ក្តី បាន ងាយស្រួល។ ដោយ សម្បូណ៌ ពាក្យ វេវចនៈ ដែល អាចអោយ អ្នកនិពន្ធ យក ពាក្យនិមួយៗ មកប្រើ តាម ជម្រៅចិត្ត ដែល ខ្លួន មាន នៅក្នុងអារម្មណ៍ អន្តែតអណ្តូង ជា កវីនិពន្ធ។ ខ្មែរបូរាណយើង ទុក អ្នកនិពន្ធ ជា កវី ព្រោះ គាត់ទុក ការសរសេរ ជា វិចិត្រសិល្ប: ផ្សិត ជា ស្នាដៃ ពិសេសពិសាល របស់ វិញ្ញូ មាន សុជី, ជា គ្រូ នៃ ចំណេះចេះដឹង ផង និង ជា ជន ពិសម័យ ផង ប្រើ ភាសាជាតិ សំរាប់ កន្ត្រាក់ អារម្មណ៍ ធម្មតា របស់អ្នកស្តាប់ ឬ អ្នកអាន អោយមក ស្ថិតនៅ ក្នុង បរិយាការណ៍ ប្រកបដោយ សេចក្តីរំភើបចិត្ត។ គេដឹង ថាភាសា មិនមែន គ្រាន់តែ ជា ឧបករណ៍ សំរាប់ ធ្វើការ ទាក់ទងគ្នា ក្នុងជីវភាពរាល់ថ្ងៃ, សំរាប់ ធ្វើការអប់រំ នូវ សព្វ

មុខវិជ្ជា, សំរាប់ សំដែង អារម្មណ៍ គ្រប់បែបយ៉ាង តែ ប៉ុណ្ណោះឡើយ, វា គឺ ជា សារជាតិ នៃ ជាតិសាសន៍មួយ ក្នុង លក្ខណៈ ជា គ្រិះ នៃ ប្រជាជាតិ។

ការវិវត្តន៍ នៃ ភាសា ជា ដំណើរមួយ យ៉ាងយូរ ក្នុងពេល វេលា នៃ មនុស្សជាតិ។ នៅ ស្រុកខ្មែរ ឧទ្ទង្គត នៃ សម័យ មហានគរ គឺ ជា លទ្ធផល នូវ ការរីកចំរើន សព្វការចេះដឹង របស់ជាតិសាន៍ខ្មែរ ; មិនមែន គ្រាន់តែ ចេះធ្វើសង្គ្រាម, ចេះសង់ប្រាសាទ, ចេះធ្វើកសិកម្ម តែ លើស ពី ចំណេះ ទាំងឡាយនេះ ទៅទៀត គឺ ខ្មែរ មាន ភាសា ជា ថាមវន្ត សំ រាប់ ផ្សាយ គ្រប់ ចំណេះចេះដឹង ក្នុងសង្គម អោយមាន លក្ខណៈ ជា ចំណេះជាតិ និង សាកល ដែល អាច ខ្ចរខ្ចាយ ដល់ ជាតិសាសន៍ ដទៃទៀត ដែល រស់នៅក្រោម ឥទ្ធិពល របស់ ប្រជាជាតិខ្មែរ។ តែ ភាសា ខ្មែរ ក៏ទទួល ឥទ្ធិពល ច្រើនណាស់ដែរ ពី អារ្យធម៌ នៃ ជាតិសាសន៍ ដទៃ ដូចយ៉ាង អារ្យធម៌ ឥណ្ឌា ដែលជា អារ្យធម៌ ធំមួយ ក្នុងចំណោម អារ្យ ធម៌ នានា នៅក្នុង ពិភពលោក។ តែ ជាតិសាន៍ខ្មែរ មាន លទ្ធភាព នៃ បញ្ញា អាច កែច្នៃ អ្វី ដែល ខ្លួនបានទទួល អោយក្លាយ ជា របស់ជាតិ។ អាស្រ័យហេតុនេះ បាន ជា

ភាសាខ្មែរ សម្បូណ៌ ពាក្យ សំរាប់ បញ្ចេញគំនិត ឬ សំដែងមនោសញ្ចេតនា ដោយ វាចា នៅក្នុងកំរិតខ្ពស់ ពិរោះស្តាប់។ ដូច្នេះ ខ្មែរយើង កុំនាំគ្នា ទុកភាសាខ្លួន ដែល មានប្រភពចេញពី ភាសាបាលី និង ភាសាសំស្ក្រឹត ជា ការពិបាក ឬ ជា ភាសាបរទេស យកមកប្រើ តែត្រូវយល់ថាភាសាទាំងនោះ វាក្លាយ ជា ភាសាជាតិ សុទ្ធសាតទៅហើយព្រោះ អ្នកប្រាជ្ញបូរាណខ្មែរ គាត់យកវាមកធ្វើ ខេមរូបនីយកម្ម រួចស្រេច ហើយ យកវាមក ប្រើអស់ច្រើនសតវត្សនៅក្នុង អក្សរសាស្រ្តខ្មែរ។ពាក្យខ្មែរ មាន ពោរពា សំរាប់ប្រើក្នុង រាជវង្សានុវង្ស, ក្នុង សហធម្មិក, ក្នុង អក្សរសាស្រ្ត, ក្នុងសំដីផម្ចតា និង ក្នុង សំដី អសុរោះ ហើយ ពាក្យទាំងអស់នេះឯង វា ផ្សំជា ភាសាជាតិ ដែលខ្មែរ ត្រូវតែរក្សា សំរាប់ខ្មែរ ជំនាន់ក្រោយ។ ទោះបី មាន វណ្ណះ នៅក្នុង ការប្រើពាក្យ តែ ពាក្យទាំងនោះ គឺ វិញ្ញូបូរាណខ្មែរ ជា អ្នកបង្កើតសំរាប់ ញែក ពាក្យ អោយមាន ភាពល្អិតល្អន់ ក្នុងការប្រើភាសា, ដូច្នេះបើ ចេះ យល់ ពាក្យ មួយណាហើយ ទោះ បីពាក្យ នោះ មាន ធាតុ ជា វណ្ណះពាក្យ គួរ កុំបោះបង់វាចោល ព្រោះថា ពាក្យ វា គ្មានកំហុស អ្វីនោះទេ គឺ អ្នកយក

វា មកប្រើទេ ដែល ជា អ្នកទទួល ខុសត្រូវ ក្នុងការប្រើពាក្យ។

ខ្មែរយើង មាន វចនានុក្រម របស់ សម្តេច ព្រះស័ង្ឃរាជ គណៈមហានិកាយ ជួន ណាត ជោតញ្ញាណោ សំរាប់ ពន្យល់ពាក្យ និង វចនានុក្រម ដទៃទៀត ជាច្រើន សំរាប់ បកប្រែភាសាពីខ្មែរ ដែល សំរួល ដល់ ការសរសេរ, អាន និងស្រាវជ្រាវ សំរាប់ផ្សាយ ចំណេះ ដល់ ខ្មែរយើង ដែល មិនចេះអាន ភាសាបរទេស។ មួយវិញទៀត ភាសាខ្មែរ មានលក្ខណៈ ជា ជិពភាសា មាន លទ្ធភាព អាច សម្របនឹង ពាក្យសម័យ និង វិទ្យាស្សង្ស សាកល បានងាយស្រួល។ ជិពភាសានេះទៀត ដែលជា គុណសម្បត្តិ នៃ ភាសាខ្មែរ អាច សរសេរជា កំណាព្យ ឬ ប្រលោមលោក ក្នុងដំណើរពាក្យ មាន វិភាពនិង បញ្ញាភា ព្រោះ ភាសាខ្មែរ មាន សារជាតិ ជា ភាសា នៃអក្សរសាស្ត្រ ដែលជាវិចិត្រសិល្បៈ ដូចគ្នានិង រូបចម្លាក់មួយផ្លាក់ថ្ម, មួយទៀត រៀបពាក្យ សំដី ក្នុងគោលបំណងតែមួយ គឺ រកសោភ័នភាព នៃ ស្នាដៃ។

អ្នកចេះដឹងខ្មែរ គួរតែ អាន និង សរសេរ ជាភាសាខ្មែរ អោយបានច្រើន ទើបស្គាល់ តម្លៃ នៃភាសាជាតិ ដែលជាភាសា មាន សម្លេង ពិរោះ និង មាន ពាក្យ ដែល គននានូវ គំនិតពិសាល ដូចភាសា នៃ ប្រជាជាតិធំៗ ដែលមានអារ្យធម៌ខ្ពង់ខ្ពស់ នៅក្នុង ពិភពលោកនេះ។ គួរខ្មែរយើងទម្លាប់យក ពាក្យករី មកប្រើ តែ នៅតែ រក្សា ពាក្យរាយ សំរាប់និយាយ ក្នុង បរិបទ របស់វា នៅក្នុង មនោសាស្ត្រ រក្សាភាសាជាតិ, អម្បាលយ៉ាង ការប្រើ ពាក្យ អាសុរោះ ក៍មិនមែន សុទ្ធតែ ជា មនុស្សលាមក បើអ្នកប្រើ យកវា មកប្រើដើម្បី បង្ហាញ ចរិត របស់ មហាត ប្រព្រឹត្តិ តែ អំពើ ទុច្ចរិតបំផ្លាញ សង្គមជាតិ។ អ្វី ដែល ជា គ្រោះថ្នាក់ ដល់ វប្បធម៌ខ្មែរ គឺ បើសិនជា អ្នកចេះដឹងខ្មែរ នាំគ្នា មានគំនិតមើលងាយ ភាសាជាតិ ខ្លួនឯង ហើយ យក ភាសាបរទេសជា យីហោ នៃ ការចេះដឹង របស់ខ្លួន។ តែ ក៍គ្មាន នរណា គេហាមឃាត់ មិនអោយ ខ្មែរយើង ខំរៀន ជា ជម្រៅ នៃភាសាបរទេសនោះដែរ គឺ មាន តែ ការលើកទឹកចិត្ត ព្រោះភាសា និមួយៗ ជា សម្បត្តិរួម នៃ បញ្ញា នៃមនុស្សជាតិគ្មាន សីមា ; តែបើ ចេះជ្រៅជ្រះ ភាសា បរទេស តែទុក

ភាសាជាតិខ្លួនឯង ជា ចំណេះបន្ទាប់បន្សំ, រឿងនេះ នឹង ចោទ ជា បញ្ហា នៃ ស្មារតីជាតិ តែ ក៏មិនទុក ជា ឧក្រិដ្ឋកម្ម អ្វីនោះដែរព្រោះ បុគ្គលម្នាក់ៗ ជាម្ចាស់ នៃ ការចេះដឹង របស់ខ្លួន និង ជា សេរីជន, ប៉ុន្តែ ពលរដ្ឋម្នាក់ៗ ជាម្ចាស់ ផង និង ជា អ្នកការពារផង នៃ កេតនភ័ណ្ឌ នៃបញ្ញាជាតិ បីដូច ភាសាជាតិ ក្នុងចំណោម កេតនភ័ណ្ឌ ដទៃទៀត។ ការការពារ ប្រកបដោយ ប្រសិទ្ធិភាព គឺ ការចេះដឹង អោយបាន ជ្រៅជ្រះ នៃ ភាសាជាតិខ្លួនឯងសិន ទើប អាច មើល ឃើញ នូវ ទីកន្លែងកិត្តិយស នៃ ភាសាខ្មែរ នៅក្នុង ចំណោម ភាសាបរទេសនានា។ ទោះបី ភាសាខ្មែរ សំរាប់ ប្រើតែ នៅ ក្នុងស្រុកខ្មែរ និង និគមជនខ្មែរ នៅបរទេស តែ ជា ភាសាជាតិ សំរាប់សំគាល់ ជាតិសាសន៍ និង ប្រជាជាតិ មួយ ហើយជា មូលដ្ឋាននៃ មោទនភាពខ្មែរ ដែលខ្មែរគ្រប់ជំនាន់ ខំបីបាច់ថែរក្សា ទោះបី ជាតិខ្លួន បាន ជួបប្រទះនូវគ្រប់ សេចក្តីវិនាសធំៗ នៅក្នុង ប្រវត្តិសាស្ត្រ ជាតិ។ ទង្វើនេះហើយ ជា ការតស៊ូ អង់អាច នៃ ជាតិ សាសន៍ខ្មែរ នៅចំពោះមុខ ការគំរាម គ្រប់បែបយ៉ាង ពី សំណាក់ បរទេស ដើម្បី បំផ្លាញ ឬ បន្សាបរាប់ម៉ឺនឆ្នាំ វប្បធ

ម៍ជាតិខ្មែរ។ ម្យ៉ាងមួយទៀត សោភ័នភាព នៃ ភាសាខ្មែរ វា ជា កំពែង ធម្មជាតិ មួយដ៏សំខាន់ សំរាប់ ការពារខ្លួន ដោយខ្លួនឯង ព្រោះ ភាសាខ្មែរ ជា ព្រលឹងនៃ ជាតិខ្មែរ។ សួរថា តើទៅអានាគត តើ ភាសាខ្មែរ នៅតែមាន ថាមពល អាច ការពារខ្លួន បានដែរឬទេ នៅក្នុង នយោបាយ សិក្សាធិការជាតិ បច្ចុប្បន្ន ដឹកនាំ ដោយ បរទេស ? សព្វថ្ងៃនេះ អ្នកដឹកនាំជាតិ, រស់នៅក្នុង ប្រព័ន្ធ នយោបាយ គ្មានការទទួលខុសត្រូវ ដល់អានាគតជាតិ, ពួកគាត់ និយាយភាសាខ្មែរពិត តែនៅក្នុង គំនិតបរទេស ព្រោះ រាល់ទង្វើ របស់ ពួកគាត់ គឺ ជា ពន្លឺឆ្លុះ នូវ គំនិត បរទេស ទាំងអស់ជាពិសេសគំនិត យួនកុម្មុយនិស្ត គឺ អប់រំផ្សាំង ពួកគាត់ កុំអោយ លើកតម្កើង តម្លៃជាតិ ហើយមោន កតញ្ញូតា ដល់ យៀកណាម ដោយយក ថ្ងៃ ទី ៧ មករា ជា ខួប រំលឹក កតវេទិតា ដូចត្រូវដឹងគុណ មាតា បិតា។ រួមសេចក្ដីមក គឺថា បើគ្រាន់តែចេះនិយាយ ភាសា ខ្មែរ តែគ្មាន ស្មារតីជាខ្មែរ ក៍មិន អាចទុក ជា ជាតិសាសន៍ ខ្មែរ បាននោះឡើយ ព្រោះ ភាសាខ្មែរ វា ជា ចិត្តគំនិត នៃ ប្រជាជាតិខ្មែរ ដូចបាន ជំរាប ខាងលើ ថាភាសាជាតិ ជា

ព្រលឹងជាតិ ហើយ ព្រលឹងជាតិ នេះឯង ជាខ្លឹមសារ នៃ សោភ័នភាព ឥតស្រពោន នៃ ភាសាខ្មែរ ដែលជា គ្រិះ នៃ ប្រជាជាតិ ខេមរា ជា សហស្សវត្ស៕

## គ្រាណា យុត្តិធម៌ ក្លាយជា រំពាត់ របស់ អំណាច...

*សេរីការ*



នៅពេល ដែល យុត្តិធម៌ ក្លាយជា រំពាត់ របស់ អំណាច តើ ប្រជាធិបតី ក្លាយជាអ្វី ? អស់ច្រើន ទស្សវត្សរ៍ មកហើយ ខ្មែរយើង តែងតែ សួរសំណួរហ្នឹង ហើយ ឆ្លើយឥតខុស ថា ក្នុង ករណី បែបនេះ គឺ អំណាចផ្តាច់ការ។ ហើយ អំណាច នេះ ប្រើមធ្យោបាយ តុលាការ ដើម្បី កំទិច កម្លាំងប្រឆាំង គ្រប់រូបភាព ក្នុង គោលបំណង បំភ័យប្រជាពលរដ្ឋ អោយ ខ្លបខ្លាចខ្លួន។ ទង្វើនេះ វា មាន ជោគជ័យ ដូចបំណង ខ្លួន ព្រោះប្រជាពលរដ្ឋក្តី អ្នកប្រឆាំងក្តី ខ្លប នៅចំពោះ មុខ រំពាត់យុត្តិធម៌ របស់ អំណាចផ្តាច់ការ, ដូច្នេះ ហេតុអ្វី ក៏មិន អនុវត្ត នូវ គោលវិធី បែបនេះ បន្តទៅទៀត។ ការ បន្តនេះ គឺ នៅក្នុង បច្ច័យភាព (logique) តែមួយគត់ គឺ ខ្លួន តែងតែ ទទួលជោគជ័យ ជានិច្ច ព្រោះគ្មាន កម្លាំង ណាមួយ ជា ជីវពលក្តី ជា នយោបាយក្តី អាចទប់ទល់ ឬ ទូរ នឹង ខ្លួនបានសោះឡើយះ

- កម្លាំងជីវពល គឺមហាជន, សព្វថ្ងៃ កម្លាំងនេះគ្មាន វត្តមាននៅក្នុង ជីវិភាពនយោបាយខ្មែរ ព្រោះ មានតួនាទី

ត្រឹមតែ ជា អ្នកបោះឆ្នោត នៅក្នុង របបនយោបាយ ដែល គេហៅ ថា « ពិធីប្រជាធិបតេយ្យ » (démocrature) គឺ ជា របប សិទ្ធិអំណាច យកការបោះឆ្នោត នៅក្រោម ការ ត្រួតត្រា របស់ខ្លួន មកធ្វើ ជា ពិធី ជា សញ្ញាល័ក្ខ នៃ ប្រជាធិបតី គ្មាន និតិរដ្ឋ។ មហាជនខ្មែរ សព្វថ្ងៃ រស់នៅ ក្នុង លក្ខណៈ ជា រាស្ត្រទាស (peuple d’esclaves) របស់ អ្នកកាន់ អំណាច ដែលជា ម្ចាស់ជីវិតលើត្បូង អាចសម្លុត រាស្ត្រ ដូច កំញើញ កូនក្មេង, អាច ពិឃាត មនុស្ស ដូចសម្លាប់ សត្វ, ទុក រាស្ត្រទាស ជា ហ្វូងម្រឹគ កៀងបញ្ចូល ទៅក្នុង ក្រោល ឃួនកុម្មុយនិស្ត ព្រោះ តែ ប្រជារាស្ត្រខ្លាច រំពាត់ សំរាប់ វាយ ខ្លួន ជា ទណ្ឌកម្ម ដើម្បី រក្សា សន្តិភាព គ្មាន យុត្តិធម៌ គ្មាន សីលធម៌ គ្មាន អធិបតេយ្យភាពជាតិ។ មូលហេតុ នៃ រឿង នេះ គឺ មក ពី រាស្ត្រខ្មែរ ត្រូវបាន អ្នកដឹកនាំជាតិ តាំងពី ព្រេងនាយមក គេ ផ្សាំង អោយខ្លាចអំណាច គឺ ឃើញ រំពាត់នាំគ្នា អង្គុយ កន្ទ្រាន ជា ទម្លាប់ គិត តែ សំពិន (supplier) យំអង្វរ ស្រកោក (en vain) រក មេត្តាធម៌ ពី អ្នកពាលា លើ សិទ្ធិខ្លួន, ទុក ទឹកភ្នែក ជា សក្ការ ថ្វាយព្រះ សូម អោយ មេត្តាជួយ មនុស្ស ប្រតិបត្តិធម៌, សូមអោយ

អ្នកមានអំណាច អាស្វូរកាយ ដល់ អ្នកបាត់ជម្រក, សូម អោយ ចោរ អាណិតចិត្ត ដល់ អ្នកមានអប្បទ្រព្យ។ ព្យាយាម ទាំងសណ្ដាប លើកស្ទួយ មន្ទានុភាព (pouvoir magique) ហើយ នាំគ្នា បោះបង់ មនោមយិទ្ធ (pouvoir de la volonté) ជា ពលរដ្ឋ ជា ខ្មែរ អ្នកជា ជា ម្ចាស់ស្រុក ធ្លាប់ ការពារជាតិ ក្នុងឋានៈ ជា ជីវពលខ្មែរ។

- កម្លាំងនយោបាយ គឺ គ្រហែត ព្រោះ គ្រប់ គណបក្ស ប្រឆាំង នាំគ្នា សម្ងំរស់ ក្នុង របបពិធីប្រជាធិបតេយ្យ ទុក ការបោះឆ្នោតបង្គ្រប់កិច្ច ជា បាដិហារិយ៍ (miracle) ដែល អាចនឹងមាន ការផ្លាស់ប្ដូរ អ្នកដឹកនាំ តាមក្បួត នៃ ប្រជាធិបតី ដូច មាន នៅប្រទេសភូមា។ចក្ខុវិស័យនេះ គឺ ពិត ជា យុត្តៈនយោបាយ (politiquement correct) តែ វា មិន ស្របនឹង បរិបទខ្មែរ ព្រោះ នៅ កម្ពុជា មាន យួនកុម្មុយនិស្ត ជា ថៅហ្វាយ នៃ ជីវភាពនយោបាយខ្មែរ។ ដូច្នេះ ការ ផ្លាស់ប្ដូរ អ្នកដឹកនាំ វានាំអោយមាន ការសើរើ នូវអ្វី ដែល គេ បានចំណេញរួចហើយ។ ត្រូវដឹងថា យួនកុម្មុយនិស្ត មិន អោយកម្ពុជា រួចចេញពី កណ្ដាប់ដៃគេ ជាដាច់ខាត បើ គ្មាន កម្លាំង ជាតិខ្មែរ ណាមួយ អាច រំដោះ ប្រជាជាតិខ្មែរ

បាន, ហើយ កុំនាំគ្នា ស្រម័យ ថា យៀកណាម បោះបង់ ហ៊ុន សែន ដែល ជា សុភរជន (homme docile) របស់គេ មក ជ្រើសរើសយក សម រង្ស៊ី អោយសោះ ព្រោះ លោក សម រង្ស៊ី ទោះបី គាត់ តែងតែ មាន និន្នាការ ចង់ជានា ដល់ យៀកណាម ថាគាត់ អាច បន្ត នយោបាយ គាំទ្រយួន យ៉ាងណាក៏ដោយ ក៏យួន គេ មើលឃើញថាគាត់ជា មនុស្ស គ្មាន សេចក្តីម៉ឺងម៉ាត់ សំរាប់ បំរើ នយោបាយ យួនបាន។ នយោបាយយួន គឺ យួនទុក កម្ពុជា ជា ដែនដី យុទ្ធសាស្ត្រ សំរាប់ រក្សា ស្ថិរភាព គណបក្សកុម្មុយនិស្តយួន និង ជា ដែនដី សេដ្ឋកិច្ច ឬ ជីវទីកដី (espace vitale) សំរាប់ ចិញ្ចឹម ប្រជាពលរដ្ឋយួន ដែល មាន ចំនួនកាន់តែ កើនច្រើនឡើងៗ។ ត្រួតត្រា លើ កម្ពុជា ជានិមិត្តរូប នៃ វិជយ: (grande victoire) នៃ បណ្តាំ ខ្មោច លោក ហូ ជី មិុញ ដែល អ្នកដឹងនាំយួន បច្ចុប្បន្ន គេទុក ជា មោទនភាព នៃ ប្រជាជាតិយួន។

ទុព្វលភាពខ្មែរ ដែលបាន រៀបរាប់ ខាងលើនេះឯង ដែល អ្នកកាន់អំណាច គេ ខំ ថែ រក្សា ដោយប្រើ រំពាត់គ្រប់មុខ ទៅ តាម កាលៈទេសៈ ដូចយ៉ាង រំពាត់ គ្រាប់កាំភ្លើង, ការ

ដាក់កំហិត គ្រប់បែបយ៉ាង, យុត្តិធម៌។ ហើយ រំពាត់ យុត្តិធម៌ នេះឯង ដែល ពួកកុម្មុយនិស្ត ឬ ពួកដឹកនាំ នៅ ក្នុង របប ពិធីប្រជាធិបតេយ្យ គេ យក មក ប្រើ ដើម្បី ទប់ទល់ នឹង ការរិះគន់ ពី សំណាក់ សហគមអន្តរជាតិ និង អង្គការ ការពារ សិទ្ធិមនុស្សដោយ សំអាង លើ អធិបតេយ្យភាពជាតិ និមួយៗ។ ហើយ នៅពេលណា ដែល យុត្តិធម៌ ក្លាយ ជា រំពាត់ គឺ ថា នៅក្នុង ប្រទេសនោះ គឺ ច្បាស់ជា មាន អ្នកផ្តាច់ការ ឬ របបកុម្មុយនិស្ត ជា អ្នកដឹកនាំជាតិ ជា ពុំខាន ព្រោះ ប្រព័ន្ធ យុត្តិធម៌ តាម គោលការណ៍ ជាស្ថាប័នឯករាជ្យ ជា អំណាចជាតិ ក្នុង ចំណោម អំណាច ពីរទៀត ដូចជា អំណាច នីតិបញ្ញត្តិ និង នីតិប្រតិបត្តិ ; បើ ជា អំណាចជាតិ គឺ ជា អំណាច ប្រជាពលរដ្ឋ ដូច្នេះយុត្តិធម៌ មិន អាច ក្លាយ ជា រំពាត់ របស់ អ្នកដឹកនាំ បាននោះឡើយ។

ដូច្នេះ កុំនាំគ្នា ស្រងើ (étonné) បើ មើលឃើញថា នៅ ស្រុកខ្មែរ មាន រំពាត់ យុត្តិធម៌ព្រោះ រំពាត់នេះ ជា រំពាត់ របស់ យួនកុម្មុយនិស្ត ដែល ជា អ្នកត្រួតត្រា នៅស្រុកខ្មែរព្រោះ ស្រុកខ្មែរ ជា នគរសមន្តរាជ (Etat vassal) របស់ យៀកណាមកុម្មុយនិស្ត តាំង ពី ឆ្នាំ ១៩៧៩ មកម្លេះ។ បើខ្មែរ នៅតែ

មិនយក កត្តា នេះ ទុកជា បញ្ហា ចម្បងហើយ សំខាន់ របស់ ប្រជាជាតិខ្លួន គឺ ថា គ្រប់ ដំណោះស្រាយ ដែល គ្រប់ គណបក្សប្រឆាំង ស្វែងរក ជា មួយ គណបក្ស កាន់អំណាច ដែល ជា គណបក្ស ជាប់ ឃ្នាង យួនកុម្មុយនិស្ត គឺ គ្រាន់តែ ជា មាយាការ (សេចក្តីភាន់ច្រឡំ) យក មក ធ្វើ ជា សេចក្តីពិតតែ ប៉ុណ្ណោះ ដើម្បី បំភាន់ ប្រជាពលរដ្ឋ ដែល កំពុង នាំគ្នា អង្គុយ កន្ត្រោន ជា ទម្លាប់ចំពោះមុខ រំពាត់ របស់ អ្នកកាន់អំណាច នោះឯង។ ការពិតនេះហើយ បើ ខ្មែរយើង លើកវា មក និយាយ វា ហាក់បី ដូចជា ស្ដោះ លើ ទ្រូង ខ្លួនឯង តែ បើ ខ្មែរយើង ចេះតែនាំគ្នាដើរតួ ជា ជនរងគ្រោះ ហើយ ចេះ តែនាំគ្នា ថា យួន/សៀម ឬ អ្នកដទៃ ជា មូលហេតុ នៃ ភ័ព្វអាក្រក់ របស់ខ្លួន ដោយ មិនបាន សម្ដីគិត អំពី ចំណុចខ្សោយ របស់ខ្លួន គឺ ខ្មែរយើង នៅតែ រស់នៅ ក្នុង ស្មារតី ជា ជនជាតិ ទន់ខ្សោយ ជានិច្ច នៅក្នុង ពិភពលោក សព្វថ្ងៃ ដែល ប្រទេសនិមួយៗ គេ ផ្អែក ទាំងស្រុក ទៅលើ គុណសម្បត្តិ នៃប្រជាពលរដ្ឋគេ ដើម្បីធ្វើ ការអភិវឌ្ឍន៍ ប្រជាជាតិ គេ។ ដូច្នេះ រំពាត់អំណាច វា មានន័យ ជា អំណាចផ្តាច់ការ ផង ជា ចាតប័ត្រ (résignation) របស់

ខ្មែរយើងផងដែរ។សមាយោគ នៃ កត្តា ទាំងពីរ នេះឯង ដែល នាំអោយ ប្រជាជាតិខ្មែរ រស់ នៅក្នុង សភាព ជា ប្រជាជាតិ ទន់ខ្សោយ ចំពោះមុខ ប្រទេស ជិនខាងផង ក្នុងដំបន់ផងនិង នៅក្នុង ពិភពលោកផង។ បើខ្មែរយើង នៅតែនាំគ្នា ខ្លាចរំពាត់ គឺច្បាស់ ជា រំពាត់នេះវា មាន ឬទ្ធានុភាព កាន់តែខ្លាំងឡើងៗ ហើយ លទ្ធផល ជាទី បញ្ចប់គឺ ស្រុកខ្មែរ នឹងក្លាយ ជា កម្ពុជាក្រោម យ៉ាងងាយ ស្រួល ជា ទីបំផុត ដែល ជា ជោគជ័យ ជាស្ថាពរ របស់ យៀកណាម។ ហើយ សព្វថ្ងៃនេះ គឺ ប៊ិះ នឹងក្លាយ រួចបាត់ទៅ ហើយ៕

# កំនួច នៃ បញ្ហាខ្មែរ ចង ដោយ យួនកុម្មុយនិស្ត

សេរីការ



យើងឃើញថា សព្វថ្ងៃនេះ ពួកអ្នកដឹកនាំ មាន ប្រសាទកុប្បនា (nervosité) ខ្លាំងណាស់ ហើយ បាន ប្រព្រឹត្តិ អំពើបំពាន ច្បាប់ គ្រប់បែបយ៉ាង លែងមាន ដែនកំរិតលែងញញើត អង្គការ សហប្រជាជាតិ, សហាគមអន្តរជាតិ។ សួរថា មកពីហេតុអ្វី ?

អ្នកវិភាគនយោបាយខ្លះ យល់ឃើញ ថា ជា វិធានការ បំរុងទុក សំរាប់ សម្លុតគណបក្សប្រឆាំង និង អង្គការសង្គមស៊ីវិល នៅពេលបោះឆ្នោត ខាងមុខនេះ ; អ្នកខ្លះទៀត យល់ឃើញថា ជាទម្លាប់ធម្មតា ពីយូរយារ មកហើយ របស់ រដ្ឋាភិបាល លោកហ៊ុន សែន ; អ្នកខ្លះទៀត ទុកជា តម្រុយ ប្រាប់ដល់ ប្រជាពលរដ្ឋ ថា គ្មាន ការប្តូរអ្នកដឹកនាំ ជា ដាច់ខាត ; អ្នកខ្លះទៀត ចោទដល់ សហគមន៍ អន្តរជាតិ ថា បោះបង់ចោលប្រជាពលរដ្ឋខ្មែរ ទៅក្នុងជ្រោះទុក្ខ ក្នុងនាម នយោបាយប្រាកដនិយម (realpolitik) ;អ្នកខ្លះ មើលឃើញ ភាពកំសោយ របស់គណបក្សប្រឆាំង ; អ្នកខ្លះ ថា មកពីខ្មែរខ្សោយមិនអាចបង្កើត កម្លាំងជាតិបាន

ដើម្បី ការពារ លទ្ធិប្រជាធិបតេយ្យ និង ប្រជាជាតិខ្លួន។ អនេកប្បមាណ នៃ វិស័យមតិ ទាំងឡាយនោះ សុទ្ធតែមាន ខ្លឹមសារ ត្រឹមត្រូវ របស់វា តែ កត្តា មួយថ្មី ដែល ខ្មែរយើង ត្រូវពិចារណា ថែមទៀត គឺ ការប្តូរ អ្នកដឹងនាំ នៅប្រទេស យៀកណាម មាន នយោបាយ រូតរះ ដើម្បី ក្តាប់ទាំងអស់ នូវ ការដឹងនាំ នៅស្រុកខ្មែរ មុនការបោះឆ្នោត ខាងមុខ ព្រោះ អ្នកដឹងនាំ យួនកុម្មុយនិស្ត មិនចង់ អោយមាន កើត ព្រឹត្តិការណ៍ ម្តងទៀត ដូចនៅឆ្នាំ ២០១៣/១៤។ សព្វ ថ្ងៃនេះ អ្នកដឹងនាំ យួនកុម្មុយនិស្តគេមាន ធនធាន មនុស្ស គ្រប់គ្រាន់ គ្រប់ វិស័យ សំរាប់ ក្តាប់ ស្រុកខ្មែរ។ ដំណាក់ការត្រួតត្រា ស្រុកខ្មែរ មិនចំពោះ ដោយ យក ខ្មែរ រណប ដើរតួ ជា អ្នកដឹកនាំខ្មែរ បាន ដល់ ត្រើយ រួចហើយ ដូច្នេះ ត្រូវ ចាំបាច់ ចាប់ផ្តើម ត្រួតត្រា ដោយចំពោះដោយ ប្រើខ្មែរមានកំណើត ជាយួន អោយ ក្តាប់អំណាច ទាំងអស់ ហើយ ទុក អ្នកដឹកនាំខ្មែររណប ជា អ្នកប្រថាប់ត្រា។ ត្រូវ ដឹងថា គោលវិធីនេះ យួន គេធ្លាប់ធ្វើ នៅ កម្ពុជាក្រោម ប្រកបដោយជោគជ័យ ហើយ អ្នកដឹងនាំ យួនកុម្មុយនិស្ត គេ យកមក ធ្វើ បុនក្ការ (rénover) អោយ ស្របនឹង បរិប

ទ ខ្មែរបច្ចុប្បន្ន ដែល ជា សុភកាល (moment favorable) សំរាប់ អនុវត្តនយោបាយ ប្រជាភិវឌ្ឍន៍ ជនជាតិយួន នៅកម្ពុជា។ អ្នកដឹងនាំយួនកុម្មុយនិស្ត គេ ដឹងច្បាស់ថា បើខ្មែរ លើកបញ្ហា ខ្មែរ មាន ដើមកំណើតជាយួន មក រិះគន់ គឺ នឹងធ្លាក់ ចូលទៅ ក្នុងរឿង ប្រកាន់ពូជសាសស្ត្រនិយម ; បើ ចង់ប្រឆាំងតាម ដំរួយ អាវុធ គឺ នឹងធ្លាក់ចូលទៅ ក្នុងរឿង សង្គ្រាមស៊ីវិល ព្រោះ យួន កើតនៅស្រុកខ្មែរ មាន សញ្ជាតិខ្មែរ ជា ពលរដ្ឋខ្មែរពេញលេញ ; បើ ចង់ តវ៉ា តាម ផ្លូវ ច្បាប់អន្តរជាតិ គឺ គ្មាន ពួកអ្នកនយោបាយខ្មែរ អង់អាច មាន កេរ៍ឈ្មោះ ល្បីល្បាញ លើឆាក អន្តរជាតិ អាចរាប់រង កិច្ចការ ជាតតិយុត្ត ដ៍ធំនេះបាន ហើយ បច្ចុប្បន្ននេះ បរិបទនៃពិភពលោក វាមិនត្រូវឪកាស នឹងបញ្ហាខ្មែរ ; បើ យក ការបោះឆ្នោត ជា បាដិហារិយ៍ ដូចនៅ ប្រទេសភូមា គឺ ពួកអ្នកដឹកនាំគណបក្សប្រឆាំង គាត់ គ្មាន លទ្ធភាព នៅក្នុងនីតិកាល ទី៥ ធ្វើអ្វី ជា វិជ្ជមាន ដែល អាច ប្តូរទាំងស្រុង អោយ គ.ជ.ប. ក្លាយ ជា អង្គការ ឯករាជ្យ ដែល នឹង ធានា នូវ ការរៀបចំបោះឆ្នោត ត្រឹមត្រូវ តាមច្បាប់។

យើងឃើញថា កំនួច នៃ បញ្ហាខ្មែរ នេះ យួន គេ ចងក្ដួច អស់រយៈ ច្រើន ទសវត្សរ៍ មកហើយ នាំអោយ ខ្មែរយើង ពិបាកនឹង ស្រាយកំនួច នេះណាស់ ជា ពិសេស ក្រោយពី ឆ្នាំ ១៩៩១ មក អ្នកដឹកនាំខ្មែរ ឬ អ្នកនយោបាយខ្មែរ ធ្វើ កំហុសច្រើនណាស់ ដែលអាច អោយ យួនកុម្មុយនិស្ត រក្សា បាន តាមផ្លូវច្បាប់ នូវ គណបក្សខ្មែរ រណបគេនៅ ក្នុង ជីវិតភាពនយោបាយខ្មែរ ដែល មាន ភ្នាក់ងារ របស់គេ ទាំង ស៊ីវិល និង យោធាអាច លាក់ខ្លួនបាន នៅក្នុង ជួរ គណបក្សប្រជាជន និង កងទ័ព របស់ខ្លួន ដើម្បី ធ្វើ វិទ្ធ ស្សនា គ្រប់បែបយ៉ាង សំរាប់ កំទិច នូវ ខេមរះអ្នកស្នេហា ជាតិ អោយបាត់សូន្យ ពី ជីវិតភាពនយោបាយ ហើយ បន្លិចបន្លង់ ប្រជាពលរដ្ឋខ្មែរ។ កំហុស នេះ ជា ចលករ មានប្រេងសាំងកម្លាំង សំរាប់ អ្នកដឹងនាំយួនកុម្មុយនិស្ត បង្កើនល្បឿននៃ នយោបាយ លេប ទឹកដីខ្មែរ អោយបាន រហ័សបំផុត។ សួរថា ការបោះឆ្នោត នាពេល ខាងមុខនេះ ជា ថ្នាំកែរោគ យួនកុម្មុយនិស្ត លួចដីខ្មែរ ឬ គ្រាន់តែ ជា នយោបាយ ថែរ រោគ របស់ ពួកអ្នកដឹកនាំ គ្រប់ គណបក្ស ប្រឆាំង ? បញ្ហាពិបាកដោះស្រាយ នេះហើយ ជា កំនួច

របស់យួនកុម្មុយនិស្ត កួច បន្ទប់ខ្យល់ អោយ ប្រជាជាតិខ្មែរ ស្លាប់ ព្រោះ ដំណោះស្រាយរបស់ អ្នកដឹកនាំ គ្រប់ គណបក្សប្រឆាំង ទុរា ក្នុង ភាពមោហ៍ប៉ាំង សព្វថ្ងៃនេះ គ្រាន់តែជា ល្បិតដោះខ្លួន (faux-fuyant) សំរាប់ ស្វែង រកសុខតែប៉ណ្ណោះ, គឺ ថា សព្វគ្នា(chacun) សុទ្ធ តែ មាន ផ្លូវ សំរាប់គេខ្លួន, បើ នរណាមួយ ជាប់គុក ពួកគាត់ គ្រាន់តែនាំគ្នាទៅសួរ សុខទុក្ខ ហើយ និយាយថា ដេកចាំឈ្នះឆ្នោតសិនទៅ៕

## យុត្តិធម៌ ចាត់ការរហ័ស របស់ បក្សសង្គ្រោះជាតិ

*សេរីការ*



គណបក្សសង្គ្រោះ សម្រេច ដេញ លោក យង់ ណុយ ហៅ Brady Young ចេញពីសមាជិកអ្នកគាំទ្រគណបក្សនៅក្រុងឡង់បិច (ស.រ.អ.) ដោយសារ លោក យង់ ណុយចោទប្រកាន់ថា លោក ហ៊ុន ម៉ាណែត មិនមែនជាកូនបង្កើតរបស់ លោក ហ៊ុន សែន។តើ បច្ឆាប័ននេះ មានន័យបែបណា ? ជា ទណ្ឌកម្ម ទុកជាមេរៀនសំរាប់សមាជិកគណបក្សថា កុំអោយប៉ះពាល់ដល់ លោក ហ៊ុន សែន និង គ្រួសារលោក អោយសោះពុំនោះនឹងត្រូវដេញចេញពីគណបក្ស។

តាមពិតរឿងចោទប្រកាន់នេះ ជារឿងឯកជនសុទ្ធសាតព្រោះ លោក យង់ ណុយ មិនបាននិយាយ ក្នុងនាម លោកជា សមាជិកគណបក្សនោះឡើយ, ដូច្នេះយុត្តិធម៌ បែបនេះគឺ ប្រាកដ ជាមានរូបភាព ជា ការទទួលបញ្ជាពីអំណាចលោក ហ៊ុន សែននោះហើយ ហើយ វាខុសពី ខ្សែនាយកយុទ្ធសាស្ត្រគណបក្សថា “មិនឆ្លើយ មិនឈ្លោះ” ថែមទៀតផង។

លោក យង់ ណុយ អាច ប្រឈរមុខ នៅចំពោះមុខតុលាការពីបទ បរិហារកេរ៍ បើលោក ហ៊ុន ម៉ាណែត ឬ លោក ហ៊ុន

សែន ប្ដឹងលោក ទៅ តុលាការ នៅស្រុកខ្មែរ ឬ នៅ ក្រុង ឡុងបិច បើការចោទប្រកាន់នេះ វា ជា រឿងប្រឌិត ហើយ អាចទទួលទោស ទៅតាមច្បាប់ជាធរមាន ដូច្នេះ គួរគាំបី អ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ ដែលខ្លួន តែងតែទុក ខ្លួន ជា អ្នករងគ្រោះ ពីសំណាក់ប្រព័ន្ធយុត្តិធម៌ របស់ លោក ហ៊ុនសែន រង់ចាំ មើល នូវ ការវិវត្តន៍ ជាគតិយុត្ត នៃ រឿងនេះសិន មុននឹងសម្រេចចិត្តដេញអ្នកគ្រាន់តែ និយាយរឿង ដែលគេនិយាយពេញមួយនគរ, តែពួកគាត់ បែរជា ប្រើ យ៉ាងរវីសរវៀសនូវប្រព័ន្ធយុត្តិធម៌ របស់បក្ស បំពាន លើសិទ្ធិសេរីភាព របស់ សមាជិកខ្លួនឯង ដោយ យកការភិតភ័យរបស់ពួកខ្លួន ធ្វើជា យុត្តិធម៌ចាត់ការរហ័ ស (justice expéditive)។ សួរថាតើ ក្រុមវិន័យ របស់បក្ស មាន ទន្និករណ៍ អ្វីច្បាស់លាស់ សំរាប់ បញ្ជាក់ថា លោក យង់ ណុយ និយាយ តៗគ្នានោះ ជាការមិនពិត ហើយ មិនទាំង បានកោះហៅ គាត់ឲចូលបំភ្លឺ តាមច្បាប់ ស្របតាមលក្ខន្តិ កៈបក្សនោះដែរ ដើម្បី អោយគាត់អាច ការពារខ្លួន។ ដូច្នេះ អ្វីដែលពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ កំពុង ធ្វើ ពាក់ព័ន្ធនឹងគោលការណ៍យុត្តិធម៌ គឺ ពួកគាត់ ធ្វើដូច

លោក ហ៊ុន សែន បេះបិទ ហេតុដូច្នេះ តើអោយ នរណា គេជឿបានថា គណបក្ស សង្គ្រោះជាតិ នៅពេល ដែលខ្លួនមាន អំណាច នឹងដូរ ប្រព័ន្ធដឹកនាំ នៅស្រុកខ្មែរ ជាពិសេសប្រព័ន្ធយុត្តិធម៌។ មួយវិញទៀត ករណី លោក យង់ ណុយ វា មិនខុសគ្នានឹងករណី លោក សម រង្ស៊ី ដែល លោក ហេង សំរិន ប្តឹងគាត់ ពីបទបរិហារកេរ៍ ចុះហេតុអ្វី ក៏ក្រុមវិន័យ គណបក្សសង្គ្រោះជាតិ មិនប្រកាស ដេញគាត់ ចេញពីសមាជិក និងប្រធានបក្សផង ? បុគ្គល នៅចំពោះមុខច្បាប់ វាគ្មានឋានៈ ឬ វណ្ណៈ អ្វីនោះឡើយ !

សំណួរសួរថា ការចាត់ការរហ័ស បែបនេះ តើ វា ជា បំណុយ របស់ លោក កឹម សុខា ត្រូវសង លោក ហ៊ុន សែន ដែលមិនបានចាប់គាត់ដាក់ គុកព្រៃស ពីបទ មិនចូលខ្លួន តាមដីការបស់តុលាការ នោះឬ ? នេះហើយ វប្បធម៌ មិនឆ្លើយ មិនឈ្លោះ តែក្នុងនេះវាមានល្បិចដូរប្រយោជន៍គ្នា គឺថា លោក កឹម សុខា ចំណេញ សុខមួយរយៈ ៦ ចំណែកលោក ហ៊ុន សែន វិញ គាត់ ចំណេញ ភាពឃោឃៅរហូត។ ទ្រង់ទ្រាយ នៃបច្ចាប័ន ចំពោះ លោក យង់ ណុយ នេះ ជានិមិត្តរូប នៃ បូជនកិច្ច មនុស្ស ចំពោះ អាទិទេពហ៊ុន

សែន សូម សេចក្តីសុខ ដល់អាត្មា តែទង្វើនេះ គឺជា ការភ្លាំងភ្លាត់ (lapsus) នៃប្រាជ្ញា ជា ខ្មែរ អ្នកជា នោះដែរ។ លោក កឹម សុខា គាត់ កំពុង ស្រវាចាប់ នូវគ្រប់មធ្យោបាយ ដើម្បី អញរស់បានសុខ តែប៉ុណ្ណោះ រហូត ហ៊ាន ទាំងបំពានច្បាប់បក្ស ចុះហត្ថលេខា លើ ឯកសារ ប្រកាសដេញ លោក យង់ ណុយ ព្រោះ តាមធម្មតា គឺ អ្នកតំណាងក្រុមវិន័យបក្សនោះទេ ដែល ត្រូវ ប្រថាប់ត្រា ក្នុងនាម ជាអង្គការឯករាជ្យ ពីអង្គការដឹកនាំ របស់ គណបក្ស។ ហត្ថលេខារបស់ លោក កឹម សុខា ជាការផ្ញើសារដល់លោក ហ៊ុន សែន នោះឯង ; នេះឯង ដែល ជា អ្នកប្រជាធិបតេយ្យសម័យតោជោ៕

# គណបក្សសង្គ្រោះជាតិជាសេចក្ដីខ្មាសសំរាប់ជាតិខ្មែរ

*សេរីការ*



ថ្មីៗនេះកិមសុខាបានឆ្លើយប្រាប់អ្នកកាសែតថាគណបក្សសង្គ្រោះជាតិត្រូវតែចូលបោះឆ្នោត ទើបអាចដឹង អំពីល្បិចខូច របស់គណបក្សកាន់អំណាច និង គ.ជ.ប., ដែលកំពុងធ្វើគ្រប់មធ្យោបាយបន្លំលួចឆ្នោតដើម្បី យកឈ្នះ។ ដូច្នេះសំដីនេះ យើងអាចទុកជា សេចក្ដីសម្រេចដាច់ស្រេច របស់គណបក្សសង្គ្រោះជាតិ ចូលរួមការបោះឆ្នោត គ្មានសេរី, គ្មានយុត្តិធម៌ សំរាប់តែយួនឈ្នះ នាខែកក្កដាខាងមុខនេះ។

សំដីបែបនេះ ធ្វើឲយើងនឹកឃើញសំដីលីលារបស់ហ៊ុនសែនបង្កើតបនល្លែងនៅតាមទល់ដែនយួន ដើម្បី ធ្វើជារបងការពារទល់ដែន ដែលជាគំនិតអ្នកដឹកនាំយួននៅស្រុកខ្មែរ គេបង្គាប់ឲហ៊ុនសែននិយាយឲ ”ក្ដ”ដល់ខ្មែរ ព្រោះយួនវាមើលងាយជនជាតិខ្មែរ បើវាចង់ឲអាយ៉ងវានិយាយអ្វី គឺវាឥតចាំបាច់រកគំនិតសមហេតុសមផលអ្វីនោះទេ។

កិមសុខា មិនខុសពីហ៊ុនសែន ជាសមមិត្តខ្លួនផង ជាគូប្រឆាំងអាការៈក្រៅតាមបញ្ជាហាណូយផង, និយាយទ្វែៗ

តាមបង្គាប់យួនហើយមានសានុមត ពីចិនដែរ ថាត្រូវតែចូលរួមបោះឆ្នោត ទើបអាចដឹងអំពីល្បិចខូច គ.ជ.ប។ សំដីបែបនេះ គឺអ្នកដឹកនាំយួននៅស្រុកខ្មែរ គេយកមាត់កឹមសុខា ដើម្បីថា "ក្ដខ្មែរ" ម្ដងទៀតហើយ។

កឹមសុខា ប្រើសំដីបែបនេះ ជាសំដីមើលងាយប្រជាពលរដ្ឋខ្មែរ ទុកខ្មែរជាមនុស្សល្ងង់ អាចជឿខ្លួនគ្រប់បែបយ៉ាង ព្រោះថាគណបក្សសង្គ្រោះជាតិដែលខ្លួនបង្កើតឡើង, ហើយដណ្ដើមអំណាចពីសមរង្ស៊ីបានងាយស្រួលដោយសារមានជំនួយពីគង់គាំ, ប៉ែនសុវណ្ណ, និងមិត្តទ្រុះសមរង្ស៊ីមួយចំនួន, បានដូរគំនិតផ្ទុយស្រឡះ ពីការវិភាគស្ថានភាពនយោបាយនៅស្រុកខ្មែរ របស់ខ្លួនថា ជាតិកំពុងមានគ្រោះថ្នាក់ ជា អាសន្ន ហើយ ខ្លួនបានចង្អុលបង្ហាញគ្រប់ចំណុច ភយន្ដរាយ ថែមទាំងបានបង្ហាញផ្លូវដែលត្រូវដើរដើម្បី ស្រាកទុក្ខប្រជាពលរដ្ឋខ្មែរ។ ក្នុងវិភាគស្ថានភាពនយោបាយស្រុកបែបនេះ កឹម សុខា ត្រូវដឹងច្បាស់ថា អ្នកណាជាសត្រូវជាតិពិតប្រាកដ ស្គាល់យុទ្ធសាស្ត្របំផ្លាញជាតិរបស់សត្រូវ ហើយ ត្រូវដើរតួជាអ្នកប្រាប់រឿងស្ងាត់កំបាំងខ្នាំងជាតិ ឲ ប្រជាពលរដ្ឋខ្មែរ និង សហគមន៍អន្ដរជាតិ ឲ

ដឹងច្បាស់ តែបែរជានិយាយស្រួល លើកយកហេតុផលដ៏ចម្លែកមួយ គ្មានសមហេតុសមផលថា ត្រូវតែចូលរួមបោះឆ្នោតគ្មានសេរី, គ្មានយុត្តិធម៌ ជាមួយសត្រូវជាតិសិន ទើបខ្លួនអាចបញ្ជាក់បានអំពីគ្រោះថ្នាក់ជាតិទៅវិញ។ សូមបងប្អូនខ្មែរយើងយកគំនិត កិមសុខានេះ ទៅពិចារណាចុះ ដែលជាបុគ្គលម្នាក់តាំងខ្លួនជាអ្នកប្រជាធិបតេយ្យ ជាអ្នកសង្គ្រោះជាតិខ្មែរ។

សំដី មោហោ កិម សុខា ខាងលើនេះ បញ្ជាក់បង្ហាញថែមទៀតអំពីគោលបំណងវិលវល់របស់គណបក្សសង្គ្រោះជាតិ នៅចំពោះមុខគ្រោះថ្នាក់ជាតិ ដែល កិម សុខា និង បក្សពួកខ្លួនមួយក្ដាប់ ទុកស្មើត្រឹមតែជាគ្រោះថ្នាក់អាសនៈរបស់ពួកគេនៅក្នុងរដ្ឋសភានៃ មនុស្សស្វា ធ្វើ ថ្លង់, គ, និង ខ្វាក់ ដើម្បី កៅអីតែប៉ុណ្ណោះ។ ពួក កិម សុខា កំពុងបន្តវិធីធ្វើការ « ធ្វើសិនទៅចាំគិតក្រោយទៀត » ដែលជាទម្លាប់អាក្រក់របស់ខ្មែរយើង។

គំនិត កិម សុខា និង បក្សពួកខ្លួនបែបនេះ, យើងជាខ្មែរមិនត្រូវនាំគ្នាឆ្ងល់អ្វីទេអំពីបរាជ័យមហាបាតុកម្មគណ

បក្សសង្គ្រោះជាតិ នាថ្ងៃទី២៤ មេសា នៅទីក្រុងភ្នំពេញ ដែលជាទីកន្លែង ដែលគេទុកជា សេរីសេរីវិញ្ញាណនយោបាយជាតិ ជាទីប្រជុំយុវជន, កម្មករ, អ្នករាជការគ្រប់ថ្នាក់ ។ល។ មានអ្នកចូលរួមត្រឹមតែជាងពីរបីរយនាក់តែប៉ុណ្ណោះ ទោះបីមានការអំពាវនាវនាំឲរំភើបចិត្តពីសមរង្ស៊ីផ្ទាល់ យ៉ាងណាក៏ដោយ។ រាជ័យនេះ វា មាន ភាពផ្ទុយ ពីការឃោសនា របស់ គណបក្ស ថា ខ្លួនកំពុង ទទួល ការគាំទ្រ យ៉ាងខ្លាំងក្លា ពីសំណាក់ប្រជាពលរដ្ឋ ទាំងក្នុងប្រទេស និង ក្រៅប្រទេស។

យើងលើកមកនិយាយនេះ គ្មានគំនិត នាំបំបែកបំបាក់ខ្មែរនិងខ្មែរនោះឡើយ ហើយ ក៏មិនយកខ្មែរណាជាសត្រូវនឹងយើងដែរ តែយើងមានករណិយកិច្ចជាពលរដ្ឋខ្មែរ ជាខ្មែរសេរី ធ្វើបរិយារ ជូនដល់ប្រជាពលរដ្ឋខ្មែរឲជ្រាបដឹង និង យល់ច្បាស់ អំពីសកម្មភាព របស់សត្រូវជាតិចេញមុខ ឬ លាក់មុខក្តី ដូចជា សកម្មភាព កិម សុខា និង បក្សពួកនាបច្ចុប្បន្ន កំពុងបោកប្រាស់អ្នកប្រជាធិបតេយ្យ, ប្រជាពលរដ្ឋ ក្នុងគោលបំណងតែមួយគត់ គឺ បំរើនយោបាយចិនយួនកុម្មុយនិស្ត ដើម្បីកៅអី និង បំណាច់ អាសនៈ ជា

តំណាងរាស្ត្រ សំរាប់ធ្វើច្បាប់ ការពារជនជាតិយួនរស់ឥត ច្បាប់នៅក្នុងស្រុកខ្មែរ។ ការពន្យល់ហេតុផល នៃ ការចូល រួមបោះឆ្នោតគ្មានសេរី, គ្មានយុត្តិធម៌ របស់គណបក្សស ង្គ្រោះជាតិគឺដូចជា ពួកគេកំពុងនិយាយប្រាប់ខ្មែរថា បើ ចង់ដឹងថា ភ្លើងក្តៅត្រូវនាំគ្នាលូកដៃចូលភ្លើងសិន ទើប យើងដឹងថាវាក្តៅ ប៉ុន្តែ គេដឹងរួចស្រេចទៅហើយថា ធាតុ ក្តៅរបស់ភ្លើងជាភាពជាក់ស្តែង ឥតចាំបាច់លូកដៃ ដើម្បី ឲដឹងនោះឡើយ ពន្យល់បែបនេះ គឺដូចគ្នានឹង សំរ៉ងសី កឹមសុ ខា និយាយថា ត្រូវតែចូលរួមបោះឆ្នោតគ្មានសេរី, គ្មាន យុត្តិធម៌ ក្នុងរបបផ្តាច់ការសិន ទើបអាចដឹងច្បាស់បាន, តែការបោះឆ្នោតនេះ, សូម្បី សហគមន៍អន្តរជាតិ ក៏គេទុក រួចស្រេចទៅហើយថា ជាការបោះឆ្នោត គ្មានលក្ខណ:ប្រជា ធិបតេយ្យ។ នេះហើយជា ភាពមិនទំនងក្នុងគំនិត កឹម សុ ខា ព្រោះជា សំរ៉ងសី និយាយតាមបញ្ជាអ្នកដឹកនាំយួននៅ ស្រុកខ្មែរ ដូចហ៊ុនសែនដែរ។ សួរថាកឹមសុខានិយាយបែប នេះ៖

១. មានគោលដៅបែបបណា ? គឺសង្គ្រោះជនជាតិយួន ដែលមករស់ឥតច្បាប់នៅក្នុងស្រុកខ្មែររាប់លាននាក់។

២. មានគោលបំណងបែបណា ? រក្សាកៅអី និង បំណាច់អាសនៈពួកខ្លួនមួយក្ដាប់នៅក្នុងរដ្ឋសភា នៃ មនុស្សស្វាធ្វើ គ, ថ្លង់ និង ខ្វាក់។

៣. មានគោលការណ៍បែបណា ? រក្សាអំណាចយួនកុម្មុយនិស្ត និងអំណាចខ្មែរអាយ៉ងយួនក្នុងស្រុកខ្មែរ។

ដើម្បីទប់ស្កាត់អំពើទុច្ចរិតនេះ, ខ្មែរយើង មានមធ្យោយតែមួយគត់ ដែលជា មធ្យោបាយអហិង្សា គឺធ្វើពហិការ កុំនាំគ្នាទៅបោះឆ្នោតឲយួនឈ្នះ, ឲអំណាចអាយ៉ងយួនបន្តបម្រើប្រយោជន៍យួន បំផ្លាញខ្មែរតទៅមុខទៀត។ ចំពោះយើងវិញ, យើងគ្មានការរួញរា ធ្វើការរិះគន់ ដល់គណបក្សសង្គ្រោះជាតិ ព្រោះថា ក្នុងបច្ចុប្បន្ននេះ គណបក្សនេះ ធ្វើសកម្មភាព បម្រើចេញមុខប្រយោជន៍យួន ដូច្នេះយើងឈប់ទុកគណបក្សនេះ ជាគណបក្សប្រឆាំងទៀតហើយ។

ហ៊ុន សែន ឥតក្លាចភ័យថា គណបក្សប្រជាជន ចាញ់ឆ្នោតនោះឡើយ, ឈ្នះគឺជាការពិតរបស់ហ៊ុន សែន តែ ហ៊ុន សែន ក្លាចជ័យជំនះខ្លួននេះមិនមានការទទួលស្គាល់ពីសហគមន៍អន្តរជាតិ ដែលជា ទាយកជំនួយសំរាប់របប

ខ្លួនរស់ សំរាប់ជួយជនជាតិយួន រស់ឥតច្បាប់នៅក្នុងស្រុក ខ្មែរ ហេតុនេះឯង ហ៊ុន សែន បញ្ជាឲកែន ពួកស្តេច តាម បង្គាប់យួនឲមកចូលធ្វើនយោបាយវិញ តែនៅរក្សា បំណាច់ ជាពូជស្តេចដដែល ដូចជាភរិយា លោក កែវ ពុទ្ធ រស្មី ឈ្មោះ អរុណរស្មី កូនស្រីសីហនុ ឲធ្វើជាប្រធានគណបក្ស ហ្វុនសិប៉ិច ឲទ្រង់សិរីវឌ្ឍ ប្អូនសីហនុ អាចចូលជួយក្ដួយស្រី បាន ឲទ្រង់ធម្មកោ ចូលគណបក្សសង្គ្រោះជាតិ ជាការ ដាក់ថ្នាំកម្លាំងកុហកប្រជាពលរដ្ឋខ្មែរថា គណបក្សនេះ កំពុងមានការគាំទ្រពីសំណាក់ខ្មែរគ្រប់មជ្ឈដ្ឋាន ដើម្បី ធ្វើ ធម្មានុរូបកម្ម នៃការសម្រេចចូលរួមការបោះឆ្នោតគ្មាន សេរី, និងគ្មានយត្តិធម៌ដែលជាការធានារមួយឲជ័យជំនះ ហ៊ុន សែន មានការទទួលស្គាល់ ពីសំណាក់ សហគមន៍ អន្តរ ជាតិ។

កំណែន ពួកស្តេច របស់ អ្នកដឹកនាំយួន នៅស្រុកខ្មែរនេះ ពួកវា ទុកជាកាតព្វកិច្ចរបស់ពួកព្រះ ឬ អង្គម្ចាស់ខ្មែរ ចំពោះជនជាតិយួន ដែលគេមកស្លាប់នៅស្រុកខ្មែរ ដើម្បី ជួយបង្កើតឡើងវិញ នូវ របបរាជានិយមខ្មែរ, ជាការសង គុណ ឥតគននា នៃ ជំនួយយួន ដល់ស្តេចសីហនុ ដែលពួក

ស្តេច ទុកជា វរៈក្សត្រ ជាបីតា របស់ពួកខ្លួន។ តែពួកស្តេចត្រូវដឹងថា បើពួកខ្លួនចូលធ្វើនយោបាយ, ពួកខ្លួនពុំអាចរក្សាឋានៈ ឬ វណ្ណៈខ្លួនជាស្តេចបានទៀតទេ ព្រោះក្នុងលាននយោបាយ, សមភាព រវាងគូរប្រទាំង ជាល័ក្ខខណ្ឌត្រូវមានខានមិនបាន ដូច្នេះ គេឥតចាំបាច់ហៅ លោកស្រី អរុណរស្មី លោក ធម្មកោ សិរីវឌ្ឍ និង ស្តេចឯទៀតថា "ព្រះ ឬ អ្នកអង្គម្ចាស់" អ្វីទៀតនោះឡើយ, ហៅលោក, និង លោកស្រី វាគ្រប់គ្រាន់ណាស់ទៅហើយ។

គេដឹងថា, សហគមន៍អន្តរជាតិ, គេមិនបញ្ជូនអ្នកសង្កេតការណ៍មកពិនិត្យការបោះឆ្នោតថ្នាក់ជាតិខាងមុខនេះទេ ព្រោះ គេដឹងថាការបោះឆ្នោតនេះ វាគ្មានលក្ខណៈប្រជាធិបតេយ្យ។ ត្រូវខ្មែរយើងដឹងបន្តទៀតថា សហគមន៍អន្តរជាតិ គេមិនអាចនិយាយប្រាប់ខ្មែរយើង ត្រង់ៗថា ត្រូវធ្វើពហិការ ក្នុងការបោះឆ្នោត គ្មាន សេរី, គ្មាន យុត្តិធម៌នោះបានឡើយ ព្រោះ វាខុសនឹង សីលធម៌របស់គេ, តែការមិនបញ្ជូនអ្នកសង្កេតការណ៍នេះ គឺជា ការបញ្ជាក់មិនចំមុខរួចស្រេចទៅហើយ ថាប្រជាពលរដ្ឋខ្មែរ ត្រូវទទួលការខុសត្រូវដោយខ្លួនឯង ក្នុងការបោះឆ្នោត គ្មានសេរី, និងគ្មាន

យុត្តិធម៌នេះ បើនៅតែនាំគ្នាទៅបោះឆ្នោត ឬចូលរួមបោះឆ្នោត គឺខ្មែរខ្លួនឯង ជាអ្នកទទួលផលអាក្រក់សំរាប់ជាតិខ្លួនឯង។ ព្រោះថ្នាក់ធំមួយចំពោះជាតិខ្មែរ ក្នុងការទៅបោះឆ្នោត ឬ ចូលរួមបោះឆ្នោត គ្មានសេរី, គ្មានយុត្តិធម៌បែបនេះ គឺខ្មែរយើងកាត់ផ្ដាច់ប្រទេសខ្មែរយើងដោយខ្លួនឯងពីសហគមន៍អន្តរជាតិ ក្នុងវិស័យការពារលទ្ធិប្រជាធិបតេយ្យ, សិទ្ធិមនុស្ស ជាពិសេសជា ការឈប់ទទួលស្គាល់ដោយខ្លួនឯង នូវ កិច្ចព្រមព្រៀងសន្តិភាពនៅស្រុកខ្មែរនៅថ្ងៃទី២៣ តុលា ឆ្នាំ ១៩៩១ ដែល គេយកមូលដ្ឋានលទ្ធិប្រជាធិបតេយ្យ ជាគោលការណ៍សំខាន់បំផុត។ ដូច្នេះ ការចូលរួមបោះឆ្នោត គ្មានលក្ខណៈលទ្ធិប្រជាធិបតេយ្យគឺ ជាការបំពាន ជាក់លាក់ ដោយខ្លួនឯងលើកិច្ចព្រមព្រៀង ថ្ងៃទី២៣ តុលា ឆ្នាំ ១៩៩១។

កឹម សុខា និង បក្សពួកខ្លួន រួមនឹង គណបក្សប្រជាជនរស់ក្រោមអំណាចយួនកុម្មុយនិស្ត កំពុងនាំគ្នា សម្លាប់ជាតិខ្មែរ ព្រោះ នាំគ្នាធ្វើការបោះឆ្នោត គ្មានសេរី, គ្មានយុត្តិធម៌។ ការបោះឆ្នោត បែបនេះ គេអាចទុក ជា ចំណុចគ្មានអាចត្រឡប់វិញបាន នៃ ដំណើរ ទៅរក មរណៈភាព របស់

ជាតិខ្មែរ។ ដំណើរឆ្ពោះទៅកម្ពុជាកណ្តាល របស់ជនជាតិយួននិង ឥណ្ឌូចិន ក្នុងឆ្នាំ២០១៣ ជា ការពិតមួយសំរាប់ខ្មែរ ហើយ ជាការបញ្ជាក់បង្ហាញពីដង្ហើមចុងក្រោយ របស់ជាតិខ្មែរដែរ។ យើងសួរថា តើកិម សុខា និង បក្សពួកគាត់នៅមានខួរក្បាល ជាខ្មែរដែរឬទេ ? យើងមិនបាច់សួរទៅសម រង្ស៊ី អ្វីទៀតទេ ព្រោះ បុគ្គលនេះ ត្រូវបាន គង់ គាំ, ប៉ែន សុវណ្ណ និង កិម សុខា យកទៅដាក់ចោលក្នុងមឈូសយួន បាត់ទៅហើយ។ ភាពជាក់ស្តែង គឺ កិម សុខា គាត់ពាក់ងារជា ប្រធានស្តីទី គឺមានន័យថា ប្រធាន សម រង្ស៊ីឥតមានមុខ នាទីអ្វីទៀតទេ ក្នុងគណបក្ស សង្គ្រោះជាតិហើយ បើបុគ្គល សម រង្ស៊ី ធ្វើសេចក្តីថ្លែងការណ៍អ្វីមួយ, សេចក្តីថ្លែងការណ៍នោះ គណបក្សសង្គ្រោះជាតិ គេមិនទុកជាផ្លូវការ របស់គណបក្សនោះឡើយ ជាពិសេស បើ សម រង្ស៊ីចង់ធ្វើពហិការគឺគេទុកសេចក្តីសម្រេចនេះជាសេចក្តីសម្រេចឯកជនតែប៉ុណ្ណោះ។ ងារជាប្រធានស្តីទី របស់ កិមសុខា ជាការបិទទ្វារមិនឲ សម រង្ស៊ី មានលទ្ធភាពគ្រប់បែបយ៉ាង ជ្រៀតជ្រែង ក្នុងសកម្មភាពគណបក្សសង្គ្រោះជាតិនៅក្នុងប្រទេស។ ដូច្នេះ សម រង្ស៊ី បានក្លាយ ជាបុគ្គល

ដែល គង់ គាំ, ប៉ែនសុវណ្ណ និង កិម សុខា គេមិនចង់ឃើញមុខនៅស្រុកខ្មែរ ជាពិសេសនៅពេលបោះឆ្នោត គ្មានសេរី គ្មានយុត្តិធម៌ ខាងមុខនេះ។

យើង មិនមែន ជា កម្លាំង ជាចលនា ឬ ជា គណបក្សនយោបាយនោះឡើយ យើងគ្រាន់ ជា សម្បជញ្ញជាតិខ្មែរតែប៉ុណ្ណោះ ដូច្នេះយើង មិនធ្វើការអំពាវនាវឲខ្មែរយើងធ្វើពហិការក្នុងការបោះឆ្នោតគ្មានសេរី, គ្មានយុត្តិធម៌ ខាងមុខនេះឡើយ, យើងគ្រាន់តែមានជំនឿថា ការសម្រេចចិត្ត របស់ខ្មែរម្នាក់ៗ ធ្វើពហិការនេះ ជាសម្បជញ្ញជាតិខ្មែរដែលយើងទុកវាជាកម្លាំងជាតិខ្មែរ ឥតអាចមានកម្លាំងណាមួយ អាចយកឈ្នះវាបាននោះឡើយ ដូច្នេះ ផ្លូវពហិការនេះឯង ជាការសង្គ្រោះជាតិពិតប្រាកដ ផ្ទុយពីការចូលរួមបោះឆ្នោត នៃ គណបក្សសង្គ្រោះជាតិដែលក្លាយជា គណបក្សជាសេចក្ដីខ្មាស សំរាប់ជាតិខ្មែរនៅចំពោះមុខគ្រប់ប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរី ជារបបដឹកនាំជាតិ៕

សេរីការ



# ដំណាក់ការថ្មី នៃទំនាក់ទំនង សហរដ្ឋអាមេរិក ជាមួយនឹង យៀកណាមគណ

ទំនាក់ទំនងនេះ ចុះនាមក្នុង យុទ្ធសាស្ត្រ ភូមិសាស្ត្រនយោបាយ នៃសហរដ្ឋអាមេរិក (ស.រ.អ.) នៅក្នុងដំបន់អាស៊ីផ្នែកអគ្នេយ៍ ដើម្បី ទប់ទល់នឹង អនុត្តរភាព នៃប្រទេសចិនកុម្មុយនិស្តនៅអាស៊ីប៉ាស៊ីហ្វិក។ទោះបី ស.រ.អ. មិនគាំទ្រ យៀកណាម នូវការទាមទារកោះក្តី ពីប្រទេសចិន តែ ស.រ.អ. ផ្តល់លទ្ធភាព អោយយៀកណាម មានមធ្យោបាយយោធា ការពារខ្លួន តាមការលែងហាម យៀកណាម មិនអោយទិញអាវុធយុទ្ធភ័ណ្ឌ ដើម្បី ធ្វើទំនើបភាវូបនីយកម្មកងទ័ព។ ការលែងហាមនេះ វានឹងមានកម្មវិបាកដល់ស្រុកខ្មែរ និងលាវ ដែលរស់នៅក្រោមឥទ្ធិពលយៀកណាម ព្រោះយួន រឹតតែមានកម្លាំងយោធា ដើម្បី បន្តនយោបាយលេបទឹកដី ខ្មែរ និងលាវ។ ស.រ.អ. ហាក់បីដូចជាទទួលស្គាល់ជាតុណ្ហី នូវស្ថានភាពបច្ចុប្បន្ននៅតំបន់ឥណ្ឌូចិនដែលមាន យៀកណាម ជា អ្នកត្រួតត្រា និង ជា អ្នកបំពានបូរណភាពទឹកដី ស្រុកខ្មែរ និង លាវ។ ពិតប្រាកដណាស់ថា លោក Barak Obama នៅពេល ធ្វើទស្សនាកិច្ចជា

ផ្លូវការថ្មីៗនេះនៅយៀកណាម បានលើក បញ្ហាសិទ្ធិមនុស្ស មកសំដែងប្រាប់ដល់អ្នកដឹកនាំយៀកណាម ថាជាអំពល់សំខាន់មួយ របស់ ស.រ.អ.តែលោក ប្រធានាធិបតី មិនបានបញ្ចេញសារអ្វីមួយ ដែលអាចអោយប្រជាពលរដ្ឋ ខ្មែរ និង លាវ មានសេចក្តីកក់ក្តៅ អំពី ការទប់ទល់ របស់ស.រ.អ. នៅចំពោះមុខ មហិច្ឆិតាលេបទឹកដីរបស់យួននៅឥណ្ឌូចិន។

អ្នកដឹកនាំយួនកុម្មុយនិស្តបច្ចុប្បន្ន ឆ្លៀត ទាញយកបានប្រយោជន៍ ពី ជម្លោះ នៃ ភូមិសាស្ត្រ នយោបាយ របស់គេជាមួយចិនកុម្មុនិស្ត ដើម្បី ពង្រឹងជំហរ របស់គេ ជាប្រមុខអ្នកដឹកនាំនៅឥណ្ឌូចិន ដែលជា គោលដៅរយឆ្នាំ នៃបុព្វបុរស របស់គេ។ នៅក្នុងសម័យអាណានិគមបារាំងយួនយកបានទឹកដីកម្ពុជាក្រោម ជាស្ថាពរ ; នៅពេល ស.រ.អ. ដកទ័ពចេញ ពី យៀកណាម ប្រទេសនេះ មាន ឯកភាព ហើយក្លាយជា មហាអំណាចយោធានៅឥណ្ឌូចិន អាចវាយរំលាយ របបកម្ពុជាប្រជាធិបតេយ្យ និយមចិនបែកខ្ទេចតែ បួនដប់ សប្តាហ តែប៉ុណ្ណោះ ; នៅក្នុងកិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ១៩៩១ យួន អាចប្តូរ សង្គ្រាមរំដោះខ្មែរ

ពីការកាន់កាប់យោធាយួន អោយក្លាយជា សង្គ្រាមស៊ីវិល រវាង យុទ្ធការីខ្មែរ ហើយលាក់កម្លាំងយោធាយួន នៅក្នុង កងទ័ពបក្សខ្មែររណបខ្លួន និង ប្រជាជនយួន រាប់លាន នាក់ នៅស្រុកខ្មែរ ; សព្វថ្ងៃនេះ យួនជាអ្នកដឹកនាំស្រុក ខ្មែរដោយចំពោះ តែប្រើដៃរាជរដ្ឋាភិបាលខ្មែរសំរាប់សម្លាប់ ឬ ចាប់ដាក់គុក ខ្មែរណា ដែលហ៊ានចេញមុខប្រឆាំងនឹង ខ្លួន។

យើងធ្វើសេចក្តីសន្និដ្ឋានបានថា ទ័ពយួន ប្រដាប់ដោយ អាវុធយុទ្ធភ័ណ្ឌទំនើប ច្បាស់ជាមហាទុក្ខសំរាប់ស្រុក ខ្មែរ និង លាវ ជាងការបារម្ភរបស់ចិនកុម្មុយនិស្ត អាស្រ័យហេតុ នេះ យើងជាខ្មែរ មិនគាំទ្រជាដាច់ខាត នូវ នយោបាយ របស់ ស.រ.អ. នូវ ការលែងហាម យៀកណាម ៗ ទិញអាវុធ យុទ្ធភ័ណ្ឌ នោះឡើយ ល្អីកណាតែ យៀកណាមនៅតែជ្រៀត ជ្រែកចូលក្នុងជីវិតភាពនយោបាយនិងបំពាន បូរណភាព ទឹកដីខ្មែរ។ អ.រ.ស. ជាមិត្តល្អរបស់ខ្មែរពិត តែ នយោបាយ យកយួនកុម្មុយនិស្ត ជាដៃគូ គឺជា នយោបាយ ផ្លូវលុង សំ រាប់ អានាគត ប្រជាពលរដ្ឋ ខ្មែរ និងលាវ៕

# តើអាជ្ញាធរយួននៅស្រុកខ្មែរនឹងចាប់ខ្លួន លោក កឹមសុខា ដែរឬទេ ?

*សេរីការ*



អាជ្ញាធរយួនកុម្មុយនិស្តនៅស្រុកខ្មែរ ប្រាកដជានឹងចាប់ លោក កឹមសុខា ព្រោះ យុទ្ធសាស្រ្តយួន នៅស្រុកខ្មែរ គឺជា យុទ្ធសាស្រ្ត វាយលុក ដោយ ប្រើ ប្រព័ន្ធយុត្តិធម៌ ជា កម្លាំង ទោះបិ មធ្យោបាយ របស់ខ្លួន យកមកប្រើ វាជា វិតក្កម ក៍ ដោយ។

## គុណប្រយោជន៍ របស់យួននៃការចាប់ខ្លួនលោកកឹម សុខា

តើ ការចាប់ លោក កឹម សុខា ដាក់ពន្ធនាគារ ដូចគ្នានឹង គោលបំណងចាប់ លោក សម រង្ស៊ី ជាគុណប្រយោជន៍ អ្វី សំរាប់អាជ្ញាធរយួន ?

គឺបង្កើត កោលាហល ជាអចិន្ត្រៃយ៍ នៅស្រុកខ្មែរ ដូចយ៉ាង ករណី ស្រី ចំរើន, ធី សុវណ្ណថា ។ល។ ជាការបង្កើតនៃបញ្ហា សំរាប់ អុកឡុកសង្គមខ្មែរអោយមានអនិរភ័យ ដើម្បី បញ្ចៀល អារម្មណ៍ខ្មែរ ទៅលើរឿង យួនចូលស្រុកខ្មែរ រាប់លាននាក់។ ត្រូវដឹងថា បើខ្មែរមានទុក្ខ វាជា សេចក្ដីសុខ

ដល់ជនជាតិយួន ដែលមករស់នៅខុសច្បាប់នៅស្រុកខ្មែរ ; តែ បើ ខ្មែរ មាន សេចក្ដីសុខ វានឹងអាចបង្កើត កម្លាំងសាមគ្គីជាតិ ដែលជា ការគំរាមដល់យួន លួចចូលមកក្នុងស្រុកខ្មែរ។ ដូច្នេះសេចក្ដីសុខ របស់ខ្មែរវាផ្ទុយពីសេចក្ដីសុខរបស់យួន។ គំនិតបែបនេះហើយ វាជា ពិចារណាកិច្ច របស់អាជ្ញាធរយួនកុម្មុយនិស្តនៅស្រុកខ្មែរ។

ដូច្នេះ អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ ទោះបីខំ បង្អោនខ្លួន ជាអ្នកចុះចាញ់ នៅចំពោះមុខ គណបក្សកាន់អំណាចក៏វាគ្មានប្រយោជន៍អ្វីនោះដែរព្រោះ ឥរិយាបថនេះ វាគ្មានទាក់ទងអ្វីនឹង ពិចារណាកិច្ចរបស់អាជ្ញាធរយួន ត្បិត យួនមិនដែលយក គណបក្សប្រជាជនខ្មែរជា ការកំណត់ នៃយុទ្ធសាស្ត្រ វាយលុករបស់គេ នៅស្រុកខ្មែរ។ លោក ហ៊ុន សែន និង បក្សពួកគាត់ គឺជា ភ្នាក់ងារ ដែលខ្មែរយើងហៅថា បាតដៃទី៣ សំរាប់ប្រតិបត្តិ នូវ អំពើព្រៃផ្សៃ ចំពោះខ្មែរ អ្នកប្រឆាំងនឹងយួន។ តែ ពួក លោក ហ៊ុន សែន មិនមែនជា ពួករងគ្រោះនឹងយុទ្ធសាស្ត្រយួននោះឡើយ ព្រោះពួកគាត់ ចូលរួម ប្រកប ដោយ ស្មារតីស្ម័គ្រចិត្ត បំរើប្រយោជន៍យួន។

## វិធានការ របស់ គណបក្សសង្គ្រោះជាតិ

វិធានការគ្រប់បែបយ៉ាង ដែល ពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិកំពុងរកដំណោះស្រាយ កុំអោយ អាជ្ញាធរយួន ចាប់ លោក កឹម សុខាគ្រាន់តែជា កាតព្វកិច្ច នៃ សាមគ្គីភាព រវាង សមាជិករួម តែប៉ុណ្ណោះ ព្រោះ បើតាមការពិសោធ ធ្លាប់មានមក ពួកគាត់ គ្មានចិត្តមុតនឹង រានទីនឹង អំណាចយួន នោះឡើយ ដូចយ៉ាង ករណី លោក សម រង្ស៊ី, ហុងសុខហួរ, អ៊ុំ សំអាន និង អ្នកទោសមនសិការ ពួកគាត់ គ្មានប្រតិកម្មនយោបាយអ្វី ក្រៅពី បន្ត សកម្មភាពជា ធម្មតា នៅក្នុងរដ្ឋសភា ដូចជារឿងទាំងនោះ ជា កិច្ចជានា នៃ សេចក្ដីសុខ របស់ពួកគាត់ទៅវិញ។រឿងនេះជាការចំឡែកមែន ! ព្រោះ ការស្វែងរកសេចក្ដីសុខនេះហើយ ដែលនាំអោយអាជ្ញាធរយួន បន្តយុទ្ធសាស្ត្រ វាយលុក របស់គេជានិច្ច ព្រោះយួន គេមានពុតច្បាស់លាស់ ឯចំណែកគណបក្សប្រឆាំង មិនដែលចោលការចែចូវ ដូចមានចែងនៅក្នុង បណ្ដាំចាស់បូរាណខ្មែរ។

## គោលជំហរប្រជាពលរដ្ឋខ្មែរ

នៅក្នុងវិបត្តិបច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរ ភាគច្រើនដាច់ខាត ច្បាស់ជាគាំទ្រ គណបក្សប្រឆាំង ព្រោះរឿងនេះ វាជាប្រត្យក្សភាព របស់អ្នកស្នេហាជាតិខ្មែរ តែ យើងអាចសួរជា សំណួរថា តើ ពួកអ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិគាត់ ប្រាកដ ជា នៅជា មួយអ្នកគាំទ្រគាត់ជានិច្ចនោះដែរឬទេ ? គ្មានអ្វី ជាការពិតប្រាកដនោះឡើយ ព្រោះការពិសោធន៍នៅ ឆ្នាំ ២០១៣-១៤ បង្ហាញ អោយឃើញច្បាស់ថា ពួកអ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ ភាគច្រើន ជាអ្នករេតាមខ្យល់ ដូច្នេះ បើគាត់ មើលឃើញ អត្ថប្រយោជន៍របស់ពួកគាត់ គឺគាត់ច្បាស់នឹង ដើរចេញពីជួរប្រជាពលរដ្ឋ អ្នកគាំទ្រពួកគាត់ ជា ពុំខាន៖ រូបភាព ពួកគាត់ដើរចូលរដ្ឋសភា, លោក សម រង្ស៊ី ស្រស់ស្រូបអាហារ ជាមួយលោក ហ៊ុន សែន វាមិនអាចលុបបាត់ពីសតិម្ចាស់ឆ្នោតបាននោះទេ។

## សម្ភខីកម្ម ផ្ទាល់

អាជ្ញាធរយួន ថា រឿង លោក កឹម សុខា ជា កិច្ចការយុត្តិធម៍ ចំណែកពួកអ្នកដឹកនាំគណបក្សសង្គ្រោះជាតិ ថា ជា

រឿង នយោបាយ, បើជារឿងនយោបាយ, ដោយបច្ច័យភាព ត្រូវមាន មធ្យោបាយនយោបាយសំរាប់យកទៅដោះស្រាយ បញ្ហា តើ ពួកអ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ មានមធ្យោបាយបែបណា ? តាមទម្លាប់ ពួកគាត់តែងតែធ្វើសម្បទាន ជាមួយនឹងអំណាចយួន តាមរយៈ គណបក្សប្រជាជនៈ ចូលរដ្ឋសភា, បង្កើត គ.ជ.ប. ថ្មី តែមានអ្នកដឹកនាំចាស់, វប្បធម៌សន្ទនា។ល។ តើ លើកនេះ ពួកគាត់មានអ្វីថ្មីទៀត យកទៅដូរ ជាមួយនឹងអំណាចយួន បើអាជ្ញាធរយួន គេ ព្យួរសិន នូវការចាប់ខ្លួន លោក កឹមសុខា ? យើងដឹងរួចហើយ ថា តុលាការយួន តែងតែព្យួរសិនរឿងយុត្តិធម៌ជាមួយអ្នកប្រឆាំងមតិនឹងអំណាចយួន តែពេលណា គេចង់លើក យកមករករឿងវិញ គេ គ្រាន់តែគឿនឡើងវិញ ដូច ករណី លោក សម រង្ស៊ី និង អ្នកទោសមនសិការសព្វថ្ងៃ ជាឧទាហរណ៍ ដូច្នេះបើមានអ្វីថ្មីយកទៅដូរ ក៏វាគ្មានអ្វីបញ្ចប់រឿងនោះដែរ អ្នកជាប់ចោទ នៅតែនៅក្នុងអន្ទាក់ យុត្តិធម៌យួនជានិច្ច ព្រោះ អាជ្ញាធរយួន វាមិនដែល គោរពច្បាប់ខ្មែរ ម្តងណាឡើយ។

## ការភ្ញាល់ប្រថុយ

អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ មានបំណង យក ការមិនធ្វើ មហាបាតុកម្មអហិង្សា ទៅដូរនឹង ការឈប់តាមចាប់ លោក កឹម សុខា, សួរថា តើ ពួកគាត់ នៅមានលទ្ធភាពអាចកោះហៅប្រជាពលរដ្ឋ អោយធ្វើបាតុកម្ម បានដែរឬទេ ? ព្រោះ អំពើ នេះ ជា ការបង្ហាញ កម្លាំងនយោបាយ របស់ បក្ស។ តែការភ្ញាល់នេះវាជាការប្រថុយណាស់ក្នុងឋានៈគណបក្ស សង្គ្រោះជាតិ ជា គណបក្ស អាចប្តូរអំណាចបាន ព្រោះថា បើអាជ្ញាធរយួន ចាប់ លោក កឹម សុខា ហើយ ពួកអ្នកដឹកនាំគណបក្សប្រឆាំង មិនអាចប្រមូលមនុស្សអ៊ឹកធឹកធ្វើបាតុកម្មបាន គឺ ជា បារាជ័យនយោបាយមួយធំណាស់, តែបើពួកគាត់ មិនធ្វើអ្វីសោះ ក៏ទុកជា បរាជ័យនោះដែរ។

## អ្វីដែលគេមិនទាន់ដឹង

គឺ សេចក្តីក្លាហាន របស់ ពួកអ្នកដឹកនាំគណបក្សសង្គ្រោះជាតិ និងសេចក្តីស្ម័គ្រចិត្ត របស់ប្រជាពលរដ្ឋ ហ៊ានប្រឈរមុខនឹងអំណាចចក្រពត្រយួនបំពានច្បាប់ខ្មែរ និងឈ្លានពានទឹកដីខេមរា។ ព្រឹត្តិការណ៍ ដែលកំពុងកើត

មាននេះ ជា វិញ្ញាសាមួយ នៃ សាមគ្គីភាព រវាងខ្មែរ ជាអ្នករងគ្រោះនឹងអំណាចចក្រពត្រយួន ដែល យួន យកគណបក្សប្រជាជនធ្វើជាបាតដីទី៣ សំរាប់ សម្លាប់ អ្នកស្នេហាជាតិខ្មែរ។ បើខ្មែរ មានសេចក្ដីក្លាហាន គឺខ្មែរឈ្នះ តែបើខ្មែរយើង កំសាក គឺច្បាស់ជាប្រជាជាតិខ្មែរនឹងស្លាប់ នៅពេលខ្លីខាងមុខនេះជាពុំខាន។ សេចក្ដីក្លាហានមិនមែនត្រូវប្រើ កម្លាំងហិង្សា ប្រឆាំងនឹង អំណាចចក្រពត្រយួននោះឡើយ, សេចក្ដីក្លាហាន គឺប្រើ សិទ្ធិអំណាចយើង ជាពលរដ្ឋខ្មែរ ការពារយុត្តិធម៌ប្រឆាំងនឹង អយុត្តិធម៌ តាមសន្តិវិធី។ តើខ្មែរយើងអាចធ្វើបានដែរឬទេ ?

# យួនត្រួតត្រានៅស្រុកខ្មែរ មិនគោរពច្បាប់ខ្មែរ

*សេរីការ*



ពួកយួនកុម្មុយនិស្ត ត្រួតត្រានៅស្រុកខ្មែរ វាមិនគោរពច្បាប់ខ្មែរ ហើយ វា នាំ គ្នា ប្រើប្រព័ន្ធយុទ្ធធម៌ខ្មែរ អោយបំពានច្បាប់ជាតិ ឥតរញ៉រាបន្តិចបន្តួចនោះឡើយ ដូចយ៉ាង ចាប់ខ្លួន លោក ហុង សុខហួរ, អ៊ុំ សំអាន ដែល ជាបុគ្គល ប្រដាប់ដោយ អភ័យឯកសិទ្ធិ ជា សមាជិកសភាជាតិហើយ បច្ចុប្បន្ននេះ មានបំណងចាប់ លោក កឹម សុខា, ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ និង ជា តំណាងរាស្ត្រ ពីបទ មិនចូលខ្លួន បំភ្លឺតុលាការ តាមដីកាកោះហៅរបស់ សុភាចារបុរស ក្នុងឋានៈជា សាក្សីក្នុងរឿង ពាក់ព័ន្ធនឹងសញ្ញារកម្ម។

## ការរំឭក អំពីច្បាប់ខ្មែរ

ការរំឭក អំពីច្បាប់ខ្មែរ ដល់ពួកយួនត្រួតត្រានៅស្រុកខ្មែរៈ ដីកា របស់សុភាចារបុរស វាខុសច្បាប់ រដ្ឋធម្មនុញ្ញជាតិខ្មែរ ព្រោះ លោក កឹមសុខា,ដូចគ្នានឹង ករណី លោក ហុង សុខហួរ, អ៊ុំ សំអាន, ជា បុគ្គល ប្រដាប់ដោយ អភ័យឯកសិទ្ធិក្នុង ឋានៈគាត់ ជា សមាជិកសភា ដូចបានជំរាបខាងលើ

រួចហើយ ; ដូច្នេះ បើគ្មានការអនុញ្ញាតពីរដ្ឋសភា តាមការបោះឆ្នោត យល់ព្រមដក អភ័យឯកសិទ្ធិ ពីសមាជិកខ្លួនតុលាការ គ្មាន នីតិសម្បទាន អាចកោះហៅសមាជិកសភាអោយចូលខ្លួនបំភ្លឺ ក្នុង ឋានៈជាអ្វីមួយនោះឡើយ ហើយនគរបាលព្រហ្មទណ្ឌ គ្មានអំណាចណាទៅចាប់ សមាជិកសភា បាននោះដែរ វៀរលែងតែ បុគ្គលនោះ ប្រព្រឹត្តបទល្មើសជាក់ស្តែង។ ដូច្នេះ កោលាហល ដែល ពួកយួន នៅស្រុកខ្មែរ កំពុងធ្វើនេះ គឺ ច្បាស់ជាពួកទាំងនោះ ប្រើ ច្បាប់ព្រៃ ឬ ច្បាប់ កុម្មុយនិស្ត ដែលពួកចៅហ្វាយខ្លួននៅស្រុកយួន ប្រើសំរាប់វាយកំទិចអ្នកប្រឆាំងលទ្ធិកុម្មុយនិស្តយួន។

## ការរំឭក អំពី ការចរចា

ការចរចា អាចមាន លទ្ធផលជាវិជ្ជមាន លុះត្រាតែ ដៃគូនៃ ការចរចាមានគោលប្រយោជន៍រួម និង មាន កម្លាំងស្មើគ្នា, តែថា នៅស្រុកខ្មែរយួនកុម្មុយនិស្ត និង ភាគីខ្មែរដែល ជាគណបក្សប្រឆាំង គ្មានអ្វីដែលអាចទុកជា គោលប្រយោជន៍រួម ហើយ គ្មានកម្លាំងស្មើគ្នា នោះឡើយ,ដូច្នេះការចរចា រកដំណោះស្រាយនយោបាយ គឺគ្មានអ្វីក្រៅពី ភា

គឺខ្មែរត្រូវតែ ទទួលយល់ព្រម តាមការចង់បាន របស់ភាគីយួន, តែងតួ ជាខ្មែរ, តែប៉ុណ្ណោះ ហើយ ការចរចា ជាមួយគណបក្សកាន់អំណាច វាគ្មានប្រយោជន៍អ្វីនោះដែរ ព្រោះគណបក្សនេះ ជា អាយ៉ងយួន ហើយ គ្មានអំណាចអ្វី ធ្វើការសម្រេចលើអ្វីមួយ ដែលជាប្រយោជន៍ខ្មែរ ក្រៅពី មានអំណាចយួនប្រគល់អោយ សំរាប់ សម្លាប់ខ្មែរអ្នកប្រឆាំងនឹងប្រយោជន៍យួន ក្នុងតួនាទីជាបាតដីទី៣។ ប្រតិកម្មទូតសហរដ្ឋអាមេរិក សូមឲបន្តរប្បធម៌សន្ទនា គឺគ្រាន់តែជាសំដីខ្យល់គ្មានយកការពិតខ្មែរ មកធ្វើជាគោលពិចារណាអ្វីបន្តិចនោះឡើយ គឺថាដូចសូមអោយកូនចៀមបន្ត ការចរចា ជាមួយខ្លាអត់ឃ្លានចំណី យូរថ្ងៃមកហើយ។ យួនគ្មានប្រយោជន៍អ្វី អោយខ្មែរ មានសាមគ្គីភាពជាតិនោះជាដាច់ខាត ហើយ ក៏មិនចង់អោយ លទ្ធិប្រជាធិបតេយ្យ មានជ័យជំនះនៅស្រុកខ្មែរព្រោះ វាជាគ្រោះថ្នាក់ ដល់យួន និង លទ្ធិកុម្មុយនិស្តខ្លួន ដូច្នេះយួន បង្កើត ការរីករវជាអចិន្ត្រៃយ៍នៅស្រុកខ្មែរ។

## ការរំឭក អំពី ទង្វើភាន់ច្រឡំ របស់គណបក្សប្រឆាំង

គណបក្ស ប្រឆាំង គ្មាន យុទ្ធសាស្ត្រអ្វីច្បាស់លាស់ សំរាប់ប្រឆាំងនឹង គណបក្សកាន់អំណាច ក្រៅពីដេកចាំបោះឆ្នោត ដោយសង្ឃឹម ថា អាចនឹងមានការបោះឆ្នោតមួយត្រឹមត្រូវ ព្រោះមាន គ.ជ.ប. ថ្មី។ មាយាការ នេះឯង ដែលនាំឲគណបក្សប្រឆាំង ចុន គិតតែរង នូវ ការវាយប្រហារ ឬ បំពាន គ្រប់បែបយ៉ាង មកលើខ្លួន រហូត គេហ៊ានវាយប្រហារ លោកសម រង្ស៊ី ដែលជាប្រមុខរបស់ខ្លួន ក៏គ្មានប្រតិកម្មសមាមាត្រនឹង ទង្វើនេះដែរ បែរជាបង្កើត យុទ្ធសាស្ត្រ មិនឆ្លើយ, មិនឈ្លោះ ដែលជាយុទ្ធសាស្ត្រ សំរាប់ អ្នកខ្សោយ សូមរស់តែប៉ុណ្ណោះនៅក្នុង របបសិទ្ធិអំណាច។អ្វីដែលបន្តកើតឡើងសព្វថ្ងៃនេះ គឺជា សមាថ័យ នៃ ទង្វើភាន់ច្រឡំរបស់គណបក្សប្រឆាំងខ្លួនឯង តែកម្មផលវិញ គឺ ប្រជាពលរដ្ឋខ្មែរ ជាអ្នកទទួល ព្រោះ ជាការភាន់ច្រឡំបើកឱកាស អោយយួន អាចពង្រឹងអំណាចគេបានងាយស្រួលបំផុតនៅស្រុកខ្មែរ បើនិយាយជាសង្ខេប គឺអប្បបញ្ញានៃ ពួកអ្នកដឹកនាំគណបក្សប្រឆាំង ជា លាភជ័យ របស់យួន នោះឯង។

## ដំណោះស្រាយ

គឺគ្មានអ្វីក្រៅពីការវិល មករក ធាតុសារវន្ត របស់ខ្លួន ជា គណបក្សប្រឆាំង ដែលមានតួនាទីជា អ្នកប្រឆាំង ជាពិសេស នៅក្នុង បរិបទនៃជីវិតភាពនយោបាយខ្មែរ។ នាំគ្នាដេកចាំបោះឆ្នោត ជា និស្សកម្ម ; តែធ្វើសកម្មភាព ក្នុងឋានៈជា អ្នកប្រឆាំងនឹងអំណាចយួន ដើម្បីឲមានការបោះឆ្នោតត្រឹមត្រូវ ជា សកម្មភាពវិជ្ជមាន ដូច្នេះ មិនត្រូវខ្លាច ធ្វើពិហិការ បើសិន លក្ខខណ្ឌ នៃ ការបោះឆ្នោត វាមិនស្របនឹង លទ្ធិប្រជាធិបតេយ្យ។ ការឈប់ធ្វើសហការគ្រប់បែបយ៉ាង ទោះបីនៅក្នុងរដ្ឋសភា ជាមួយ គណបក្សកាន់អំណាច ដែល ជា បក្សបំរើប្រយោជន៍យួន គឺជា ការបង្ហាញ នូវគោលជំហរច្បាស់លាស់ ក្នុងឋានៈជាអ្នកប្រជាធិបតេយ្យ។ តែបើ គណបក្សប្រឆាំង នៅតែមាន មាយាការថា ការចរចា ជាមួយគណបក្សកាន់អំណាច អាចរកឃើញដំណោះស្រាយ សំរាប់រកប្រយោជន៍ជាតិបាន គឺ ច្បាស់ជានាំគ្នា ការពារប្រយោជន៍យួនកុម្មុយនិស្ត ជាពុំខាន។ ត្រូវខ្មែរមានស្មារតីថា បញ្ហាខ្មែរសព្វថ្ងៃ គឺជាបញ្ហា ខ្មែរនឹងយួន មិនមែនជា បញ្ហា ខ្មែរនិងខ្មែរ នោះឡើយ ព្រោះស្រុកខ្មែរជា ស្រុក រស់នៅក្រោម អាណានិគមយួន។ សព្វថ្ងៃអង្គការ

សហប្រជាជាតិក្តី, សហគមន៍អន្តរជាតិក្តី, សហរដ្ឋអាមេរិកក្តីគេស្គាល់ បញ្ហាខ្មែរច្បាស់ណាស់ តែគេមើលឃើញថា កត្តានៃ អប្បបញ្ញានៃ អ្នកនយោបាយខ្មែរ ដែលជា បញ្ហា មិនអាច អោយខ្មែរជួយខ្លួនដោយខ្លួនឯងបាននោះឡើយ ដូច្នេះ គេមិនអាចប្រកាន់ជំហរណាមួយ ដើម្បី ជួយដោះស្រាយ បញ្ហាខ្មែរ បើ គេ មើលមិនឃើញ នូវ ឧទ័យ (émergence) នៃ កម្លាំងជាតិខ្មែរ ណាមួយ កើតឡើងដែល មានអ្នកដឹងនាំ មាន គុណសម្បត្តិ ជាអ្នកដឹកនាំជាតិ ពិតប្រាកដ ព្រោះសម័យ ប៉ុល ពត នៅតែលងគេជានិច្ច ; មួយវិញទៀត ស្រុកខ្មែរ មិនមែនជាអាទិភាព នៃនយោបាយ អន្តរជាតិ នោះឡើយ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា បើខ្មែរយើង មិនជួយខ្លួនឯង គឺ យួនគេជួយយួនគ្នាគេ អោយយកស្រុកខ្មែរ ធ្វើជាស្រុកយួននោះឯង៕

# រាជានិយមខ្មែរ

*សេរីការ*



គេថាស្រុកខ្មែរ មានអ្នកដឹកនាំ ពន្លង់ ក្នុង អវិជ្ជា យកក្បួនលក់ជាតិជា នាយកជម៌ ពាក់ងារ ជា អភិជន អហិរិក , ភ្លេច វណ្ណភាពខ្លួន ពីកំណើត ជា រាស្ត្រ,  ប្រើ អំណាច ជា យុត្តិធម៌ ប្រើ វណ្ណៈ ជា អាជ្ញា ស៊ីករូប ជា ព្រះ អួតខ្លួន ថា ជា អ្នកមានបុណ្យ នាំគ្នា អនុវត្ត ច្បាប់ តាមចិត្តចង់បាន, ចាប់ អ្នកស្នេហាជាតិ និង អ្នកការពារសិទ្ធិមនុស្ស ដាក់គុក ឥតមាន ការវិនិច្ឆ័យ, សម្លាប់ ខ្មែរអ្នកជា ចោទថា ជនក្បត់សន្តិភាព ព្រោះ ខ្លួន មាន យួន ជា អ្នកការពារ ជា បងធំ រស់ជា អ្នកធំ នៅកម្ពុជា ពាក់ស័ក្តិ ជា មន្ត្រីជាតិខេមរា ដូរឈ្មោះ ជា ខ្មែរ សែនពិរោះ រួចធ្វើ ជា អ្នកអាន់ជ្រី ពេញក្រសួង ទុកខ្លួនជា  ពួកជើងកាប់ ប្លន់ បាន រដ្ឋខេមរា យកមកធ្វើ ជា កម្មសិទ្ធិ ហើយ ដឹកយួន រាប់លាននាក់ ចូលមករស់នៅពេញស្រុកខ្មែរ ធ្វើជា ម្ចាស់ បំណុល ៧ មករា ស៊ីការប្រាក់ សងមិនដាច់ ទាំងដើមទាំងការ ត្រូវ ប្តូរនឹង ទឹកដី ជា កតវេទិតា ។

សព្វថ្ងៃ ស្តេច ថ្មី បាក់អំនួត គ្មាន អាមាត្រ ជា អ្នកទាស យក ព្រះសង្ឃជា អ្នកជំនួសអោយលុតជង្គង់ សំពះ អញ ជា ស្តេច វង្វេងជាតិ ព្រោះគ្មានចំណេះ ជាមហារាជ្យ មាន ទស ពិធរាជធម៌ យក ពុទ្ធសាសនា ជា ធម៌ យក យុត្តិធម៌ ជា ក្បួន ស្វែងរក សុខដុម សំរាប់ សង្គមជាតិ។ ស្តេចសីហមុនី ឈ្មោះនេះ មានន័យល្អ សមជា ក្សត្រ មាន ការចេះដឹង មានបារមី ជា សមណ: ដើរស្វែង រកធម៌ ដើម្បី បំរើប្រជារាស្ត្រ ព្រោះជារាស្ត្រទ្រទ្រង់ព្រះអង្គ ហើយ ទុកជាឧត្តមជន មានគតិយុត្តិធម៌ ក្នុងប្រាជ្ញាប្រកបដោយ សេចក្តីស្នេហា ដែលជា ជម្រក ជ័ត្រជាក់ត្រជុំ ដល់ ជាតិខេមរា។ តែការពិត ឈ្មោះ និង អាកប្បកិរិយា របស់ព្រះអង្គ មានខ្លឹមសារ ខុសគ្នា ព្រោះ ឈ្មោះ សីហមុនី ជា គោឃ្មួន គេចិញ្ចឹមក្នុង សួនសត្វ ហៅថាវាំង មាន របបចំណី គឺ សាច់កូនខ្មែរ និង ឈាមជាតិខេមរា ជាទឹកផឹក រស់គ្មានដឹងការពិតពីទុក្ខ ខ្មែរ, គិតតែងតាំងងារ ពួកលួចជាតិជា សម្តេច ហើយ មាន អ្នកបន្ទរ ថាត្រូវគោរព ព្រោះជាងារ រាជអំណោយ ជាមហាកិត្តិយស សំរាប់រាស្ត្រ ទោះបីជាតិកំពុងមាន អន្តរាយ ដោយសារមានយួនរស់ពេញស្រុក ; ត្រូវនាំគ្នា ប្រើ

រាជងារ ក្នុងចុតហ្មាយ ដើម្បី ជាប្រណិប័តន៍ ដល់បូជនីយ: (homme respectable) ព្រោះពួកសម្តេច ជាអ្នកដឹងគុណ ដល់ឃួន ស្រជាំង នឹង គុណមាតា។

ស្តេចខ្មែរណា មានអគតិ គឺជាស្តេច មិនស្គាល់ព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃជា ព្រះរតនត្រ័យ ដែលប្រសើរ ក្រៃលែងជាង អវិញ្ញាណករតនៈ និង សវិញ្ញាណករតនៈ មានមាសជាដើមក្តី មានស្រីកែវជាដើមក្តី ប្រៀបផ្ទឹមនឹង ព្រះរតនត្រ័យមិនបានទេ ដូចយ៉ាង មាសប្រាក់ បើគេយកទៅប្រដាប់លើ មនុស្សទុច្ចរិត វាមិនអាចធ្វើគេ ឲក្លាយទៅជាមនុស្សល្អ គួរគោរពបានឡើយ មិនប្លែកគ្នាពីគេយក មកុដ ទៅប្រដាប់ ឲស្វាប់ប៉ុន្នានទេ ។ ការយកព្រះសង្ឃ ជា ទ្រនាប់ព្រះបាត លុតជង្គង់ ក្រាបថ្វាយបង្គំអញ ជា ស្តេច គឺដូចគ្នានឹង ស្វាប្រដាប់មកុដ មិនស្គាល់ បុណ្យ-បាប ជា ជនខ្មែរ មិនដឹង ប្រពៃណី ជា មហាក្សត្រខេមរា រស់ទំនឹមនឹង មនុស្សពាល ឥតសាសនា។ គេសន្និដ្ឋានបានថា រាជានិយមមានស្តេច ឥតស្គាល់ ព្រះរតនត្រ័យ ជា រាជានិយមកាឡៃ នៅក្នុងរដ្ឋមាន ពុទ្ធសាសនា ជាខ្សែសីមា សំរាប់ការពាររដ្ឋា មាន ព្រះសង្ឃនាំថាគ្រប់បីដង សំរាប់អ្នកសមាទានថាតាមៈ

ខ្ញុំព្រះករុណា សូមដល់ព្រះពុទ្ធ ជាទីពឹង ទីរឮក។ ខ្ញុំព្រះករុណា សូមដល់នូវធម៌ ជាទីពឹង ទីរឮក។ ខ្ញុំព្រះករុណា សូមដល់ព្រះសង្ឃ ជាទីពឹង ទីរឮក។ ដូច្នេះ ព្រះរតនត្រ័យពិតជាទីពឹង ទីរឮក ជា កត្តូបការៈ និងពំនឹងនៃ ប្រជាជាតិ រាប់ពាន់ឆ្នាំ។ ចុះហេតុអ្វី ស្តេច សីហមុនី ព្រះអង្គ ប្រមភ្លេចធាតុដើមកំណើតខ្លួន ជា វង្ស អ្នកទ្រទ្រង់ពុទ្ធសាសនា និងពុទ្ធសាសនិក ច្រើនសតវត្ស តតលំអៀង ក្នុងដែនសុវណ្ណភូមិ ? ចម្លើយមាន តែមួយគត់ ព្រោះ ព្រះអង្គ ខ្លាច យួនកុម្មុយនិស្ត អ្នកប្រទូសសាសនា; ឪ! អនិច្ចា នេះហេតុតែព្រះអង្គ ជាលុទ្ធបុគ្គល ស្រឡាញ់បល្ល័ង ជាង ជាតិ និងសាសនា សុខចិត្ត ធ្វើស្វា ប្រដាប់មកុដ រស់ក្នុងសុភមង្គលអាត្មា លើទុក្ខរាស្ត្រ, រស់ សំរាប់ជាតិស្លាប់ ព្រោះ ចង់ធ្វើស្តេចទាសបំរើយួនយ៉ាងមោះមុត រហូតដល់ថ្ងៃស្លាប់ ភ្លេច ញាតិមិត្ត ជាអ្នកស្នេហាជាតិ ភ្លេចអស់ថាស្រុកខ្មែរ មានខ្មែរជាម្ចាស់ស្រុក៕




ឱ! អនិច្ចា នេះហេតុតែ ព្រះអង្គ ក្បត់សាសនា  ពួកយួនកុម្មុយនិស្ត ត្រួតត្រានៅស្រុកខ្មែរ វាមិនគោរព។

# ឈានទៅចាប់យកអ្វី ?

*សេរីការ*



អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ ជ្រើសរើស ការដោះស្រាយ ស្រំដែល ដែលខ្លួនធ្លាប់ប្រើគ្មានប្រសិទ្ធិភាពអ្វីនោះឡើយ។ សួរថា តើ ពួកគាត់ ទុកប្រជាពលរដ្ឋ ជាអ្នកល្ងង់ខ្លៅ អាចបញ្ឆោតបានរាល់ដង ឬ ពួកគាត់ជាពួកលលាគ្មានចេះដកការពិសោធពីទង្វើគ្មានលទ្ធផល យកមកធ្វើជាមេរៀន។ អធិយោគ ក្នុងការភាន់ច្រឡំ មិនមែនជាសញ្ញា នៃ បញ្ហានោះឡើយ ផ្ទុយទៅវិញ វាជា ភាពកន្ទ្រានក្នុងភពអវិជ្ជាដូចយ៉ាង៖

## ការដោះស្រាយតាមផ្លូវព្រះមហាក្សត្រ

អនុស្សតិ វានៅមាន ថ្មីៗ នៅឡើយ លើ អាក្សកិរិយា ព្រះមហាក្សត្រក្រុងកម្ពុជា ក្នុង វិបត្តិនយោបាយខ្មែរ គឺ ព្រះអង្គតែងតែស្ថិតនៅ ខាងពួកអ្នកប្រព្រឹត្តអំពើអយុត្តិធម៌ជានិច្ច ព្រោះ ព្រះអង្គ ជា មហាក្សត្រ ដែលក្រុមនោះ គេជ្រើសតាំងឡើង ដើម្បី បំរើ ប្រយោជន៍នយោបាយរបស់ពួកគេ ដូច្នេះ ព្រះអង្គ គង់លើបល្ល័ងបាន ត្រូវមានសរុណ: (សេចក្ដីទីពឹង) លើពួកគេ ពុំនោះ ព្រះអង្គ នឹងអាចមាន

បញ្ហាដល់រាជ្យរបស់ព្រះអង្គ។ រឿងនេះ នរណា ក៏គេដឹងដែរ ថា ស្តេចខ្មែរបច្ចុប្បន្ន ជាឧបករណ៍នយោបាយ របស់យួន កុម្មុយនិស្ត តែបើពួកអ្នកដឹកនាំគណបក្សប្រឆាំង ធ្វើជា មិនដឹង គឺពួកគាត់ជាអ្នកសក់ឡក់ យកព្រះមហាក្សត្រ មកលែងសើច នាំគ្នាថ្វាយ ប្រជាបង្គនាលិខិត ដល់ ព្រះ អង្គទោះបីដឹងថា ព្រះអង្គ គ្មានអំណាចប្រត្យក្ស និង សិទ្ធិ សិលធម៌ អ្វី សំរាប់ធ្វើអន្តរាគមន៍ ក្នុងវិបត្តិនយោបាយ បច្ចុប្បន្ន ក៏ដូច សព្វដង ដែលវាធ្លាប់មានកើតឡើងរួច មកហើយ។ តែ ព្រះមហាក្សត្រ ក៏ឆ្លើយតបវិញតាមការ មាក់ងាយ ដល់ប្រជាពលរដ្ឋ ដូចយ៉ាង អោយមន្ត្រីរាជវាំង ចេញមកទទួលញត្តិប្រជារាស្ត្រ នៅក្រៅរបងរាជវាំង ហាក់ បីដូចទុក ពួកអ្នកតំណាងរាស្ត្រ ដែលនាំញត្តិទៅថ្វាយព្រះ អង្គ ជាមនុស្សគ្មានតម្លៃអ្វីបន្តិចនោះឡើយ។ អាកប្ប កិរិយាបែបនេះ ជាកញ្ចប ដែលនាំអោយព្រះអង្គ មិនអាច ជា រតនៈក្សត្រ នោះឡើយចំពោះប្រជារាស្ត្រ។ ទោះជាមាន ប្រតិកម្មអវិជ្ជមាន បែបនេះក៏ដោយ ក៏ពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិនៅតែទទូច ប្រមូលហត្ថលេខានៃ ប្រជាពលរដ្ឋ យកទៅ ថ្វាយព្រះមហាក្សត្រ បន្តទៀត។

ករណីបែបនេះ លោក កឹម សុខា ខ្លួនឯង ក៏គាត់ធ្លាប់ និយាយ ពីអតិតកាលថា ការរក សេចក្តីរំពឹងពី ព្រះមហាក្សត្រ ជាការសង្ឃឹមខកចិត្តតែប៉ុណ្ណោះ។

## វិធីដើងល័ព្វ

ប្រាកដណាស់ថា ការតស៊ូ ត្រូវធ្វើសកម្មភាពជានិច្ច តែបើសកម្មភាពនោះ វាជា វញ្ញកម្ម គឺ វា នឹងនាំអោយ ប្រជាពលរដ្ឋ ខូចទឹកចិត្ត នៅពេលណាមួយជាពុំខាន ព្រោះធនធានមនុស្ស វាមានកំរិត ទាំងផ្លូវរូបវន្ត និង គោលចំណង់ របស់វា។ ការប្រមូលអ្នកគាំទ្រអោយបានចំនួនច្រើនសំរាប់ ទ្រទ្រង់ការតស៊ូអោយមានរូបភាពពិតប្រាកដ គឺ ដើម្បីធ្វើមហាបាតុកម្មអហិង្សា ព្រោះ វាជា ជិពវិញ្ញាត្តិនៃ កម្លាំងមតិប្រឆាំងនឹង អំពើអយុត្តិធម៌ ដែលអាថ្មជរយួន តែងតែ ប្រព្រឹត្ត ជា អនន្តរ មកលើអ្នកស្នេហាជាតិ និង ប្រជាពលរដ្ឋខ្មែរ, ជាពិសេស យកច្បាប់រដ្ឋធម្មនុញ្ញខ្មែរ មកជញ្ជាន់ បិដូចយក សិរសា ប្រជាជាតិខ្មែរ មកជាន់ ដើម្បី ប្រមាទមាក់ងាយ។ ដូច្នេះ នាំគ្នាអង្គុយចាំយួនចាប់ខ្លួន លោក កឹម សុខា សិន ទើបនាំគ្នាធ្វើបាតុកម្ម វាជា វិធី

ការពារខ្លួន គ្មានប្រសិទ្ធិភាពចំពោះការវាយលុក របស់អ្នកដឹកនាំយួន នៅស្រុកខ្មែរ៖ គេ ការពារខ្លួន មុនពេលចាប់ មិនមែន ចាប់រួចហើយ ទើបនាំគ្នា ការពារខ្លួននោះឡើយ ព្រោះថា កម្ម និង ប្រតិកម្ម វាមាន អនុភាព ខុសគ្នា៖ កម្ម គឺជាសកម្មភាព រកដំណោះស្រាយ ដែលចង់បានជាស្ថាពរ ក្នុងគោលដៅវិសាយ, រីឯ ប្រតិកម្មវិញ គឺជា សកម្មភាព រង នឹងកម្លាំងវាយលុក លើគោលដៅដែលមានដែនកំណត់ច ង្អៀត។ ហេតុនេះឯងពួកអ្នកដឹកនាំគណបក្សប្រឆាំង ត្រូវ ដឹងខ្លួនឯង អោយ ច្បាស់ អំពី ការចង់បាន របស់ខ្លួនក្នុង ករណី លោក កឹម សុខា៖ គឺថា ចង់បាន ត្រឹមតែកុំអោយ អាជ្ញាធរយួនកុំចាប់ខ្លួនលោក កឹម សុខា ឬ លើកនេះ ចង់ ការពារ នូវ យុត្តិធម៌ទូទៅ ដែលអាជ្ញាធរយួន តែងតែ បំពានមកលើច្បាប់ខ្មែររហូតមកដល់សព្វថ្ងៃនេះ។

បច្ចុប្បន្ននេះ ពួកអ្នកដឹកនាំគណបក្សសង្គ្រោះជាតិគាត់ កំពុងធ្វើដូចគ្នានឹងទង្វើឆ្នាំ ២០១៤ នៅទីលានប្រជាធិប តេយ្យ, ដូច្នេះ របៀបចាស់ វានឹងនាំមកនូវលទ្ធផលចាស់ នោះដែរ។ នរណាក៏គេដឹងដែរថា ពេលវេលាវាធ្វើការអោយ អាជ្ញាធរយួន ព្រោះយួន គេស្គាល់មារយាទ របស់ពួកអ្នក

ដឹងនាំ គណបក្សប្រឆាំង ច្បាស់ណាស់ គឺ៖ ឆ្អិនក្បាល ស៊ីក្បាល ឆ្អិនកន្ទុយ ស៊ីកន្ទុយ។

## ទីបញ្ចប់ វានឹងមានប្រយោជន៍អ្វី ?

ឈានទៅចាប់យកអ្វី ? ទទេ ? ត្បិត សំណួរ របស់យើង វាគ្មានចម្លើយជាទូទៅ, ដូច្នេះ សុំទុកការៈជូន មិត្តអ្នកអានឆ្លើយដោយខ្លួនឯង ព្រោះរឿងនេះជារឿងរបស់ប្រជាជាតិ។ ជាពិសេស វិស័យមតិ របស់យើងមិនមែនមាន លក្ខណៈជាការវិនិច្ឆ័យ ដាក់កំហុស ដល់ពួកអ្នកដឹកនាំគណបក្សប្រឆាំងនោះឡើយ តែគ្រាន់តែជា វិធីសាស្ត្រ ដែលយើងយល់ឃើញតែប៉ុណ្ណោះ។ ព្រោះកំហុស របស់ ពួកអ្នកដឹងនាំគណបក្ស សង្គ្រោះជាតិ វា មាន រួចស្រេចនៅក្នុងទង្វើខុសឆ្គងរបស់ពួកគាត់តាំងពីដើមអាណត្តិរដ្ឋសភាបច្ចុប្បន្ន គឺថា ពួកគាត់ នាំគ្នាជួយប្តូររូប រដ្ឋសភាខុសច្បាប់ អោយក្លាយជា សភាជាតិ ហើយនាំគ្នា ចូលធ្វើ សហការដោយស្ម័គ្រចិត្ត។ ដោយអកុសល រដ្ឋសភានេះឯង ដែលបានបោះឆ្នោត ខុសច្បាប់រដ្ឋធម្មនុញ្ញ ដកអភ័យឯកសិទ្ធិ លោកសម រង្ស៊ី និង អ៊ុំ សំអាន, តើពេលនោះពួកគាត់មានប្រតិកម្មអ្វី

ដែរ ? ពួកគាត់នៅតែបន្ត ធ្វើសហការជាប្រក្រតីនៅក្នុងរដ្ឋសភា, សួរថាតើ ករណី លោក កឹម សុខា វាខុសគ្នាអ្វីនឹងករណី លោក សម រង្ស៊ី និង អ៊ុំ សំអាន ? បើសិនជាពួកគាត់មានចម្លើយសមហេតុផលនឹងសំណួរនេះ គឺច្បាស់ជាពួកគាត់មិននៅចាំមើលអាផ្សាធរឃួន នឹងចាប់ខ្លួន លោក កឹម សុខា នោះឡើយព្រោះ អង្គុយចាំនេះ គឺ ជា យុទ្ធកថាបានតែចថា រឿង លន្លង់លន្លោច ជា អ្នករងគ្រោះ ខុសពីការប្រកាសថា ជា អ្នកសង្គ្រោះ ឬ ទំពាអៀងនៃបរាជ័យនៅក្នុងឆ្នាំ២០១៤ ដែល មាន រាស្ត្រ ជា សាខាគ្រោះ តែប៉ុណ្ណោះ៕

**បណ្តាំ របស់ ភិក្ខុ ប៉ាង ខាត់ :**

**បុគ្គលពុំគប្បីចងមិត្តសម្លាញ់ ឬ ចងស្ពានមេត្រីជាមួយទុរជន៙សោះ ពីព្រោះមនុស្សនោះប្រៀបដូចផ្សូង បើនៅក្តៅ វារលាកដៃ បើរលត់ វាប្រឡាក់ដៃ។ គេថាស្រុកខ្មែរ មានអ្នកដឹកនាំ ពន្លង់ ក្នុង អវិជ្ជា យក៕**

# ផលាយួនកុម្មុយនិស្ត នៅស្រុកខ្មែរ

*សេរីការ*



យើងដឹងច្បាស់ថា គណបក្សប្រជាជនកម្ពុជា ជាសាខា នៃ គណបក្សកុម្មុយនិស្តយួន បំរើផ្ទាល់ អាជ្ញាធរយួន នៅស្រុកខ្មែរ ជា បាតដៃទីបី ឬ ឃាតករ ដើម្បី ការពារប្រយោជន៍ យួន ដែលគេអោយឈ្មោះថា  សន្តិភាព ដើម្បីធ្វើអភិវឌ្ឍន៍ ជាតិ។

## ទស្សនៈយួនកុម្មុយនិស្តអំពីស្រុកខ្មែរ

សព្វថ្ងៃនេះ  អាជ្ញាធរយួន  នៅស្រុកខ្មែរ គេឈប់លាក់ខ្លួន នៅក្នុងអំណាចរដ្ឋខ្មែរទៀតហើយ ព្រោះ គេជឿថា គេមាន កម្លាំងគ្រប់គ្រាន់ដើម្បី  ត្រួតត្រាផ្ទាល់ស្រុកខ្មែរ ដោយគេ យល់ឃើញថា ជាតិខ្មែរ  គ្មានលទ្ធភាពទាំងពលំនិងបញ្ញា ដើម្បី  ប្រឆាំងនឹង  កម្លាំងយួននៅស្រុកខ្មែរបានជាដាច់ ខាត៖ ទោះបីជាតិខ្មែរនៅមានសល់កម្លាំងស្តួល តែកម្លាំង នេះ  មិនគ្រប់គ្រាន់ សំរាប់បង្កើតជា  កម្លាំងជាតិ  តស៊ូ រំដោះជាតិ  បាននោះឡើយ,កម្លាំងនោះ  គ្រាន់តែ  សំរាប់ តវ៉ា នូវសិទ្ធិរស់នៅ ជាប្រជាជន ភាគតិច ដូចខ្មែរ នៅកម្ពុជាក្រោម  តែប៉ុណ្ណោះ។ ចំពោះ យួនកុម្មុយនិស្ត ដំណើរ នៃ

យួនរូបនីយកម្មនៅស្រុកខ្មែរ ពុំអាចថយក្រោយបាននោះឡើយ ព្រោះ បរិបទ ជាតិខ្មែរនិងអន្តរជាតិបច្ចុប្បន្ននេះវាជាសុទិន[64] សំរាប់ជម្រុញអោយដំណើរនេះ កាន់តែលឿនបន្ថែមទៀត៖ យួន កុម្មុយនិស្ត កំពុង ធ្វើអោយ សុបិនដូនតាយួន ក្លាយជាការពិត។ នៅក្នុងទស្សវត្សរ៍៣០ យួនកុម្មុយនិស្ត គេទុកស្រុកខ្មែរ ជាទីកដី សំរាប់យួន អាចវាយដណ្តើមយកបាន។ នៅក្នុង ទស្សវត្សរ៍ ៧០ ទ័ពយួន កាន់កាប់ទឹកដីខ្មែរ ២/៣ យកទឹកដីខ្មែរ ធ្វើជាសមរភូមិយោធាសំរាប់ វាយប្រហារ កងទ័ពជាតិខ្មែរផង និង សហរដ្ឋអាមេរិក/យួនខាងត្បូងផង ដែលមាន សម្តេច សីហនុ និង ពួកខ្មែរក្រហម ជាបរិស័ទ ហើយបន្ទាប់មក យួន អង្គុយមើលខ្មែរ សម្លាប់រង្គាលគ្នាឯង (១៩៧៥-១៩៧៩) រួចចាំឱកាសល្អនៅពេលខ្មែរខ្សត់កម្លាំង ដើម្បី វាយយកស្រុកខ្មែរ ដាក់ជាប្រទេស ចំណុះ (៧ មករា១៩៧៩)។ នៅក្នុង ទស្សវត្សរ៍ ៨០ យួន ត្រួតត្រា ស្រុកខ្មែរទាំងមូល តាមកម្លាំងទ័ព ហើយ ធ្វើសង្គ្រាម ទប់ទល់នឹង ទ័ពខ្មែរអ្នកតស៊ូ។ នៅក្នុង ទស្សវត្សរ៍

---

64 សុទិន ; temps favorable។

៩០ ក្នុងកិច្ចព្រមព្រៀង សន្តិភាព ២៣តុលា១៩៩១ យួនធ្វើពុត ដកទ័ពចេញពីស្រុកខ្មែរហើយអង្គុយចាំមើល ខ្មែរអ្នកដឹកនាំជាតិ តាំងខ្លួន ជា អ្នកជាតិនិយម អ្នកស្នេហាជាតិមាន សម្តេច សីហនុ ជា ប្រមុខ គិតតែ ពី ឆ្លៀត រកប្រយោជន៍ផ្ទាល់ខ្លួន បក្សពួក និង រាជវង្ស ភ្លេចដោះស្រាយ បញ្ហាជាតិ ទុកអោយ ភ្នាក់ងារយួន លាក់ខ្លួននៅក្នុងជួរគណបក្សប្រជាជនរណបយួន ពង្រឹង និង អនុវត្តយុទ្ធសាស្ត្រ យួនរូបនីយកម្ម បានងាយស្រួលបំផុត។ នៅក្នុង ទស្សវត្សរ៍ ២០០០ យួនកុម្មុយនិស្ត, ឈ្លះឈ្លាន[65] គេកំពុង ដើរពាក់អាវផាយ នៅមុខ បរមរាជវាំង បេះផលាដែល គេបាន ដាំនៅស្រុកខ្មែរនៅក្នុង ទស្សវត្សរ៍ ៣០។ ជ័យជំនះនេះ ជាផលិត មាន យីហោ របស់ គណបក្ស កុម្មុយនិស្តឥណ្ឌូចិន ដែល នាំ អោយប្រជាពលរដ្ឋខ្មែរ រស់នៅ ក្នុងគំនិត ដ៍ស្រណោក ស្តាយ នូវ ភាពរុងរឿង នៃ ជាតិខ្មែរ ពីអតិតកាល និង រស់គិត ពីអនាគត ដោយ រអាចិត្ត ព្រោះ

---

65 ឈ្លះឈ្លាន, អ្នកឈ្លានពានគ្មានការបារម្ភ, agresseur sans crainte។

ការរស់នៅ ក្នុងបច្ចុប្បន្នកាល ជាជីវិត គ្មានន័យ និង គ្មាន កិត្តិយស អ្វីបន្តិចនោះឡើយ។

## ប្រតិកម្មអ្នកនយោបាយខ្មែរ

សព្វថ្ងៃនេះ ឃួន កុម្មុយនិស្ត ឈ្នះខ្មែរទាំងអស់ ព្រោះខ្មែរ ទាំង ស្តេច ទាំង អ្នកនយោបាយ រេតាមខ្យល់ មួយចំនួន ហាក់បីដូចជា ទទួលយកជ័យជំនះឃួន ជា លទ្ធវត្ថុ[66] ហើយ នាំគ្នា លែងហ៊ាន សូម្បី តែ គិតក្នុងចិត្ត ថា ឃួន ជា សត្រូវ របស់ជាតិ ក៍យល់ ថា ជា គ្រុរគុណ[67] ចំពោះ អ្នកមាន គុណ ៧ មករា នោះដែរហើយ បែរជានាំគ្នាបញ្ឆោត ប្រជារាស្ត្រ ថា បញ្ហាជាតិ ជា បញ្ហាខ្មែរនិងខ្មែរ ទៅវិញព្រោះ ពួកគាត់ ស្រមើថា ពួកគាត់ ជា មួយក្រុម លោក ហ៊ុនសែន អាចនឹងចែក កាកសម្ល ដែលពួកឃួនគេស៊ីសល់ ទុកអោយស៊ី ដើម្បី មានកម្លាំងពលំ សំរាប់ជាន់ក រាស្ត្រខ្មែរ តាមមធ្យោបាយ ដែល ពួកគាត់ មាន រៀងៗខ្លួនៈ លោកហ៊ុន

---

66 លទ្ធវត្ថុ ,អ្វីដែលធ្វើបានសំរេចរួចអស់ហើយ ,chose acquise។
67 គ្រុរគុណ, កំហុសធ្ងន់, Faute grave។

សែន គាត់ ហ៊ាន សម្លាប់ខ្មែរ ប្រឆាំងនឹង ប្រយោជន៍យួន, លោក សម រង្ស៊ី គាត់ បញ្ឆោត ប្រជាពលរដ្ឋខ្មែរ ឲអង្គុយ ចាំតែបោះឆ្នោត សំរាប់ ឲយួនមានសេចក្តីសុខ,ហើយមាន សហគ្គករណ៍ជន នៃប្រជាករ[68] លាក់ខ្លួនក្នុងជួរ អ្នកស្នេហា ជាតិ មួយក្រុមនិយាយ ល្បួង ខ្មែរ កញ្ឆោត ឲជឿទៅលើ ចំណុច ដែល លោក ហ៊ុន សែន ចង់បាន គឺសន្តិភាព សំរាប់ អាត្មាអញ ដើម្បី ធ្វើអភិវឌ្ឍន៍ សេដ្ឋកិច្ច សំរាប់ ពាណិជ្ជ គិតតែរកចំណេញ និង ឈ្មួញ មិនសូវសុចរិត ហើយ សូម អោយខ្មែរ នាំគ្នា លាងសាជ[69] ជាមួយ ស្រមោលយួន ក្នុង នាម វប្បធម៌សន្ទនា ព្រោះ គាត់ នាំ គ្នា និយាយថា ជា ដំណោះស្រាយ តែមួយគត់ ដែល គេ យក មក អនុវត្ត នៅ ក្នុង ពិភពលោក ដើម្បី ដោះស្រាយជម្លោះ ដូច្នេះប្រជា ពលរដ្ឋខ្មែរ ត្រូវទទួលយកវា ជាដាច់ខាត។ តែរឿងនេះវា មិនដែលឃើញមាន មនុញ្ញផល[70] ដល់ខ្មែរសោះ ផ្ទុយទៅវិញ ឃើញតែ ទទួលទុក្ខ នាំ អោយ ជាតិខ្មែរ មានកង្វល់ រហូត

---

68 សហគ្គករណ៍ជន នៃប្រជាករ ; manipulateur de la masse populaire។
69 លាងសាជទទួល ,យកការផ្សះផ្សា ,accepter la réconciliation។
70 មនុញ្ញផល ,ផលល្អ ,bon résultat។

មកដល់សព្វថ្ងៃនេះ។ ជាការពិតណាស់ហើយថា ការចរចារក ដំណោះស្រាយ វា ជា គុណធម៌ នៃ មនុស្សជាតិ តែចរចា សុំចាញ់ នៅក្នុងបរិបទខ្មែរ ជា ការរួមគំនិត ជាមួយអ្នកលក់ជាតិអោយយួន។ ដូច្នេះសំដី របស់ លោក សម រង្ស៊ី ធ្វើឫក ជាអ្នកចេះ (pédantisme) ថា សូមអោយខ្មែរ ជួយពង្រឹង វប្បធម៌ សន្ទនា គឺ ជា សម្បជានមុសាវាទ[71] ព្រោះ វប្បធម៌សន្ទនា វា មិនដែលមានពិតសោះឡើយ, តើត្រូវធ្វើដូម្តេច នឹងអាច ពង្រឹងវាបានកើត ? វប្បធម៌ សន្ទនា វាគ្រាន់តែជា មធ្យោបាយ សំរាប់សុំបុណ្យ ពី លោក ហ៊ុន សែនតែប៉ុណ្ណោះ។ ដូចយើងឃើញស្រាប់ហើយ ថាកៅអីតំណាងរាស្ត្រ, ទុកជា លទ្ធផល នៃវប្បធម៌ សន្ទនា, ដែលហ៊ុន សែនចែកអោយ សម រង្ស៊ី ជា កៅអីថោកទាបបំផុតព្រោះ ក្នុងលទ្ធិប្រជាធិបតេយ្យ មិនដែលមាន បុគ្គលណាម្នាក់ក្លាយជា តំណាងរាស្ត្រ មិនចាំបាច់បោះឆ្នោតនោះឡើយ។ រឿងនេះបញ្ជាក់អោយឃើញអំពី នរតម្លៃ (valeur humaine) របស់ សម រង្ស៊ី គឺ មាន កំរិត ត្រឹមតែ ប៉ុណ្ណោះឯង។

---

[71] សម្បជានមុសាវាទ, ការកុហករកប្រយោជន៍ ; mensonge intentionné។

ឧទាហរណ៍ ដូចមាន នៅក្នុងបន្ទុក[72] លិខិត របស់គាត់ ផ្ញើទៅ ហ៊ុន សែន ថ្មីៗនេះ គាត់ សរសេរឈ្មោះ និងងារ ហ៊ុន សែន ជា អក្សរពុម្ពក្រាស់ ដើម្បី សំដែង នូវ សម្មានចិត្ត បរិសុទ្ធ នៃការប្រណិប័តន៍ ជាសុក្រិត របស់គាត់ ចំពោះ ហ៊ុន សែន ដែល គាត់ ទុកជា ការគោរអភិសិត្តជន (Culte de personnalité)។ មារយាទ ពួកខ្មែរបែបនេះឯងហើយ ជា ផលារបស់យួន ព្រោះ លោក សម រង្ស៊ី និងបក្សពួកគាត់ គ្មានបានធ្វើអ្វីមួយ សំរាប់ជាតិ ក្នុងអាណត្តិទី៥របស់ រដ្ឋសភាក្រៅពីនាំគ្នា ដេកចាំ បោះឆ្នោត និង ចាំលទ្ធផលចុងក្រោយ។ តើ ពួកគាត់ដឹងដែរឬទេថា លទ្ធផលចុងក្រោយ ដែលពួកគាត់ កំពុងរង់ចាំ ជាពិសេស លោក សម រង្ស៊ីគឺ ជាផលា របស់យៀកណាម សមមូល្យនឹងលជ្ជាភាព[73] សំរាប់ប្រជាជាតិខ្មែរ។ តើជ័យជំនះយួននេះ វាជា សិទ្ធិជ័យ (victoire définitive) សំរាប់ប្រជាពលរដ្ឋខ្មែរ ?

---

[72] បន្ទុក ,contenu។
[73] សមមូល្យនឹងលជ្ជាភាព ; équivalence de l’humiliation។

## សេចក្តីសន្និដ្ឋាន

យួនឈ្នះខ្មែរ មិនមែនដោយសារ អ្នកដឹកនាំយួន ជាបញ្ញាជននោះឡើយ, យួនវាឈ្នះខ្មែរ ព្រោះ អ្នកនយោបាយខ្មែរបច្ចុប្បន្នជា ជនអប្បបញ្ញា តែតាំងខ្លួន ជា ឃ្និត ដ៍ចំណាន (grand penseur), ជួនកាល គាត់ដើរតួ ជា អ្នកសង្គ្រោះជាតិ ជួនកាលជា អ្នករងគ្រោះ ដេកចាំ៤ជាតិជួយគាត់ ដូចករណី លោក កឹម សុខា ជា អ្នកដឹកនាំ គណបក្ស តស៊ូដើម្បី ប្តូរ អ្នកដឹកនាំ តែបែរ ជាពួនសម្ងំ នៅក្នុងផ្ទះ ហើយអោយគ្នាគាត់ និយាយប្រាប់រាស្រ្តថា គាត់ជា អ្នកក្លាហានតែសុំពឹងរាស្រ្ត ៤ទៅសុំស្តេច ៤ ជួយ, ភ្លេចគិតថា គាត់ខ្លួនឯង ជា កម្លាំងនយោបាយ សំរាប់តស៊ូ ប្រឆាំងនឹងគ្រប់អំពើអយុត្តិធម៌។ ការតាំងខ្លួនជា ជនរងគ្រោះទោះបីនៅក្នុងកាលៈទេសៈ បែបណាក៏ដោយ គឺ វា មិនសមឋានៈ ជាប្រមុខ នៃ កម្លាំង នៃ ការផ្លាស់ប្តូរអ្នកដឹកនាំដែលខ្មែរភាគច្រើន កំពុងគាំទ្រ យ៉ាងសកម្ម នោះឡើយ។ បើលោក កឹម សុខា គាត់ មិនឈាន មួយជំហានទៅមុខទៀត ដែលជា ជំហាន កលយុទ្ធ ដែល លោក យ៉ែម បុញ្ញឫទ្ធិ ប្រិយមិត្តរបស់ គាត់ តែងតែ លើក មកនិយាយ ជា យុទ្ធសាស្រ្ត

នយោបាយ « មួយជំហានម្តង-មួយជំហានម្តង » គឺជាការបញ្ឈប់ នៃ ប្រជាជវនៈ (élan populaire) ដើម្បី សង្គ្រោះជាតិខ្មែរ ហ្នុះឯង។ បើចង់ អោយមាន ការបោះឆ្នោត ប្រកបដោយយុត្តិធម៌ គឺ បវត្តិកាលនេះឯង[74] ដែល ត្រូវហ៊ាន ប្រឈរមុខ ជា សកម្ម នឹង អំពើ អយុត្តិធម៌ ជាក់ស្តែង ដែលកំពុង មាន កើតឡើង, ពុំនោះ ច្បាស់ ជា លោក បន្តសម្រាន្ត ចាំឪកាស លើកចោលរហូត (calendes grecque) ពីអាណត្តិមួយ ទៅអាណត្តិមួយទៀត ដែលជា ពេលវេលា សំរាប់យួន គេបេះផលា នៅស្រុកខ្មែរ។ មួយវិញទៀត បើលោក នៅកំពុង សួរខ្លួនឯង ថា ត្រូវធ្វើអ្វីទៀត គឺ ច្បាស់ជា លោក មិនទាន់ស្គាល់កម្លាំងបក្ស របស់លោក ឬ ក៏បក្សរបស់ លោក គ្រាន់តែ ជា បក្ស សំរាប់ តែបោះឆ្នោតប៉ុណ្ណោះ។ ការធ្វើ ញត្តិ មិនទុកជា ការប្រមូល កម្លាំងនយោបាយ នោះទេ វាគ្រាន់តែជា ការស្ទង់មតិ រកការគាំទ្រ ព្រោះ វាជា សកម្មភាពអកម្មជាពិសេស ក្នុងឋានៈ ជាអន្តរការី (intermédiaire) ព្រោះ ពួកលោក គ្រាន់តែជា

---

[74] បវត្តិកាលនេះឯង ; c’est maintenant។

អ្នកនាំញត្តិនោះ ទៅថ្វាយ ព្រះមហាក្សត្រ ដែលពួក លោក ដឹងច្បាស់ថា ជា សំណើរ គ្មានចម្លើយ។ បើពួកលោកដឹង ដូច្នេះ ហើយនៅតែបន្តធ្វើ គេអាចទុក ទង្វើនេះ ជាការប ញ្ឆោត ប្រជារាស្ត្រ អំពី គុណប្រយោជន៍ នៃ ញត្តិ ដែលពួក គាត់ ហ៊ានចេញមុខផ្ទាល់ ឥតញញើត ប្រឆាំងនឹងអំណាច ផ្តាច់ការ។ បើពួកលោក គ្មាន សេចក្តីប្តេជ្ញាចិត្តក្នុងការត ស៊ូនេះ កុំនាំគ្នា ធ្វើសកម្មភាព សិប្បនិម្មិត នាំអោយ អ្នក គាំទ្រ ពួកលោក ក្លាយជា អ្នកទទួលសាខាគ្រោះ (victimes collatérales) ពីសំណាក់ ពួកបាតដីទីបី ដូចនៅឆ្នាំ ២០១៣-២០១៤៕

# ហេតុផល នៃ ដំណោះស្រាយ

*សេរីការ*



ស្ថានភាព គណបក្សសង្គ្រោះជាតិ សព្វថ្ងៃ ហាក់បីដូចជាផ្កាស្រពោនមួយដើម ដាំលើដីមានជីជាតិល្អ។ គំនិតនេះ គឺយើង ចង់ប្រើប្រដូចនឹង ទឹកចិត្តប្រជាជនខ្មែរភាគច្រើនដែលកំពុងខឹងច្រលោតនឹង ការដឹកនាំនៃរបបផ្តាច់ការសព្វថ្ងៃ គឺមានន័យថា ជាគោលការណ៍ នៅក្នុងស្ថានការណ៍បែបនេះ វាជាសុភកាល សំរាប់គណបក្សប្រឆាំង ព្រោះចរន្តនយោបាយរបស់ខ្លួន វាស្របនឹងខ្សែទឹក នៃទឹកចិត្តខ្មែរ ជាអ្នករងគ្រោះមួយនគរ តែផ្ទុយទៅវិញ យើងឃើញថាអ្នកដឹកនាំគណបក្សសង្គ្រោះជាតិ គាត់បែរជានាំគ្នាហែលបញ្ច្រាស ចរន្តទឹកចិត្តប្រជាជនខ្មែរ ដូចផ្កាដុះលើដីល្អ តែមិនបានក្រេបយករស់ជាតិដីនោះឯង ដែលនាំអោយខ្លួនស្រពោន លើ ដី មាន ជីជាតិ។ ពួកគាត់នាំគ្នាម្នីម្នាទៅពួនក្នុងជម្រង ‹វប្បធម៌ សន្ទនា› ឥតផល តាំងពី ឆ្នាំ២០១៤មក ហើយ នាំគ្នា លែងកម្រើកទាល់តែសោះ សម្ងំរង់ចាំមើលសញ្ញា នៃសេចក្តីអត់ឱនលោក ហ៊ុន សែនចំពោះខ្លួនទោះបី ពួកគាត់ដឹងច្បាស់ថា ការចរចារ ជាមួយបក្សកាន់អំណាច វានាំបង្កើត នូវបញ្ហាច្រើនជាងដំណោះស្រាយ។

និច្ចលភាពនេះ វានាំបង្កើត នូវបញ្ហាផ្ទៃក្នុងគណបក្ស សង្គ្រោះជាតិ ព្រោះជា សម្ពន្ធ មាន កិច្ចព្រមព្រៀង ជាទម្រង់ឈរលើ ភាគកំរិត (quota) នៃគណបក្សពីរ សំរាប់បែងចែកប្រយោជន៍គ្នា ដោយយកចំនួនអាសនៈ មានក្នុងរដ្ឋសភានៃអណត្តិទី៤ ជាគោល គឺថា គណបក្សសមរង្សី មានអាសនៈ២៦ និងគណបក្សសទ្ធិមនុស្ស មានអាសនៈ៣ ដូច្នេះ អ្នកធំ ស៊ីតាមធំ រីឯ អ្នកតូចស៊ីតាមតូច។ ការរួបរួមបែបនេះ គឺធ្វើឡើងនៅក្នុង មនោគតិ នៃសម្ពន្ធ (esprit d'union) ដែលវាមានធម្មជាតិវាខុសពី មនោគតិ នៃអភិគម (esprit de fusion) ព្រោះទី១ ជាការរួបរួម នៃប្រយោជន៍ រួម របស់ ដៃគូ រីឯទី២វិញ វាជាការប្រមូល នៃកម្លាំងនយោបាយ ដើម្បី ប្រយោជន៍ជាតិ ដែល ជា ឧត្តមប្រយោជន៍។

ត្រូវដឹងថា មនោគតិសម្ពន្ធនេះ បើវានៅមានប្រយោជន៍សំរាប់ចែកគ្នាបានរវាងដៃគូ វាមានដំណើររលូនល្អ តែបើមានទំនាស់ នៃប្រយោជន៍ វិញ គឺច្បាស់ជាលេចចេញនូវបញ្ហា ជាពុំខាន។ ព្រោះថា បច្ចុប្បន្ននេះ លោក សម រង្ស៊ី និង លោក កឹម សុខា គាត់មាន អត្តប្រយោជន៍របស់គាត់

ផ្ទុយគ្នា នៅក្នុងការ រកដំណោះស្រាយ នៃ បញ្ហា ជាមួយ លោក ហ៊ុន សែន ៖ លោក សម រង្ស៊ី គាត់និរទេសខ្លួនឯង ទៅរស់នៅក្រៅប្រទេស ដើម្បី គេចពន្ធនាគារព្រៃស រីឯ លោក កឹម សុខា វិញ គាត់ភៀសខ្លួនមករស់នៅក្នុងទីស្ដីការគណបក្ស ក៏ដូច លោក សម រង្ស៊ី ដែរ គឺ ដើម្បី វៀរចាក ពន្ធនាគារ របស់ លោក ហ៊ុន សែន ដូច្នេះគាត់កំពុងស្វែង រកដំណោះស្រាយ តាមទម្លាប់ ដែលគាត់ធ្លាប់បានធ្វើថៃ បំប្រែ នៅពេលដែលគាត់នៅបែកគ្នា។

## ដំណោះស្រាយរបស់ លោក សម រង្ស៊ី

គឺជាដំណោះស្រាយនយោបាយ ដែលមានគាត់ ជា វត្ថុចម (objet principal) ព្រោះយល់ឃើញថា គាត់ជាប្រមុខ ផង និង ជាមេ នៃភាគីភាគច្រើន នៃគណបក្ស ផង នៅក្នុង ក្របខណ្ឌកិច្ចព្រមព្រៀងឈរលើភាគកំរិត។ នៅក្នុងមនោគតិនេះលោកសម រង្ស៊ី គាត់ជ្រើសរើសយក គោលវិធី ធ្វើឋានានុក្រម នៃដំណោះស្រាយ[75] គឺថា ត្រូវដោះស្រាយបញ្ហា

[75] Hiérarchiser des solutions.

គាត់ជាមុន ក្នុងឋានៈ ជា មេអ្នកដឹកនាំកំពូល។ ដូច្នេះ បញ្ហា លោក គឹម សុខា ត្រូវទុកទៅថ្ងៃក្រោយ។ គំនិតនេះ ត្រូវបាន គូកនគាត់ មួយក្រុម យល់ស្រប។ ហេតុនេះឯង បានជាមានការប៉ុនប៉ង រកឥស្សរជនមកជំនួស លោក គឹម សុខា តែមិនបានសំរេច ព្រោះ ជាគំនិតនយោបាយមិន ត្រឹមត្រូវ ដែលនាំបង្កើតនូវបញ្ហាផ្ទៃក្នុងគណបក្ស។

## ដំណោះស្រាយរបស់ លោក គឹម សុខា

លោក កិម សុខា ក៏ដូច លោក សម រង្ស៊ី ដែរ គឺជ្រើសយក គោល វិធីធ្វើឋានានុក្រម នៃដំណោះស្រាយ តែ គាត់ ឈរ លើអាទិភាព របស់អ្នកនៅក្នុងប្រទេស គឺ ខ្លួនគាត់ជា ប្រធានគណបក្សស្ដីទី ដូច្នេះ ជាប្រធានកំពុងកាន់កាប់ កិច្ចការ និងជាអ្នកទទួលខុសត្រូវ។ ដូច្នេះហើយបានជា មានការប៉ុនប៉ង ដោះស្រាយជាមួយ លោក ហ៊ុន សែន ដាច់ពី បញ្ហា លោក សម រង្ស៊ី ដែលអាចអោយគាត់ទៅចុះ ឈ្មោះបោះឆ្នោតបាន ប្ដូរនឹង ការវិលចូលប្រជុំរដ្ឋសភា នៃ

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។ សញ្ញានេះ នាំអោយលោក កឹម សុខា នឹកស្មានថា វាជាចំហួលក្រអូបនៃដំណោះស្រាយ។ តែការសាកល្បងនេះ វាមិនអាចបន្តទៅមុខទៀតបាន ព្រោះថា ជាមួយលោក ហ៊ុន សែន វាគ្មានដំណោះស្រាយ អ្វីពិត ក្រៅពី ស្លុំ ចុះចូលនឹងគាត់ ដោយ គ្មានលក្ខខណ្ឌតែប៉ុណ្ណោះ។ ការខកខានចូលរដ្ឋសភា នៃតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ គឺវាស្ថិត នៅក្នុងស្មារតីរបស់លោក ហ៊ុន សែន ព្រោះគាត់មិនអាចទទួលយកលក្ខខណ្ឌខ្មែរ ដែលវាផ្ទុយពីប្រយោជន៍យួននោះឡើយ។

## ដំណោះស្រាយរបស់ លោក ហ៊ុន សែន

លោក ហ៊ុន សែន ជាជនផ្តាច់ការ ដូច្នេះគាត់មាន ហេតុផល ជាជនផ្តាច់ការ គឺថា អ្វីជាអត្ថប្រយោជន៍ជាសក្តានុភូត ដល់សត្រូវរបស់គាត់ ទោះបីជាចំអឹង គឺវាអាចជាគ្រោះថ្នាក់ដល់គាត់ទៅថ្ងៃមុខ។ ពីហេតុផលនេះ គាត់មានដំណោះស្រាយ តែមួយគត់ គឺ កំទិច អ្វី ជា ឧបសគ្គនឹងអំណាច គាត់ អោយបាត់សូន្យ។ ហេតុផលនេះឯង ដែលពួកអ្នកដឹកនាំគណបក្សប្រឆាំងអោយឈ្មោះថា យុទ្ធសាស្ត្រ

‹ឈ្នះឈ្នះ› តែពួកគាត់គ្រាន់តែបាននិយាយជាសំដីជាអ្នក ‹ចាញ់ចាញ់› តែប៉ុណ្ណោះ ព្រោះពួកគាត់ នាំគ្នាប្រើយុទ្ធសាស្ត្រជាអ្នកចាញ់ជានិច្ច ទោះបីខ្លួនជាអ្នកឈ្នះក៏ដោយ ដូចនៅឆ្នាំ២០១៣។

## សេចក្តីសន្និដ្ឋាន

ដំណោះស្រាយ លោក សម រង្ស៊ី និង គិម សុខា ដែលយើងលើកយកវាមកបង្ហាញខាងលើនេះ វាស្ថិតនៅក្នុង ហេតុផល របស់ លោក ហ៊ុន សែន គឺ បំបែក ដើម្បី កំទិច។ ទោះចង់ក្តីឬមិនចង់ក្តី វិបត្តិ វាលាស់ឡើងវិញ រវាង លោក សម រង្ស៊ី នឹង កឹម សុខ ដែលវាកប់នៅក្នុងជម្ពូជាតិរបស់លោកទាំងពីរផង និងគណបក្សរៀងៗខ្លួនផង។ តែអធិករណ៍ បើក ឬ បិទមុខក្តី វា ជា ទុក្ខ សំរាប់ លោកទាំងពីរ តែប៉ុណ្ណោះ។ លោក សម រង្ស៊ី ក្តី កឹម សុខា ក្តី បើគាត់នៅតែបន្តប្រើស្នៀតអកម្ម សំរាប់ ការពារ រៀងៗខ្លួន ដូចសព្វថ្ងៃនេះ គឺ គាត់ មានស្មារតីចាកពី ចរណៈជាអ្នកដឹកនាំ នៅពេលជាតិជួបអន្តរាយនោះឯងហើយ ដូចមានប្រិយប្រាយថ្លែងថាមហាបុរសកើតចេញមកពីមហាព្រឹត្តិការណ៍ជាតិ។

តែ នៅស្រុកខ្មែរ វិញ យើង ឃើញថា មហាព្រឹត្តិការណ៍ជាតិច្រើន ជា មហោកាល បង្កើត មហាត លួច និង បំផ្លាញជាតិ ដែលនាំអោយ ស្រុកខ្មែរ ក្លាយជាប្រទេសខ្ញុំឃួន។

លោក សម រង្ស៊ី និង កឹម សុខា គួរសួរខ្លួនឯងថា បើគណបក្ស សង្គ្រោះជាតិ ស្រពោន តើ នរណា ជា អ្នកទទួលខុសត្រូវ ? អ្នកដឹកនាំល្អ ជាអ្នកទទួលផល ស្មើនឹង ទទួលកំហុសដូច្នេះ ត្រូវចេះធ្វើបូកបោះ អោយ ដឹងច្បាស់អំពី អំពើ ជាជម្រៅ របស់ខ្លួន។ នៅក្នុងករណីរបស់លោក សម រង្ស៊ី និងកឹម សុខា បើ គេ យកតុល្យការ នៃ សកម្មភាពរបស់លោកទាំងពីរ មកពិនិត្យនៅក្នុងសន្សាកាល នៃអាណត្តិនីតិបញ្ញត្តិ ទី៥ សព្វថ្ងៃនេះ វា គ្មាន ឃើញអ្វីសំរាប់ពង្រឹងជ័យជំនះ នៃគណបក្ស ក្រៅពីទុកពេលវេលាអោយ លោក ហ៊ុនសែន អាចបំពើងទ្រូងបានវិញ ដើម្បីវាយតបកំទិចលោកទាំងពីរ។ ការណ៍នេះ ជាប្រត្យក្សភាព នៃអ្នកផ្តាច់ការ ព្រោះគ្មាន ការចរចា បែបណាមួយ ដែល នាំ អោយខ្លួនបាត់អំណាចនោះឡើយ។ បើសិនជាលោកសម រង្ស៊ី និង កឹម សុខា គាត់នៅតែបន្តយល់ឃើញថា ការចរចាជាមួយអំណាចផ្តាច់ការ ជាដំណោះស្រាយ ព្រោះ ពួកអ្នកតំណាងបរទេស

គេ និយាយប្រាប់គាត់ ថា ត្រូវតែចរចាជាមួយលោក ហ៊ុន សែន គឺលោកទាំងពីរ នៅតែ មិនស្គាល់ បរិបទពិត នៅស្រុកខ្មែរ។ ត្រូវដឹងថា អនុសាសន៍នេះវាជា សំដីទូត ព្រោះគេ មើលឃើញច្បាស់ថា អ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ ពួកគាត់ គ្មាន សមត្ថភាព នឹងដឹកនាំ ចលនាមហាជន ប្រឆាំងនឹង អំណាចផ្តាច់ការ ដែល មាន យួន ជា អ្នកដឹកនាំនោះឡើយ ឧទាហរណ៍មាននៅ ឆ្នាំ២០១៣-១៤។ ការចរចា វាស្ថិតនៅលើសំណួរសួរថា តើគណបក្សសង្គ្រោះជាតិ ក្រៅពីការគាំទ្រ ពីសំណាក់យុទ្ធកៈបក្ស តើនៅមានកម្លាំងមហាជន ជា សយម្ភូត ផុសឡើងដោយសកម្ម ប្រឆាំងនឹងអំណាចយួន នៅស្រុកខ្មែរដែរឬទេ ព្រោះរាល់ការចរចា លុះត្រាតែ ភាគីនិមួយៗ មាន កម្លាំងសំរាប់សំឡុត និងស្គាល់ចំណុចខ្សោយខ្លួនផង សំរាប់សំរួល។ នៅក្នុងករណី របស់ពួកអ្នកដឹកនាំ គណបក្សប្រឆាំង ពួកគាត់មានកម្លាំងសន្លឹកឆ្នោតសំរាប់ប្រើនៅក្នុងបរិបទ នៃ លទ្ធិប្រជាធិបតេយ្យ ហើយ គាត់ស្គាល់ចំណុចខ្សោយរបស់គាត់ សំរាប់សំរួល គឺ សំរាប់ តែរករកប្រយោជន៍រៀងៗខ្លួន។ ចំណុចខ្លាំងបែបនេះ វា មិនអាច សំរាប់ សំឡុត នៅលើតុកចរចាបាននោះ

ឡើយ ព្រោះពួកអ្នកផ្តាច់ការមិនអនុវត្តលទ្ធិប្រជាធិបតេយ្យ ដូច្នេះ វានឹងគ្មាន ការបោះឆ្នោតដោយសេរី និងដោយយុត្តិធម៌ រីឯចំណុច ខ្សោយ របស់ពួកអ្នកដឹក នៃ បក្សសង្គ្រោះជាតិ វិញ វា ជា កម្លាំងសំឡូត របស់ ពួកអ្នកផ្តាច់ការនោះឯង។ ដូច្នេះ លោក ហ៊ុន សែន គាត់គ្មានមានប្រយោជន៍អ្វី នឹង ចរចា ជា មួយ ភាគីគ្មាន កម្លាំងសំឡូតគាត់ទោះបីភាគីនោះ មាន បរទេសគាំទ្រ តាមផ្លូវចិត្ត ព្រោះគាត់វិញ ក៏មាន បរទេសការពារដែរ តែតាមផ្លូវកម្លាំងមាន ប្រទេសចិន/យួនជាអាថ៌។

យើងអាចសួរទៅ បរទេស ដែលស្នើអោយបក្សសង្គ្រោះជាតិធ្វើការចរចាជាមួយបក្សប្រជាជន ថាតើការចរចានោះ គឺត្រូវធ្វើតាមគោលវិធីបែបណា បើវាគ្មាន សមតា នៃកម្លាំងរវាង ភាគី ចរចាទាល់តែសោះ ? តើ ជា ការចរចា សំរាប់ចុះចាញ់ ឬ សំរាប់តែអោយមានការបោះឆ្នោតគ្មានសេរី និងគ្មានយុត្តិធម៌ សំរាប់ពួកគាត់ស្រួលធ្វើទំនាក់ទំនងជាមួយអំណាចផ្តាច់ការ នៅស្រុកខ្មែរ ដែល វា កើតចេញ ពីហិបឆ្នោតចោរ ដូចនៅឆ្នាំ ២០១៣ តែប៉ុណ្ណោះ។ យើងក៏សួរទៅពួកអ្នកដឹកនាំគណបក្សសង្គ្រោះជាតិដែរ ក្រោយពីបានឮ

សំដីពួកគាត់និយាយថា អោយតែបក្សសង្គ្រោះជាតិ និង បក្សប្រជាជន ចរចាគ្នា គឺ គ្រប់បញ្ហាស្រុកខ្មែរ នឹងអាច ដោះស្រាយបាន ជា ពុំខាន សំនួរយើង នៅក្នុងបរិបទខ្មែរ សព្វថ្ងៃ គឺ ការចរចា រវាងភាគីទាំងពីរនេះ តើវាអាចដោះ ស្រាយបញ្ហាអំណាចយួននៅស្រុកខ្មែរ បានដែរឬទេ ? ត្រូវ ដឹងថា ប្រយោគ ‹បើមានការចរចា គ្រប់បញ្ហាស្រុកខ្មែរ នឹងអាចដោះស្រាយបានជាពុំខាន› មាន ន័យ ជា សារដែរ ថា បក្សសង្គ្រោះជាតិ សូមតែសុខតែប៉ុណ្ណោះ។ តើអំណាច យួននៅស្រុកខ្មែរ វា អោយ ខ្មែរបានសុខដែរឬទេ ? សំនួរ ជាបញ្ចប់គឺ តើ វា មាន ការចរចាអ្វីក្រៅពីការអនុវត្តច្បាប់ ដែល ទុក ជា ដំណោះស្រាយ រវាងបក្សទាំងពីរុ ? ព្រោះការ ចរចា លុះត្រាតែមានច្បាប់ជាអាជ្ញាកណ្តាល ដូច្នេះ តើមាន នរណាធ្វើជាមជ្ឈត្តករ ? ខ្មែរត្រូវមានស្មារតីជានិច្ចថា សូម្បី កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ យៀកណាម និង បក្សប្រជាជនមិនគោរពផង តើពួកគេនិងគោរព កិច្ចសន្យា ជា មួយ ពួកអ្នកដឹកនាំបក្សសង្គ្រោះជាតិ ? ដូច ជាកិច្ចសន្យា នៅ ឆ្នាំ ២០១៤ តើ លោក ហ៊ុន សែន គាត់ មាន បានគោរព ដែរឬទេ ? ចម្លើយគឺ ហេតុ នៃ ដំណោះ

ស្រាយ ជាមួយ អំណាចយួននៅស្រុកខ្មែរ គឺ ផ្តាច់ទំនាក់ទំនង ជាមួយបក្សប្រជាជនដែលជាបក្សរណបយួន ហើយដើរ ជាមួយ ប្រជាពលរដ្ឋ ឈររួម ជាមហាជន នាំគ្នាស្រែកទាមទារ មិនព្រមឈប់ អោយអង្គការសហប្រជាជាតិ និងសហគមអន្តរជាតិ ធ្វើសម្ពាធ ដល់គណបក្សកាន់អំណាចអោយ គោរពច្បាប់រដ្ឋធម្មនុញ្ញ និង អោយមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ក្រោមការត្រួតត្រារបស់អង្គការសហប្រជាជាតិ ឬ សហគមអន្តរជាតិ។ កិច្ចការនេះមើលទៅ វាហាក់បីឃើញដូចជាពិបាកធ្វើណាស់ តែប្រជាពលរដ្ឋខ្មែរក្លាហាន អាចនឹងធ្វើបាន បើមានអ្នកដឹកនាំមាន សេចក្តីក្លាហាន និងប្រកបដោយសីលធម៌។ បើគ្មានដំណោះស្រាយ ចេញពីផល នៃកម្លាំងប្រជាពលរដ្ឋខ្មែរនោះទេ ស្រុកខ្មែរនឹងក្លាយជាខេត្តយួន ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះជាពុំខាន។ ត្រូវដឹងថា អ្នកដឹកនាំពិតនៅស្រុកខ្មែរសព្វថ្ងៃ គឺសុទ្ធជាជនជាតិយួន មានឈ្មោះជាខ្មែរ។ រដ្ឋាភិបាលដឹកនាំដោយលោក ហ៊ុន សែន គឺ គ្រាន់តែជា អង្គការនៅក្រោមបង្គាប់យួន សំរាប់ អនុវត្ត នយោបាយយួនតែប៉ុណ្ណោះ តែ យួន អនុញ្ញាត អោយពួកខ្មែរបំរើយួនអាច

សម្លាប់ខ្មែរ បានតាមសេរី ព្រោះ ពួកនោះរៀនអំណាចជាឃាតករ ដូច អ្នករៀនអាភៀននោះដែរ បើ មិនអោយសម្លាប់ខ្មែរ គឺពួកនោះ វានឹងមានជម្ងឺ ខ្វះសេចក្ដីឃោឃៅនៅក្នុងចិត្ត។ ដូច្នេះ លោក សម រង្ស៊ី និង លោក កឹម សុខា បើគាត់មើលឃើញ វិនាដកម្មជាតិនេះ គឺគាត់មិនអាចឈ្លោះគ្នា បាននោះឡើយ ហើយ គាត់ក៏មិនអាចក្បត់ឆន្ទៈប្រជាពលរដ្ឋខ្មែរ ម្ដងទៀតនោះដែរ។ សូម អោយការរួបរួមខ្មែរនឹងខ្មែរ និង ការចរចា ជាការបំរើប្រយោជន៍ជាតិ៕

**ថ្ងៃទី ៣១ ធ្នូ ឆ្នាំ ២០១៦**